**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៥៦/០១០/២០០២

ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

**សេចក្តីសម្រេច**

លេខ : ០៥០/០០១/២០០៣ កបធ.ច

ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញលិខិតចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់សមាជិកសភា ១៣រូប នៃគណបក្ស សម រង្ស៊ី ជូនឯកឧត្តមប្រធាន **ជិន ឈិន** ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ ឆ្នាំ ដដែល ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សមាជិកសភាចំនួន ១៣រូប បានស្នើមកក្រុមប្រឹក្សាធម្មនុញ្ញក្នុងចំនួនលើសពីមួយភាគដប់ ( ១/១០ x ១២២ ) ឱ្យបកស្រាយមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ សំណើនេះស្របតាមមាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញអាចយកសំណើនេះមកពិនិត្យបាន ។

- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ម្យ៉ាងជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ម្យ៉ាងទៀតជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតនៅក្រោមការចាត់តាំង ឬ ការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ( មាត្រា ៤២ ) ។ ក្នុងឋានៈជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីធំធេងក្នុងការបំរើកិច្ចការមូលដ្ឋាន រៀបចំសណ្តាប់ធ្នាប់សាធារណៈ សេវាសាធារណៈ ផាសុកភាព និង សុខុមាលភាព អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ថែរក្សាបរិស្ថាន ។ ល ។ ក្នុងក្របខ័ណ្ឌនយោបាយវិមជ្ឈការ ។ ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគោរព និង អនុវត្តតាមការណែនាំថ្នាក់លើ តាមលំដាប់ឋានានុក្រម ។
- យល់ឃើញថា មាត្រា ៣០ ( វាក្យខ័ណ្ឌទី១ និង ទី២ ) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំជ្រើសរើសមេភូមិ ។ មេភូមិត្រូវរៀបចំចាត់តាំង អនុប្រធានភូមិ និង សមាជិកជាជំនួយការ ( លក្ខណៈគ្រប់គ្រាន់ ) បានតម្រូវយ៉ាងច្បាស់ថា ( វាក្យខ័ណ្ឌទី៣ ) : " រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការភូមិ " ដែលជាបទបញ្ញត្តិមានលក្ខណៈចាំបាច់ ។ មាត្រា ៨៦ បានបញ្ជាក់បន្ថែមក្នុងអន្តរប្បញ្ញត្តិថា ត្រូវធ្វើ ... " តាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០ នៃច្បាប់នេះ " ។
- យល់ឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មិនបានកំណត់រយៈពេលឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចេញសេចក្តីណែនាំក្នុងរឿងនេះទេ ប៉ុន្តែការពិនិត្យបានបង្ហាញឱ្យឃើញថា មានការកំណត់រយៈពេលសម្រាប់រឿងផ្សេងៗឯទៀត មានយ៉ាងយូរត្រឹម ០៦ ខែ ។ ការពិនិត្យបន្ថែមបានបង្ហាញឱ្យឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យក្រសួងមហាផ្ទៃចេញសេចក្តីណែនាំចំនួនប្រហែលម្ភៃសម្រាប់បង្កើនប្រសិទ្ធភាពនៃនយោបាយវិមជ្ឈការនេះ ។
- យល់ឃើញថា " គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ " ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន បង្កើតដោយមាត្រា ៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្នុងគោលដៅបង្កលក្ខណៈសម្បត្តិងាយស្រួលដល់នយោបាយវិមជ្ឈការមានសមត្ថកិច្ចគ្រប់គ្រាន់ ( មាត្រា ៨៨ ) ក្នុងការដោះស្រាយ ឬ ជំរុញឱ្យមានការណែនាំក្នុងរយៈពេលសមស្របមួយ ។
- យល់ឃើញថា តាមមាត្រា ៤៤ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឋានៈជាភ្នាក់ងាររដ្ឋ អាចត្រូវបានទទួលប្រតិភូកម្មអំណាចពីសំណាក់អាជ្ញាធររដ្ឋសម្រាប់កិច្ចការអនុវត្តន៍ វៀរលែងតែវិស័យដែលមានចែងច្បាស់ក្នុងមាត្រា ៤៥ ដែលជាសមត្ថកិច្ចរបស់អាជ្ញាធរកណ្តាល ។
- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋត្រូវស្នើសុំការណែនាំគោលការណ៍នៃ

ការរៀបចំជ្រើសរើសមេភូមិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទោះបីក្នុងលក្ខណៈជាការជ្រើសរើសបណ្ដោះអាសន្នក៏ដោយ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានកាតព្វកិច្ចត្រូវឆ្លើយតបចំពោះសំណូមពរនេះក្នុងរយៈពេលមួយសមស្រប ។

## **សម្រេច**

**មាត្រា ១** : មាត្រា ៣០ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបកស្រាយតាមមូលបទខាងលើនេះ ។

**មាត្រា ២** : សេចក្ដីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មករា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ: ០៥៩/០០៣/២០០៣

ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ: ០៥១/០០២/២០០៣ កបធ.ច

ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញមាត្រា ៥០ថ្មី មាត្រា ៥៤ថ្មី និងមាត្រា ៦២ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក **លី  រី** តំណាងឱ្យឈ្មោះ **ពៅ  សោភ័ណ្ឌ** មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់
- យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងក្នុងកាលបរិច្ឆេទត្រឹមត្រូវតាមការកំណត់នៃច្បាប់
- យល់ឃើញថា ក្រុមប្រឹក្សាជំនុំជម្រះបានចោទសួរភាគីទាំងពីរ ព្រមទាំងសាក្សីបានសព្វគ្រប់ហើយ
- យល់ឃើញថា សាក្សីឈ្មោះ **គង់  ថន** និងឈ្មោះ **ឯក  រតនា** ពិតជាស្គាល់មនុស្សដែលមានឈ្មោះថា **ពៅ  សោភ័ណ្ឌ** ពិតមែន
- យល់ឃើញថា ឈ្មោះ **ពៅ  សោភ័ណ្ឌ** ពុំមានឯកសារអ្វីមួយបញ្ជាក់ថាមានសញ្ជាតិខ្មែរ តាមមាត្រា ៥០ថ្មី និង មាត្រា ៥៤ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យ

ប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ប៉ុន្តែនៅមុខក្រុមប្រឹក្សាជំនុំជម្រះសាធារណៈនាថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាង **ពៅ សោភ័ណ្ឌ** បានបញ្ជាក់ជាច្រើនដងថា នាងមានប័ណ្ណបោះឆ្នោត ឆ្នាំ ១៩៩៨ និង ឆ្នាំ ២០០២

- យល់ឃើញថា កាលបរិច្ឆេទបញ្ឈប់ការចុះឈ្មោះបោះឆ្នោតមិនទាន់ហួសពេលនៅឡើយ ។

**ហេតុដូច្នេះ**

**សំរេចចំពោះមុខគូភាគី**

**មាត្រា ១** : ទទួលពាក្យបណ្តឹងតវ៉ារបស់លោក **លី រី** តំណាងឱ្យឈ្មោះ **ពៅ សោភ័ណ្ឌ** ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

**មាត្រា ២** : បដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៣ លើសាក្សី និង តំកល់សេចក្តីសំម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដដែលលើឯកសារបញ្ជាក់ពីសញ្ជាតិខ្មែរ ។ ប៉ុន្តែបើក្នុងករណីនាង **ពៅ សោភ័ណ្ឌ** បង្ហាញប័ណ្ណបោះឆ្នោតដល់ក្រុមប្រឹក្សាសង្កាត់បឹងសាឡាងមុនពេលផុតកំណត់ការចុះឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៣ នោះ នាង **ពៅ សោភ័ណ្ឌ** ត្រូវតែបានចុះឈ្មោះបោះឆ្នោត ។

**មាត្រា ៣** : សេចក្តីសំរេចនេះប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៥៨/០០២/២០០៣

ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥២/០០៣/២០០៣ កបធ.ច

ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើលេខ ១១៧ រស ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព លើវិសោធនកម្មប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ២០០៣
- បានឃើញប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានរដ្ឋសភាបានផ្ញើមកក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃ ខែ ឆ្នាំ ដដែល

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី២ ឃ្លាទី១ ដែលចែងថា " បទបញ្ជាផ្ទៃក្នុង

រដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។ " និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្ម ប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ជាការស្របតាមរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពលើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោយផ្អែកតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី២ ឃ្លាទី២ ដែលចែងថា " ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិប ( ៣០ ) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ ។ "
- យល់ឃើញថា ប្រការ ៣៦ ថ្មី និង ប្រការ ៣៦ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ខុសគ្នាត្រង់ការបន្ថែមលើប្រការ ៣៦ ( ចាស់ ) នូវវាក្យខ័ណ្ឌមួយថ្មីទៀតដែលចែងថា " វិធីបញ្ចេញមតិដោយលើកដៃ ឬ ដោយបោះឆ្នោតចំហខាងលើនេះអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ។ "
- យល់ឃើញថា ប្រការ ៣៨ ថ្មី និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាខុសគ្នាត្រង់ប្រការ ៣៨ ថ្មី ប្តូរដាក់ ពណ៌ស សម្គាល់ថា ព្រម មុនដាក់ ពណ៌ខៀវ សម្គាល់ថា មិនព្រម ។ អត្ថន័យទាំងអស់នៅដដែល ការប្តូរដាក់មុនក្រោយ ដើម្បីឱ្យមានភាពរលូន និង ពិរោះស្តាប់ " ព្រម " " មិនព្រម " " អនុបវាទ " មិនមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ប្រការ ៣៦ ថ្មី មិនមានចែងច្បាស់លាស់អំពីនីតិវិធីដែលត្រូវប្រើប្រព័ន្ធអេឡិចត្រូនិចក្នុងការបោះឆ្នោតចំហ ។ ការមិនបានចែងនីតិវិធីអាចនឹងបណ្តាលឱ្យមានការប៉ះពាល់ដល់ប្រការ ៣៨ ថ្មី ដែលមានបញ្ជាក់ត្រង់ថា " អាជ្ញាសភាកាន់ហិបឆ្នោតដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា " ។ ទោះបីមានបច្ចេកវិទ្យាដល់កម្រិតខ្ពស់ក៏នៅមានការលំបាកក្នុងការបំពេញល័ក្ខខ័ណ្ឌ ឱ្យមានអាជ្ញាសភាប្រតិបត្តិការងារដូចនេះបានឡើយ
- យល់ឃើញថា ដើម្បីឱ្យស្របនឹងរដ្ឋធម្មនុញ្ញ ត្រង់មាត្រា ៥ គួរប្រើភាសាខ្មែរ ដែលមានសម្រាប់ជំនួសពាក្យបរទេស គឺពាក្យ អសន្យាណូ ជំនួសពាក្យ " អេឡិចត្រូនិច " ។

## សម្រេច

**មាត្រា ១** : វិសោធនកម្មលើប្រការ ៣៦ និងប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២** : សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៦៨/០១២/២០០៣

ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៣/០០៤/២០០៣ កបធ.ច

ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៣៩០ រស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣ របស់ប្រធានរដ្ឋសភា ស្នើឱ្យក្រុម-ប្រឹក្សាធម្មនុញ្ញបំភ្លឺចំពោះបណ្តឹងលេខ ១៨២/០៣ គ.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៣ របស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិនៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ហើយដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់**

- យល់ឃើញថា ការសុំរបស់ប្រធានរដ្ឋសភាក្នុងលិខិតលេខ ៣៩០ រស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣

ឱ្យបំភ្លឺចំពោះសំណើរបស់លោក **គល់ បញ្ញា** លេខ ១៨២/០៣ គ.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៣ សុំឱ្យបកស្រាយមាត្រា ១៣៧ ថ្មី វាក្យខ័ណ្ឌទី១ និង ទី២ នៃព្រះរាជក្រម លេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ អាចយកមកពិនិត្យបាន ដោយអនុលោមតាមមាត្រា ១៤១ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨

- យល់ឃើញថា វាក្យខ័ណ្ឌទី១ នៃមាត្រា ១៣៧ ថ្មី នៃព្រះរាជក្រមលេខ នស/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០០២ នេះ សំដៅទៅលើទីកន្លែងនៃការរាប់សន្លឹកឆ្នោតដែលត្រូវធ្វើជាគោលការណ៍ នៅទីស្នាក់ការគណៈកម្មាធិការឃុំ សង្កាត់រៀបចំការបោះឆ្នោត ប៉ុន្តែក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោតមានសិទ្ធិកំណត់យកទីកន្លែងសុវត្ថិភាពណាមួយក៏បាន
- យល់ឃើញថា វាក្យខ័ណ្ឌទី២ នៃមាត្រា ១៣៧ ថ្មី ដដែលនេះ មិនមានលំអិតឱ្យច្បាស់លាស់អំពីនីតិវិធីនៃការដឹកជញ្ជូនហិបឆ្នោត ឬ ការរាប់សន្លឹកឆ្នោតទេ ដោយទុកភារកិច្ចនេះជូនគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត ( គ.ជ.ប ) ក្នុងស្មារតីចង់ឱ្យ គ.ជ.ប មានលទ្ធភាពគ្រប់គ្រាន់ក្នុងការរិះរកប្រតិបត្តិភាព ( ភាពដែលអាចប្រតិបត្តិបាន ) ដែលត្រូវឆ្លើយនឹងល័ក្ខខ័ណ្ឌតម្លាភាព សុវត្ថិភាព គ្មានការគំរាមគំហែង គ្មានការបំភិតបំភ័យ លក្ខណៈសេរី ត្រឹមត្រូវ និង យុត្តិធម៌ ដែលច្បាប់បានបញ្ញត្តិនោះ ។

  ដូច្នេះ ជាស្មារតីច្បាប់ ក៏ពុំមានត្រង់ណាដែលបង្ហាញឱ្យឃើញថា ចង់ឱ្យមានការចាក់បញ្ចូលសន្លឹកឆ្នោតតាមរបៀបណាមួយជាក់ច្បាស់នោះឡើយ
- យល់ឃើញថា ការសម្ងាត់របស់អ្នកបោះឆ្នោតក្នុងការបោះឆ្នោត ជាគោលការណ៍ សម្រាប់ការពារសិទ្ធិផ្ទាល់ខ្លួនបុគ្គលអ្នកបោះឆ្នោត និង សន្តិសុខសុវត្ថិភាពរបស់គេ ។ គោលការណ៍នេះ ក្នុងពេលបច្ចុប្បន្នពុំអាចមានវិសាលភាពដល់ភូមិករ និង សហគមន៍ភូមិសាស្ត្រឡើយ ទោះបីក្នុងករណីណាក៏ដោយ ។ នៅក្នុងច្បាប់បោះឆ្នោតជាធរមាន ពុំទាន់មានគោលការណ៍ដើម្បីការពារការសម្ងាត់អ្នកបោះឆ្នោតជាសមូហភាពតាមសហគមន៍ភូមិសាស្ត្រនៅឡើយទេ ។

## សម្រេច

**មាត្រា ១** : វាក្យខ័ណ្ឌទី១ និង ទី២ នៃមាត្រា ១៣៧ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២** : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៦៩/០១៣/២០០៣

ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៤/០០៥/២០០៣ កបធ.ច

ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨ /០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៩/០៣ កបធ.សជណ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៣
- បានឃើញលិខិតរបស់តំណាងរាស្ត្រចំនួន ១៨រូប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ ស្នើសុំឱ្យក្រុមប្រឹក្សា-ធម្មនុញ្ញបកស្រាយបំភ្លឺលើខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ថាតើចំពោះមុខស្ថានភាពខាងលើនេះ ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា តំណាងរាស្ត្រចំនួន ១៨ នាក់ គឺលើសពីមួយភាគដប់ ( ១៣រូប ) នៃចំនួនតំណាងរាស្ត្រ នៅរដ្ឋសភាបានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០០៣ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ នៅវេលាម៉ោង ១០ ព្រឹក ។ ចំនួន ១៨ នាក់នេះ គ្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ផងដែរ ។
- យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយបំភ្លឺនូវខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញក្នុងបរិបទនៃសំណួរមួយដែលសួរថា ចំពោះមុខស្ថានភាពនេះ តើការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?
- យល់ឃើញថា ចំពោះសំណួរនេះ បញ្ហានឹងកើតមានឡើងតែក្នុងករណីដែលគ្មានការជ្រើសតាំង អ្នកតំណាងរាស្ត្រថ្មីជំនួសអ្នកតំណាងរាស្ត្រដែលទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាក សមាជិកភាពរដ្ឋសភា ហើយដែលចំនួនតំណាងរាស្ត្ររដ្ឋសភាទាំងអស់ត្រូវចុះថយនៅសល់តិចជាង ១២០ រូបប៉ុណ្ណោះ ។ ក្នុងបរិបទនេះនេះ ក្រុមប្រឹក្សាធម្មនុញ្ញសូមធ្វើការបកស្រាយដូចតទៅ :

**១_វាក្យខ័ណ្ឌទី១ មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ**

វាក្យខ័ណ្ឌទី ១ នៃមាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ ចែងថា : រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។ ត្រង់នេះមានន័យថា យ៉ាងតិចណាស់ត្រូវមានសមាជិកជាតំណាងរាស្ត្រចំនួន ១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន ។ ច្បាប់បោះឆ្នោតមិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង ១២០រូប បានទេ ។ វាក្យខ័ណ្ឌទី១ នេះជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការបង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសម្រាប់ដំណើរការរបស់រដ្ឋសភាទេ ។

នៅពេលបោះឆ្នោតចប់ហើយ លទ្ធផលត្រូវឱ្យបានតំណាងរាស្ត្រចាប់ពី ១២០រូប ឡើងទៅ ទៅតាមការកំណត់នៃច្បាប់បោះឆ្នោត ទើបអាចបង្កើតរដ្ឋសភានីតិកាលថ្មីមួយបាន ដោយគោរពទៅតាមនីតិវិធីដែល

មានចែងក្នុងមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ គឺថា រដ្ឋសភាដែលកើតចេញពីការបោះឆ្នោត ត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ហើយនឹងមានការប្រកាសសម្រេចសុពលភាពឈ្មោះអ្នកតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និង ជាសាធារណៈ ។ ចាប់ពីពេលនេះមក រដ្ឋសភានឹងមានសុពលភាពរហូតដល់ចប់អាណត្តិរបស់ខ្លួនក្នុងករណីធម្មតា លើកលែងតែក្នុងករណីពិសេសនៃការរំលាយរដ្ឋសភាដោយមកពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល ១២ ខែ ដូចមានចែងក្នុងមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។ ហេតុដូច្នេះហើយ ទើបមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញចែងថា " រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ ... " ។

ការវិភាគខាងលើនេះ បង្ហាញឱ្យឃើញថាការប្រែប្រួលនៃចំនួនតំណាងរាស្ត្រ ក្នុងរយៈវេលានៃការប្រព្រឹត្តទៅនៃនីតិកាល មិនអាចធ្វើឱ្យប៉ះពាល់ដល់សុពលភាពរដ្ឋសភាទាំងមូលបានឡើយ ។ ដូច្នេះទោះបីចំនួនតំណាងរាស្ត្រប្រែប្រួលចុះថយក្រោម ១២០រូប យ៉ាងណាក៏ដោយ កុំឱ្យតែទាបជាងកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ក៏រដ្ឋសភានៅតែអាចដំណើរការបានដូចធម្មតា ហើយជាពិសេសការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញក៏អាចនឹងប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

**២-មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ**

មាត្រា ៩៥ នេះ ចែងថា : ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាពដែលកើតមានឡើង ៦ ខែយ៉ាងតិចមុនចប់នីតិកាលត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះតាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ក្នុងច្បាប់បោះឆ្នោត ។

ក្នុងបរិបទនៃសំណួររបស់អ្នកតំណាងរាស្ត្រទាំង ១៨ នាក់នោះ ការបកស្រាយមាត្រា ៩៥ នេះសំដៅតែទៅលើបញ្ហានៃការចាត់ការជ្រើសតាំងសមាជិកជំនួស និង រយៈពេល ៦ ខែ មុនចប់នីតិកាល ។ ដូច្នេះចំណុចផ្សេងៗទៀតនៃមាត្រា ៩៥ នឹងមិនត្រូវលើកយកមកពិនិត្យក្នុងទីនេះទេ ។

មានពីរករណីដែលត្រូវវែកញែក គឺ :

ករណីទី១ : បើនីតិកាលនៅយូរជាង ៦ ខែ ឬ ស្មើនឹង ៦ ខែ ត្រូវមានការជ្រើសតាំងសមាជិកជំនួសតាមនីតិវិធីដែលមានចែងក្នុងច្បាប់បោះឆ្នោត ឧទាហរណ៍ដូចសព្វថ្ងៃនេះគឺមាត្រា ១២០ នៃច្បាប់បោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ ។ តាមមាត្រា ១២០ នេះសាមីគណបក្សនយោបាយអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះ-ឆ្នោតនៃមណ្ឌលរបស់សាមីខ្លួននោះមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។ សាមីគណបក្ស

នយោបាយ ជាចាំបាច់ ត្រូវតែស្នើជ្រើសតាំងសមាជិកថ្មីជំនួស ទើបស្របនឹងមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ ដែលបានចែងច្បាស់ថា " ត្រូវចាត់ការជ្រើសតាំងជំនួស ... " ។

ករណីទី២ : បើនីតិកាលនៅសល់តិចជាង ៦ ខែ ថ្វីបើមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមិនបានបញ្ជាក់ក៏ដោយប៉ុន្តែតាមខ្លឹមសារ គឺមិនត្រូវមានការជ្រើសតាំងសមាជិកថ្មីជំនួសទេ ។

- យល់ឃើញថា ទោះក្នុងករណីណាក៏ដោយ លើកលែងតែចំនួនតំណាងរាស្ត្រនៅសល់តិចជាងកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានជានិច្ច រហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយឥតខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

## សម្រេច

**មាត្រា ១** : វាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ និង សុពលភាពនៃការប្រជុំពេញអង្គ ជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភាត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

**មាត្រា ២** : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ: ០៧០/០១៤/២០០៣

ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ: ០៥៥/០០៦/២០០៣ កបធ.ច

ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះសារលិខិតរបស់សម្តេចក្រុមព្រះ **នរោត្តម  រណឫទ្ធិ** ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៨២ ហសប/ជស ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៣ ផ្ទេរសិទ្ធិថ្វាយស្តេចក្រុមឃុន **នរោត្តម  សិរីវុឌ្ឍ** អគ្គលេខាធិការ គណបក្សហ៊្វុនស៊ិនប៉ិច ដើម្បីជាតំណាងក្នុងរឿងប្តឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បណ្តឹងលេខ ៦៩៧ ហសប/សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញពាក្យបណ្តឹងរបស់ស្តេចក្រុមឃុន **នរោត្តម  សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៩៧ ហសប/សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ ប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និង គ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទទួលបាននៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១១:៣០ នាទី
- បានឃើញលិខិតរបស់គណបក្សហ៊្វុនស៊ិនប៉ិចលេខ ៦៦៧ ហសប.សណ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣ ឧទ្ទេសនាមលោក **សុន  អរុណ** ជាប្រធានការិយាល័យមេធាវី និង លោក **ម៉ី  ច័ន្ទវាសនា** ជាប្រធានផ្នែករដ្ឋបាលមេធាវីរបស់គណបក្ស ដើម្បីបំពេញភារកិច្ចដាក់ពាក្យបណ្តឹង និង ទំនាក់ទំនងជាមួយក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុសួរយកចម្លើយដែលបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិច កាលពី

ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

- បានឃើញកំណត់ហេតុសួរយកចម្លើយ ពីតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពី ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញលិខិតពឹងពាក់មេធាវី លេខ ៦៧៨ ហសប.សណ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ្វ៊ុនស៊ិនប៉ិច សុំឱ្យមេធាវី ៦ រូប ដើម្បីជាតំណាងក្នុងពេលសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៨.១៦៨៦/០៣ គ.ជ.ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ ឯកឧត្តម **អ៊ឹម សួស្តី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់តាំងតំណាង គ.ជ.ប ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និង លិខិតលេខ ០៨.១៦៩០/០៣ គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **អ៊ឹម សួស្តី** ប្រធាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីការបន្ថែមសមាជិក គ.ជ.ប ចំនួន ៣រូប ដើម្បីចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ក្រោយពីបានស្តាប់របាយការណ៍ របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ស្តេចក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ្វ៊ុនស៊ិនប៉ិចបានដាក់បណ្តឹង លេខ ៦៥៧ ហសប.សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ មកក្រុមប្រឹក្សាធម្មនុញ្ញ ។ ដោយផ្អែកតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបណ្តឹងនេះអាចទទួលយកមក ពិនិត្យបាន
- យល់ឃើញថា បណ្តឹងនេះបានដាក់ក្នុងរយៈពេល៧២ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្នរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា គណបក្សហ្វ៊ុនស៊ិនប៉ិចសុំប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលគេយល់ថាបានបំពេញ ភារកិច្ចរៀបចំការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និង គ្មានការទទួលការខុសត្រូវ នាំឱ្យលទ្ធផលនៃ ការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ ។ ពាក្យបណ្តឹងនេះសុំឱ្យផ្តន្ទាទោសគណៈកម្មាធិការជាតិរៀប ចំការបោះឆ្នោត តាមច្បាប់ជាធរមាន
- យល់ឃើញថា ពីដំបូង លោក **សុន អរុណ** បានឆ្លើយថា លោកមិនមែនជាតំណាងដើមបណ្តឹងទេ លោកជាមេធាវីតំណាងដើមចោទជាមួយនឹងមេធាវី ៥នាក់ទៀត ។ ក្រោយពីឯកឧត្តមប្រធានសួរបញ្ជាក់ថា តើមានដើមបណ្តឹងមកទេ ពេលនោះលោក **សុន អរុណ** ឆ្លើយថាគាត់ជាមេធាវីតំណាងដើមបណ្តឹង ហើយ ឯកឧត្តម ប្រធានអនុញ្ញាតឱ្យគាត់ឡើងនិយាយក្នុងនាមជាដើមបណ្តឹង ។ លោក **សុន អរុណ** ក៏ឡើងមក សុំប្តឹងក្រុមប្រឹក្សាធម្មនុញ្ញអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានបំពេញភារកិច្ចរៀបចំ

ការបោះឆ្នោតមានភាពលំអៀង អសមត្ថភាព ខ្ជីខ្ជា និង គ្មានការទទួលខុសត្រូវ នាំឱ្យលទ្ធផលនៃការបោះឆ្នោតផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ

- យល់ឃើញថា លោក **មាន សទិ** តំណាងឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឆ្លើយដោះសារចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានរៀបចំការបោះឆ្នោតស្របទៅតាមច្បាប់ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងទៅតាមបទបញ្ជា និងនីតិវិធីរបស់ខ្លួន
- យល់ឃើញថា ឯកឧត្តមប្រធានបានសួរ លោក **សុន អរុណ** ថាមានសាក្សីទេ ? ។ លោក **សុន អរុណ** បានឆ្លើយថា មានសាក្សី ១៧៦ នាក់ តែមានវត្តមានតែ ៩៥ នាក់ទេ ។ ឯកឧត្តមប្រធានសុំឱ្យលោក **សុន អរុណ** នាំសាក្សីម្នាក់ក្នុងខេត្តណាមួយ ក្នុងរឿងណាមួយមកបំភ្លឺក្រុមប្រឹក្សាជំនុំជម្រះអំពីភាពលំអៀងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ប៉ុន្តែ លោក **សុន អរុណ** បែរជាសួររកលិខិតចាត់តាំងមេធាវីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង លិខិតតែងតាំងតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅវិញ ។ ឯកឧត្តមប្រធានសួរទៅតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាចុងចម្លើយឱ្យបង្ហាញសាក្សី តែលោក **មាន សទិ** បានបញ្ជាក់ថាលោកគ្មានសាក្សីទេ មានតែឯកសារ និង មន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- យល់ឃើញថា លោក **សុន អរុណ** បានលើកដៃ ហើយឡើងសួរឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះអំពីនីតិវិធីជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ ឯកឧត្តមប្រធានបានបំភ្លឺថា នីតិវិធីជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានរួចហើយ
- យល់ឃើញថា លោក **សុន អរុណ** បានចោទក្រុមប្រឹក្សាធម្មនុញ្ញថាបានលាក់ទុកនីតិវិធីនេះមិនឱ្យកូនក្តីដឹង ។ ឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជម្រះបានបំភ្លឺលោក **សុន អរុណ** ថានីតិវិធីនេះបានកសាង និងផ្សព្វផ្សាយតាំងពីឆ្នាំ ១៩៩៨ ។ ពេលនោះមានមេធាវីម្នាក់របស់ដើមបណ្តឹងបានលើកដៃហើយក្រោកឡើងនិយាយថាក្នុងចំណោមមេធាវីទាំង ៦ នាក់ ពុំមានអ្នកណាជាប្រធានទេ
- យល់ឃើញថា ក្នុងខណៈនោះមេធាវីទាំង ៦ នាក់របស់ដើមបណ្តឹង ក៏បានក្រោកដើរចេញពីសវនាការនៅម៉ោង ៨:៣២ នាទី
- យល់ឃើញថា ក្នុងពេលដំណាលគ្នានោះ ឯកឧត្តមប្រធានក្រុមប្រឹក្សាជម្រះបន្តនិតីវិធី ដោយសុំអោយសមាជិកក្រុមប្រឹក្សាជំនុំជំម្រះសួរដើមចោទ និង ចុងចម្លើយ ។ ឯកឧត្តម **ច្រាក់ សុខ** បានសុំឱ្យលេខាអានកំណត់ហេតុសួរយកចម្លើយពី លោក **សុន អរុណ** ត្រង់ទំព័រទី ៤ កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ ។ លេខបានអានថា លោក **សុន អរុណ** បានឆ្លើយថា: « មិនប្តឹងពីលទ្ធផលនៃការបោះឆ្នោតទេ គឺប្តឹងអំពីការលំអៀងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាំងឥរិយាបថ និង ទាំងការអនុវត្តន៍របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត »
- យល់ឃើញថា ទោះបីមានការដកខ្លួនថយចេញពីសវនាការរបស់មេធាវីតំណាងឱ្យដើមបណ្តឹង ក៏ក្រុមប្រឹក្សាជំនុំជម្រះនៅតែមានសុពលភាពគ្រប់គ្រាន់ក្នុងការបន្តនីតិវិធីជំនុំជម្រះក្នុងរឿងក្តីនេះ
- យលខ្ញុំឃើញថា ពាក្យបណ្តឹងនេះមិនប្តឹងពីលទ្ធផលនៃការបោះឆ្នោតទេ គឺប្តឹងអំពីអាកប្បកិរិយារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសុទ្ធសាធក្នុងការរៀបចំការបោះឆ្នោត

- យល់ឃើញថា តាមមាត្រា ១២៦ ថ្មី និង វាក្យខ័ណ្ឌទី ៣ នៃមាត្រា ១៥ ថ្មីនៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការដាក់ទណ្ឌកម្មគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ
- យល់ឃើញថា ពុំមានមាត្រានៃច្បាប់ណាដែលចែងថា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវដោះស្រាយបណ្តឹងរបស់គណបក្សនយោបាយដែលប្តឹងពីឥរិយាបថ និង សកម្មភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាននោះទេ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចឆ្លើយតបតាមពាក្យសុំរបស់គណបក្សហ៊្វុនស៊ិនប៉ិចបានឡើយ ។

**សម្រេច**

**ចំពោះមុខគូភាគី**

**មាត្រា ១ :** ទទួលពាក្យបណ្តឹងលេខ ៦៥៧ ហសប.សរ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ របស់ស្តេច ក្រុមឃុន **នរោត្តម សិរីវុឌ្ឍ** អគ្គលេខាធិការគណបក្សហ៊្វុនស៊ិនប៉ិច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ប៉ុន្តែបដិសេធចោលដោយបណ្តឹងនេះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ២ :** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ប៊ិន ឈិន**

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខៈ ០៧២/០១៦/២០០៣

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខៈ ០៥៦/០០៧/២០០៣ កបធ.ច

ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តនៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះសារលិខិត របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ៦៨១ ហសប/ជស ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៣ ផ្ទេរសិទ្ធិជូន ឯកឧត្តម **ញឹក ប៊ុនឆៃ** អគ្គលេខាធិការរង ប្រធានគណបក្ខហ្វ៊ុនស៊ិនប៉ិច ដើម្បីជាតំណាងក្នុងរឿងប្តឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងបណ្តឹង លេខ ៦៦៥ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញពាក្យបណ្តឹងរបស់ឯកឧត្តម **ញឹក ប៊ុនឆៃ** អគ្គលេខាធិការរងគណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ៦៦៥ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣ ប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមិនបានបំពេញភារកិច្ច រៀបចំការបោះឆ្នោតឱ្យស្របតាមបទបញ្ញា នីតិវិធី ក្រមសីលធម៌ និង ច្បាប់បោះឆ្នោត ដែលអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ០៨:៣៥ នាទី
- បានឃើញលិខិតរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ៦៦៧ ហសប.សណ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣ ឧទ្ទេសនាមលោក **សុន អរុណ** ជាប្រធានការិយាល័យមេធាវី និង លោក **ម៉ី ច័ន្ទវាសនា** ជាប្រធានផ្នែក រដ្ឋបាលមេធាវីរបស់គណបក្ស ដើម្បីបំពេញភារកិច្ចដាក់ពាក្យបណ្តឹង និង ទំនាក់ទំនងជាមួយក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុសួរយកចម្លើយ ដែលបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិចកាល

ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

- បានឃើញកំណត់ហេតុសួរយកចម្លើយ ពីតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញលិខិតពឹងពាក់មេធាវី លេខ ៦៧៩ ហសប.សណ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **ញឹក ប៊ុនឆៃ** អគ្គលេខាធិការរងគណបក្សហ្វ៊ុនស៊ិនប៉ិច សុំឱ្យមេធាវី ៦ រូប ដើម្បីជាតំណាងក្នុងពេលសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៨.១៦៨៦/០៣ គ.ជ.ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **អ៊ឹម សួស្ដី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់តាំងតំណាង គ.ជ.ប ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ និង លិខិតលេខ ០៨.១៦៩០/០៣/គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៣ របស់ឯកឧត្តម **អ៊ឹម សួស្ដី** ប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោត ស្ដីពីការបន្ថែមសមាជិក គ.ជ.ប ចំនួន ៣ រូប ដើម្បីចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្ដាប់ចម្លើយរបស់ចុងចម្លើយ**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ឯកឧត្តម **ញឹក ប៊ុនឆៃ** តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច បានដាក់បណ្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញមានលក្ខណៈអាចទទួលយកមកពិនិត្យបាន ដោយផ្អែកតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា បណ្ដឹងនេះបានដាក់ក្នុងរយៈពេល ៧២ ម៉ោង បន្ទាប់ពីការប្រកាសលទ្ធផលបណ្ដោះអាសន្នរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា ការចោទប្រកាន់របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីការមិនបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតឱ្យស្របតាមបទបញ្ជា នីតិវិធី ក្រមសីលធម៌ និង ច្បាប់បោះឆ្នោតមាន ០៥ ចំណុច គប្បីយកបញ្ហាទាំងនេះមកពិចារណាបន្តបន្ទាប់តាមករណីនីមួយៗ
- យល់ឃើញថា មុនពេលយុទ្ធនាការឃោសនាបោះឆ្នោត ពុំមានច្បាប់ណាហាមឃាត់មិនឱ្យគណបក្សនយោបាយធ្វើការចែកអំណោយដល់ប្រជាពលរដ្ឋឡើយ ។ នៅពេលយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៣ មានលេចបញ្ហាចែកអំណោយដើម្បីទិញសន្លឹកឆ្នោតតែបញ្ហាទាំងនោះក៏បានត្រូវបណ្ដាគណបក្ស និង គណៈកម្មាការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់បានដោះស្រាយមួយចំនួន ហើយមួយចំនួនទៀត ពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់ ។ ក្នុងសវនាការជំនុំជម្រះនេះ ពុំឃើញមានភស្តុតាងអំពីបញ្ហានេះ ឱ្យបានច្បាស់លាស់ឡើយ
- យល់ឃើញថា វត្តមានអាជ្ញាធរដែនដីដូចជាអភិបាលស្រុក-ខណ្ឌ មេឃុំ ចៅសង្កាត់ និង មេភូមិ ដែលនៅកន្លែងខ្លះត្រូវ បានចោទប្រកាន់ថារំលោភលើសេចក្ដីណែនាំរួមរបស់ក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនោះ ត្រូវបានដោះស្រាយទៅតាមទីកន្លែងរួចស្រេចអស់ហើយ ជាមួយនឹងគណបក្សនយោបាយ

គណៈកម្មការបោះឆ្នោតគ្រប់ថ្នាក់រួចហើយ

- យល់ឃើញថា បញ្ជីបោះឆ្នោតនៅការិយាល័យនានាមានខ្វះចន្លោះ ខ្លះដោយអចេតនា ខ្លះដោយបច្ចេកទេសប៉ុន្តែភាពមិនប្រក្រតីធ្ងន់ធ្ងរពុំកើតមានឡើយនៅទូទាំងប្រទេស
- យល់ឃើញថា ការផ្លាស់ប្តូរទីតាំងការិយាល័យ និង ការបិទផ្សាយទីតាំងការិយាល័យបោះឆ្នោត ដែលត្រូវបានចោទថា មិនអនុវត្តតាមមាត្រា ៨៦ នៃច្បាប់បោះឆ្នោត និងការបិទបញ្ជីបោះឆ្នោតនៅតាម ការិយាល័យមិនបានគ្រប់ ២៤ ម៉ោង មុនថ្ងៃបោះឆ្នោត ជាបណ្តឹងមិនមានមូលដ្ឋានគ្រប់គ្រាន់ លើកលែងតែករណីតិចតួច ដែលមានការប្តូរកន្លែងមុនថ្ងៃបោះឆ្នោត ទៅកន្លែងដែលជិតបំផុត ដើម្បីសម្របសម្រួលតាមច្បាប់ តាមការជាក់ស្តែង និង ទឹកលិចដែលជាករណីប្រធានស័ក្តិ ដោយមានការឯកភាពជាមួយ គណបក្សនយោបាយនានា ពិសេសគណបក្សធំទាំងបី ។ អ្នកមិនបានទៅមើលឈ្មោះមុនថ្ងៃបោះឆ្នោត មានការពិបាកខ្លះ ប៉ុន្តែអាចបោះឆ្នោតបាន ។ ករណីទាំងនេះ មិនបង់ឱ្យមានភាពមិនប្រក្រតីធ្ងន់ធ្ងរជះឥទ្ធិពលទៅលើលទ្ធផលនៃការបោះឆ្នោតទូទាំងប្រទេសឡើយ
- យល់ឃើញថា ការអះអាងរបស់គណបក្សហ៊្វុនស៊ិនប៉ិចថាបណ្តឹងរបស់គណបក្សនេះ ត្រឹម ១ ភាគ៤ តែប៉ុណ្ណោះត្រូវមន្ត្រីគណៈកម្មាធិការរៀបចំការបោះឆ្នោតថ្នាក់ឃុំ សង្កាត់ និង ខេត្ត ក្រុង យកមកដោះស្រាយ ឯ ៣ ភាគ ៤ ទៀតមិនបានយកមកដោះស្រាយទេ ។ បណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិចទាំងប៉ុន្មាន សុទ្ធសឹងបានពិចារណាពីខាងលើរួចហើយនៅកន្លែងខ្លះមានភាពមិនប្រក្រតីតិចតួច ប៉ុន្តែមានមូលហេតុគ្រប់គ្រាន់ខាងផ្លូវច្បាប់ និង ជាក់ស្តែងព្រមទាំងមិនជះឥទ្ធិពលដល់លទ្ធផលនៃការបោះឆ្នោតឡើយ ។ ចំពោះបញ្ហានេះការដោះសាររបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលឆ្លើយក្នុងអង្គសវនាការ បញ្ជាក់ថា: មានបណ្តឹងមួយចំនួនត្រូវបានបញ្ចប់រួចហើយ នៅត្រឹមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ឯមួយចំនួនទៀតត្រូវបានបញ្ចប់ត្រឹមគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត មានបណ្តឹងតិចតួចណាស់ដែលប្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានដោះស្រាយរួចរាល់អស់ហើយ ។ ចំពោះពាក្យបណ្តឹងដែលអះអាងថា នៅសល់បណ្តឹង ៣ ភាគ ៤ ទាក់ទង នឹងភាពមិនប្រក្រតីមិនទាន់ត្រូវបានដោះស្រាយនោះ ពុំមានភស្តុតាង គ្រប់គ្រាន់មកបញ្ជាក់នោះទេ ។

## សម្រេច

## ចំពោះមុខចុងចម្លើយ  គាំបាំងមុខដើមបណ្តឹង

## ប៉ុន្តែចាត់ទុកជាចំពោះមុខ

**មាត្រា ១ :** បដិសេធពាក្យបណ្តឹងរបស់ ឯកឧត្តម **ញឹក  ប៊ុនឆៃ** តំណាងគណបក្សហ៊្វុនស៊ិនប៉ិច លេខ ៦៦៥ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៣ ប្តឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលថាមិនបានបំពេញភារកិច្ចរៀបចំការបោះឆ្នោតឱ្យស្របតាមបទបញ្ជា នីតិវិធី ក្រមសីលធម៌ និង ច្បាប់បោះឆ្នោត។

**មាត្រា ២ :** បដិសេធពាក្យបណ្តឹងរបស់ ឯកឧត្តម **ញឹក  ប៊ុនឆៃ** ដែលទាមទារឱ្យក្រុមប្រឹក្សាធម្មនុញ្ញប្រកាសបដិសេធលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ។

**មាត្រា ៣ :** សេចក្តីសម្រេចនេះប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៣

ជា សេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្ត ទៅលើអំណាចទាំងអស់ ដែលមានចែងនៅ ក្នុង រដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខៈ ០៧១/០១៥/២០០៣

ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខៈ  ០៥៧/០០៨/២០០៣

ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញពាក្យបណ្តឹង គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ របស់ ឯកឧត្តម **សម  រង្ស៊ី** ប្រធានគណបក្ស សម រង្ស៊ី ប្តឹងតវ៉ាអំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ ២០០៣
- បានឃើញលិខិត  គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ របស់ ឯកឧត្តម **សម  រង្ស៊ី**  ប្រធានគណបក្ស សម រង្ស៊ី ផ្ទេរសិទ្ធិឱ្យទៅ ឯកឧត្តម **អ៊ូ  ប៊ុនឡុង** ប្រធានគណៈកម្មការបោះឆ្នោតគណបក្ស សម រង្ស៊ី ដើម្បីដាក់ពាក្យបណ្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ៨:៣០ របស់សមាជិកក្រុមទី ២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពី ឯកឧត្តម **តេព  នីថា** អគ្គលេខាធិការ គ ជ ប ដើម្បីបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១៥:៣០ របស់សមាជិកក្រុមទី២ នៃ ក្រុមប្រឹក្សាធម្មនុញ្ញ ដែល សួរយកចម្លើយពី លោក **លុន     ឆេងកៃ** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតក្រុងភ្នំពេញ ដើម្បីបញ្ជាក់បន្ថែម ទៅលើពាក្យបណ្តឹង របស់ គណបក្ស សម រង្ស៊ី គ្មានចុះលេខ

ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣

- បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ៨:០០ របស់សមាជិកក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពីឯកឧត្តម **តេព នីថា** អគ្គលេខាធិការ គ ជ ប ដើម្បីបញ្ជាក់បន្ថែមទៅលើពាក្យបណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១៥:៣០ របស់សមាជិកក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលសួរយកចម្លើយពី ឯកឧត្តម **អ៊ូ ច័ន្ទរ័ត្ន** ប្រធានគណៈកម្មការបោះឆ្នោតគណបក្ស សម រង្ស៊ី ដើម្បីបញ្ជាក់បន្ថែម ទៅលើពាក្យបណ្តឹង របស់ គណបក្ស សម រង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣
- បានឃើញលិខិតលេខ ០៨/១៦៨៦/០៣ គ ជ ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣ របស់ ឯកឧត្តម **អ៊ឹម សួស្តី** ប្រធាន គ ជ ប ដែលបានចាត់តាំងឱ្យតំណាង គ ជ ប ដើម្បីឆ្លើយបំភ្លឺនាពេលសវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៣
- បានឃើញលិខិតលេខ ០៨/១៦៩០/០៣ គ ជ ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៣ របស់ ឯកឧត្តម **អ៊ឹម សួស្តី** ប្រធាន គ ជ ប ស្តីពីការបន្ថែមសមាជិក គ ជ ប ចំនួន ៣ រូប ដើម្បីឆ្លើយបំភ្លឺនាពេលសវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ លីពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៣

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានស្តាប់សាក្សីទាំងសងខាង**

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា ពាក្យបណ្តឹងតវ៉ារបស់ ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្ស សមរង្ស៊ី គ្មានចុះលេខ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ ជាពាក្យបណ្តឹងដោយផ្ទាល់ក្នុងកំឡុងពេល ៧២ ម៉ោងក្រោយពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររបស់ គ ជ ប ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៣ វេលាម៉ោង ១០:៣០ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់

**ករណីភ្នំពេញ (១២)**

- យល់ឃើញថា ការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៣ នេះត្រូវធ្វើនៅទីស្នាក់ការឃុំ សង្កាត់ ខុសពីការចុះឈ្មោះបោះឆ្នោតកន្លងមក ដែលធ្វើនៅគ្រប់ការិយាល័យបោះឆ្នោតនីមួយៗ ទូទាំងប្រទេស
- យល់ឃើញថា ពេលចុះឈ្មោះបោះឆ្នោតដំបូង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ខ្លះបានចុះឈ្មោះលើសពី ៧០០ នាក់ ដែលច្បាប់កំណត់សម្រាប់មួយការិយាល័យ ។ នៅក្រោយពេលមានការណែនាំរបស់គណៈកម្មការក្រុងរៀបចំការបោះឆ្នោត ក៏មានការកែតម្រូវ ដោយបញ្ចូលឈ្មោះអ្នកចុះឈ្មោះ ទៅការិយាល័យថ្មីដែលនៅជិត ហើយដែលជាហេតុនាំឱ្យមានការប្តូរលេខបង្កាន់ដៃ និង លេខកូដការិយាល័យ ។
- យល់ឃើញថា ការសុំបញ្ជីបោះឆ្នោតដែលមិនទាន់ធ្វើបច្ចុប្បន្នភាព ហើយដែលមិនត្រូវបានផ្តល់ជូនដោយ គ ជ ប មិនពាក់ព័ន្ធដល់មាត្រា ៦៣ ថ្មីនៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនោះទេ ។

## ករណីខេត្តស្វាយរៀង (២០)

- យល់ឃើញថា គណបក្ស សម រង្ស៊ី ក្រោយពីបានទទួលទម្រង់បែបបទ ១១០៥ យកមកផ្ទៀងផ្ទាត់តួលេខឃើញថា មានខុសតួលេខដែលបានបូកផ្ទៀងផ្ទាត់ហើយ ក៏ ប្ដឹងទៅ គ ជ ប ដើម្បីផ្ទៀងផ្ទាត់ឡើងវិញលើ ទម្រង់បែបបទ ១១០៥ ទៅនឹងទម្រង់បែបបទ ១១០៤ ទាំង ១៤ ឃុំ នៅខេត្តស្វាយរៀង
- យល់ឃើញថា គ ជ ប យល់ព្រមឱ្យក្រុមត្រួតពិនិត្យធ្វើការផ្ទៀងផ្ទាត់ចំនួន ១៤ ឃុំ តាមបណ្ដឹងរបស់គណបក្ស សម រង្ស៊ី ដោយមានតំណាងគណបក្ស និង អ្នកសង្កេតការណ៍ចំនួន ១៤ រូប ចូលរួមផង
- យល់ឃើញថា មន្ត្រីគណៈកម្មការឃុំរៀបចំការបោះឆ្នោត មានការធ្វេសប្រហែសក្នុងការស្រង់តួលេខចូលក្នុងទម្រង់បែបបទ ១១០៥ ដោយមិនបានផ្ទៀងផ្ទាត់ជាមួយទម្រង់បែបបទ ១១០៣ ឱ្យបានត្រឹមត្រូវ បណ្ដាលឱ្យមានការភ័ន្តច្រឡំតួលេខនៃគណបក្សតូចៗ ។ ប៉ុន្តែការភ័ន្តច្រលំនេះ មិនបណ្ដាលឱ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោតទេ
- យល់ឃើញថា លទ្ធផលដែលគណបក្ស សម រង្ស៊ី ចាញ់គេមាន ១៤៦ សំលេងគឺត្រូវជា 0.06% នឹងទទួលបានមួយអាសនៈហើយទាមទារឱ្យរាប់ និង ផ្ទៀងផ្ទាត់ឡើងវិញនោះមិនសមស្របទេ
- យល់ឃើញថា ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនមានចែងឱ្យមានការរាប់ និង ផ្ទៀងផ្ទាត់ឡើងវិញ ដោយសារការប្រៀបធៀបមធ្យមភាគដែលគណបក្សនយោបាយបានទទួលនោះទេ
- យល់ឃើញថា មានតួលេខខុសគ្នាពីលទ្ធផលបណ្ដោះអាសន្នប្រកាសនៅគណៈកម្មការឃុំរៀបចំការបោះឆ្នោត និង ខុសពីទម្រង់បែបបទ ១១០៥ ជាមួយនឹងលទ្ធផលបណ្ដោះអាសន្នប្រកាសជាផ្លូវការដោយ គ.ជ.ប និង បណ្ដាលមកពីការខ្វះខាតរបស់គណៈកម្មការឃុំរៀបចំការបោះឆ្នោត ស្រង់តួលេខចូលទម្រង់បែបបទ ១១០៥ ប៉ុន្តែ ទម្រង់បែបបទ ១១០៣ មិនមានខុសទេ ។ ការខុសឆ្គងនេះត្រូវបានកែតម្រូវឡើងវិញ បន្ទាប់ពីក្រុមត្រួតពិនិត្យ គ.ជ.ប រកឃើញការខ្វះខាតទាំងនេះ
- យល់ឃើញថា គណៈកម្មការឃុំរៀបចំការបោះឆ្នោត ឃុំដូង (០៣៩) ចេញទម្រង់បែបបទ ១១០៥ ដល់ទៅពីរច្បាប់ ហើយតួលេខខុសគ្នានេះជាការខ្វះខាតរបស់គណៈកម្មការឃុំរៀបចំការបោះឆ្នោតដែរ ប៉ុន្តែមូលហេតុសំខាន់គឺទម្រង់បែបបទ ១១០៥ នេះត្រូវបានកែតម្រូវឡើងវិញក្រោយពេលពិនិត្យផ្ទៀងផ្ទាត់រួចមក ។ ចំពោះទម្រង់បែបបទ ១១០៣ គឺត្រឹមត្រូវដដែល ។
- យល់ឃើញថា លើទម្រង់បែបបទ ១១០៤ (កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់) នីមួយៗ ឃើញថា នៅក្រុមរាប់សន្លឹកឆ្នោតទូទាំង ១៥ ឃុំ មានចុះហត្ថលេខាលើទំរង់បែបបទ ១១០៤ ពីតំណាងគណបក្សនានា ក្នុងនោះមានតំណាងគណបក្ស សម រង្ស៊ី ដែរ លើកលែងតែក្រុមរាប់សន្លឹកឆ្នោតចំនួន ៥ ក្រុម ដូចជា :
  - ឃុំប្រសូតិ ក្រុមរាប់មាន ៣ ក្រុមរាប់ទី១ និង ទី ៣ មានចុះហត្ថលេខារួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ២ មិនមានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ប៉ុន្តែពុំមានពាក្យបណ្ដឹងអ្វីទាំងអស់
  - ឃុំដូង ក្រុមរាប់មាន ៤ ក្រុមរាប់ទី១ ទី២ និង ទី៣ មានចុះហត្ថលេខាតំណាងគណបក្សនានារួម ទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ៤ មិនមានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី
  - ឃុំច្រកម្ទេសក្រុមរាប់មាន ៤ ក្រុមរាប់ទី ២ ទី ៣ និង ទី ៤ មានចុះហត្ថលេខាតំណាងគណបក្សនានារួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ១ មិនមានតំណាងគណបក្សនយោបាយណាចុះហត្ថលេខាទេ
  - ឃុំញរ ក្រុមរាប់មាន ៣ ក្រុមរាប់ទី ១ និង ទី ៣ មានចុះហត្ថលេខាតំណាងគណបក្សនយោបាយនានារួម

ទាំងតំណាងគណបក្ស សម រង្ស៊ី ផង លើលែងតែក្រុមរាប់ទី ២ គ្មានចុះហត្ថលេខាទេ

- ឃុំត្រពាំងស្ដៅ ក្រុមរាប់ទី២ តំណាងគណបក្ស សម រង្ស៊ី មិនបានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ មែន តែក្នុងទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាដោយតំណាងគណបក្ស សម រង្ស៊ី ដែរ

- យល់ឃើញថា លើទម្រង់បែបបទ ១១០៨ ទាំង ១៥ ឃុំ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញមានចុះហត្ថលេខារបស់តំណាងគណបក្សនានា រួមទាំងហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ផង លើកលែងតែនៅ :

- ឃុំប្រសូតិ ក្រុមរាប់ទី ២ គ្មានចុះហត្ថលេខារបស់តំណាងគណបក្ស សម រង្ស៊ី ទេ

- ឃុំដូង ក្រុមរាប់ទី ២ និង ទី ៣ គ្មានចុះហត្ថលេខារបស់តំណាងគណបក្ស សម រង្ស៊ី ទេតែក៏គ្មានពាក្យបណ្ដឹងអ្វីដែរ ក៏ប៉ុន្តែនៅលើទម្រង់បែបបទ ១១០៩ និង ទម្រង់បែបបទ ១១០៣ មានហត្ថលេខារបស់តំណាងគណបក្ស សម រង្ស៊ី ដែរ

- នៅឃុំច្រកម្ទេស ក្រុមរាប់ទី ១ មិនបានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ មែន តែក្នុងទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

- នៅឃុំញរ ក្រុមរាប់ទី ២ មិនបានចុះហត្ថលេខាលើទម្រង់បែបបទ ១១០៤ មែន តែក្នុងទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

- យល់ឃើញថា លើទម្រង់បែបបទ ១១០៣ ទាំង ១៥ ឃុំ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញ មានចុះហត្ថលេខារបស់តំណាងគណបក្សនានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី លើកលែងតែឃុំប្រសូតិ (០៧៦) ដែលគ្មានតំណាងគណបក្សណាមួយចុះហត្ថលេខាទេ ប៉ុន្តែក៏គ្មានពាក្យបណ្ដឹងដែរ

- យល់ឃើញថា លើទម្រង់បែបបទ ១១០៩ ទាំង ១៥ ឃុំ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញ ឃើញថា :

- ឃុំប្រសូតិ (០៧៦) គ្មានហត្ថលេខាតំណាងគណបក្សណាទេ

- ឃុំកំពង់ចក (០២៥) មិនមានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ីទេ ប៉ុន្តែក្នុងទម្រង់បែបបទ ១១០៨ មានហត្ថលេខាតំណាងគណបក្សនានា រួមទាំងហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ផង ហើយក្នុងទម្រង់បែបបទ ១១០៣ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី រហូតដល់ ៣ នាក់

- ឃុំថ្មី (០២១) គ្មានតំណាងគណបក្សនយោបាយណាមួយចុះហត្ថលេខាទេ ប៉ុន្តែក្នុងទម្រង់បែបបទ ១១០៨ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

- ឃុំត្រពាំងស្ដៅ (០៤៧) គ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ទេ ប៉ុន្តែ ក្នុងទម្រង់បែបបទ ១១០៣ និង ទម្រង់បែបបទ ១១០៨ មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដែរ

- យល់ឃើញថា ទម្រង់បែបបទ ១១០៣ ទាំង ១៥ ឃុំ ដែលស្នើឱ្យរាប់ឡើងវិញ ជាឯកសារសំខាន់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុងនោះ ហើយក្នុងទម្រង់បែបបទទាំងនោះ មានចុះហត្ថលេខាដោយតំណាងគណបក្សនានា រួមទាំងហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី លើកលែងតែ ឃុំប្រសូតិ (០៧៦) តែមួយគត់ ដែលគ្មានហត្ថលេខាតំណាងគណបក្សណាទាំងអស់ ។

ការខ្វះខាតនានា ដែលបានលើកឡើង រួមមានការខ្វះខាតក្នុងការស្រង់តួលេខដាក់ចូលក្នុងទម្រង់បែបបទ ១១០៥ (ក្រដាសលទ្ធផលនៃការបោះឆ្នោតឃុំ សង្កាត់) សម្រាប់ជូនគណបក្សនានាវាមិនអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោតទេ

- យល់ឃើញថា ក្នុងចំណោមឃុំទាំង ១៥ ដែលគណបក្ស សម រង្ស៊ី សុំឱ្យរាប់ឡើងវិញនោះ តំណាងគណបក្ស សម រង្ស៊ី ខ្លួនឯង សុទ្ធតែបានចុះហត្ថលេខាទទួលស្គាល់តួលេខត្រឹមត្រូវអស់ហើយ ដោយមានចុះហត្ថលេខានៅលើទម្រង់បែបបទខ្លះលេខ ១១០៨ ខ្លះលេខ ១១០៩ ខ្លះលេខ ១១០៤ ហើយនិងខ្លះទៀតលេខ ១១០៣ ។
- យល់ឃើញថា លើទម្រង់បែបបទ ១១០៣ មានចុះហត្ថលេខាតំណាងគណបក្សនានា រួមទាំងគណបក្ស សម រង្ស៊ី ផង លើកលែងតែឃុំប្រសូតិ (០៧៦) មួយ គឺជាការទទួលស្គាល់ការបូកសរុបលទ្ធផលនៃការបោះឆ្នោតទាំង ១៥ ឃុំ ដែលប្ដឹងឱ្យរាប់ឡើងវិញ ។ ដូច្នេះការស្នើឱ្យរាប់ឡើងវិញមិនជាការចាំបាច់ទេ ។

## ករណីខេត្តកំពង់ធំ (០៦)

- យល់ឃើញថា គណបក្ស សម រង្ស៊ី បានប្ដឹងមកគណៈកម្មការខេត្តរៀបចំការបោះឆ្នោត (គ ខ ប) ចំនួន ២៣បណ្ដឹង ក្នុងខេត្តកំពង់ធំ ។ ចំពោះបណ្ដឹងសុំឱ្យរាប់ឡើងវិញ ៦ ឃុំ គ ខ ប បានឱ្យតំណាងគណបក្ស សម រង្ស៊ី ជ្រើសរើស ២ ឃុំ ដែលសង្ស័យថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ។ តំណាងគណបក្សសម រង្ស៊ី បានឯកភាពជាមួយ គ ខ ប ដោយឱ្យផ្ទៀងផ្ទាត់ និង រាប់សន្លឹកឆ្នោតខូចនៅឃុំដូង (០៣៩) និង រាប់ឡើងវិញនៅឃុំសាគ្រាម (០៤២) ។ ចំពោះបណ្ដឹងសុំឱ្យផ្ទៀងផ្ទាត់ចំនួន ១៤ ឃុំ គ ខ ប បានធ្វើការផ្ទៀងផ្ទាត់ចំនួន ៦ ឃុំគឺ ឃុំក្រវ៉ាញ (០១១) ឃុំញ៉ោ (០៦៥) ឃុំគគីរ (០១០) ឃុំពង្រ (០១៣) ឃុំច្រនាង (០០៦) និង ឃុំដូង (០៣៩) ពុំឃើញមានភាពមិនប្រក្រតី គួរឱ្យកត់សំគាល់ឡើយ
- យល់ឃើញថា គណបក្ស សម រង្ស៊ី បានប្ដឹងមក គ ជ ប ដោយសុំឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួន ២៦ ឃុំ ហើយ គ ជ ប សំរេចធ្វើការផ្ទៀងផ្ទាត់ចំនួន ១១ ឃុំ គឺ ឃុំស្វាយភ្លើង (០១៦) ឃុំកំពង់ធំ (០២៩) ឃុំក្ដីដូង (០៣២) ឃុំក្រយា (០៤០) ឃុំទួលគ្រើល (០៤៥) ឃុំចំណារក្រោម (០៧០) ឃុំព្រះដំរី (០៧៨) ឃុំសំព្រោជ (០៨០) មានការខុសតួលេខបន្តិចបន្តួច ហើយបានឯកភាពគ្នាកែតម្រូវរួចហើយ ។ ចំពោះ៣ ឃុំ ទៀតគឺ ឃុំបាក់ស្នា (០០១) ឃុំសណ្ដាន់ (០៥៧) ឃុំកោះ (០៦៣) គ្មានអ្វីគួរឱ្យកត់សំគាល់ពីភាព មិនប្រក្រតីឡើយ ដោយក្នុងទម្រង់ ១១០៨ ទម្រង់ ១១០៤ ទម្រង់ ១១០៩ ទម្រង់ ១១០៣ និង ទម្រង់ ១១០៥ ក្នុងពេលផ្ទៀងផ្ទាត់ មានលក្ខណៈត្រឹមត្រូវទាំងអស់ ហើយក្នុងពេលផ្ទៀងផ្ទាត់នោះ ក៏មានការចូលរួមពីតំណាងគណបក្ស សម រង្ស៊ី និង អង្គការដទៃទៀតតែពុំបានដាក់ចូលក្នុងកំណត់ហេតុគឺជាការខ្វះខាតមួយរបស់ក្រុមត្រួតពិនិត្យ គ ជ ប
- យល់ឃើញថា ការរាប់សាកល្បងរបស់ គ ខ ប ចំនួន ២ ឃុំគឺ ឃុំដូង (០៣៩) បានផ្ទៀងផ្ទាត់និងរាប់សន្លឹកឆ្នោតខូច និង ឃុំសាគ្រាម (០៤២) រាប់ឡើងវិញតាមពាក្យបណ្ដឹងរបស់ លោក **ម៉ៅ សុភារិទ្ធ** តំណាងគណបក្ស សម រង្ស៊ី ដែលប្ដឹងសុំឱ្យរាប់ឡើងវិញចំនួន ៦ ឃុំ រួមមាន : ឃុំផាន់ញើម (០៤១) ឃុំដូង (០៣៩) ឃុំគោល (០៤៦) ឃុំសណ្ដាន់ (០៤៧) ឃុំជ្រាប់ (០៦១) និង ឃុំសាគ្រាម (០៤២) មិនឃើញមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់លទ្ធផលបោះឆ្នោតទេ
- យល់ឃើញថា សន្លឹកឆ្នោតដែលលើស ៦៣ សន្លឹក បណ្ដាលមកពីការស្រង់លេខច្រឡំក្នុងទម្រង់ ១១០៥ ដោយសន្លឹកឆ្នោតខូចមានចំនួន ១៨ សន្លឹក តែសរសេរ ៨១ សំលេង (៨១-១៨ = ៦៣) គឺជាការខ្វះខាតមួយរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គ ឃ ប)
- យល់ឃើញថា ក្នុងទម្រង់បែបបទ ១១០៤ មានហត្ថលេខានានា រួមទាំងតំណាងគណបក្ស សមរង្ស៊ី ផងដែរលើកលែងតែ ក្រុមរាប់មួយចំនួនគ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ដូចជា : ឃុំបន្ទាយស្ទោង ក្រុមរាប់ទី ១

ទី ២ ទី ៤ ឃុំចុងដូង ក្រុមរាប់ទី ១ ឃុំងន ក្រុមរាប់ទី ១ ឃុំសាលាវិស័យ ក្រុមរាប់ទី ១ ឃុំសណ្ដាន់ ក្រុមរាប់ទី ៤

- យល់ឃើញថា ក្នុងទម្រង់បែបបទ ១១០៨ ដែលក្រុមត្រួតពិនិត្យ គ ជ ប បានពិនិត្យឡើងវិញ ចំនួន ១១ ឃុំ ក្នុងចំណោម ២៦ ឃុំ ដែលសុំឱ្យផ្ទៀងផ្ទាត់ឡើងវិញដោយ គណបក្ស សម រង្ស៊ី នោះឃើញថាមានហត្ថលេខា តំណាងគណបក្ស សម រង្ស៊ី លើកលែងតែក្រុមរាប់ទី ៣ ឃុំ ចំណារក្រោម (០៧០) ដែលមាន ៤ក្រុមរាប់ដែលគ្មាន ហត្ថលេខា តំណាងគណបក្ស សម រង្ស៊ី ប៉ុន្តែលើទម្រង់បែបបទ ១១០៩ នៃ ឃុំទាំងនេះមានហត្ថលេខា តំណាង គណបក្សសមរង្ស៊ីដែរ
- យល់ឃើញថា លើទម្រង់បែបបទ ១១០៣ ទាំង ៣៩ ឃុំ ឃើញថាមានហត្ថលេខា ៣៨ ឃុំ ដែលមានហត្ថលេខា របស់តំណាងគណបក្សនានា រួមទាំងតំណាងគណបក្ស សម រង្ស៊ី ។ ដោយឡែក ឃុំចំណារក្រោម (០៧០) មាន ៤ ក្រុមរាប់តែក្រុមរាប់ទី ៣ គ្មានហត្ថលេខាតំណាងគណបក្ស សម រង្ស៊ី ប៉ុន្តែនៅ លើទម្រង់បែបបទ ១១០៩ នៃឃុំ ទាំងនេះ មានហត្ថលេខាគណបក្ស សម រង្ស៊ី ដែរ
- យល់ឃើញថា ក្នុងទម្រង់បែបបទ ១១០៩ ដែលក្រុមត្រួតពិនិត្យ គ ជ ប បានពិនិត្យឡើងវិញចំនួន ១១ ឃុំ ក្នុង ចំណោម ២៦ ឃុំ ដែលសុំឱ្យផ្ទៀងផ្ទាត់ឡើងវិញ ដោយគណបក្ស សម រង្ស៊ី នោះ ឃើញថា មានតំណាងគណបក្ស នានាចុះហត្ថលេខា រួមទាំងតំណាងគណបក្ស សម រង្ស៊ី ដែរ
- យល់ឃើញថា ទម្រង់បែបបទ ១១០៣ ជាឯកសារសំខាន់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលនៃការបោះឆ្នោតខេត្តក្រុង មានចុះហត្ថលេខាទទួលស្គាល់ដោយតំណាងគណបក្សនានា រួមទាំង គណបក្ស សម រង្ស៊ី ផង លើកលែងតែឃុំ កំពង់ចិនត្បូង (០៧៣) មួយ ប៉ុន្តែតំណាងគណបក្ស សម រង្ស៊ី បានចុះ ហត្ថលេខាលើទម្រង់បែបបទ ១១០៤ ដែរ ។ ដូច្នេះការស្នើឱ្យរាប់ឡើងវិញ មិនជាការចាំបាច់ទេ ។

## ករណីខេត្តបន្ទាយមានជ័យ (០១)

- យល់ឃើញថា មានអ្នកបោះឆ្នោតនៅឃុំប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ មានអត្រាត្រឹម ៤៦% យើងទទួលស្គាល់ថា តិចមែន បើប្រៀបធៀបនឹងអត្រាទូទាំងខេត្ត ដែលមាន ៧៤% ប៉ុន្តែ ក្នុងច្បាប់បោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ ពុំមានកំណត់ថា តើអត្រាអ្នកបោះឆ្នោតប៉ុន្មានអាចទទួលយកបាន អត្រាអ្នកបោះឆ្នោត ប៉ុន្មាន មិនអាចទទួលយកបាន ព្រោះប្រជាពលរដ្ឋ មានសិទ្ធិទៅបោះឆ្នោត ដែលធានាដោយច្បាប់ មិនមែនជា កាតព្វកិច្ចដែលតម្រូវចាំបាច់ត្រូវតែទៅបោះឆ្នោតទេ ។ ចំណុចនេះ មានចែងក្នុងវាក្យខ័ណ្ឌ ទី២ មាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ៗ ប្រជាពលរដ្ឋទាំងពីរភេទដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។
- យល់ឃើញថា ការិយាល័យបោះឆ្នោតចំនួន ២៧ បានប្តូរទៅកន្លែងផ្សេងទៀត តាំងតែពីឆ្នាំ ២០០២ ម្ល៉េះ ។ ដូច្នេះមានពេលវេលាគ្រប់គ្រាន់ ក្នុងការផ្សព្វផ្សាយជូនសាធារណជន និង បានបិទផ្សាយត្រឹមត្រូវស្របតាម មាត្រា ១៣៥ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយយោងតាមការបញ្ជាក់របស់ អ្នកស្រី **ឡាយ ហ៊ុនគី** ប្រធានគណៈកម្មការខេត្តរៀបចំការបោះឆ្នោតខេត្តបន្ទាយមានជ័យ នៅក្នុងសវនការ គ ជ ប
- យល់ឃើញថា ការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំប៉ោយប៉ែត មិនមានចម្ងាយលើសពី ៥ គីឡូម៉ែត្រ ទេតាម ការបញ្ជាក់ពី ឈ្មោះ **មាន សារិត** ដើមចោទមកពីគណបក្ស សម រង្ស៊ី ដែលបានអះអាងក្នុងសវនការ គ ជ ប និង តាមការបញ្ជាក់ពីលោក **សាន ស៊ានហូ** ជួសមេឃុំប៉ោយប៉ែត កាលពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣

- យល់ឃើញថា ឈ្មោះអ្នកបោះឆ្នោតខ្លះ ពុំមានភូមិនៅក្នុងឃុំប៉ោយប៉ែតទេ បញ្ហានេះមាន តាមការដោះសា របស់ គ ជ ប ជាកំហុសបច្ចេកទេស
- យល់ឃើញថា អ្នកមានប័ណ្ណបោះឆ្នោតឆ្នាំ ២០០២ ឬ លិខិតបញ្ជាក់អត្តសញ្ញាណ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ ២០០៣ មិនបានបោះឆ្នោត ដោយលើកជាភស្តុតាង ៤ នាក់ នោះតាមការពិនិត្យយើងឃើញម្នាក់ក្នុង ៤ នាក់ គឺ ឈ្មោះ **គឿន សារិន** ក្នុងប័ណ្ណបោះឆ្នោតទៅជាឈ្មោះ **គឿង សារិន** ក្នុងបញ្ជីបោះឆ្នោតរបស់ គ ជ ប
- យល់ឃើញថា អ្នកផ្តិតមេដៃ ៥៥៤ នាក់ សុំតវ៉ាឱ្យបោះឆ្នោតឡើងវិញ ដោយសំអាងមូលហេតុជាច្រើន ដូចជារកការិយាល័យមិនឃើញ គេមិនឱ្យកន្ទុយប័ណ្ណ បាត់ឈ្មោះ ។ល។ ភាគច្រើន គឺ រកការិយាល័យមិនឃើញ ចំណុចនេះ ក៏ជាការខ្វះខាតរបស់សាមីខ្លួនដែរ ព្រោះស្ថានភាពសន្តិសុខល្អជាធម្មតា
- យល់ឃើញថា ការចោទថា សមត្ថកិច្ចមិនព្រមប្រគល់ទម្រង់បែបបទ ១០១៨ តាមការអះអាងរបស់ ឈ្មោះ **ម៉ុត ស៊ីលន** ជាការមិនពិតទេ ព្រោះអ្នកចុះឈ្មោះបោះឆ្នោតដែលមានទម្រង់បែបបទ ១០១៨ នេះមាន ៣.២១០ នាក់ ។ ហើយអ្នកមកយកទម្រង់នេះ មានតែជាង ២.០០០ នាក់ប៉ុណ្ណោះ អ្នកឯទៀតមិនបានមកយកទេ ដោយមូលហេតុ អ្នកចុះឈ្មោះខ្លះត្រឡប់ទៅស្រុកកំណើតវិញ អ្នកខ្លះស្លាប់ អ្នកខ្លះចុះឈ្មោះរួចមួយចំនួនទៅ រកស៊ីនៅប្រទេសថៃ ។ ក្នុងពេលចុះឈ្មោះនោះ ក៏ចំពេលមានព្រឹត្តិការណ៍វាយស្ថានទូតថៃ និង ក្រុមហ៊ុនថៃ បណ្តាលឱ្យមានការបិទព្រំដែន ។ ពលករដែលត្រឡប់មកពីប្រទេសថៃ ត្រូវសកម្មជនគណបក្សខ្លះ ប្រកួកប្រកាសឱ្យទៅចុះឈ្មោះបោះឆ្នោតតាមវិធីលើកទឹកចិត្តផ្សេងៗ ។ ដល់ពេលព្រំដែនបើកឡើងវិញ ពលករភាគច្រើនបាន ទៅធ្វើការនៅប្រទេសថៃ ហើយមិនបានមកបោះឆ្នោតទេ
- យល់ឃើញថា ការសុំបញ្ជីបោះឆ្នោតដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព ហើយដែលមិនត្រូវបានផ្តល់ជូនដោយ គ ជ ប មិនពាក់ព័ន្ធដល់មាត្រា ៦៣ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។
- យល់ឃើញថា យោងទៅលើមូលហេតុ និង ឯកសារដែលជាភស្តុតាងខាងលើ មិនអាចចាត់ថា ការបោះឆ្នោតនៅឃុំប៉ោយប៉ែត មានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលតម្រូវឱ្យមានការបោះឆ្នោតសាឡើងវិញទេ ។

## ហេតុដូច្នេះ

## សំរេចចំពោះមុខគូភាគី

**មាត្រា ១** : ទទួលពាក្យបណ្តឹងតវ៉ារបស់ឯកឧត្តម សម រង្ស៊ី ចំពោះករណីរាជធានីភ្នំពេញ ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តបន្ទាយមានជ័យ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២** : តំកល់សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្តីពីការប្រកាសលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ លេខ ០៨.៩០៤/០៣ គ ជ ប ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៣ ទុកជាត្រឹមត្រូវទាំងមូល ។

**មាត្រា ៣** : សេចក្តីសំរេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអនុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងនៅក្នុង រដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៧៥/០១៩/២០០៣

ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

**សេចក្តីសម្រេច**

លេខ : ០៥៨/០០៩/២០០៣ កបធ.ច

ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៤៦/០០១/២០០២ កបធ.ច ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤២៧ រស ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាបញ្ជូនលិខិតលោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ( COMFREL ) មកក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យធ្វើការបកស្រាយមាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង-តំណាងរាស្ត្រ តាមពាក្យបណ្តឹង លេខ ២៨៧/គ.ប.ស.យ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា តាមមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្តឹងរបស់សម្តេចក្រុមព្រះប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យពិភាក្សាបាន
- យល់ឃើញថា មាត្រា ៧៦ វាក្យខ័ណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិឱ្យច្បាប់បោះឆ្នោតកំណត់អំពី " អង្គការរៀបចំការបោះឆ្នោត បែបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោត "
- យល់ឃើញថា តាមការបញ្ជាក់របស់ក្រសួងមហាផ្ទៃ ដែលជាអ្នកតាក់តែងសេចក្តីព្រាងដើមនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គំនិតគឺឱ្យ គ.ជ.ប ជាអ្នកធ្វើការពិន័យ
- យល់ឃើញថា តាមកំណត់ហេតុនៃការពិភាក្សានៅរដ្ឋសភានាឆ្នាំ២០០២ និង ឆ្នាំ១៩៩៧ ពុំមានយោបល់សុំកែប្រែគំនិតដើមរបស់សេចក្តីព្រាងមាត្រា ១២៤ ថ្មី និង មាត្រា ១២៤ ចាស់ លើចំណុចខាងលើនេះទេ
- យល់ឃើញថា មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្របានចែងថា " ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតលុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន ( ៥.០០០.០០០ ) រៀល ទៅម្ភៃប្រាំលាន ( ២៥.០០០.០០០ ) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ... " ។ ក្នុងឃ្លានេះ យោងតាមទទ្ធិករណ៍ខាងលើការពិន័យជាប្រាក់ ក៏ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គ.ជ.ប ដែរ ។

## សម្រេច

**មាត្រា ១** : មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានក្នុងមូលបទខាងលើ ។

**មាត្រា ២** : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ហត្ថលេខា និង ត្រា**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :០៨១/០០៤/២០០៤

ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០០៤

**សេចក្ដីសំរេច**

លេខ:០៥៩/០០១/២០០៤ កបធ.ច

ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០០៤

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ១០៧ រស ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ របស់សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភាស្ដីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាព នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤

**ក្រោយពីបានស្ដាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយប្រធានរដ្ឋសភាស្ដីទីជាការស្របនិងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា នៅក្នុងគ្រប់ជំពូក និងប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ពុំមានបទបញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទបញ្ញត្តិនៃប្រការ ៥១ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្តីពីការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំ ។ បទបញ្ញត្តិនេះ ជាប្រការមួយមានការលំបាកក្នុងការអនុវត្តន៍ជាក់ស្តែង ហើយមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ។

**សំរេច**

**មាត្រា១**~បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មាន ១៧ ជំពូក និង ៨៣ ប្រការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថាស្រប នឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥១ ដែលមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ។

**មាត្រា២**~សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តន៍ទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០០៤

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨២/០០៥ /២០០៤
ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦០/០០២/២០០៤ កបធ.ច
ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតរបស់តំណាងរាស្ត្រ ចំនួន២១រូប ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤" ស្នើសុំពិនិត្យ អំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវ ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញ ទទួលបាននៅ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៤ វេលាម៉ោង ១៥ និង ៤០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា កថាខណ្ឌទី១នៃមាត្រា ១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា " ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញនិង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ" ។ កថាខណ្ឌនេះពុំមានចែងអ្វីទាក់ទងដល់សមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមទេ ។

-យល់ឃើញថា ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងផ្នែកទី២ ស្តីពីសមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញចំពោះធម្មនុភាពនៃច្បាប់ជាព្រះរាជក្រមដែលចែងលំអិតសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញពិសេសនៅត្រង់ មាត្រា ១៥ បានចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្នុងក្របខ័ណ្ឌ នៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់" ។ មាត្រ១៥ នេះ ពុំមានចែងថាក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចពិនិត្យធម្មនុញ្ញភាពនៃ ច្បាប់ធម្មនុញ្ញបន្ថែមទេ ។

-យល់ឃើញថា សំណើរបស់ ឯកឧត្តម លោកជំទាវតំណាងរាស្ត្រ ចំនួន ២១រូប ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤"ស្នើសុំពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" មិនស្ថិតនៅក្នុង

ក្របខ័ណ្ឌមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុង មាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

- យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញ ធ្លាប់បានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាច្រើន ប៉ុន្តែពុំដែលបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ដែលមានលក្ខណៈជារដ្ឋធម្មនុញ្ញ ដូចជាច្បាប់ធម្មនុញ្ញបន្ថែមនេះទេ ។ ម្យ៉ាងទៀតច្បាប់ធម្មនុញ្ញបន្ថែមនេះជាច្បាប់កំពូលមួយ មានចែងពីគោលដៅរបស់ច្បាប់មានមាត្រានៃច្បាប់ដោយឡែក និង ឋានានុក្រមស្មើនឹងច្បាប់រដ្ឋ-ធម្មនុញ្ញ ឆ្នាំ ១៩៩៣ ទៅហើយ ។ ដូច្នេះច្បាប់ធម្មនុញ្ញនេះ គឺជារដ្ឋធម្មនុញ្ញ ដែលពុំអាចពិនិត្យធម្មនុញ្ញភាពបានឡើយ ។

## សម្រេច

**មាត្រា ១** ៎ យោងតាមមូលបទខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ការពិនិត្យធម្មនុញ្ញភាពនៃ " ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ " ពុំមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

**មាត្រា២** ៎ សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាច ទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ជិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ០៨៣/០០៦/២០០៤

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

**សេចក្តីសំរេច**

លេខ : ០៦១ /០០៣/២០០៤ កបធ.ច

ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិត ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៦ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ

-បានឃើញឯកសារទទួលពីរដ្ឋសភាទាក់ទងនឹងការពិភាក្សារបស់សភាធម្មនុញ្ញ លើមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ

**ក្រោយពីបានស្តាប់របាយការណ៍សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រ ១៦ រូប គឺលើសពីមួយភាគដប់នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៤ :២៣ នាទី។ ចំនួន ១៦ រូប នេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ផងដែរ ។

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដោយដាក់ជាបញ្ហា ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ " *ក្រោយពីមានព្រះរាជសាររបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជហឫទ័យចង់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗ គ្នា រវាងនាយករដ្ឋមន្ត្រី និង ក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។* " ពាក់ព័ន្ធសំខាន់លើវាក្យខ័ណ្ឌទី ២ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញដែលចែងថា " *ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត* " ។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។ ព្រះរាជតួនាទី ក្នុងការគ្រងរាជសម្បត្តិ ជាប់ជាមួយព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ។ ដូច្នេះ ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ និង ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងគ្រងរាជសម្បត្តិ រហូតដល់ពេលព្រះអង្គចូលទិវង្គត ។

-យល់ឃើញថា សភាធម្មនុញ្ញបានអនុម័តមាត្រា ១២ មាត្រា ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រ សោយទិវង្គតតែប៉ុណ្ណោះ ។

-យល់ឃើញថា ការដាក់រាជសម្បត្តិ មិនមានចែងក្នុងរដ្ឋធម្មនុញ្ញទេ ។

**សំរេច**

**មាត្រា ១.-** មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៤/០០៧ /២០០៤
ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤

**សេចក្តីសម្រេច**
លេខ : ០៦២/០០៤/២០០៤ កបធ.ច
ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តំណាងរាស្ត្រចំនួន ១៣ រូប ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប បានធ្វើលិខិតមួយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃខែឆ្នាំ ដដែល វេលាម៉ោង ១០:០០ ព្រឹក។ តំណាងរាស្ត្រជាម្ចាស់សំណើមានចំនួន ១៣ រូប ដូចនេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបានដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម / ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។

-យល់ឃើញថា បាតុកម្ម ជាអំពើប្រព្រឹត្តដោយជនមួយក្រុម សំដែងឱ្យសាធារណជនទាំងពួងឃើញ ឬ ដឹងនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈណាមួយរបស់ក្រុមខ្លួន ។ សិទ្ធិធ្វើបាតុកម្ម និង សិទ្ធិធ្វើកូដកម្ម ជាសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែប្រជាពលរដ្ឋ ត្រូវប្រើសិទ្ធិនេះ ដោយសន្តិវិធី កុំឱ្យប៉ះពាល់

ដល់សិទ្ធិអ្នកដទៃ ហើយក៏កុំឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ បរិស្ថាន សុខុមាលភាពសាធារណៈ និង សន្តិសុខសង្គម ។ មានតែច្បាប់ទេ ដែលកំណត់ក្របខ័ណ្ឌនៃការធ្វើបាតុកម្ម គឺច្បាប់កំណត់ឱ្យអាជ្ញាធរសាធារណៈ ចាត់វិធានការនានា ដើម្បីធានាសិទ្ធិរបស់បាតុករផង ហើយដើម្បីរក្សាឱ្យបាននូវរបៀបរៀបរយសាធារណៈ បរិស្ថាន សុខុមាលភាព និង សន្តិសុខសង្គមផង ។ មាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ចែងច្បាស់ថា " *សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។* " ។

-យល់ឃើញថា កាលបើក្របខ័ណ្ឌដែលច្បាប់កំណត់ឱ្យអាជ្ញាធរសាធារណៈ ចាត់វិធានការណាមួយនោះ លែងសមស្របនឹងសភាពការណ៍បច្ចុប្បន្ននៃប្រទេសជាតិ មានតែរដ្ឋសភាទេ ដែលអាចកែប្រែបទបញ្ញត្តិនៃច្បាប់ដែលពុំសមស្របនោះ ឱ្យសមស្របទៅវិញ ។ បើពុំនោះសោតទេ បទបញ្ញត្តិនៃច្បាប់នោះ នៅតែបន្តមានអានុភាពអនុវត្តដដែល ។ មាត្រា ១៥៨ ថ្មី ( មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងច្បាស់ថា " *ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និង ដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។* " ។

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប ដែលបានស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាតុកម្ម ដែលរដ្ឋសភានៃអតីតរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ បានលើកឡើងថា ខ្លឹមសារក្នុងមាត្រាខ្លះនៃច្បាប់នេះបានផ្ទុយទៅនឹងស្មារតីមាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ប៉ុន្តែពុំបានចង្អុលឱ្យចំថា តើបទបញ្ញត្តិនៃមាត្រាណាមួយ ដែលផ្ទុយនោះទេ ។

-យល់ឃើញថា បើនិយាយអំពីខ្លឹមសារវិញ ច្បាប់ស្តីពីបាតុកម្មដែលអនុម័តដោយរដ្ឋសភាអតីតរដ្ឋកម្ពុជា កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ មិនផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីបាតុកម្ម ដែលអនុម័តដោយរដ្ឋសភាអតីតរដ្ឋកម្ពុជា កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ជិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៥/០០៨ /២០០៤
ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៣/០០៥/២០០៤ កបធ.ច
ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តំណាងរាស្ត្រចំនួន ១៣ រូប ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប បានធ្វើលិខិតមួយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១៤:២០ ល្ងាច ។ តំណាងរាស្ត្រជាម្ចាស់សំណើចំនួន ១៣ រូបនេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។

-យល់ឃើញថា សំណើរបស់តំណាងរាស្ត្រចំនួន ១៣ រូប បានលើកឡើងថា *បទបរិហារកេរ្តិ៍ និងជេរប្រមាថដែលមានចែងក្នុងមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល បានអនុម័តដោយឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា តាំងពីថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ មកម្លេះ ។ នៅឆ្នាំ ១៩៩៣ សភាធម្មនុញ្ញបានអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាថ្មីមួយ*

*ដែលបានផ្តល់អភ័យឯកសិទ្ធិដល់សមាជិករដ្ឋសភា ដូចចែងក្នុងមាត្រា ៨០ ថា " តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។...*"។ ហេតុដូច្នេះហើយទើបតំណាងរាស្ត្រចំនួន ១៣ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលពាក់ព័ន្ធទៅនឹងមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីអភ័យឯកសិទ្ធិសភា ។

-យល់ឃើញថា តំណាងរាស្ត្រគ្រប់រូប មានអភ័យឯកសិទ្ធិសភា ដែលធានាមិនឱ្យតំណាងរាស្ត្របារម្ភអំពីការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ឬ អំណាចតុលាការ ។ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ក៏មានព្រំដែនកំណត់ដែរ ។

-យល់ឃើញថា តំណាងរាស្ត្រ មិនអាចប្រើប្រាស់អភ័យឯកសិទ្ធិនេះឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ( មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ) ឬ ប្រព្រឹត្តអំពើល្មើសច្បាប់ព្រហ្មទណ្ឌ។

-យល់ឃើញថា យោងតាមខ្លឹមសារមាត្រា ៣១ មាត្រា ៣៨ មាត្រា ៣៩ និង មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ មាត្រា ៦៣ ស្តីពីការបរិហារកេរ្តិ៍ និង ការជេរប្រមាថ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ឃើញថា មិនមានចំណុចណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា មាត្រា ១៥៨ ថ្មី ( មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងថា " *ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និង ដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។* "។ ដូច្នេះផ្អែកលើខ្លឹមសារមាត្រា ១៥៨ ថ្មី ( មាត្រា ១៣៩ ចាស់ ) នៃរដ្ឋធម្មនុញ្ញ មាត្រា ៦៣ ស្តីពីការបរិហារកេរ្តិ៍ និង ការជេរប្រមាថ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ត្រូវស្ថិតនៅជាធរមាន ពីព្រោះពុំទាន់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលនូវបទបញ្ញត្តិនៃមាត្រានេះទេ ។

## សម្រេច

**មាត្រា ១.-** មាត្រា ៦៣ ស្តីពីការបរិហារកេរ្តិ៍ និង ការជេរប្រមាថ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៧/០១០ /២០០៤
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៤/០០៦/២០០៤ កបធ.ច
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២៥៥ រស ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី បានផ្ញើលិខិតលេខ ២៥៥ រស ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញបានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១១:១៥ ព្រឹក ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។

- យល់ឃើញថា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ត្រូវបានតាក់តែងឡើងក្រោយពីព្រះមហាក្សត្រទ្រង់បានផ្ញើព្រះរាជសាររបស់ព្រះអង្គ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ ផ្ញើថ្វាយប្រគេន ព្រះសង្ឃ និង ជូនជនរួមជាតិដើម្បីសុំចូលនិវត្តន៍ ហើយបើតាមខ្លឹមសារនៃព្រះរាជសារនេះ និងព្រះរាជសារបន្តបន្ទាប់ ការចូលនិវត្តន៍ គឺការដាក់រាជសម្បត្តិ ។ ព្រះរាជសាររបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងមានអានុភាពខ្ពស់បំផុត ។

- យល់ឃើញថា ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនេះ មាន ៥ ជំពូក ចែកចេញជា ១៨ មាត្រា ។

១-ជំពូកទី ១

ជំពូកនេះ មាន ២ មាត្រា ហើយចែងអំពីបទបញ្ញត្តិទូទៅ ពាក់ព័ន្ធនឹងគោលដៅនៃច្បាប់ និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ដែលជាអ្នកជ្រើសតាំងព្រះមហាក្សត្រថ្មី ។ ត្រង់នេះ គឺស្របនឹងមាត្រា ១០ នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌ ទី ១ ដែលចែងថា " *របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង* " ហើយនិងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌ ទី ៣ ដែលចែងថា " *ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នឹងមានកំណត់ក្នុងច្បាប់មួយ* " ។ ជំពូកទី ១ ទាំងមូលស្របនឹងរដ្ឋធម្មនុញ្ញ ។

២-ជំពូកទី ២

ជំពូកនេះ មាន ៥ មាត្រា ពាក់ព័ន្ធនឹងការរៀបចំ និង សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ ហើយបញ្ជាក់អំពីតួនាទី និង ភារកិច្ចរបស់ប្រធាន អនុប្រធាន និង រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដែលត្រូវរក្សាកំណត់ហេតុ និង ឯកសារទាំងអស់របស់ក្រុមប្រឹក្សារាជសម្បត្តិ មិនឱ្យខូចខាតបានឡើយ ។ ក្រុមប្រឹក្សារាជសម្បត្តិមានប្រធានព្រឹទ្ធសភាជាប្រធាន និង អនុប្រធាន ២ រូប គឺ ប្រធានរដ្ឋសភាជាអនុប្រធានទី ១ និង នាយករដ្ឋមន្ត្រី ជាអនុប្រធានទី ២ ។ ក្រៅពីនេះ មានសមាជិក ៦ រូបទៀត ដូចមានចែងក្នុងមាត្រា ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ។ ដូច្នេះ ជំពូកទី ២ ទាំងមូលស្របនឹងមាត្រា ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ។

៣-ជំពូកទី ៣

ក្នុងជំពូក នេះមាន ៨ មាត្រា ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចជារបៀបធ្វើការប្រជុំ កូរ៉ុម ការសម្ងាត់នៃការពិភាក្សា ការអនុម័ត ការបោះឆ្នោតសម្ងាត់ ការជ្រើសរើសជាព្រះមហាក្សត្រ ក្នុងចំណោមសមាជិកនៃព្រះរាជវង្សានុវង្ស ដូចមានចែងក្នុងមាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ការធ្វើសច្ចាប្រណិធាន ការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មី និង ការធ្វើព្រះរាជពិធីអភិសេកជាដើម ។ ដោយឡែកមាត្រា ១០ ដោយសារការសុំចូលនិវត្តន៍ គឺជាការដាក់រាជសម្បត្តិ ដូចបានបញ្ជាក់ក្នុងការយល់ឃើញខាងលើ ដូច្នេះជំពូកទី ៣ ស្របនឹងរដ្ឋធម្មនុញ្ញ ។

៤-ជំពូកទី ៤ និង ទី ៥

ជំពូកទាំងពីរនេះពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញឡើយ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលមាន ៥ ជំពូក និង ១៨ មាត្រា ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៨៦/០០៩ /២០០៤

ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

**សេចក្តីសម្រេច**

លេខ : ០៦៥/០០៧/២០០៤ កបធ.ច

ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២៥៣ រស ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតនេះ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ៧:៤៨ ព្រឹក ។

-បានឃើញសេចក្តីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា " ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ " ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទបញ្ញត្តិទាំងឡាយណាដែលបានចែងថា " ... ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ៣ " ដែលជាទោសសម្លាប់ ក្នុងមាត្រា ២០៩ មាត្រា ៥០០ មាត្រា ៥០៦ និង មាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ ។

-បានឃើញសេចក្តីសម្រេចលេខ ០៤៣/០០៥/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែល

រដ្ឋសភាបានអនុម័តយល់ព្រមធ្វើនីយតកម្ម កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ស្របនឹងរដ្ឋធម្មនុញ្ញ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះដោយប្រធានរដ្ឋសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លា ទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ចំណុចដែលបានកែប្រែមានជាអាទិ៍ដូចតទៅ ÷

១-ការកែប្រែអាជ្ញាយុកាល ( មាត្រា ៣ ថ្មី ) គឺអាជ្ញាយុកាលនៃពាក្យបណ្ដឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំ តទៅទៀត ( រីឯមាត្រា ៣ ចាស់ អាជ្ញាយុកាលនេះ ត្រូវបានពន្យារពេលបន្ថែម ២០ ឆ្នាំ ទៀតតែប៉ុណ្ណោះ ) ។

២-ការកែសម្រួលរចនាសម្ព័ន្ធសាលាជម្រះក្ដី ( មាត្រា ៣ ថ្មី ) គឺរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញដែលមាន ៣ ថ្នាក់ ត្រូវបានសម្រួលមកត្រឹម ២ ថ្នាក់ គឺសាលាដំបូង និង តុលាការកំពូល ( តុលាការកំពូលជាកន្លែងទទួលពាក្យបណ្ដឹងឧទ្ធរណ៍ផង និងសម្រេចសេចក្ដីចុងក្រោយផង ) ។

៣-ការកែប្រែសមាសភាពនៃអង្គជំនុំជម្រះតុលាការកំពូលឱ្យមានចៅក្រមខ្មែរ ៤ រូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមអន្តរជាតិ ៣ រូប ។ អង្គជំនុំជម្រះតុលាការកំពូលនេះ សម្រេចសេចក្ដីបិទផ្លូវតវ៉ា (មាត្រា ៩ ថ្មី) ។

៤-ការកែប្រែអំពីសិទ្ធិពេញលេញរបស់ជនជាប់ចោទ និង អភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការ និង មេធាវីដោយផ្អែកលើអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ( មាត្រា ៤២ ថ្មី ) ។

៥-ការកែប្រែបន្ថែមអំពីនីតិវិធីឱ្យបានច្បាស់ថែមទៀតដូចតទៅនេះ : " ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងអំពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របនៃនីតិវិធីទាំងអស់នេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកំរិតអន្តរជាតិ " (មាត្រា ២០ ថ្មី មាត្រា២៣ ថ្មី) ។

៦-ការចែងបន្ថែមអំពីវិសាលភាពនៃការលើកលែងទោស និង អនុគ្រោះទោសដែលអាចផ្ដល់ឱ្យមានមុនការអនុម័តច្បាប់នេះ គឺសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ( មាត្រា ៤០ ថ្មី ) ។

៧-ការចែងបន្ថែមអំពីល័ក្ខខ័ណ្ឌចៅក្រមដែលត្រូវតែងតាំង ហើយបំរើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវមានបទពិសោធន៍រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង ( មាត្រា ១០ ថ្មី ) ។

៨-សហព្រះរាជអាជ្ញាបរទេស មានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងបរទេស ( មាត្រា ២២ ថ្មី ) ។

៩-ការចែងបន្ថែមអំពីភាពមិនអាចរំលោភបំពានបាននៃបណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និង ជាទូទៅឯកសារ និង

សម្ភារៈទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬ ប្រើប្រាស់ដោយជនណាក៏ដោយក្នុងរយៈពេលនៃដំណើរការជំនុំជម្រះនេះ ( មាត្រា ៤២ ថ្មី )។

១០-ការកាត់បន្ថយការប្រើប្រាស់ភាសាជាផ្លូវការមកត្រឹម ៣ ភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង ( មាត្រា ៤៥ ថ្មី )។

១១-ការកែប្រែដោយលុបចោលបទបញ្ញត្តិដូចតទៅ :

-លុបពាក្យ " មូលនិធិស្ម័គ្រចិត្ត " នៅក្នុងចំណុចទី ២ នៃមាត្រា ៤៤ ចាស់

-លុបចំណុចទី ៣ នៃមាត្រា ៤៤ ចាស់ ។

ចំណុចកែប្រែទាំង ១១ ខាងលើ និងចំណុចកែប្រែដទៃទៀត ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនេះ ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៤៨/០១១/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៦/០០៨/២០០៤ កបធ.ច
ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញលិខិតលេខ ៣០៣ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ពុំមានចំណុចណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

## **សម្រេច**

**មាត្រា ១.-** ច្បាប់ស្ដីពីការបង្កើតក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៩០/០១៣/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៧/០០៩/២០០៤ កបធ.ច
ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩ កបធ.សសរ.ច ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលបានប្រកាសថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៩៩ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩ មិនស្របនឹងរដ្ឋធម្មនុញ្ញ

-បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ១២ កបធ.សសរ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ដែលបានប្រកាសថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៩ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៩ ស្របនឹងរដ្ឋធម្មនុញ្ញ

-បានឃើញលិខិតលេខ ៣០៥ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតនេះនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលប្រធានរដ្ឋសភាសុំពិនិត្យធម្មនុញ្ញភាព ជាច្បាប់រៀបចំអង្គការមួយ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព ស្របតាមមាត្រា ១៤០ ថ្មី កថាខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ។

-យល់ឃើញថា  មាត្រា ១ ដល់មាត្រា ៦ ដែលចែងពីការបង្កើតក្រសួងកិច្ចការនារី ស្របនឹងសេចក្តីសម្រេច នៃក្រុមប្រឹក្សាធម្មនុញ្ញលេខ ១២ កបធ.សសរ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ និងមិនមានអ្វីផ្ទុយនឹង រដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃ ក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាច ទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៩/០១២/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៨/០១០/២០០៤ កបធ.ច
ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញលិខិតលេខ ៣០៤ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីត-យុទ្ធជន និង យុវនីតិសម្បទា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :០៩២ / ០០២/២០០៥

ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ : ០៦៩/០០១/២០០៥ កបធ.ច

ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ធម្មនុញ្ញបន្ថែមឆ្នាំ២០០៤
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៨៣រស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួល នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០៥

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។* " និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា " *ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ* " ។

ដូច្នេះសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា លេខ ១៨៣ រស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០៥ គឺស្របតាមរដ្ឋធម្មនុញ្ញ ។

- យល់ឃើញថា ក្នុងប្រការ ៣៣ ថ្មី វាក្យខ័ណ្ឌទី ៣ មានបទបញ្ញត្តិដែលចែងថា" ការប្រជុំនេះមិនទាមទារកូរ៉ុមទេ" ដែលត្រង់នេះ គេគួរពិចារណាទៅលើមាត្រា ៨៨ វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ដែលចែងថា : " ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល " ។ ក្នុងស្មារតីនៃប្រការ ៣៣ ថ្មី នេះ គឺ រដ្ឋសភាចង់ចោទសួររាជរដ្ឋាភិបាល ក្នុងមួយសប្តាហ៍មួយថ្ងៃ ដើម្បីជាពតិមាន ។ រដ្ឋធម្មនុញ្ញ ពុំមានបទបញ្ញត្តិណាហាមប្រជុំរបៀបនេះទេ ដូច្នេះការដាក់ពាក្យបន្ថែមដូចខាងលើ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។
- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ត្រង់ប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែមនោះទេ ។

## សម្រេច

**មាត្រា១.-** វិសោធនកម្មនៃប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និង ប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែម ។

**មាត្រា២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៩៦/០០៦/២០០៥

ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ : ០៧០/០០២/២០០៥ កបធ.ច

ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ៥៣៨ រស ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តយល់ព្រម កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ព្រមតាមទម្រង់ និងគតិច្បាប់នេះ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ផងដែរ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលសំណើនេះ នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ នូវបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ទម្រង់នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលមាន ១៣ ជំពូក ៣៧ មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៩៧/០០៧ /២០០៥

ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ : ០៧១/០០៣/២០០៥ កបធ.ច

ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ៦៣៣ រស ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៥ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពប្រការ ៤៧ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៥

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំអោយពិនិត្យធម្មនុញ្ញភាព ប្រការ ៤៧ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពនៃប្រការ ៤៧ ថ្មី (ពីរ) បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ប្រការ ៤៧ ថ្មី (ពីរ) នេះ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ពុំមានអ្វីផ្ទុយនឹងមាត្រា ៨៨ ថ្មី វាក្យខ័ណ្ឌ ទី ៣ នៃរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ប្រការ ៤៧ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៩៨/០០៨/២០០៥

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥

**សេចក្តីសម្រេច**

លេខ : ០៧២/០០៤/២០០៥ កបធ.ច

ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតលេខ ២០២/០៧០៥/ពស/នវ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៥

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយប្រធានព្រឹទ្ធសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីផ្ទុយនឹងមាត្រា ១១១ ថ្មី (មួយ) វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ប្រកាស ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

RBHraCaNacRkkmCa
Cati sasna RBHmhakSRt
3

RkmRbkSaFmnBa

3
sNer0g
e l x ³100 ¼ 010¼2005
cHéfTI 24 Ex F qa 2005
esckIseRmc
e l x ³ 073¼005¼2005 kbF›c
cHéfTI 29 Ex F qa 2005

RkmRbkSaFmnBa

- )aneXIj rdFmnBa én RBHraCaNacRkkmCa
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfTI 08 Ex emsa qa1998 Rbkas [ eRbIc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼1297¼06 cHéfTI 26 Ex F qa 1997 Rbkas [ eRbI c,absBkare)aHeqateRCIstagtNagra®s
- )aneXIj RBHraCRkme l x ns¼rkm¼0902¼017 cHéfTI 17 Ex kBaa qa2002 Rbkas [ eRbIc,absBvesaFnkmc,absBkare)aHeqateRCIstagtNagra®s
- )aneXIj RBHraCRkme l x ns¼rkm¼0605¼020 cHéfTI 20 Ex mfna qa2005 Rbkas [ eRbIc,absBkare)aHeqateRCIstagsmaCkRBTsPa
- )aneXIj bTbBaaépkgénrdsPaénRBHraCaNacRkkmCa
- )aneXIj l xteprsTcHéfTI 20 Ex F qa2005 rbse l ak ng eRsg CaGnRbFan RkmRbkSaKNbkS sm rgS extéRBEvg eprsT [ e l akemFavI emA sParT smaCk KN³emFavénRBHraCaNacRkkmCa edm,IkarBar ng eFICatNag
- )aneXIj BaküBNgrbse l ak emA sParT cHéfTI 24 Ex F qa2005 Ed l bgCTas esckIseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfTI 19 Ex F qa2005 Ed l

GKelxaFkardanRkmRbkSaFmnBaTTl)anenAéfTI 24 Ex F qa2005 evlaemag 11 RBk

- )aneXjlxtbgabkarelx 425¼05 K>C>b cHéfTI 28 Ex F qa2005 rbsÉk]tm
Gm ss RbFanKN³kmaFkarCaterobckare)aHeqat cattagtNagrbsKN³kmaFkar
Caterobckare)aHeqat edlm,bPkgsvnakarCnCRmHrbsRkmRbkSaFmnBa.

eRkayB)ansabr)aykarNrbssmaCkraykarN

eRkayB)ansabcemlyrbsKPaK

eRkayB)anBPakSaRtmRtvtamc,abehly

- ylXjfa BakübNgelak emA sParT tNag[KNbkS sm rgSman lkN³
RtmRtvtamTRmgc,ab GacTTlykmkBntü)an

- ylXjfa eQaH xm vasna Rtv)anKNbkS sm rgSlbeQaHecjBbBasmaCk
KNbkStamesckIseRmcelx 050 ssr cHéfTI 15 Ex kkda qa2005. decHeQaH
xm vasna R)ascakBIsmaCkPaBKNbkSCabeqat ¬KNbkS sm rgS¦ tambTbBat
énRbkar 83 fénbTbBaaépkgénrdsPa ng Rtv)atbgKNPaBCatNagra®s

- ylXjfa esckIseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfTI 19 Ex F
qa2005 EdltmlesckIseRmcrbsKN³kmkarerobckare)aHeqatextéRBEvg EdlsGag
faeQaH xm vasna enACatNagra®s edayGKelxaFkardanrdsPa)ancHeQaHkg
bBaGkcHeQaHe)aHeqat BmanmldanKtytRKbRKaneLy.

ehtdecH

seRmcceBaHmxKPaK

maRta 1>- TTlBakübNgrbselak emA sParT cHéfTI 24 Ex F qa2005 TkCaRtmRtvtamTRmg ng Ktc,ab.

maRta 2>- bdeesFesckIseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfTI 19 Ex F qa2005.

maRta 3>- [KN³kmaFkarCaterobckare)aHeqat lbeQaH xm vasna ecjBbBacHeQaHe)aHeqat eRCIstagsmaCkRBTPasRmabnItkalT2 EdlngRbRBteTAnaéf GaTtü TI 22 Ex mkra qa2006.

maRta 4>- esckIseRmcenH RbkasnasvnakarCnCRmHCasaFarN³ enAraCFanIPeB jéfTI 29 Ex F qa2005 CaesckIseRmcsaBrbTpvtva ehIymanGnPaBGnvteTAelIGNacTagGsEdlman

EcgenAkgrdFmnBa ng RtvcHpSaykgraCkc.

raCFanIPeB j / éfTI 29 Ex F qa 2005

C>RkmRbkSaFmnBa ng C>RkmRbkSaCnCRmH

RbFan

bn Qn

RBHraCaNacRkkmCa
Cati sasna RBHmhakSRt
3



RkmRbkSaFmnBa
3
sNer0g
elx ³ 102¼002¼2006
cHéfTI 15 Ex mina qa 2006
esckIseRmc
elx ³ 074¼001¼2006 kbF›c
cHéfTI 17 Ex mina qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkmelx Cs¼rkm¼0498¼06 cHéfTI 08 Ex emsa qa 1998 Rbkas[eRbI c,absBIkarerobc ngkarRbRBtteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkmelx ns¼rkm¼0306¼06 cHéfTI 09 Ex mina qa 2006 Rbkas[eRbI c,abFmnBa sBIvesaFnkmmaRta 82 maRta 88fI maRta 90fI maRta 98 maRta 106fI maRta 111fI ¬my¦ maRta 114fI énrdFmnBa ngmaRta 6 énc,abFmnBabEnmsedAFana nvdeNIrkarCaRbRktiénsabnCati
- )aneXIj lxtelx 20¼2003 kbF cHéfTI 22 Ex kBaa qa 2003 rbsRkmRbkSaFmnBa Edl TI lfayeyab l ceBaHRBHmhakSRtGBIcNcEpkc,abmycnn BessGBRBHraCtNag Edl manEcgkgRbkar 5fI¬Br¦ énbTbBaaépkgénrdsPaénRBHraCaNacRkkmCa
- )aneXIj lxtelx 274 rs cHéfTI 15 Ex mina qa 2006 rbssemc ehg srn GnRbFan TI1 rdsPa esIs[RkmRbkSaFmnBaBntüFmnBaPaBelIvesaFnkmRbkar 2 fI 5 fI 10 fI 35 47 fI¬Br¦ ngRbkar 82 énbTbBaaépkgénrdsPaénRBHraCaNacRkkmCa Edl GKelxa FkardanRkmRbkSaFmnBa)anTTlenAéfTI 15 Exmina qa2006 evlaemag 10³31 naTI.
eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)anBPakSaRtmRtvtamc,abehIy

- ylEXIj fa maRta 140fI énrdFmnBa qa 1993 RtgkfaxNT2 XaTI 1 Ecgfa{ *bTbBaaépkg rdsPa bTbBaaépkgRBTsPa ng c,aberobcGgkarTagLay RtvEtbBaneTARkmRbkSaFmnBa*

*BntümnngRbkas[eRb*.} ngmaRta 16 énc,absBkarerobcngkarRbRBteTAénRkmRbkSaFmnBa )anEcgfa { *c,aberobcGgkar bTbBaaépkgrdsPa ng vesaFnkménc,aberobcGgkar ng bTbBaaépkgrdsPa eRkayBrdsPa)anGnmtRtvdakCnRkmRbkSaFmnBa edayRbFanrdsPa edm,BntüetC,abTagenaHRsb b mnRsbngrdFmnBa mnngRtv)anRbkas[eRb* }.

seNIrbssemc ehg srn GnRbFanT1 rdsPa e l x 274 rs cHéfT 15 Ex mina qa2006 Ed l GKe l xaFkardanRkmRbkSaFmnBa )anTT l enAéfT 15 Ex mina qa2006 enAev l aemag 10³31naT KRsbtamrdFmnBa ng c,absBkarerobcngkarRbRBteTAénRkmRbkSaFmnBa. RkmRbkSaFmnBaGacTT l ykseNIsBntüFmnBaPaBenHmkBntü)an.

- y l eX j fa vesaFnkménbTbBaaépkgénrdsPaénRBHraCaNacRkkmCa Ed l )anGnmtenA éfT 15 Ex mina qa 2006 nasmyRbCrdsPae l kT 4 ntka l T3Rtg Rbkar 2f 5f 10f 35 47 f¬Br¦ ngRbkar 82 Bman l kN³pyngrdFmnBaeT.

sRmc

maRta1- vesaFnkmRbkar 2 f 5 f 10 f 35 47 f¬Br¦ ngRbkar 82 énbTbBaaépkgénrdsPa énRBHraCaNacRkkmCa Ed l )anGnmtenAéfT 15 Ex mina qa 2006 nasmyRbCrdsPa e l kT 4 ntka l T 3Rtv)anRbkasfa RsbngrdFmnBa.

maRta2- esckIseRmcenH eFIenAraCFanIPeBj éfT 17 Ex mina qa 2006 nasmyRbCeBjGgén RkmRbkSaFmnBa CaesckIseRmcsaBr bTpvtva ehIymanGanPaBGnvteTAe l IGNac TagGsEd l manEcgkgrdFmnBa ngRtvcHpSaykgraCkc.

raCFanIPeBj éfT 17 Ex mina qa 2006

C>RkmRbkSaFmnBa

RbFan

bn Qn

RBHraCaNacRkkmCa
Cat sasna RBHmhakSRt

3

RkmRbkSaFmnBa
3
sNer0g
elx³ 103¼003¼2006
cHéfT 21 Ex mına qa 2006
esckIseRmc
elx³ 075¼002¼2006 kbF›c
cHéfT 07 Ex emsa qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkmelx Cs¼rkm¼0498¼06 cHéfT 08 Ex emsa qa 1998 Rbkas[eRbIc,ab sBIkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkmelx ns¼rkm¼0701¼10 cHéfT 23 Ex kkda qa 2001 Rbkas[eRbIc,ab sBIkaryl RBm ng karGnvtGnsBaaGgkarshRbCaCat EcgBIkarTTlsal ng karRbtbtnv escklseRmcmCÄtkrbreTs
- )aneXIj seNIelx 300 rs cHéfT 21 Ex mına qa 2006 rbssemc ehg srn RbFan rdsPa esls[RkmRbkSaFmnBa BntüFmnBaPaBénc,absBImCÄtkarEpkBaNCkm Edl rdsPa )anGnmtyl RBmkal BéfT 06 Ex mına qa 2006 nasmyRbCrdsPael kT 4 nltkal T 3 ehyRBTsPak)anyl RBm[rdsPabnnltvFtamry³lxtelx 017¼0306¼Bs¼nv cHéfT 17 Ex mına qa 2006 . GKelxaFkardanRkmRbkSaFmnBa )anTTlseNIenH enAéfT 21 Ex mına qa 2006 evlaemag 10³40 naT RBk .

eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)ansabr)aykarNbPrbstNagRksgBaNCkm
eRkayB)anBPakSaRtmRtvtamc,abehy

- yleXIj fa rdsPa )anGnvtyagRtmRtv tamEbbbTEdlmanEcgkgmaRta 140 f vaküxNT 2 énrdFmnBa kgkarbBanmk[RkmRbkSaFmnBa BntümnngcI,abenH Rtv)anRbkas[eRbI

- ylеXjfa rdsPa ngRBTsPa )anGnvtyagRtmRtv tamEbbbTEdlmanEcgkgmaRta 113f énrdFmnBa kgkarBntü Gnmtc,abenH
- ylеXjfa maRta 5 énc,absBmCÄtkarEpkBaNCkm RtvbkRsayfa tlakarGaceFGnraKmn )ankgkrNEdlPaKess ehymnkRmtGNacrbstlakareLy
- ylеXjfa maRta 42 énc,absBmCÄtkarEpkBaNCkm Edl)anRbKlsT[salа]TrNseRmc elkarbgCTas karTTlsal ngkardak[GnvtmCÄtvncy)anEtkgkrNEdltlakarBaNCkm mnTan)anbegIt
- ylеXjfa xmsarénc,absBmCÄtkarEpkBaNCkm eRkABImaRta 5 ngmaRta 42 Edl)ankt smalxagelI BmanGImnRsbngrdFmnBaeT

sеRmc

maRta 1- c,absBmCÄtkarEpkBaNCkm Edlrdsa)anGnmt kalBéfT 06 Ex mIna qa 2006 nasmy RbCrdsPaelkT 4 ntkalT 3 ehyRBTsPak)anylRBmeGayrdsPabnntvFtamry³lxt elx 017¼0306¼Bs¼nv cHéfT 17 Ex mIna qa 2006 Rtv)anRbkasfa RsbngrdFmnBa .

maRta2- esckIseRmcenH eFenAraCFanIPeBj éfT 07 Ex emsa qa 2006 nasmyRbCeBjGgrbs RkmRbkSaFmnBa CaesckIseRmcsaBr bTpvtva ehymanGanPaBGnvteTAelIGNacTagGsEdl manEcgkgrdFmnBa ngRtvcHpSayk graCkc.

raCFanIPeBj éfT 07 Ex emsa qa 2006
C>RkmRbkSaFmnBa
RbFan

bn Qn

RBHraCaNacRkkmCa
Cat sasna RBHmhakSRt
3

RkmRbkSaFmnBa
3
sNer0g
elx ³ 104¼004¼2006
cHéfT 07 Ex emsa qa 2006
esckIseRmc
elx ³ 076¼003¼2006 kbF›c
cHéfT 13 Ex emsa qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkmelx CS¼rkm¼0498¼06 cHéfT 08 Ex emsa qa 1998 Rbkas[eRbI c,absBkarerobc ngkarRbRBteTAénRkmRbkSaFmnBa
- )aneXIj esckIseRmcelx 069¼001¼2005 kbF›c cHéfT 25 Ex km³ qa 2005 rbs RkmRbkSaFmnBa
- )aneXIj lxtelx 367 rs cHéfT 07 Ex emsa qa 2006 rbssemc ehg srn RbFan rdsPa esIs[RkmRbkSaFmnBaBntüFmnBaPaBelIvesaFnkmRbkar 15 f ngRbkar 48 f énbTbBaaépkgrdsPaénRBHraCaNacRkkmCa Ed lGKelxaFkardanRkmRbkSaFmnBa)an TTlenAéfT 07 Ex emsa qa 2006 evlaemag 10 RBk .
eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)anBPakSaRtmRtvtamc,abehIy
- ylEXIj fa maRta 140f énrdFmnBa qa 1993 RtgkfaxNT2 XaT 1 Ecgfa { *bTbBaaépkg rdsPa bTbBaaépkgRBTsPa ng c,aberobcGgkarTagLay RtvEtbBaneTARkmRbkSaFmnBa BntümnngRbkas[eRb .* } ngmaRta 16 énc,absBkarerobcngkarRbRBteTAénRkmRbkSaFmnBa )anEcgfa { *c,aberobcGgkar bTbBaaépkgrdsPa ng vesaFnkménc,aberobcGgkar ng bTbBaaépkgrdsPa eRkayBrdsPa)anGnmtRtvdakCnRkmRbkSaFmnBa edayRbFanrdsPa edm,Bntüetc,abTagenaHRsb b mnRsbngrdFmnBa mnngRtv)anRbkas[eRb* } .
seNIrbs semc ehg srn RbFanrdsPa elx 367 rs cHéfT 07 Ex emsa qa 2006

Ed l GKe l xaFkardanRkmRbkSaFmnBa )anTT lenAéfT 07 Ex emsa qa 2006 KRsbtam rdFmnBa ng c,absBkarerobcngkarRbRBteTAénRkmRbkSaFmnBa .
RkmRbkSaFmnBaGacTT lykseNsBntüFmnBaPaBenHmkBntü)an .

- ylеXjfa vesaFnkménbTbBaaépkgrdsPaénRBHraCaNacRkkmCa Ed l )anGnmtenAéfT 07 Ex emsa qa 2006 nasmyRbCrdsPae lkT 4 ntka lT 3 RtgRbkar 15 f ng Rbkar 48 f BmanGpyngrdFmnBaeT.

sеRmc

maRta1- vesaFnkmRbkar 15 f ngRbkar 48 f énbTbBaaépkgrdsPaénRBHraCaNacRkkmCa Ed l )anGnmtenAéfT 07 Ex emsa qa 2006 nasmyRbCrdsPae lkT 4 ntka lT 3 Rtv)anRbkasfa RsbngrdFmnBa.

maRta2- esckseRmcenH eFenAraCFanPeB j éfT 13 Ex emsa qa 2006 nasmyRbCeB j Ggén RkmRbkSaFmnBa CaesckseRmcsaBr bTpvtva ehymanGanPaBGnvteTAe lGNac TagGsEd l manEcgkgrdFmnBa ngRtvcHpSaykgraCkc .

raCFanPeB j éfT 13 Ex emsa qa 2006
C>RkmRbkSaFmnBa
RbFan

bn Qn

RBHraCaNacRkkmCa

Cat sasna RBHmhakSRt

3

RkmRbkSaFmnBa

3

sNer0g

elx³ 105¼005¼2006

cHéfT 23 Ex ]sPa qa 2006

esckIseRmc

elx³ 077¼004¼2006 kbF>c

cHéfT 01 Ex mfna qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkmelx Cs¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas [eRbc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj lxtelx 054¼0506¼Bs¼nv cHéfT 23 Ex ]sPa qa2006 rbs semc Ca sm RbFanRBTsPa esls [RkmRbkSaFmnBaBntüFmnBaPaBénbTbBaa-épkgfrbsRBTsPa Edl GKelxaFkardanRkmRbkSaFmnBa )anTTlenAéfT 23 Ex ]sPa qa 2006 evlaemag 14³10 naT

eRkayB)ansabr)aykarNrbssmaCkraykarN

eRkayB)anBPakSaRtmRtvtamc,abehIy

- ylEXIjfa maRta 140 fénrdFmnBa RtgkfaxNT2 XaT1 Ecgfa{*bTbBaaép-kgrdsPa bTbBaaépkgRBTsPa ng c,aberobcGgkarTagLay RtvEtbBaneTA RkmRbkSaFmnBaBntümnngRbkas [eRb*}. seNIrbssemc Ca sm RbFanRBT-sPa elx054¼0506¼Bs¼nv cHéfT 23 Ex ]sPa qa2006 Edl GKelxaFkardan RkmRbkSaFmnBa )anTTlenAéfT 23 Ex ]sPa qa 2006 evlaemag 14³10naT KRsbtamrdFmnBa. RkmRbkSaFmnBa GacTTlykseNIsBntüFmnBaPaBenH mkBntü)an

- ylеXIjfa maRta 106 f¬my¦énrdFmnBa )anRbKl[RBTsPa ¬mnEmnkar-yalybeNaHGasneT¦ RbkassBlPaBénGaNtrbssmaCknmy²nge)aHeqat eRCIserIsdacedayELkBIKanvRbFan GnRbFanRBTsPang smaCkTagGsénKN³-kmkarnanarbsRBTsPa edaymtPaKeRcIndacxaténcnnsmaCkRBTsPaTagml
- ylеXIjfa Rbkar 5 cNc x EdlEcgfa { *karyalybeNaHGasnmanParkc eRCIstagRbFan ng GnRbFanTagBIrrbsRBTsPa* } pyngmaRta 106 fI¬my¦én rdFmnBa BIeRBaHkaryalybeNaHGasnmansTerobckare)aHeqateRCIstagRbFan ngGnRbFanTagBIrrbsRBTsPaEtbeNaH . kareRCIstagRbFan ng GnRbFanTagBIr rbsRBTsPa CaParkcrbsRBTsPa
- ylеXIjfa Rbkar 19 kfaxNT2 EdlEcgfa { *kgkrNBessbnan EdlmnGac e)aHeqatdacedayELkBIKa)an kare)aHeqatGaceFeLgkgeBlEtmy manTagRbFan GnRbFanT1 GnRbFanT2 )an . snkeqat RtveFdacedayELkBIKa* } pyng maRta 106 fI¬my¦kfaxNT2énrdFmnBa EdlEcgfa { *mncabepmkargarrbs xn RBTsPaRtvRbkassBlPaBénGaNtrbssmaCknmy² ng Rtve)aHeqat eRCIsersdacedayELkBIKanvRbFan GnRbFanRBTsPa ng smaCkTagGsénKN³-kmkarnanarbsRBTsPa edaymtPaKeRcndacxaténcnnsmaCkRBTsPaTagml* } EtbeNaH
- ylеXIjfa Rbkar20 EdlEcgfa{*kaleberRCsersRbFan ng GnRbFan)anehy RbFankaryalybeNaHGasn RtvRbkasbBabParkcrbskaryalybeNaHGasn ehyRbKlkargarCnRbFanRBTsPaEdleTb)aneRCstag* } pyngmaRta 106 fI ¬my¦kfaxNT2énrdFmnBa EdlEcgfa{*mncabepmkargarrbsxn RBTsPaRtv RbkassBlPaBénGaNtrbssmaCknmy² ng Rtve)aHeqateRCsersdaceday ELkBIKanvRbFan GnRbFanRBTsPang smaCkTagGsénKN³kmkarnanarbsRBT-sPa edaymtPaKeRcndacxaténcnnsmaCkRBTsPaTagml* }
- ylеXIjfa Rbkar 25 pyngmaRta 106 fI¬my¦énrdFmnBa
- ylеXIjfa Rbkar 109 kfaxNT2 )anEcgfa { *kgkrNTjTalBmanEcgkg bTbBaaépkgenHeT RbFanRBTsPaRtvskarseRmcBKN³kmaFkarGcé®ny b B smyRbCeBjGgGBntvFsmRsb EdlRtvykmkGnvt* } enaH manlkN³pyng

maRta140 f kfaxNT2 énrdFmnBaEd l Ecgfa} *bTbBaaépkgrdsPa bTbBaa-épkgRBTsPa ng c,aberobcGgkarTagLay RtvEtbBaneTARkmRbkSaFmnBa BntümnngRbkas[eRb }*

- yl eX j fa enAkgRKbCBk ng RbkarTagGsénbTbBaaépkgfrbsRBTsPa Bman bTbBatNaEd l mnRsbngrdFmnBaeT e l kE l gEtbTbBaténRbkar 5 cNc x Rbkar19 kfaxNT2 Rbkar20 Rbkar25 ng Rbkar109 kfaxNT2 .

sеRmc

maRta 1- bTbBaaépkgfrbsRBTsPaénRBHraCaNacRkkmCa Ed l )anGnmtenAéfT 22 Ex ]sPa qa 2006 nasmyRbCRBTsPae l kT 1 ntka l T 2 Rtv)anRbkasfa RsbngrdFmnBa e l kE l gEtRbkar 5 cNc xEd l mnRsbngmaRta 106 f ¬my¦ énrdFmnBa Rbkar19 kfaxNT2 Rbkar20 Rbkar 25 mnRsbngmaRta 106f ¬my¦kfaxNT2énrdFmnBa ng Rbkar 109 kfaxNT2 mnRsbngmaRta140 f kfaxNT2énrdFmnBa.

maRta 2- escklseRmcenHeFenAraCFanPeB j éfT01Ex mfna qa2006 nasmyRbCeB j Gg énRkmRbkSaFmnBa CaescklseRmcsaBr bTpvtva ehymanGanPaBGnvteTAe l GNacTagGsEd l manEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanPeB j éfT 01 Ex mfna qa 2006

C>RkmRbkSaFmnBa

RbFan

bn Qn

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x ³106 ¼006 ¼2006

cHéfTI 14 Ex mfna qa2006

esckIseRmc

e l x ³078¼005 ¼ 2006 kbF>c

cHéfTI 16 Ex mfna qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas [eRbIc,absBIkarerobc ng karRbRBtteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼0301¼05 cHéfTI 19 Exmna qa2001 Rbkas [eRbIc,absBIkarRKbRKgrd)a l X sgat
- )aneXIj RBHraCRkme l x ns¼rkm¼0301¼04 cHéfTI 19 Exmna qa2001 Rbkas [eRbIc,absBIkare)aHeqateRCIserIsRkmRbkSaX sgat
- )aneXIj esckIseRmcrbsRkmRbkSaFmnBa e l x 042¼004¼2001 kbF>c cHéf T07 Ex mna qa2001
- )aneXIj l xte l x 662 rs cHéfTI 14 Ex mfna qa2006 rbssemc ehg srn RbFanrdsPa esIs [RkmRbkSaFmnBaBntüFmnBaPaBénc,absBvesaFnkmc,ab sBIkare)aHeqateRCIserIsRkmRbkSaX sgat Ed l rdsPa)anGnmty l RBm ka l Béf TI 25 Ex ]sPa qa2006 nasmyRbCrdsPae l IkT4 ntka l T3 ehyRBTsPa)an Bntü ng [eyab l y l RsbtamTRmg ng Kténc,abenHTagRsg edayKankarEkERb ka l BéfTI 09 Ex mfna qa2006 nasmyRbCeBj Gge l IkT1 ntka l T2 Ed l GKe l xaFkardanRkmRbkSaFmnBa )anTT l enAéfTI 14 Ex mfna qa2006 ev l a emag09³15naTI .

eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)anBPakSaRtmRtvtamc,abehIy

- ylexIjfa rdsPa ngRBTsPa)anGnvtyagRtmRtvtamEbbbT Edl manEcgkg maRta 113 fI énrdFmnBa kgkarBntüngGnmtc,absBvesaFnkmc,absBkar e)aHeqaterCserIsRkmRbkSaX sgat
- ylexIjfa seNrbssemc ehg srn RbFanrdsPa RsbngmaRta 140fén rdFmnBa ngmaRta16énc,absBkarerobcngkarRbRBteTAénRkmRbkSaFmnBa Edl Rbkas [eRbeda yRBHraCRkme lxCs¼rkm¼0498¼06 cHéfT 08 Exemsaqa1998
- ylexIjfa TRmgénkartakEtg ng Gnmtc,absBvesaFnkmc,absBkare)aHeqat erCserIsRkmRbkSaX sgat BmanGxsngrdFmnBaeT
- ylexIjfa enAkgRKbmaRtaTagGsénc,absBvesaFnkmc,absBkare)aHeqaterCs- erIsRkmRbkSaX sgat BmanbTbBatNaEdl mnRsbngrdFmnBaeT .

sERmc

maRta 1- tamml bTxagel c,absBvesaFnkmc,absBkare)aHeqaterCserIsRkmRbkSaX- sgat Edl rdsPa)anGnmtkal BéfT 25 Ex ]sPa qa2006 nasmyRbCrdsPa el kT 4 ntkal T 3 ehyRBTsPa)anBntü ng [eyab lyl Rsbtam TRmgng Kténc,abenHTagRsgedayKankarEkERb kal BéfT 09 Ex mfna qa 2006 na smyRbCeB j Gge l kT1 ntkal T2 Rtv)anRbkasfa RsbngrdFmnBa .
maRta 2- esckIsERmcenHeFenAraCFanIPeB j éfT 16 Ex mfna qa2006 nasmyRbCeB j Gg énRkmRbkSaFmnBa CaesckIsERmcsaBr bTpvtva ehymanGanPaBGnvteTAel I GNacTagGsEdl manEcgkgrdFmnBa ng RtvcHpSayk grraCkc .

raCFanIPeB j éfT 16 Ex mfna qa 2006
C>RkmRbkSaFmnBa
RbFan

bn Qn

RBHraCaNacRkkmCa

Cat sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x ³ 107¼007¼2006

cHéfT 14 Ex mfna qa 2006

esckþseRmc

e l x ³ 079¼006¼2006 kbF›c

cHéfT 16 Ex mfna qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas [eRbIc,absBkarerobc ng karRbRBtþeTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼1297¼06 cHéfT 26 Ex F qa 1997 Rbkas [eRbIc,absBkare)aHeqatþeRCIstagtNagra®s
- )aneXIj esckþseRmcrbsRkmRbkSaFmnBa e l x 047¼002¼2002 cHéfT 06 Ex kBaa qa 2002
- )aneXIj RBHraCRkme l x ns¼rkm¼0902¼017 cHéfT 17 Ex kBaa qa 2002 Rbkas [eRbIc,absBvesaFnkmc,absBkare)aHeqatþeRCIstagtNagra®s
- )aneXIj l xte l x 663 rs cHéfT 14 Ex mfna qa 2006 rbssemc ehg srn RbFanrdsPaesIs [RkmRbkSaFmnBa BntüFmnBaPaBGtbTc,absBvesaFnkm maRta 13 f énc,absBvesaFnkmc,absBkare)aHeqatþeRCIstagtNagra®sEdl GKe l xaFkardanRkmRbkSaFmnBa )anTTl enAéfT 14 Ex mfna qa 2006 ev l aemag 9³ 15 naT .

eRkayB)ansabr)aykarNrbssmaCkraykarN

eRkayB)anBPakSaRtmRtvtamc,abehIy

- yleXIjfa maRta 140 fénrdFmnBa RtgkfaxNT2 XaT1 Ecgfa{*bTbBaaép-kgrdsPa bTbBaaépkgRBTsPa ng c,aberobcGgkarTagLay RtvEtbBaneTA RkmRbkSaFmnBaBntümnngRbkas [eRb*}. seNIrbssemc ehg srn RbFan rdsPa elx 663 rs cHéfT 14 Ex mfna qa 2006 EdlGKelxaFkardan RkmRbkSaFmnBa )anTTlenAéfT 14 Ex mfna qa 2006 evlaemag 9³15 naT KRsbtamrdFmnBa. RkmRbkSaFmnBa GacTTlykseNIsBntüFmnBaPaBenH mkBntü)an

- yleXIjfa rdsPa ngRBTsPa)anGnvtyagRtmRtvtamEbbbTEdlmanEcgkg maRta 113f énrdFmnBa kgkarBntü Gnmtc,abxagelenH .

- ylEXIjfa xmsarc,absBvesaFnkmmaRta 13f énc,absBvesaFnkmc,absB kare)aHeqatéRCIstagtNagra®sEdl)anbEnmcnnsmaCkKN³kmaFkarCaterob ckare)aHeqatedIm, [manRbsTPaBkargar mnmanGpyngrdFmnBaeLy .

seRmc

maRta1 - c,absBvesaFnkmmaRta 13 f énc,absBvesaFnkmc,absBkare)aHeqatéRCIs tagtNagra®sEdlrdsPaGnmt enAéfT 25 Ex ]sPa qa 2006 nasmyRbC rdsPaelkT 4 ntkalT 3 ehyRBTsPak)anGnmtylRsbtamTRmg ng Ktc,abTagRsg enAéfT 09 Ex mfna qa 2006 nasmyRbCeBjGg elkT 1 ntkalT 2 Rtv)anRbkasfaRsbngrdFmnBa .

maRta 2 - esckIseRmcenHeFIenAraCFanIPeBjéfT 16 Ex mfna qa 2006 nasmyRbC eBjGgénRkmRbkSaFmnBa CaesckIseRmcsaBr bTpvtva ehymanGanPaB GnvteTAelIGNacTagGsEdlmanEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanIPeBj éfT 16 Ex mfna qa 2006

C>RkmRbkSaFmnBa

RbFan

bn Qn

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

elx ³108 ¼008 ¼2006

cHéfTI 23 Ex mfna qa2006

esckIseRmc

elx ³080¼007 ¼ 2006 kbF>c

cHéfTI 05 Ex kkda qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkmelx Cs¼rkm¼0498¼06 cHéfTI08 Ex emsa qa1998 Rbkas [eRbIc,absBIkarerobcMng karRbRBwteTAénRkmRbkSaFmnBa
- )aneXIj esckIseRmcrbsRkmRbkSaFmnBa elx 077¼004¼2006 kbF>c cHéf TI 01 Ex mfna qa2006
- )aneXIj esckIseRmcelx 076 ¼0606¼ Bs¼ sr cHéfTI 05 Ex mfna qa2006 Rbkas [eRbIbTbBaaépkgfrbsRBTsPa
- )aneXIj lxtelx 080 ¼ 0606 ¼Bs¼nv cHéfTI 23 Ex mfna qa2006 rbs semc Ca sIm RbFanRBTsPa esIs [RkmRbkSaFmnBaBnWüFmnBaPaBvesaFnkm bTbBaaépkgrbsRBTsPa EdlRBTsPa)anGnumtedaymansemgylRBmcnn 59 elI 59 kalBéfTI 23 Exmfna qa2006 nasmyRbCRBTsPaelIkTI1 nItkalTI2 ehIyEdlGKelxaFkardanRkmRbkSaFmnBa )anTTYlenAéfTI23 Ex mfna qa2006 evlaemag 16³30naTI

eRkayB)ansabr)aykarNrbssmaCkraykarN

eRkayB)anBPakSaRtmRtvtamc,abehIy

- ylEXIj fa seNIrbssemc Ca sIm RbFanRBTsPa RsbngmaRta140 fénrdFmnBa
- ylEXIj fa Rbkar 2 fI mnmanGEdlmnRsbngrdFmnBaeT
- ylEXIj fa Rbkar 4 fI¬Rbkar 5 cas EkERb¦Rsbngmartta 106 fI¬my¦énrdFmnBa

- ylXeXjfa Rbkar 18 f¬Rbkar 19 cas EkERb¦Rsbngma Rta 106 f¬my¦énrdFmnBa
- ylXeXjfa Rbkar 42 f¬Rbkar 43 cas EkERb¦ng Rbkar 105 f¬ Rbkar 106 cas EkERb¦mnmanGEdlmnRsbngrdFmnBaeT
- ylXeXjfa Rbkar 108 f¬Rbkar 109 cas EkERb¦Rsbngma Rta 114 f¬my¦én rdFmnBa .

seRmc

maRta 1- tammlbTxageRkamnivesaFnkmmbTbBaaépkgRBTsPa EdlRBTsPa)anGnmtkalBI éfTI 23 Ex mfna qa2006 nasmyRbCMRBTsPaelIkTI1 nItkalTI2 Rtv)anRbkas fa RsbngrdFmnBa .

maRta 2- esckþIsMeRmcenHmaneFenAraCFanIPeBjcab;BIéfTI 05 Ex kkda qa2006 nasmyRbCMeBjGgÁ énRkmRbkSaFmnBa CaesckþIsMeRmcsaBr bTpvtþva ehIymanGanPaBGnvtþeTAelI GNacTagGsEdlmanEcgkgrdFmnBa ng Rtv)anpSayCasaFarN³ .

raCFanIPeBj éfTI 05 Ex kkda qa 2006
C>RkmRbkSaFmnBa
RbFan

bn Qn

RBHraCaNacRkkmCa

Cat sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x ³109 ¼009 ¼2006

cHéfT 14 Ex sIha qa 2006

esckIseRmc

e l x ³081¼008¼2006 kbF>c

cHéfT 18 Ex sIha qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas [eRbIc,absBIkarerobc ng karRbRBtteTAénRkmRbkSaFmnBa
- )aneXIj esckIseRmcrbsRkmRbkSaFmnBa e l x 035¼001¼2000 kbF>c cHéfT 28 Ex mkra qa 2000
- )aneXIj RBHraCRkme l x Cs¼rkm¼0300¼06 cHéfT 03 Ex mIna qa 2000 Rbkas [eRbI c,absBIsvnkménRBHraCaNacRkkmCa
- )aneXIj l xte l x 916 rs cHéfT 14 Ex sIha qa 2006 rbssemc ehg srn RbFan rdsPaesIseGayRkmRbkSaFmnBaBntüFmnBaPaBc,absBIvesaFnkmmaRta 18 énc,absBI svnkménRBHraCaNacRkkmCa Ed l GKe l xaFkardanRkmRbkSaFmnBa)anTT l enAéfT 14 Ex sIha qa 2006 ev l aemag 10 ng 13 naT .

eRkayB)ansabr)aykarNrbssmaCkraykarN

eRkayB)anBPakSaRtmRtvtamc,abehIy

- y l eXIj fa maRta 140 fI énrdFmnBa RtgvaküxNT 2 XaT 1 Ecgfa { *bTbBaaépkg rdsPa bTbBaaépkgRBTsPa ngc,aberobcGgkarTagLay RtvEtbBaneTARkmRbkSa FmnBaBntümnngRbkaseGayeRb* } . seNIrbssemc ehg srn RbFanrdsPa

elx916rs cHéfTI 14 Ex sIha qa 2006 EdlGKelxaFkardanRkmRbkSaFmnBa)anTTlenA éfTI14 Ex sIha qa2006 evlaemag10ng13 naTIKRsbtamrdFmnBa. RkmRbkSaFmnBa GacTTlyksNs [BntüFmnBaPaBenH mkBntü)an .

- ylXjfa rdsPa ng RBTsPa )anGnvtyagRtmRtvtamEbbbTEdlmanEcgkgmaRta 113 fIénrdFmnBa kgkarBntü Gnmtc,abxagelenH .
- ylXjfa xmsarénc,absBvesaFnkmmaRta 18 énc,absBsvnkménRBHraCaNacRk kmCa mnmanGEdlmnRsbngrdFmnBaeT .

sMerc

maRta 1- c,absBvesaFnkmmaRta 18 énc,absBsvnkménRBHraCaNacRkkmCa EdlrdsPa)an Gnmtkal BéfTI 27 Ex kkda qa 2006 nasmyRbCvsamBardsPa nItkalTI 3 ehIy EdlRBTsPa)anGnmtylRsb kal BéfTI 09 Ex sIha qa2006 nasmyRbCvsamBa RBTsPa nItkalTI 2 Rtv)anRbkasfa RsbngrdFmnBa .

maRta 2- esckIsMercenH eFVenAraCFanIPeBjéfTI 18 Ex sIha qa 2006 nasmyRbCeBjGgén RkmRbkSaFmnBa CaesckIsMercsaBr bTpvtva ehIymanGanPaBGnvteTAelIGNac TagGsEdlmanEcgkgrdFmnBa ngRtvcHpSaykgraCkc .

raCFanIPeBjéfTI 18 Ex sIha qa 2006
C>RkmRbkSaFmnBa
RbFan

bn Qn

RBHraCaNacRkkmCa

Cat sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x ³111 ¼011 ¼2006

cHéfT 01 Ex vcka qa 2006

esckþseRmc

e l x ³082¼009¼2006 kbF›c

cHéfT 10 Ex vcka qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas [eRbIc,absBkarerobc ng karRbRBtþeTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼1006¼025 cHéfT21 Ex t l a qa2006 Rbkas [eRbIc,absB l knk³tNagra®s
- )aneXIj l xte l x tr›krm›30¼06 cHéfT 01 Ex vcka qa 2006 rbsÉk]tm e l akCTav tNagra®s cnn 16 rb esIs [RkmRbkSaFmnBaBntüFmnBaPaBmaRta 5 énc,absB l knk³tNagra®s Ed l GKe l xaFkardanRkmRbkSaFmnBa )anTT l enAéfT 01 Ex vcka qa2006 ev l aemag 09 ³ 30 naT.

eRkayB)ansabr)aykarNrbssmaCkraykarN

eRkayB)anBPakSaRtmRtvtamc,abehIy

- y l eXIj fa seNIrbsÉk]tm ng e l akCTavtNagra®s cnn 16rb Rsbtam l kxNén maRta 141 fIénrdFmnBa ng maRta 18 énc,absBkarerobc ng karRbRBtþeTAénRkmRbkSaFmnBa Ed l Rbkas [eRbedayRBHraCRkme l x Cs¼rkm¼0498¼06 cHéfT 08 Ex emsa qa1998 decHRkmRbkSaFmnBaGacTT l yksMNsBntüFmnBaPaBenHmkBntü)an .
- y l eXIj fa GPyÉksTsPaRtv)anp l Cnrdsa.
- y l eXIj fa tNagra®sRKbrbmanGPyÉksTsPa Ed l Fanamn [tNagra®s)armGB karre l aPbBanBIsNakGNacnItRbtbt b GNact l akar . bénGPyÉksTenH kman

RBEdnkNtEdr .

- ylXeX jfa maRta 5 énc,absBI lknk³tNagra®s manxmsareRkknrBkd ltNagra®s ehIyBmaneFI [tNagra®s)atbgGPyÉksTsParbsxneLIy.

sRmc

maRta 1- Epktamm lbTxagel I maRta 5 énc,absBI lknk³tNagra®s Ed lRbkas [eRbIeday RBHraCRkme lxns¼rkm¼1006¼025¼cHéfTI21Extl a qa2006 BmanGFmnBaPaBeT .

maRta 2- esckþIsRmcenH eFenAraCFanIPeB jéfTI 10 Ex vcka qa 2006 nasmyRbCeB jGgén RkmRbkSaFmnBa Caesck þIsRmcsaBr bTpvtva ehIymanGanPaBGnvteTAe lIGNac TagGsEd lmanEcgkgrdFmnBa ngRtvcHpSayk gra Ckc .

raCFanIPeB jéfTI 10 Ex vcka qa 2006

C>RkmRbkSaFmnBa

RbFan

bn Qn

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x ³ 117¼017¼2006

cHéfT 18 Ex vcka qa 2006

esckIseRmc

e l x ³ 083¼010¼2006 kbF>c

cHéfT 24 Ex vcka qa2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x nS¼rkm¼1297¼06 cHéfT 26 Ex F qa1997 Rbkas[ eRbIc,absBIkare)aHeqateRCIstagtNagra®s
- )aneXIj RBHraCRkme l x CS¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas[ eRbIc,absBIkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x nS¼rkm¼0301¼04 cHéfT 19 Ex mina qa2001 Rbkas[ eRbIc,absBIkare)aHeqateRCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x nS¼rkm¼0902¼017 cHéfT 17 Ex kBaa qa2002 Rbkas[ eRbIc,absBIvesaFnkmc,absBIkare)aHeqateRCIstagtNagra®s
- )aneXIj RBHraCRkme l x nS¼rkm¼0606¼020 cHéfT 27 Ex mfna qa2006 Rbkas [eRbIc,absBIvesaFnkmc,absBIkare)aHeqateRCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x nS¼rkm¼0606¼019 cHéfT 27 Ex mfna qa2006 Rbkas [eRbIc,absBIvesaFnkmmaRta 13 fI énc,absBIvesaFnkmc,absBIkare)aHeqateRCIs-tagtNagra®s
- )aneXIj l xteprsTcHéfT 16 Ex vcka qa2006 rbsÉk]tm Kg Ka RbFanKNbkS sm rgS sT eprsTCne l ak fac Xnsarn CasmaCkKN³kmaFkare)aHeqat KNbkSsm rgS edm,CatNagdakBaKübNg ng svnakarenARkmRbkSaFmnBa

- )aneXIj BakübNgrbsel ak fac Xnsarn cHéfT 17 Ex vcka qa2006 bgTam-Tars[ l beQaHcnn08nak enAsgatc,aGeBAT1 xNmanCy raCFanPeB j ec j B bBae)aHeqat Ed l GKe l xaFkardanénRkmRbkSaFmnBa )anTT l enAéfT 18 Ex vcka qa2006 ev l aemag 11³10naT
- )aneXIj l xt]eTsname l x 514¼06 K>C>b cHéfT 23 Ex vcka qa2006 cattag tNag K>C>b [c l rmkgsvnakarCnCRmHrbsRkmRbkSaFmnBa
- )aneXIj esckIseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfT 13 Ex vcka qa2006 seRmcbdesFBaküb Nge l x 0011¼06 k>T>d>b cHéfT 10 Ex vcka qa2006 rbs e l ak fac Xnsarn
- )aneXIj kNtehtcHesbGegtéfT 21 Ex vcka qa2006 enAsgatc,aGeBAT1 xNmanCy raCFanPeB j
- )aneXIj kNteht eqybPrbstNagKN³kmaFkarCaterobckare)aHeqat ka l B éfT 21 Ex vcka qa2006 ev l aemag 14³30 naT

eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)ansabcemyrbsKPaK ng sakS
eRkayB)anBPakSaRtmRtvtamc,abehIy

- yl eXIj fa bNgrbsel ak fac Xnsarn CabNgstenAkgdNakka l bTpSay CasaFarN³bBae)aHeqatdbg . decHeyagtammaRta 42 f énc,absBvesaFnkmc,ab sBkare)aHeqateRCIsersRkmRbkSaX sgat maRta 64 f énc,absBvesaFnkmc,ab sBkare)aHeqateRCIstagtNagra®s ng maRta 26 énc,absBkarerobc ng kar RbRBteTAénRkmRbkSaFmnBa bNgenH RkmRbkSaFmnBa GacTT l ykmkBntü)an
- yl eXIj fa enAkgsvnakarCnCRmHngkgBaküb Ng e l ak fac Xnsarn )anbBaak fa edaysarKatCaecAsgatrg sgatc,arGeBAT1 KatsalRbCaB l rdTag 08rb c,as ehIyKat)anrsenAkgsgatenH 10qaehIy . ÉsakSeQaH Qn T T l enA sgatdEd l )anbBaakfa GkTag 08rb nyayPasaevotNam em l TrTsSnevotNam se l okbBakevotNam ng TenomTmabtamevotNam ehIyfaGkTagenaHKan GtsBaaNbNeT

- yleXjfa enAkgsvnakarCnCRmH ng kgeBleqybP Ék]tm man sT ng Ék]tm emA sParT smaCkKN³kmaFkarCaterobckare)aHeqat )aneqyfa { *enAkgsvnakar rbsKN³kmaFkarCaterobckare)aHeqat elak fac Xnsarn KanPstagÉksarmk bgajeRkABsGageTAeleQaHCaevotNamngsenogCaevotNam. elak fac Xnsarn )anGHGagfa xnCaGkbgpg ng CaGkclrmedaHRsaypg ehy)ancHhtelxakg karedaHRsayenAkgRkmRbkSaXsgatc,arGeBAT1 edayTTlsalfa 03 nak man GtsBaaNbNsBaat Exr ng 05 nakmaneQaHenAkgbBae)aHeqatcgeRkay }.*
  TnmngenH Ék]tm man sT smaCkK>C>b )anbBaakfa { *elak fac Xnsarn mn salBGtsBaaN ng TkEngrsenArbsCnTag 08 nak enHeT }*
- yleXjfa elak fac Xnsarn sGagfa Blrd 08rb KansBaatCaExr edayRKan EteKnyayPasaevotNam emlTrTsSnbsevotNam esókBaktamEbbevotNam ehybeRgonknecArebobeKarBK»béd ng »nk,al . karsGagenH mnEmnCaPstag EdlGac [RkmRbkSaFmnBalbeQaHBlbBae)aHeqat)aneLy
- yleXjfa tamkarRsavRCavdlmldan)anbBaakfa kgceNamBlrd 08rb EdlRtv )anslbeQaH 03rb manGtsBaaNbNsBaatExr ehy 05rbeTot maneQaHenA kgbBae)aHeqatcgeRkay
- yleXjfa karbBaakGBFatBténGtsBaaNrbsbKlNamak mnEmnCasmtkc rbsRkmRbkSaFmnBaeT

# seRmc

## ceBaHmxKPaK

maRta 1- TTlBaküb Ngrbselak fac Xnsarn cHéfT 17 Ex vcka qa2006 TkCaRtm Rtvtam TRmgc,ab bEnbdesFecalédayxsngKtc,ab .

maRta 2- tmlescksemcrbsKN³kmaFkarCaterobckare)aHeqatcHéfT 13 Ex vcka qa2006 EdlseRmcbdesFbNgelx 0011¼06 k>T>d>b cHéfT 10 Ex vcka qa2006 TkCa)ankareBjTagml .

maRta 3- esckþIsMerMcenH RbkasnasvnakarCasaFarN³ enAraCFanIPeB jéfTI 24 Ex vicäika qñaM2006 CaesckþIsMerMcsaBr bTpøv½tva ehIyman GanPaBGnuvtþeTAelIGNacTagGs EdlmanEcgkñúgrdæFmμnuBaØ nug RtvcHpSaykñúgraCkic©.

raCFanIPeB jéfTI 24 Ex vicäika qñaM 2006
C>RkumRbwkSaFmμnuBaØ nug C>RkumRbwkSaCnCRmH
RbFan

bn Qn

RBHraCaNacRkkmCa

Cat sasna RBHmhakSRt

3

RkmRbkSaFmnBa

3

sNerOg

e l x ³ 112¼012¼2006

cHéfT 16 Ex vcka qa 2006

esckIsERmc

e l x ³ 084¼011¼2006 kbF›c

cHéfT 24 Ex vcka qa2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l xns¼rkm¼1297¼06cHéfT26ExF qa1997 Rbkas [ eRbI c,absBkare)aHeqatERCIstagtNagra®s
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfT 08 Ex emsa qa1998 Rbkas [ eRbIc,absBkarerobc ng karRbRBtETAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼0301¼04 cHéfT 19 Ex mIna qa2001 Rbkas [ eRbIc,absBkare)aHeqatERCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x ns¼rkm¼0902¼017 cHéfT 17 Ex kBaa qa2002 Rbkas [ eRbIc,absBvesaFnkmc,absBkare)aHeqatERCIstagtNagra®s
- )aneXIj RBHraCRkme l x ns¼rkm¼0606¼020 cHéfT 27 Ex mfna qa2006 Rbkas [ eRbIc,absBvesaFnkmc,absBkare)aHeqatERCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x ns¼rkm¼0606¼019 cHéfT 27 Ex mfna qa2006

Rbkas [ eRbc,absBvesaFnkmmaRta 13f énc,absBvesaFnkmc,absBkar e)aHeqateRCIstagtNagra®s

- )aneXj lxteprsTcHéfT16Ex vcka qa2006 rbsÉk]tm Kg Ka RbFanKNbkS sm rgS sT eprsTCne lak DNa saKN CasmaCkKN³kmaFkare)aHeqat KNbkSsm rgS edm,CatNagdakBaKübNg ng svnakarenARkmRbkSaFmnBa
- )aneXj lxtbgabkarcHéfT16Exvckaqa2006rbsÉk]tm Kg Ka RbFanKNbkS sm rgS sT
- )aneXj lxtbgabkare lx 640 Ksr¼11¼06 cHéfT 21 Ex vcka qa2006 rbs Ék]tm Kg Ka RbFanKNbkSsm rgS sT
- )aneXj BaKübNgrbse lak DNa saKN cHéfT 16 Ex vcka qa2006 bgTamTar s[ lbeQaHCnCatevotNam cnn 1›604 nak ecj BbBae)aHeqat ng bdesF esckseRmc rbsRkmRbkSaCnCRmHén K›C›b cHhte lxaeday Ék]tm Gm ss naéfT 12ngT 13 Ex vcka qa2006 Ed lGKe lxaFkardanénRkmRbkSa-FmnBa )anTT lenAéfT16 Ex vcka qa2006 ev laemag 16³38 naT
- )aneXj esckseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfT 12 Ex vcka qa2006 seRmctm lesckseRmcrbsRkmRbkSaXcgeXós Rskesomrab extesomrab
- )aneXj esckseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfT 13 Ex vcka qa2006 seRmcbdesFBaKübNge lx 0013¼06 k›T›d›b cHéfT 10 Ex vcka qa2006 rbse lak sx sGan
- )aneXj esckseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfT 13 Ex vcka qa2006 seRmcbdesFBaKübNge lx 0017¼06 k›T›d›b cHéfT 11 Ex vcka qa2006 rbse lak DNa saKN
- )aneXj lxt]eTsname lx 515¼06 K›C›b cHéfT 23 Ex vcka qa2006 cattagsmaCk ng m®nénKN³kmaFkarCaterobckare)aHeqat c lrmkgsvnakar

CnCRmHCasaFarN³ enARkmRbkSaFmnBa

- )aneX|j kNtehtcHes|bGegtenAXcgeXós Rskesomrab extesomrab X)avt Rskc®na extsayerog ng enAXseBABn RskekaHF extkNa l
- )aneX|j kNteht eq|ybPrbstNagKN³kmaFkarCaterobckare)aHeqat ka l Bl éfT 21 Ex vcka qa2006 ev l aemag 15³30naT

eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)ansabcem|yrbsKPaK ng sakS
eRkayB)anBPakSaRtmRtvtamc,abehy

- yleX|j fa bNgrbse l ak DNa saKN CabNgstenAkgdNakka l bTpSay CasaFarN³bBae)aHeqatdbg. decHeyagtammaRta 42 f énc,absBvesaFnkm c,ab sBkare)aHeqateRCserSRkmRbkSaX sgat maRta 64 f énc,absBvesaFnkm c,absB kare)aHeqateRCstagtNagra®s ng maRta 26 énc,absBkarerobc ng karRbRBteTA énRkmRbkSaFmnBa bNgenHRkmRbkSaFmnBa GacTT lykmk Bntü)an
- yleX|j fa enAkgBakübNg ng enAkgsvnakarCnCRmHe l ak DNa saKN )ans l beQaHCnbreTs cnn 1›604nak BbBae)aHeqat edaysGagfaCnTagenaHnyay Exrmnc,as rsenAtamrebobevotNam mnecHGan sresrGkSrExr nyayevotNam ehy)ane l kykc,absBsBaat ng GnRktüe l x 36 GnRk cHéfT 26 Ex kkda qa1996 mksGag. eRkABenHsakSeQaH ym F enAXcgeXós Rskesomrab extesomrab )anGHGagRbhakRbEh l ngedmbNg. sakSeQaH sx sGan enA X)avt extsayerog bBaakfa B l rd 58rb Ed l s l beQaHmanGtsBaaNc,as l as bEnmnRbRkt. sakSeQaH esm em0n enAXseBABn extkNa l )anbBaak fa RbCaCn Ed l Rtvs l beQaH xHmanGtsBaaNbN ehy)anmkrsenAtagBl qa1979 ng qabnbnab ehy)ansGagfa kgceNamB l rdEd l s l beQaHcnn

783nak man 250nak Rtv)anlbeQaHedayKN³kmkarerobckare)aHeqatext kNalenAqa2001 ehyeQaHTagenaHeXj manenAkgbBae)aHeqatdbgenH

- yleXjfa enAkgsvnakarCnCRmH ng kareqybPenAeBlsaksrcemy Ék]tm Ém spat )anbBaakfa elak DNa saKN sbglbeQaHcnn 1>604nak ecj BbBae)aHeqat edaysGagBsBaatfa CaCnevotNam bEnelak DNa saKN B manPstagGmkbBaakesaH mnsalGkEdlKat)anbg.

Ék]tm Ém spat )anbBaakfa ceBaHerOglbeQaH 250nak enAqa2001 eday KN³kmkarerobckare)aHeqatextkNal nasvnakarenA K>C>b elak DNa saKN mn)anelkbBaaenHeT. bEnqgtamkarbBaaksacHsaeLgrbssakSeQaH esm emOn eTbÉk]tm Ém spat ylfa RbCaBlrd 250nak GacHsaeLgvj enAmnkar e)aHeqatskl qa2003 ehyeQaHTagenaHstenAkgbBacgeRkay

- yleXjfa tambBaténmaRtaTagLayénCBkT12 sBGnrbBaténc,absBkar e)aHeqat ng c,absBvesaFnkmc,absBkare)aHeqateRCstagtNagra®sRbCaBlrd 250nak Edl)anlbeQaHedayKN³kmkarerobckare)aHeqatextkNal GaceTAs cH eQaHsaCaf)an

- yleXjfa tamkarcHRsavRCavdlmldanenAXcgeXós Rskesomrab xtesomrab kgceNamBlrdEdlslbeQaHcnn 763nak 2nak)ansab 26nakpasbrTlenA EdlKrlbecj BbBae)aHeqatdbg ¬maneQaHenAkg]bsmnénesckseRmcenH¦

- yleXjfa karbBaakGBFatBténGtsBaaNrbsbKlNamak mnEmnCasmtkc rbsRkmRbkSaFmnBaeT

# seRmc

## ceBaHmxKPaK

maRta 1-TTlBaKübNgrbselak DNa saKN cHéfT17 Ex vcka qa2006 TkCaRtm Rtvtam TRmgc,ab bEnbdesFecaledayxsngKtc,ab .

maRta 2-tmlesckseRmcrbsKN³kmaFkarCaterobckare)aHeqat ÷

- cHéfTI 12 Ex vcka qa2006 seRmcbdesFBaKübNge l x0007¼06 k>T>d>b cHéfTI 07 Ex vcka qa2006
- cHéfTI 13 Ex vcka qa2006 seRmcbdesFBaKübNge l x0013¼06 k>T>d>b cHéfTI 10 Ex vcka qa2006
- cHéfTI 13 Ex vcka qa2006 seRmcbdesFBaKübNge l x0017¼06 k>T>d>b cHéfTI 11 Ex vcka qa2006

maRta 3- escksSeRmcenH Rbkasnasvnakarcasa FarN³ enAraCFanIPeB j éfTI 24 Ex vcka qa2006 CaescksSeRmcsaBrbTpvtvaehIyman GanPaBGnvteTAe l IGNacTagGs Ed l manEcgkgrdFmnBa ng RtvcHpSa ykgraCkc .

raCFanIPeB j éfTI 24 Ex vcka qa 2006
C>RkmRbkSaFmnBa ng C>RkmRbkSaCnCRmH
RbFan

bn Qn

RBHraCaNacRkkmCa

RkmRbkSaFmnBa 4 — Cat sasna RBHmhakSRt 3

]bsmnénesckþseRmc

elx ³ 084¼011¼2006 kbF>c

cHéfTI 24 Ex vcka qa2006

karyal y 0481

| l>r | eQaH | ePT | éf Ex qakeNIt | elxbNbganéd | epSg² |
|---|---|---|---|---|---|
| 3 | egóg canfa | Rbs | 1983 | 9-176-923 | pasI enA |
| 9 | egóg FCag | Rs | 1971 | 5-344-699 | pasI enA |
| 14 | egóg Fdav | Rs | 1980 | 5-344-809 | pasI enA |
| 28 | egóg FTI | Rs | 1983 | R 1-923-046 | pasI enA |
| 110 | egóg yagI n | Rbs | 1960 | 5-344-877 | pasI enA |
| 112 | egóg yagsag | Rbs | 1961 | 5-344-568 | sab |
| 117 | egóg yagesg | Rbs | 1947 | 5-344-697 | pasI enA |
| 121 | egóg yaghay | Rbs | 1962 | R 1-922-962 | pasI enA |
| 129 | egóg yagehg | Rbs | 1979 | 5-344-700 | pasI enA |
| 140 | Ca yg | Rbs | 1979 | 9-176-920 | pasI enA |
| 191 | Rtg Fhay | Rs | 1923 | 5-344-850 | pasI enA |
| 198 | Rtg FGk | Rs | 1959 | 5-344-876 | pasI enA |
| 238 | pa yageCog | Rbs | 1958 | 9-176-889 | pasI enA |
| 272 | y Feh | Rs | 1949 | 5-344-698 | pasI enA |
| 304 | I yagsn | Rbs | 1932 | 5-344-507 | pasI enA |
| 369 | eL Fhy | Rs | 1963 | 9-176-885 | pasI enA |

RBHraCaNacRkkmCa

RkmRbkSaFmnBa Cat sasna RBHmhakSRt

4 3

]bsmnénesckþseRmc

e l x ³ 084¼011¼2006 kbF>c

cHéfT 24 Ex vcäka qa2006

karyal y 0482

| l>r | eQaH | ePT | éf Ex qakeNIt | e l xbNbganéd | epSg² |
|---|---|---|---|---|---|
| 10 | egóg Fj | Rs | 1940 | R 1-923-189 | pas l enA |
| 38 | egóg FEbr | Rs | 1950 | 5-342-699 | pas l enA |
| 70 | egóg Feho | Rs | 1946 | 9-209-002 | pas l enA |
| 83 | egóg yagkag | Rbs | 08-11-1970 | R 1-923-178 | pas l enA |
| 85 | egóg yagk | Rbs | 1982 | 9-209-129 | pas l enA |
| 101 | egóg yagT | Rbs | 1948 | 9-209-043 | pas l enA |
| 108 | egóg yag)an | Rbs | 1982 | 9-209-044 | pas l enA |
| 112 | egóg yagB | Rbs | 1980 | R 1-923-137 | pas l enA |
| 127 | egóg yageyOg | Rbs | 1983 | 9-209-003 | pas l enA |
| 318 | vn Fhg | Rs | 1983 | R 1-923-179 | pas l enA |
| 352 | eha Ffan | Rs | 1956 | 9-209-129 | sab |
| 353 | eha Fbn | Rs | 1977 | R 1-923-138 | pas l enA |

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3

RkmRbkSaFmnBa

3

sNer0g

e lx ³ 114¼014¼2006

cHéfTI 17 Ex vcka qa 2006

esckIseRmc

e lx ³ 085¼012¼2006 kbF>c

cHéfTI 24 Ex vcka qa2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme lx ns¼rkm¼1297¼06 cHéfTI 26 Ex F qa1997 Rbkas [eRbI c,absBIkare)aHeqateRCIstagtNagra®s
- )aneXIj RBHraCRkme lx Cs¼rkm¼0498¼06 cHéfTI 08 Ex emsa qa1998 Rbkas [eRbI c,absBIkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme lx ns¼rkm¼0301¼04 cHéfTI 19 Ex mIna qa2001 Rbkas [ eRbIc,absBIkare)aHeqateRCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme lx ns¼rkm¼0902¼017 cHéfTI 17 Ex kBaa qa2002 Rbkas [ eRbIc,absBIvesaFnkmc,absBIkare)aHeqateRCIstagtNagra®s
- )aneXIj RBHraCRkme lx ns¼rkm¼0606¼020 cHéfTI 27 Ex mfna qa2006 Rbkas [ eRbIc,absBIvesaFnkmc,absBIkare)aHeqateRCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme lx ns¼rkm¼0606¼019 cHéfTI 27 Ex mfna qa2006 Rbkas [eRbI c,absBIvesaFnkmmaRta 13 fI énc,absBIvesaFnkmc,absBIkar e)aHeqateRCIstag-tNagra®s
- )aneXIj lxteprsTcHéfTI 16 Ex vcka qa2006 rbsÉk]tm Kg Ka RbFan KNbkS sm rgS sTI eprsTCne lak eLg esg CasmaCkKN³kmaFkar e)aHeqatKNbkS sm rgS edm,ICatNagdakBakübNg ng svnakarenARkmRbkSaFmnBa

- )aneX]j BaküþNgrbs;e]ak eLg esg cHéf¶T 17 Ex vcäika qña2006 bg¥amT;ar s[]b eQaHCnCa¼tevo¼tNam cnn 257 nak ecjBIbBa©ae)aHeqña¼t ng bd¡esF esck¡Is¶IeRmcrbs;RkmRbkSaCnCRmHén K>C>b cHhte]xaeda¥yÉk]tm Gm ss½naéf¶T 12 ng T13 Ex vcäika qña2006 Ed]GKe]xaFkardanénRkmRbkSaFmnBa )anTT]enAéf¶T 17 Ex vcäika qña2006 ev]aemag 10³24 naT
- )aneX]j esck¡Is¶IeRmcrbs;KN³kmaFkarCa¼terobcMkare)aHeqña¼t cHéf¶T 12 Ex vcäika qña2006 s¶IeRmcbd¡esFBaküþNge]x 0008¼06 k>T>d>b cHéf¶T 07 Ex vcäika qña2006 rbs;e]ak eLg esg
- )aneX]j esck¡Is¶IeRmcrbs;KN³kmaFkarCa¼terobcMkare)aHeqña¼t cHéf¶T 13 Ex vcäika qña2006 s¶IeRmcbd¡esFBaküþNge]x 0015¼06 k>T>d>b cHéf¶T 10 Ex vcäika qña2006 rbs;e]ak eLg esg
- )aneX]j esck¡Is¶IeRmcrbs;KN³kmaFkarCa¼terobcMkare)aHeqña¼t cHéf¶T 13 Ex vcäika qña2006 s¶IeRmcbd¡esFBaküþNge]x 0016¼06 k>T>d>b cHéf¶T 10 Ex vcäika qña2006 rbs;e]ak eLg esg
- )aneX]j ]xt]eTs;name]x 516¼06 K>C>b cHéf¶T 23 Ex vcäika qña2006 ca¼ttag s;maCk ng m®n¢énKN³kmaFkarCa¼terobcMkare)aHeqña¼t c]rmkg;s;vnakar CnCRmH Ca s;aFarN³ enARkmRbkSaFmnBa
- )aneX]j kNtehtcHRs;avRCavrbs;tNagRkmRbkSaFmnBa enAXERBkKy Xk,a]-ekaH ng XeQ¦exA extkNa]
- )aneX]j kNtehteqøybPrbs;tNagKN³kmaFkarCa¼terobcMkare)aHeqña¼t ka]Béf¶T 22 Ex vcäika qña2006 ev]aemag 15 Kt

eRka¥yB)ans;abr)a¥ykarN¾rbs;s;maCkra¥ykarN¾
eRka¥yB)ans;abcem¶y¥rbs;KPaK
eRka¥yB)anBPakSaR¼tmR¼tv¼tamc,abeh¼y

- ¥y]eX]j fabNgrbs;e]ak eLg esg CabNgs;¼tenAkgdNakka]bTpSa¥yCa s;aFarN³bBa©ae)aHeqña¼tdbg . decHe¥yag¼tammaRa¼ta 42 f¶ énc,abs¶IBIves;aFnkmc,ab s¶IBI kare)aHeqña¼teRCIsers;RkmRbkSaX sg¼at maRa¼ta 64 f¶ énc,abs¶IBIves;aFnkmc,ab s¶IBIkar e)aHeqña¼teRCIs¼tag¼tNagra®s ng maRa¼ta 26 énc,abs¶IBIkarerobc ng kar RbRBt¼teTAén RkmRbkSaFmnBa bNgenH RkmRbkSaFmnBa GacTT]¥ykmkBn¼tü)an
- ¥y]eX]j fa enAkgs;vnakarCnCRmH ng kgBaküþNg e]ak eLg esg )an bBa¢akfa e]aks;bgedIm,]beQaHCnCa¼tevo¼tNamcnn 257 nak enAXcnn 3

enAextkNal KXk,alekaH Rskekonsay XeQexA RskekaHF ng XERBkKy Rsksag edaysGag elmaRta 50 f ng maRta 54 f cNc { K } énc,absBvesaFnkmc,absBkare)aHeqateRCstagtNagra®s . elakk)anbBaakfa enAXk,alekaH emXmnhanFanafa mnEmn yn enAXeQexAelakbBaakfa m®nerobckare)aHeqatXeQaH rs eqg )anGHGagfaCa eQaHyn EtRkmRbkSaX KansTlb enAXERBkKykaredaHRsaybNgeFeLgxsBeBl Edl)ankNt .

- ylеXjfa enAkgsvnakarCnCRmH ng kgeBlsaksrcemy Ék]tm man sT Ék]tm emA sParT smaCkKN³kmaFkarCaterobckare)aHeqat )anbPfa karGHGag rbsedmecaTmanxmsarRbhakRbEhl ngkarEdl)anGHGagenAeBlsvnakar K>C>b Edr. kgsvnakarenaHÉk]tm man sT )anbBaakfa elakesónXERBkKy)anbgaj Éksar EdlbBaakfa BlrdTag 128nak )anrsenAkgXERBkKytagBlqa1979 mkemH . enAX k,alekaH emX)anGHGagfa Blrd 67 nak )anrsenAkgX ehlymanesovePARKsar . enAXeQexA emX)anbBaakfa RbCaBlrdTag 62nak Edlslbe QaH)anrsenAtagBl qa1979 .

Ék]tm emA sParT )aneqlytbngedmecaTfa krNplngkanGtsBaaNbN sBaatExrmnRbRkt CabTelsRBhTN EdlenaHCasmtkcrbstlakar ng mnEmn Ca smtkcrbs K>C>b eT

- ylеXjfa edayeQaHEdlbg[lbecjBlbBae)aHeqatdbgqa2006enHsTEtCaGk EdlmaneQaHkgbBae)aHeqat qa1993mkemH decHGkTagenaHmnRtv)anlbeQaH ecjeT eblmnsab mnpasbrTlenA mnmaneQaHsn mnmansalRkmNamydkht sTe)aHeqat mnmanlxtKtytNamybBaakfa GkTagenaHmnmansBaatExreT
- ylеXjfabNgEdlRKanEtelkBlrdFmnBa c,ab GnRktü bTbBat ngntvFlsRmab kare)aHeqatedaymnmanPstagCakEsgtamkrNlmy²mkbBaakenaHmnmanmldan KtytRKbRKan kgkarlbeQaHGkEdlmaneQaHkgbBae)aHeqatcgeRkayrht mk )aneT
- ylеXjfa eQaHEdlRtv)anbg[lbeQaHecjBlbBae)aHeqatdbgTag 257naksT EtmaneQaHkgbBae)aHeqatcgeRkay eTaHmankarGHGagxHpyKarvagemX m®nTTl bnk kargare)aHeqatfakX ng esónX
- ylеXjfa ceBaHkrNledaHRsaybNgenAXERBkKy Edlelak eLg esg )anelk eLgGBeBlevla RkmRbkSaXERBkKy KrdkBesaFn

- yl eXj fa tamkarRsavRCavd l m l dan)anbBaakfa enAXERBkKymanGksab 8nak ngpasT l enA 7 nak ehyenAXeQexA manGksab 02 nak ng pasT l enA 3 nak Ed l Kr l becj BlbBae)aHeqatdbg ¬maneQaHenAkg]bsmnénesckIseRmcenH¦
-yl eXj fakarbBaakGBFatBténGtsBaaNrbsbK l Namak mnEmnCasmtkcrbs RkmRbkSaFmnBaeT

# seRmc

## ceBaHmxKPaK

maRta 1 ³ TT l BakübNgrbse l ak eLg esg cHéfT 17 Ex vcka qa2006 TkCaRtmRtv tamTRmgc,ab bEnbdesFeca l edayxsngKtc,ab .

maRta 2 ³ tm l esckIseRmcrbsKN³kmaFkarCaterobckare)aHeqat ÷

1-cHéfT 12 Exvcka qa2006 Ed l seRmcbdesFBaKübNge l x 0008¼06 kTdb cHéfT 07 Ex vcka qa2006

2-cHéfT 13 Exvcka qa2006 Ed l seRmcbdesFBaKübNge l x 0015¼06 kTdb cHéfT 10 Ex vcka qa2006

3-cHéfT 13 Ex vcka qa2006 Ed l seRmcbdesFBaKübNge l x 0016¼06 kTdb cHéfT 10 Ex vcka qa2006

maRta 3 ³ esckIseRmcenH RbkasnasvnakarCasaFarN³ enAraCFanIPeBj éfT 24 Ex vcka qa2006 CaesckIseRmcsaBrbTpvtva ehymanGanPaBGnvteTAel IGNac TagGs Ed l manEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanIPeBj éfT 24 Ex vcka qa 2006
C>RkmRbkSaFmnBa ng C>RkmRbkSaCnCRmH
RbFan

bn Qn

RBHraCaNacRkkmCa

RkmRbkSaFmnBa Cat sasna RBHmhakSRt

4 3

]bsmnénesckIseRmc

e l x ³ 085¼012¼2006 kbF>c

cHéfT 24 Ex vcka qa2006

1-XERBkKy Rsksag

-Gksabcnn 08 nak

| l>r | eQaH | ePT | éf Ex qakeNIt | TI l enA | epSg² |
|---|---|---|---|---|---|
| 726 | evog Fby | Rs I | 1930 | PmERBkrn | sab |
| 144 | yag sat | Rbs | 1939 | PmkgERBk | sab |
| 161 | yag sg | Rbs | 1929 | PmkgERBk | sab |
| 131 | evog Fyv | Rs I | 1930 | PmkgERBk | sab |
| 438 | evog yagpg | Rbs | 1925 | PmkgERBk | sab |
| 194 | egóg Fva | Rs I | 1930 | PmERBkrn | sab |
| 103 | egóg FCv | Rs I | 1938 | PmERBkrn | sab |
| 109 | egóg yaghg | Rbs | 1934 | PmkgERBk | sab |

-GkpasTI l enA cnn 7nak ³

| l>r | eQaH | ePT | éf Ex qakeNIt | TI l enA | epSg² |
|---|---|---|---|---|---|
| 441 | evog yagPl | Rbs | 10>05>1956 | PmkgERBk | pasTI l enA |
| 64 | evog Fyb | Rs I | 1946 | PmkgERBk | pasTI l enA |
| 65 | evog yagGk | Rbs | 1960 | PmkgERBk | pasTI l enA |
| 68 | egóg yagGk | Rbs | 1970 | PmkgERBk | pasTI l enA |
| 91 | egóg Fcag | Rs I | 1977 | PmERBkrn | pasTI l enA |

| | | | | | |
|---|---|---|---|---|---|
| 108 | egóg yagsg | Rbs | 1947 | PmERBkrn | pasTIenA |
| 436 | evog yagePOg | Rbs | 1979 | PmERBkrn | pasTIenA |

2-XeQexA RskekaHF

-karyalyelx 0348 manGkpasTIenAcnn 03 nak ³

| l>r | eQaH | ePT | éf Ex qakeNIt | TIenA | epSg² |
|---|---|---|---|---|---|
| 25 | Km gkha | Rsl | 1967 | | pasTIenA |
| 29 | eKog yagvg | Rbs | 1948 | | pasTIenA |
| 483 | eL Fdg | Rsl | 1967 | | pasTIenA |

-karyaly elx 0349 manGksabcnn 02 nak ³

| l>r | eQaH | ePT | éf Ex qakeNIt | TIenA | epSg² |
|---|---|---|---|---|---|
| 250 | pam FGan | Rsl | 1969 | | sab |
| 369 | vg rg | Rsl | 1946 | | sab |

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x ³ 115¼015¼2006

cHéfTI 17 Ex vcka qa 2006

esckIseRmc

e l x ³ 086¼013¼2006 kbF›c

cHéfTI 25 Ex vcka qa2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x ns¼rkm¼1297¼06 cHéfTI 26 Ex F qa1997 Rbkas [ eRbIc,absBkare)aHeqatERCIstagtNagra®s
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfTI08Exemsa qa1998Rbkas [ eRbIc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼0301¼04cHéfTI19Ex mna qa2001 Rbkas [ eRbIc,absBkare)aHeqatERCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x ns¼rkm¼0902¼017 cHéfTI17ExkBaa qa2002Rbkas [ eRbIc,absBvesaFnkmc,absBkare)aHeqatERCIstagtNagra®s
- )aneXIj RBHraCRkme l x ns¼rkm¼0606¼020cHéfTI27Ex mfna qa2006Rbkas [ eRbIc,absBvesaFnkmc,absBkare)aHeqatERCIserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x ns¼rkm¼0606¼019 cHéfTI27Exmfnaqa2006 Rbkas [ eRbIc,absBvesaFnkmmaRta 13 f énc,absBvesaFnkmc,absBkare)aHeqat eRCIstagtNagra®s

- )aneX|j lxteprsTcHéfT| 16 Ex vcka qa2006 rbsÉk]tm Kg Ka RbFan KNbkS sm rgS sT| eprsTCne lak Tc rT| CasmaCkKN³kmaFkare)aHeqat KNbkSsm rgS edm,|Cat NagdakBaKübNg ng svnakarenARkmRbkSaFmnBa
- )aneX|j BaKübNgrbse lak Tc rT| cHéfT| 17 Ex vcka qa2006 bgTamTars[ lbeQaHCnCatevotNamcnn 5›413 nakec j BbBae)aHeqat ng bdesFescklseRmc rbsRkmRbkSaCnCRmHén K›C›b cHhte lxaedayÉk]tm Gm ss| naéfT| 13 Ex vcka qa2006 Ed l GKe lxaFkardanénRkmRbkSaFmnBa )anTT lenAéfT| 17 Ex vcka qa2006 ev l aemag 10³24 naT|
- )aneX|j esckl|seRmcrbsKN³kmaFkarCaterobckare)aHeqat cHéfT| 13 Ex vcka qa2006 seRmcbdesFBaKübNge lx 0018¼06 k›T›d›b cHéfT| 11 Ex vcka qa2006 rbs e lak Tc rT|
- )aneX|j lxt]eTsname lx 517¼06 K›C›b cHéfT| 23 Ex vcka qa2006 cattagsmaCk ng m®nénKN³kmaFkarCaterobckare)aHeqatc lrmkgsvnakar CnCRmHCasaFarN³ enARkmRbkSaFmnBa
- )aneX|j kNtehtcHRsavRCav rbstNagRkmRbkSaFmnBa enAXERBkéRC RskekaHF extkNa l
- )aneX|j kNtehteq|ybPrbstNagKN³kmaFkarCaterobckare)aHeqat ka l B| éfT| 22 Ex vcka qa2006 ev l aemag09Kt

eRkayB|)ansabr)ayKarNrbssmaCkrayKarN
eRkayB|)ansabcem|yrbsKPaK|
eRkayB|)anBPakSaRtmRtvtamc,abeh|y

- y l eX|j fa bNgrbse lak Tc rT| CabNgstenAkgdNakka l bTpSayCasaFarN³ bBae)aHeqatdbg . decHeyagtammaRta 42 f| énc,absBvesaFnkmc,absB| kare)aHeqateRCsersRkmRbkSaX-sgat maRta 64f| énc,absBvesaFnkmc,ab sB|kare)aHeqat eRCstagtNagra®s ng maRta 26 énc,absB|karerobc ng karRbRBt eTAénRkmRbkSaFmnBa bNgenH RkmRbkSaFmnBa GacTT lykmkBntü)an

- ylelXj fa enAkgsvnakarCnCRmH ng enAkgBaKübNg elak Tc rT )anbBaak fa elakbg[lbeQaHCnCatevotNam cnn 5>413 nak ecjBbBae)aHeqat edaysGagelrdFmnBa c,absBsBaat GnRktüelx 36 GnRk cHéfT 26 Ex kkda qa1996 ehy)anbBaakfa CnTagenaHrsenAelTk nyayPasaevotNam xHnyay Exrmnc,as manRtklmnEmnExr dcCa egóg eyok eL Edlmnman lkN³sm,t TTlsBaatExr)aneLy. elakk)anbBaakEdrfa elakmn)andgfa etCnTagenaHman GtsBaaNbN b lxtbBaakGtsBaaNepSgeToteT eRBaHelak BmansTeTAs EqkeqreKeT
- ylelXj fa enAkgsvnakar ng karsaksrykcemy Ék]tm man sT ng Ék]tm emA sParT tNagKN³kmaFkarCaterobckare)aHeqat )anbBaakGBbBaa mycnn TakTgngc,absBaat bBaaCnCat GnsBaasBkarb)atkarersGgCatsasn Edl RbeTseygCahtelxmyEdrenaH. Ék]tmk)anbBaakpgEdrfa enAsvnakar K>C>b elak Tc rT KanÉksarGsGageRkAEtBfa CnTagenHmaneQaH ng senog CaevotNam. müageTotÉk]tmk)anGHGagfa elak cab sy emXERBkéRC ng Ca GttembS)andg ng salfa GkTagenaHrsenAkgXtagBqa1979 ng )an e)aHeqat tagBqa1993mk
- ylelXj fa tamkarRsavRCavrbstNagrbsRkmRbkSaFmnBa enAÉXERBkéRC Rsk ekaHF extkNal RbCaBlrdcnn 5>413nak EdlRtvslbeQaHecjB bBaae)aHeqat dbg sTEtmaneQaHkgbBae)aHeqatcgeRkay RsbtammaRta 54f cNc {K} énc,ab sBvesaFnkmc,absBkare)aHeqateRCstagtNagra®s
- ylelXj fakarbBaakGBFatBténGtsBaaNrbsbKlNamak mnEmnCasmtkc rbsRkmRbkSaFmnBaeT

# seRmc

## ceBaHmxKPaK

maRta 1- TTlBaKübNgrbselak Tc rT cHéfT 17Ex vcka qa2006 TkCaRtmRtvtam

TRmgc,ab bEnbdesFeca l edayxsngKtc,ab .

maRta 2- tm l escklseRmcrbsKN³kmaFkarCaterobckare)aHeqatcHéfT 13 Ex vcka qa2006 Ed l seRmcbdesFbNge l x 0018¼06 k>T>d>b cHéfT 11 Ex vcka qa2006 TkCa)ankareB j Tagm l .

maRta 3- escklseRmcenH Rbkasnasvnakarcasafarn³ enAraCFanPeB j éfT 25 Ex vcka qa2006 Caescklsermcsabr bTpvtva ehymanGanPaBGnvteTAe l lGNac TagGs Ed l manEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanPeB j éfT 25 Ex vcka qa 2006

C>RkmRbkSaFmnBa ng C>RkmRbkSaCnCRmH

RbFan

bn Qn



RBHraCaNacRkkmCa

Cat sasna RBHmhakSRt

3

RkmRbkSaFmnBa

3

sNer0g

e l x ³ 116¼016¼2006

cHéfT 17 Ex vcka qa2006

esckIseRmc

e l x ³ 087¼014¼2006 kbF›c

cHéfT 25 Ex vcka qa2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l xns¼rkm¼1297¼06 cHéfT 26 ExF qa1997 Rbkas[ eRbIc,absBkare)aHeqatéRCstagtNagra®s
- )aneXIj RBHraCRkme l xCs¼rkm¼0498¼06 cHéfT 08 Exemsaqa1998 Rbkas[ eRbIc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼0301¼04 cHéfT 19 Exmina qa2001 Rbkas[ eRbIc,absBkare)aHeqateRCserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x ns¼rkm¼0902¼017 cHéfT 17 ExkBaa qa2002 Rbkas[ eRbIc,absBvesaFnkmc,absBkare)aHeqateRCstagtNagra®s
- )aneXIj RBHraCRkme l x ns¼rkm¼0606¼020 cHéfT 27 Exmfna qa2006 Rbkas [eRbIc,absBvesaFnkmc,absBkare)aHeqateRCserIsRkmRbkSaX sgat
- )aneXIj RBHraCRkme l x ns¼rkm¼0606¼019 cHéfT 27 Exmfna qa2006 Rbkas [eRbIc,absBvesaFnkmmaRta 13 f énc,absBvesaFnkmc,absBkare)aHeqat eRCstagtNagra®s
- )aneXIj l xteprsTcHéfT 16 Ex vcka qa2006 rbsÉk]tm Kg Ka RbFanKNbkS smrgS sT eprsTCne l ak Bm sNag CasmaCkKN³kmaFkare)aHeqat KNbkS

sm rgS edm,CatNagdakBaKübNg ng c l rmkgsvnakarenARkmRbkSaFmnBa

- )aneX j BaKübNgrbse l ak Bm sNag cHéfT 17 Ex vcka qa2006 bgTamTar l beQaHCnCatevotNamec j BlbBae)aHeqat ng bdesFesckse RmcrbsRkmRbkSa CnCRmHénKN³kmaFkarCaterobckare)aHeqat cHhte l xaedayÉk]tm Gm ss enAéf T 13 Ex vcka qa2006 Ed l GKe l xaFkardanénRkmRbkSaFmnBa )anTT l enAéfT 17 Ex vcka qa2006 ev l aemag 15³49 naT
- )aneX j esckseRmcrbsKN³kmaFkarCaterobckare)aHeqat cHéfT 13 Ex vcka qa2006 seRmcbdesFBaKübNge l x 0010¼06 k>T>d>b cHéfT 10 Ex vcka qa2006 rbse l ak Bm sNag
- )aneX j l xte l x 518¼06K>C>bcHéfT 23 Exvcka qa2006 cattagtNagKN³ kmaFkarCaterobckare)aHeqat [c l rmkgsvnakar CnCRmHrbs RkmRbkSaFmnBa
- )aneX j kNtehtcHRsavRCavrbstNagRkmRbkSaFmnBaenAX)ae)ag XBamrk XGke l 0g XERBkxSay¬k¦ XERBkxSay¬x¦ RskBamrk XkBg l av RskkBg l av ng XkBgR)asaT RskBamCr
- )aneX j kNtehteqybPrbstNagKN³kmaFkarCaterobckare)aHeqat ka l B éfT 22 Ex vcka qa2006 ev l aemag 10 Kt

eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)ansabcemyrbsKPaK
eRkayB)anBPakSaRtmRtvtamc,abehy

- y l eX j fa bNgrbse l ak Bm sNag CabNgstenAkgdNakka l bTpSay CasaFarN³bBae)aHeqatdbg . decHeyagtammaRta 42 f énc,absBvesaFnkm c,absBkare)aHeqateRCserSRkmRbkSaX-sgat maRta 64f énc,absBvesaFnkm c,absBkar e)aHeqateRCstagtNagra®s ng maRta 26 énc,absBkarerobc ng kar RbRBteTAénRkmRbkSaFmnBa bNgenHRkmRbkSaFmnBaGacTT l ykmkBntü)an
- y l eX j faenAkgsvnakarCnCRmH ng kgBaKübNg e l ak Bm sNagsbg [ l b eQaHCnbreTs cnn 1>264nak ec j BlbBae)aHeqatdbgenAXcnnR)aBrrbs extéRBEvgedaysGagfa CnTagenaHKansBaatExr nyayExrmnc,asmnecHsresr

GkSrExrrsenAtamTk tammatTen b C l pHeKenA ehYRbkantamTenomT l ab evotNam. e l akk)anGHGageTotfaCnTagenaHKan l kN³sm,tGacc l sBaatExr tamc,absBsBaat ehykmnGacmansTcHeQaHe)aHeqat)aneT ebGnvttamc,ab sB kare)aHeqateRCserSRkmRbkSaX-sgat. e l akq l eTotfa ehtGCnxH)an kan GtsBaaNbNsBaatExr ebCnTagenaHBTanmanRBHraCRktüp l sBaatpg . e l akk )anbEnmeTotfaKN³kmaFkarCaterobckare)aHeqat ebksvnakaredaymn mancgcemy .

- y l eX j fa enAkgsvnakarCnCRmH ng kgeB l saksrcemy Ék]tm Ém spat ng Ék]tm esam cnDNa tNagKN³kmaFkarCaterobckare)aHeqat)anbBaak fa nasvnakarenAKN³kmaFkarCaterobckare)aHeqat e l ak Bm sNag )ansGag RtmEtfa CnTagenaHmaneQaH ngRtk l CaevotNam edayRKanEtRsgykeQaH ec j BbBae)aHeqat ngmn)anbBaakBeQaHkarya l yénCnEd l Rtv)ans l beQaH. krNX)ae)ag RskBamrk extéRBEvg RkmRbkSaX )anseRmc l beQaHRbCaB l rd cnn 46 nak kgceNam 172nak Ed l Rtvbgs[ l beQaH bEnkgbNgmk KN³kmaFkarCaterobckare)aHeqatenAeX j eQaHCnTagenaHenAkgbBaEd l s l b eQaH . Ék]tm Ém spat k)anbBaakpgEdrfa KN³kmaFkarCaterobckar e)aHeqateKarBtam c,ab ntvF ehykar l beQaHRtvbga j PstagRtmRtv ng c,as l as . karmn)ancHRsavRCavd l m l dan edaysarKN³kmaFkarCaterobckar e)aHeqat manrcnasmnenAÉfakX ng extehy . bEnkgsvnakarrbs KN³kmaFkarCaterobckare)aHeqat kmantNagrbsXc l rm ng manesckseRmc rbsRkmRbkSaXpgEdr
- y l eX j fa febsvnakarenAKN³kmaFkarCaterobckare)aHeqat eB l xHmnmancg cemyc l rmkeday kKN³kmaFkarCaterobckare)aHeqat GacseRmcedayk)agmx )anEdr
- y l eX j fa eQaHEd l )anbg[ l bec j BbBae)aHeqatdbg sTEtmaneQaHkgbBa e)aHeqatcgeRkay RsbtammaRta 54f cNc {K} énc,absBvesaFnkmc,ab sBkar e)aHeqateRCstagtNagra®s

- yleXjfa tamkarcHRsavRCavrbstNagRkmRbkSaFmnBa )anrkeXjfa BIrd cnn 46nak enAX)ae)ag RskBamrk extéRBEvg Rtv)anRkmRbkSaXIbecj BbBa e)aHeqatdbg edaysarxHsab xH)anpasTI enA ehtenHB IrdTagenaHKrIbeQaH ecj BbBae)aHeqatdbg ¬dckg]bsmnénesckIseRmcenH¦
- ylejfa karbBaakGBFatBténGtsBaaNrbsbKINamak mnEmnCasmtkc rbsRkmRbkSaFmnBaeT.

# seRmc

## ceBaHmxKPaKI

maRta 1- TTIBaküBNgrbseIak Bm sNag cHéfTI 17 Ex vcka qa2006 TkCaRtmRtv tam TRmgc,ab ng bdesFeca ledaysngKtc,ab .

maRta 2-tmlesckIseRmcrbsKN³kmaFkarCaterobckare)aHeqatcHéfTI 13Ex vcka qa2006 Ed lseRmcbdesFbNgelx 0010¼06 k>T>d>b cHéfTI10 Ex vcka qa2006 .

maRta 3- esckIseRmcenH RbkasnasvnakarCasaFarN³ enAraCFanIPeBjéfTI 25 Ex vcka qa2006 CaesckIseRmcsaBr bTpvtvaehymanGanPaBGnvteTAelIGNacTagGs Ed lmanEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanIPeBj éfTI 25 Ex vcka qa 2006
C>RkmRbkSaFmnBa ng C>RkmRbkSaCnCRmH
RbFan

bn Qn

RBHraCaNacRkkmCa

RkmRbkSaFmnBa Cat sasna RBHmhakSRt

]bsmnénescklseRmc

elx ³ 087¼014¼2006 kbF>c

cHéfTI 25 Ex vcika qa2006

karyal y 0528

| l>r | eQaH | ePT | éf Ex qakeNIt | elxbNbganéd | epSg² |
|---|---|---|---|---|---|
| 433 | evog yagsg | Rbs | 1955 | 8>863>252 | |

karyal y 0532

| l>r | eQaH | ePT | éf Ex qakeNIt | elxbNbganéd | epSg² |
|---|---|---|---|---|---|
| 337 | evog Fy | Rsl | 1940 | R 1>627>638 | |
| 338 | evog Fl lg | Rsl | 1981 | R 1>627>635 | |
| 339 | evog FEv | Rsl | 1983 | R 1>627>630 | |
| 340 | evog yagKg | Rbs | 1985 | R 1>627>631 | |
| 341 | evog yagej | Rbs | 1983 | R 1>627>639 | |
| 342 | evog yagtg | Rbs | 1985 | R 1>627>632 | |

karyal y 0533

| l>r | eQaH | ePT | éf Ex qakeNIt | elxbNbganéd | epSg² |
|---|---|---|---|---|---|
| 81 | cag yagGg | Rbs | 1977 | R 1>627>785 | |
| 95 | eC0g yagP | Rbs | 1958 | 8>863>119 | |
| 117 | dag yagebn | Rbs | 1939 | R 1>627>780 | |
| 122 | Dn Fekl | Rsl | 1956 | 4>578>931 | |
| 125 | Dn Feh0g | Rsl | 1958 | 4>578>994 | |
| 128 | Dn yagvag | Rbs | 1949 | R 1>627>778 | |
| 139 | Rtg yagEs | Rbs | 1960 | 4>578>954 | |

| | | | | | |
|---|---|---|---|---|---|
| 140 | Rtg yageh0g | Rbs | 1925 | 4›578›955 | |
| 142 | fam p l a | Rsl | 1973 | 4›578›013 | |
| 169 | nl eRsg | Rbs | 1937 | 4›578›826 | |
| 200 | pam ehg l l | Rbs | 1953 | 4›578›936 | |
| 258 | y Fdv | Rsl | 1950 | 4›578›025 | |
| 260 | y Fhay | Rsl | 1951 | 4›578›917 | |
| 274 | yl yagPk | Rbs | 1977 | R 1›627›706 | |
| 315 | evog Fdam | Rsl | 1965 | 4›578›977 | |
| 317 | evog Fet0g | Rsl | 1950 | 4›579›034 | |
| 321 | evog Fenok | Rsl | 1984 | R 1›627›787 | |
| 324 | evog F l | Rsl | 1943 | 4›578›930 | |
| 328 | evog FLag | Rsl | 1960 | 4›578›937 | |
| 335 | evog yagK | Rbs | 1981 | R 1›627›793 | |
| 344 | evog yagbn | Rbs | 1975 | 4›578›985 | |
| 345 | evog yagebon | Rbs | 1982 | R 1›627›786 | |
| 346 | evog yag)ag | Rbs | 1926 | R 1›627›701 | |
| 350 | evog yagvan | Rbs | 1928 | R 1›627›783 | |
| 352 | evog yagvg | Rbs | 1935 | 4›578›979 | |
| 469 | eL yagdag | Rbs | 1985 | R 1›627›784 | |

karyal y 0534

| l›r | eQaH | ePT | éf Ex qakeNIt | e l xbNbganéd | epSg² |
|---|---|---|---|---|---|
| 38 | egog yagekn | Rbs | 1950 | R 1›627›891 | |
| 39 | egog yagh | Rbs | 1948 | R 1›627›897 | |
| 51 | cag FN | Rsl | 1980 | R 1›627›944 | |
| 54 | cag Fva | Rsl | 1979 | R 1›627›943 | |
| 55 | cag Fslv | Rsl | 1982 | R 1›627›945 | |
| 68 | Cam yagRcg | Rbs | 1943 | R 1›627›913 | |
| 71 | eC0g yagfr | Rbs | 1940 | 4›579›365 | |

| | | | | | |
|---|---|---|---|---|---|
| 105 | d yagsx | Rbs | 1976 | R 1›627›904 | |
| 156 | by Fek0g | Rsl | 1958 | R 1›627›903 | |
| 172 | pam yagRcg | Rbs | 1944 | R 1›627›858 | |
| 263 | vn yaghn | Rbs | 1926 | R 1›627›899 | |
| 265 | evog CCg | Rsl | 1947 | R 1›627›892 | |
| 352 | eL Fey | Rsl | 1961 | 4›579›250 | |

RBHraCaNacRkkmCa
Cati sasna RBHmhakSRt
3



RkmRbkSaFmnBa
3
sNer0g
elx ³113¼013¼2006
cHéfT 16 Ex vcka qa 2006
esckþsþeRmc
elx ³088¼015¼2006 kbF>c
cHéfT 12 Ex F qa 2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkmelx Cs¼rkm¼0498¼06 cHéfT08 Ex emsa qa1998 Rbkas[eRbI c,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkmelx ns¼rkm¼0196¼27 cHéfT 26 Exmkra qa 1996 Rbkas[eRbI c,absBkarerobc ngkarRbRBteTAénFnaKarCaténkmCa
- )aneXIj lxtelx 1241 rs cHéfT 16 Ex vcka qa 2006 rbssemc ehg srn RbFanrdsPaesIseGayRkmRbkSaFmnBaBntüFmnBaPaBc,absBvesaFnkmmaRta 14 ng maRta 57 énc,absBkarerobc ngkarRbRBteTAénFnaKarCaténkmCa Edl GKelxaFkardan RkmRbkSaFmnBa)anTTlenAéfT 16 Ex vcka qa 2006 evlaemag 15 ng 40 naT
eRkayB)ansabr)aykarNrbssmaCkraykarN
eRkayB)anBPakSaRtmRtvtamc,abehIy
- ylXIjfa seNIrbssemc ehg srn RbFanrdsPa Rsbngmarta 140 fI énrdFmnBa ng maRta 16 énc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa decHRkmRbkSa FmnBaGacTTlykseNIenHmkBntü)an.
- ylXIjfa maRta 14 Rtv)aneFIvesaFnkmeTACamaRta 14 fI edayRKanEtlbBakü {Et 1 dgKt} kgXaT 2 cNcT 1 .

- ylEXjfa maRta 57 Rtv)aneFVesaFnkmeTACamaRta 57 f edayRKanEtEksRmlB {edayKN³kmμkarBisesSmYyEdlEtgtaMgedayraCrdaPi)al } mk { edayRksYgRbBk½SaPi)al FnaKarCatiénkmBuCa nigGaCJaFrsvnkmμCati }.

kareFVesaFnkmxageleniH BmanGnumnRsbnwgrdæFmμnuBa enaHeT .

## seRmc

maRta 1- c,absBIvesaFnkmmaRta14 ngmaRta57 énc,absBIkarerobc ngkarRbRBwtþeTAénFnaKarCati énkmBuCaEdlrdæsPa)anGnumtkalBIéf¶TI 17 Ex tula qñaM 2006 nasmyRbCMrdæsPaelIkTI 5 nItikalTI 3 ehIyEdlRBwT§sPa )anGnumtyl;RsbTaMgRsug kalBIéf¶TI 13 Ex vicäika qñaM 2006 nasmyRbCMRBwT§sPaelIkTI 2 nItikalTI 2 Rtv)anRbkasfa RsbnwgrdæFmμnuBa .

maRta 2- esckþIseRmcenH eFVenArajFanIPñeBj éf¶TI 12 Ex FñÚ qñaM 2006 nasmyRbCMeBjGgÁén RkmRbwkSaFmμnuBa CaesckþIseRmcsaBr bTpþvtþa ehIyminGacPaBGnuvtþeTAelIGNacTaMgGsEdlmanEcgkñgrdæFmμnuBa ng RtvcuHpSaykñgraCkic© .

raCFanIPñeBj éf¶TI 12 Ex FñÚ qñaM 2006
C>RkmRbwkSaFmμnuBa
RbFan

bi Qin

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3

RkmRbkSaFmnBa

3

sNer0g

e l x ³ 118¼018¼2006

cHéfTI 24 Ex vcka qa2006

esckIseRmc

e l x ³ 089¼016¼2006 kbF>c

cHéfTI 13 Ex F qa2006

RkmRbkSaFmnBa

- )aneXIj rdFmnBaénRBHraCaNacRkkmCa
- )aneXIj RBHraCRkme l x Cs¼rkm¼0498¼06 cHéfTI 08 Ex emsa qa1998 Rbkas [eRbIc,absBIkarerobc ng karRbRBteTAénRkmRbkSaFmnBa
- )aneXIj RBHraCRkme l x ns¼rkm¼1006¼025 cHéfTI 21 Ex t l a qa2006 Rbkas [eRbIc,absBI l knk³tNagra®s
- )aneXIj l xt e l x sq¼06¼99 cHéfTI 24 Ex vcka qa2006 rbstNagra®s cnn 14 rb esIsmBntümaRta 4 énc,absBI l knk³tNagra®s edm,eFIkarRbkasfa mnRsb ngrdFmnBa Ed l GKe l xaFkardanRkmRbkSaFmnBa )anTT l enAéfTI 24 Ex vcka qa2006 ev l aemag 09 ³ 30 naTI

  eRkayB)ansabr)aykarNIrbss maCkraykarN eRkayB)anBPakSaR tmRtvtamc,abehIy

- y l eXIj fa kmvtén l xtrbstNagra®s cnn 14 rb manxmsarbgabbBaa BeRBaHeRbI Bakü fa{ *smBntümaRta 4énc,absB l knk³tNagra®s edm,eFkarRbkasfamnRsbng rdFmnBa*}

- yleXjfa kareyagmaRta 140 fénrdFmnBaenAkglxtelx sq¼06¼99 cHéfT 24 Ex vcka qa2006rbstNagra®s cnn 14 rb mnRtmRtv BeRBaHc,absBlknk³tNag-ra®s Rtv)anRbkas [eRbedayRBHraCRkmelxns¼rkm¼1006¼025 cHéfT 21 Ex tla qa2006 rceTAehIy
- ylyeXjfa xmsarénlxtelxsq¼06¼99 cHéfT 24 Ex vcka qa2006 rbstNag-ra®s cnn 14 rb )anEfgfa {»eyg´)aneXjnvcemyrbsRkmRbkSaFmnBa cHéfT 10 Ex vcka qa2006 BakBnngmaRta 5énc,abenHrcehIy edayRkmRbkSaFmnBa)aneqIy bBaakfamaRta 5enaHBmanGFmnBaPaBeT . eyg´mankaresaksay Ed lRkmRbkSaB)an BntüvxmsarénmaRta 4 pgEd lmaRtaenHbgajmnGacRbEkk)annvGFmnBaPaB . eRBaH vaman lkN³gayylCag} . CaeKa lkarNngtamytsaRsrbsxntagBqa1998 mk RkmRbkSaFmnBamnGacykbBaaNamymkBntüedayxnÉg)aneLIy lHRtaEtmankar esIsB\sSrCn dcmanEcgkgmaRta 140 f maRta 141 fvaküxNT 1 énrdFmnBa bRbCara®sdcmanEcgkgmaRta 141 fvaküxNT 2énrdFmnBaeTbRkmRbkSaFmnBaBntü
- ylyeXjfa febmanbBaaxH RkmRbkSaFmnBaGacykseNrbstNagra®s cnn 14 rb mkBntüenAkgRkbxNénmaRta 141 fénrdFmnBa ng maRta 18 énc,absBkarerobcng karRbRBteTAénRkmRbkSaFmnBa Ed lRbkas [eRbedayRBHraCRkmelx Cs¼rkm¼0498¼06 cHéfT 08 Ex emsa qa1998
- ylyeXjfa GPyÉksTsPa mnEmnCaÉksTrbstNagra®seT bEnCakarFanamyplCnrdsPa edm,[karRbRBteTArbsxnmanRbsTPaB lngKan]bsK . eplmecjBGPy-ÉksTp lCnrdsPaenH smaCkmak²rbsrdsPamnRtv)aneKecaTRbkan Xatxn cabxn b XxnCadacxat edaysarkarbeBajmt b kae)aHeqatTagLaykgeB lbeBjmxgar rbsxnenArdsPa . bEn karrcptBkarTT lxsRtvenH kmanRBEdnkNtEdr KGeB b sdxsqgTagLayrbssmaCkrdsPangGacRtv)anpnaeTasEpkvnyedayrdsPa dc manEcgkgbTbBaaépkgrbsrdsPa
- ylyeXjfa eRkABeB lbeBjmxgarrbsxnenArdsPa tNagra®smak²ngGacRtv)aneK ecaTRbkan Xatxn cabxnbXxneTAekt lHRtaEtmankaryl RBmBrdsPab KN³-kmaFkarGcé®nyrbsrdsPa kgcenaHsmyRbCénrdsPa evorE l gEtkgkrNbTe l s RBhTNCakEsg . kgkrNxageRkayenH Rksgmansmtkc Rtv eFesckr aykarN CnrdsPa b CnKN³kmaFkarGcé®nyrbsrdsPa Cabnanedm,seRmc . esckseRmc

rbsKN³kmaFkarGcé®nyrbsrdsPa RtvdakCnsmyRbCrdsPaxagmx edm,IGnmt

- yleXIjfa karseRmcBürGPyÉksTsPaBItNagra®sbkarseRmcRbKl[vjnvGPy ÉksTsPadl tNagra®s CasmtkcrbsrdsPa

- ylexIjfa bTbBatkgcNcTI 1 ng cNcTI 2 énmaRta 4 énc,absBIlknk³tNagra®s manEcgGBIGPyÉksTrbstNagra®s Ed ltamkarBitCaGPyÉksTrbsrdsPaeT .

## seRmc

maRta 1- Epktamm lbTxage ll maRta4 énc,absBIlknk³tNagra®s Ed lRbkas[eRbeday RBHraCRkmel xns¼rkm¼1006¼025 cHéfTI21 Ex tlaqa2006 BmanGFmnBaPaBeT .

maRta 2- esckIseRmcenH eFIenAraCFanIPeB jéfTI 13 Ex F qa2006 nasmyRbCeB j Ggén RkmRbkSaFmnBa CaescksIseRmcsaBr bTpvtva ehIymanGanPaBGnvteTAel IGNac TagGsEd lmanEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanIPeB jéfTI 13 Ex F qa 2006

C>RkmRbkSaFmnBa

RbFan

bn Qn

RBHraCaNacRkkmCa

Cati sasna RBHmhakSRt

3



RkmRbkSaFmnBa

3

sNer0g

e l x 3 130¼002¼2007

cHéfT 02 Ex mkra qa2007

esckþseRmc

e l x 3 090¼001¼2007 kbF›c

cHéfT 05 Ex mkra qa 2007

RkmRbkSaFmnBa

- )aneXl j rdFmnBaénRBHraCaNacRkkmCa
- )aneXl j RBHraCRkme l x Cs¼rkm¼0498¼06 cHéfT 08 Ex emsa qa1998 Rbkas [ eRbIc,absBkarerobc ng karRbRBtþeTAénRkmRbkSaFmnBa
- )aneXl j RBHraCRkme l x ns¼rkm¼0902¼017 cHéfT 17 Ex kBaa qa2002 Rbkas [ eRbIc,absBvesaFnkmc,absBkare)aHeqatþeRCIstagtNagra®s
- )aneXl j l xte l x 002 rs cHéfT 29 Ex F qa2006 rbsÉk]tm gn j l RbFanrdsPasTI esÞs [ RkmRbkSaFmnBaBntüFmnBaPaBe l IGtbTc,absBvesaFnkm c,absBkarerobc ng karRbRBtþeTAénRkmRbkSaFmnBa Ed l rdsPa)anGnmtþenAéfT 27 Ex vcka qa2006 nasmyRbCrdsPae l IkT5 ntka l T3 ehyRBTsPa)anBntü ng [eyab l edayÉkPaBTagRsgtamTRmg ng KtþénGtbTc,abenH edayy\tEkERbkg smyRbCeB j GgRBTsPae l IkT 2 ntka l T 2 naéfT 25 Ex F qa2006 Ed l GKe l xaFkardanRkmRbkSaFmnBa )anTT l enAéfT 02 Ex mkra qa 2007 ev l aemag 15³30 naT .

eRkayB)ansabr)aykarNrbss maCkraykarN

eRkayB)anBPakSaRtmRtvtamc,abehIy

- yl eXIj fa rdsPa ng RBTsPa)anGnvtyagRtmRtvtamEbbbT Ed l manEcgkg maRta 113 f énrdFmnBa kgkarBntüngGnmtc,absBvesaFnkmc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa
- yl eXIj fa seNIrbsÉk]tm gn j l RbFanrdsPasT RsbngmaRta 140 f vaküxNT2énrdFmnBa ngmaRta16énc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa Ed l Rbkas [eRbedayRBHraCRkme l x Cs¼rkm¼0498¼06 cHéfT 08 Ex emsa qa1998
- yl eXIj fa TRmgénkartakEtgc,absBvesaFnkmc,absBkarerobc ng karRbRBteTA énRkmRbkSaFmnBa BmanGIxsngrdFmnBaeT
- yl eXIj fa RKbbTb,BatkgmaRtaEtmyénc,absBvesaFnkmc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa mnmancNcNaEd l GaccatTkfa mnRsbng rdFmnBaeT .

# seRmc

maRta 1- c,absBvesaFnkmc,absBkarerobc ng karRbRBteTAénRkmRbkSaFmnBa Ed l rdsPa )anGnmtenAéfT 27 Ex vcka qa 2006 nasmyRbCrdsPae l kT5 ntka l T3 ehy RBTsPa)anBntüng [eyab l edayÉkPaBTagRsgtamTRmg ng KténGtbTc,abenH edayv\tEkERbkgsmyRbCeB j GgRBTsPae l kT 2 ntka l T 2 naéfT 25 Ex F qa2006 Rtv)anRbkasfa RsbngrdFmnBa .

maRta 2- esckIseRmcenHeFenAraCFanIPeB j éfT 05 Ex mkra qa2007 nasmyRbCeB j Ggén RkmRbkSaFmnBa CaesckIseRmcsaBr bTpvtva ehymanGanPaBGnvteTAe l GNac TagGsEd l manEcgkgrdFmnBa ng RtvcHpSaykgraCkc .

raCFanIPeB j éfT 05 Ex mkra qa 2007
C>RkmRbkSaFmnBa
RbFan

bn Qn

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៣១ /00៣ /២00៧

ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២00៧

**សេចក្តីសម្រេច**

លេខ :0៩២/00៣/២00៧ កបធ.ច

ចុះថ្ងៃទី ១0 ខែ កក្កដា ឆ្នាំ ២00៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0៤៩៨/0៦ ចុះថ្ងៃទី 0៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១0៧/00៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជសារ ចុះថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ ២00៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២00៧ វេលាម៉ោង ១៤ និង ៣0 នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ ២00៧ បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

- យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា " ចំពោះបទឧក្រិដ្ឋ និង បទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរង

ទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តា មាត្រាមុនៗក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន ” ។

- យល់ឃើញថា មាត្រា ៨ នេះ កែប្រែតែមាត្រា ៧០ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល **ពុំមានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កុមារឡើយ** ។ បទបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ខាងលើនេះ ពុំមានអធម្មនុញ្ញភាពទេ ។
- យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់ ។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## សម្រេច

**មាត្រា ១.-** មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៣៣/០០៥/២០០៧

ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**សេចក្តីសម្រេច**

លេខ : ០៩៣/០០៤/២០០៧ កបធ.ច

ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ សម្រេចលុបឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៃឃុំរកាកោងទី១ ស្រុក មុខកំពូល ខេត្តកណ្តាល ( ដូចមានបញ្ជីរាយនាមភ្ជាប់ជាមួយ )

- បានឃើញពាក្យបណ្តឹងរបស់លោក **អោទ គឹមលាទ** ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅការិយាល័យលេខ ០៦៥៤ ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ០៨:៣០ នាទី
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់លោក **អោទ គឹមលាទ** សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១០:៣០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក **អោទ គឹមលាទ** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា តាមគោលការណ៍នៃច្បាប់ ម្ចាស់បណ្តឹងមានសិទ្ធិសុំដកពាក្យបណ្តឹងរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកបានគ្រប់ពេលវេលាទាំងអស់នៃនីតិវិធី ។

## សម្រេច

**មាត្រា ១.** ~ ទទួលពាក្យបណ្តឹងរបស់លោក **អោទ គឹមលាទ** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.** ~ តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅការិយាល័យលេខ ០៦៥៤ ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** ~ សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៣៤/០០៦/២០០៧

ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**សេចក្តីសម្រេច**

លេខ : ០៩៤/០០៥/២០០៧ កបធ.ច

ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលឱ្យឃុំព្រែកជ្រៃរក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ១.៣៣១ នាក់ និង នៅឃុំសំពៅពូនរក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ៧០២ នាក់
- បានឃើញពាក្យបណ្តឹងរបស់លោក **ឡុង លឹមហ៊ា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ ប្តឹងទាម-ទារសុំឱ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន ២.០៣៣ នាក់ និង សុំបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម **អ៊ឹម សួស្តី** នាថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ ( តាមពិតគឺឆ្នាំ២០០៧ ) ដែលអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១០:៤៥ នាទី
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសម រង្ស៊ី ផ្ទេរសិទ្ធិជូនលោក **ឡុង លឹមហ៊ា** ជាតំណាងគណបក្សសមរង្ស៊ី ដើម្បីដាក់ពាក្យបណ្តឹង និង ចូលរួមសវនាការជំនួសនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៣៨/០៧ គ.ជ.ប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧ ឧទ្ទេសនាមសមាជិក និងមន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមក្នុងសវនាការជំនុំជម្រះជាសាធារណៈនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុស៊ើបអង្កេតនៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧
- បានឃើញកំណត់ហេតុស៊ើបអង្កេតនៅឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ឡុង លឹមហ៊ា** កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **ឡុង លឹមហ៊ា** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា ៦៤ ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី៣ មាត្រា ២៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

បណ្ដឹងរបស់លោក **ឡុង លីមហ៊ា** បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន ទោះបីមានការខ្វះខាតនៅក្នុងកម្មវត្ថុនៃពាក្យបណ្ដឹង ដោយដាក់កាលបរិច្ឆេទនៃសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ តាមពិតគឺ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

- យល់ឃើញថា នៅក្នុងពាក្យបណ្ដឹង ក៏ដូចជាការឆ្លើយបំភ្លឺនៅពេលសាកសួរចម្លើយ លោក **ឡុង លីមហ៊ា** បានទាមទារសុំឱ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន ២.០៣៣ នាក់ ដោយសំអាងថា អ្នកទាំងនោះ ជាជនអន្តោប្រវេសន៍ខុសច្បាប់ ដែលមករស់នៅប្រទេសកម្ពុជា ដោយគ្មានច្បាប់អនុញ្ញាត ពុំមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គ្មានសៀវភៅស្នាក់នៅ មានតែប័ណ្ណស្នាក់នៅតែមួយគត់ ហើយជនជាតិវៀតណាមមួយចំនួនរស់នៅលើដីវៀតណាម នៅពេលបោះឆ្នោតពួកគេមកចូលរួមបោះឆ្នោត ។ នៅក្នុងពេលសវនាការជំនុំជម្រះ លោក **ឡុង លីមហ៊ា** ឆ្លើយបញ្ជាក់ថា ពុំមានភស្តុតាងជាលាយលក្ខអក្សរទេ ប៉ុន្តែគ្រាន់តែសង្កេតផ្ទាល់ឃើញថា ជនទាំងនោះ ជាជនវៀតណាម និយាយភាសាវៀតណាម របៀបរស់នៅជាវៀតណាម
- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះនិងការឆ្លើយបំភ្លឺនៅពេលសាកសួរចម្លើយ ឯកឧត្ដម **មាន សទិ** ឯកឧត្ដម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ថា ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចបដិសេធពាក្យបណ្ដឹងរបស់លោក **ឡុង លីមហ៊ា** ហើយរក្សាទុកឈ្មោះជនទាំង ២.០៣៣ នាក់ គឺសំអាងលើមូលហេតុបី :
  - ១- អ្នកប្ដឹងគ្មានភស្តុតាង ។ អ្នកប្ដឹងមិនមានភស្តុតាង តាមការតម្រូវរបស់មាត្រា ៦៤ ថ្មី នៃច្បាប់បោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ
  - ២- មេឃុំ និង មេប៉ុស្តិ៍ បានបញ្ជាក់ថា នៅពេលធ្វើបញ្ជីស្រង់ឈ្មោះជនអន្តោប្រវេសន៍បញ្ជូនមកក្រសួងមហាផ្ទៃ ជនទាំង ២.០៣៣ នាក់នេះ ពុំមានឈ្មោះនៅក្នុងបញ្ជីជនអន្តោ-ប្រវេសន៍ទេ ។
  - ៣- សៀវភៅស្នាក់នៅរបស់អ្នកដែលគេត្រូវប្ដឹងបានបញ្ជាក់ថា មានសញ្ជាតិខ្មែរ ។ អ្នកទាំងនោះមានទីលំនៅជាយូរមកហើយ និង មានដីធ្វើស្រែ ចំការ ។
- យល់ឃើញថា លោក **ឡុង លីមហ៊ា** ពុំមានភស្តុតាងដើម្បីសុំលុបឈ្មោះទាំង ២.០៣៣ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង ចំណែកឯការអះអាងរបស់សាមីខ្លួនពុំមានមូលដ្ឋានគតិយុត្តិឡើយ
- យល់ឃើញថា ការលើកឡើងរបស់ឯកឧត្ដម **មាន សទិ** និង ឯកឧត្ដម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលចង្អុលទៅលើមាត្រា ៦៤ ថ្មីនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មានទម្ងន់ខាងផ្លូវច្បាប់ ដែលអាចយកជាការបាន

-យល់ឃើញថា តាមការស្រាវជ្រាវរបស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញ នៅឯឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្ដាល ប្រជាពលរដ្ឋ ចំនួន ១.៣៣១ នាក់ និង នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ប្រជាពលរដ្ឋ ចំនួន ៧០២ នាក់ ដែលលោក **ឡុង លឹមហ៊ា** ប្ដឹងទាមទារសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង សុទ្ធតែមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ស្របតាមមាត្រា ៥៤ ថ្មី ចំណុច "គ" នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-យល់ឃើញថា បញ្ជីឈ្មោះដែលលោក **ឡុង លឹមហ៊ា** ប្ដឹងទាមទារសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង នៅឃុំព្រែកជ្រៃ និង នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល តាមការស៊ើបសួរដល់មូលដ្ឋានឃុំព្រែកជ្រៃ និង ឃុំសំពៅពូន របស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញ និង តាមការផ្ទៀងផ្ទាត់របស់នាយកដ្ឋានជំនាញ ដោយពិនិត្យទៅលើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីឆ្នាំ២០០៦ មានការអះអាងប្រហាក់ប្រហែលគ្នាថា គឺមានឈ្មោះមួយចំនួនធំ ឬ ស្ទើរតែទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះ ដែលលោក **ឡុច រិទ្ធី** បានដាក់ពាក្យបណ្ដឹងចុះថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នៅឃុំព្រែកជ្រៃ និង នៅឃុំសំពៅពូន មានពាក្យបណ្ដឹងរបស់លោក **ឌីណា សាគុណា** ចុះថ្ងៃទី ១៦ ខែ វិច្ឆិកាឆ្នាំ ២០០៦ ដែលក្រុមប្រឹក្សាធម្មនុញ្ញ ធ្លាប់បានពិនិត្យ និង សម្រេចរួចហើយ គឺ ÷

- ករណីឃុំព្រែកជ្រៃ តាមសេចក្ដីសម្រេចលេខ ០៨៦/០១៣/២០០៦ កបធ.ច ចុះថ្ងៃទី ២៥ ខែវិច្ឆិកាឆ្នាំ២០០៦ គឺតម្កល់សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។
- ករណីនៅឃុំសំពៅពូន តាមសេចក្ដីសម្រេចលេខ ០៨៤/០១១/២០០៦កបធ.ច ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ គឺតម្កល់សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប៉ុន្តែតម្រូវឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លុបឈ្មោះប្រជាពល-រដ្ឋ ចំនួន ០២នាក់ដែលបានស្លាប់ និង ប្រជាពលរដ្ឋ ចំនួន ២៦ នាក់ បានផ្លាស់ប្ដូរទីលំនៅ នៅឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប ក្នុងចំណោមពលរដ្ឋដែលសុំលុបឈ្មោះ ចំនួន ៧៦៣ នាក់ ។ ចំណែកករណីនៅឃុំសំពៅពូន រក្សាទុកដដែល ។

-យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ

## **សម្រេច**

**មាត្រា ១.** ~ ទទួលពាក្យបណ្ដឹងរបស់លោក **ឡុង លឹមហ៊ា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្ដែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** ~ តម្កល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលសម្រេច ៖

១-ឃុំព្រែកជ្រៃ រក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ១.៣៣១ នាក់

២-ឃុំសំពៅពូន រក្សាឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ចំនួន ៧០២ នាក់

ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** ~ សេចក្ដីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :  ១៣៥/00៧/២00៧

ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២00៧

**សេចក្តីសម្រេច**

លេខ : 0៩៥/00៦/២00៧ កបធ.ច

ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២00៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0៤៩៨/0៦ ចុះថ្ងៃទី0៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១0៧/00៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/0៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៩0២/0១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២00២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៦0៦/0១៩ ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២00៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១0៧/00៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដែលបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់គីឡូម៉ែត្រលេខ៦ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ចោលជាអាសារបង់ និង លុបឈ្មោះអ្នកបោះឆ្នោត ចំនួន ៣.២៤៤នាក់ ចេញបញ្ជីបោះឆ្នោតដំបូង សង្កាត់គីឡូម៉ែត្រលេខ៦
- បានឃើញពាក្យបណ្តឹងរបស់លោក **លី សុវិជ្ជា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ប្តឹងតវ៉ាឱ្យរក្សាឈ្មោះប្រជាពលរដ្ឋខ្មែរ ចំនួន ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងនៃសង្កាត់ គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១៦:៣៥ នាទី
- បានឃើញលិខិតប្រគល់សិទ្ធិជូនលោក **លី សុវិជ្ជា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ប្រជាពលរដ្ឋ ចំនួន ១៤ នាក់ ដែលអះអាងថា ជាតំណាងប្រជាពលរដ្ឋ ចំនួន ៣.២៤៤ នាក់ ហើយដែលត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចលុបឈ្មោះ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៣៩/០៧ គ.ជ.ប ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧទ្ទេសនាមសមាជិក និង មន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមក្នុងសវនាការជំនុំជម្រះជាសាធារណៈនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុចុះស៊ើបអង្កេតនៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **លី សុវិជ្ជា** កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៧
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី សាក្សី និង អ្នកពាក់ព័ន្ធក្នុងការបោះឆ្នោត**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **លី សុវិជ្ជា** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង ។ យោងតាមមាត្រា ៦៤ ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី៣ មាត្រា ២៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងរបស់លោក **លី សុវិជ្ជា** បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅក្នុងពាក្យបណ្តឹង ក៏ដូចជាការឆ្លើយបំភ្លឺនៅពេលសាកសួរយកចម្លើយ លោក **លី សុវិជ្ជា** បានលើកឡើងថា ៖

១-ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំបានឈរលើមូលដ្ឋានភស្តុតាងច្បាស់លាស់ឡើយ គឺគ្រាន់តែសម្រេចតាមបញ្ជីរាយនាមដែលស្រង់ដោយមេភូមិ និង ការអះអាងរបស់ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់

២-ការស្រង់បញ្ជីរបស់មេភូមិ និង ការអះអាងរបស់ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ ផ្ទុយនឹងសេចក្តីណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីព្រោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការសម្អាតបញ្ជី និងការចុះឈ្មោះបោះឆ្នោត មិនបានប្រតិភូកម្មឱ្យប្រធានភូមិ ឬ ប្រធានប៉ុស្តិ៍ទេ ។

-យល់ឃើញថា នៅពេលសវនាការជំនុំជម្រះលោក **លី សុវិជ្ជា** សុំឱ្យរក្សាទុកឈ្មោះប្រជាពលរដ្ឋទាំង ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតវិញ

-យល់ឃើញថា នៅពេលសាកសួរយកចម្លើយលោក **លី សុវិជ្ជា** មិនអាចកំណត់បានថា ប្រជាពលរដ្ឋទាំង ៣.២៤៤នាក់ ពិតជាមានទីលំនៅអចិន្ត្រៃយ៍នៅសង្កាត់គីឡូម៉ែត្រលេខ៦ ។ លោក **លី សុវិជ្ជា** មិនអាចកំណត់បានថា ប្រជាពលរដ្ឋដែលមានទីលំនៅអចិន្ត្រៃយ៍មានប៉ុន្មានភាគរយ ឬ ប្រជាពលរដ្ឋប៉ុន្មានភាគរយ ដែលពុំមានទីលំនៅជាអចិន្ត្រៃយ៍ ។ លោកបានបញ្ជាក់ថា គឺមានតែអាជ្ញាធរមូលដ្ឋានអាចបញ្ជាក់ពីបញ្ហានេះបាន

-យល់ឃើញថា ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ បានសំណូមពរឱ្យលោក **លី សុវិជ្ជា** សហការជាមួយតំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចុះទៅបណ្តាភូមិទាំង ០៣ ក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ដើម្បីអង្កេតតាមវិធី Random Check ទៅលើប្រជាពលរដ្ឋមួយចំនួនក្នុងចំណោមប្រជាពលរដ្ឋ ចំនួន ៣.២៤៤ នាក់ តាមតំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញចង្អុលឈ្មោះ ប៉ុន្តែលោក **លី សុវិជ្ជា** បានអះអាងថា អាចជូនតំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅជួបបានតែមនុស្ស ចំនួន ១៤ នាក់ ដែលបានផ្ទេរសិទ្ធិឱ្យលោកធ្វើជាតំណាង និង ឈ្មោះចំនួន ៣៦ នាក់ ទៀតតែប៉ុណ្ណោះ

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **សុខ សម្បត្តិ** ចៅសង្កាត់គីឡូម៉ែត្រលេខ៦ និងជាសាក្សីរបស់លោក **លី សុវិជ្ជា** បានបញ្ជាក់ថា ខ្ញុំសុំនិយាយតែពីរឿងជាក់ស្តែងដែលមានឯកសារភ្ជាប់មកជាមួយ ឈ្មោះដែលមានក្នុងបញ្ជីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៧ តែពេលវេលាមិនអាចឱ្យខ្ញុំស្រាវជ្រាវបាន នៅសង្កាត់ខ្ញុំពុំមានតែប៉ុណ្ណឹងទេ មានលើសពីហ្នឹងទៅទៀត

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **សុខ ឃឹម** ចៅសង្កាត់រងគីឡូម៉ែត្រលេខ៦ និងជាសាក្សីរបស់លោក **លី សុវិជ្ជា** បានបញ្ជាក់ថា ខ្ញុំចូលមកធ្វើសាក្សីនេះ ដើម្បីការពារទុកឈ្មោះប្រជាពលរដ្ឋទាំង ៣.២៤៤ នាក់ ទុកក្នុងបញ្ជីបោះឆ្នោត

-យល់ឃើញថា ការឆ្លើយបំភ្លឺនៅពេលសាកសួរចម្លើយ ក៏ដូចជានៅក្នុងសវនាការជំនុំជម្រះ ឯកឧត្តម **ឯម សូផាត** ឯកឧត្តម **ឃ្លោក ប៊ុតឌី** និង លោក **កែវ ផល្លា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ថា ÷

១-ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានមូលដ្ឋានច្បាស់លាស់ក្នុងការកាត់សេចក្តី ពីព្រោះការស្នាក់នៅរបស់ប្រជាពលរដ្ឋ គឺជាសមត្ថកិច្ចរបស់នគរបាលប៉ុស្តិ៍ ហើយការបញ្ជាក់របស់ប៉ូលីសប៉ុស្តិ៍បង្ហាញថា ពលរដ្ឋទាំងនោះពុំបានរស់នៅក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ទេ ។ ម្យ៉ាងវិញទៀត ក្នុងសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ គ្មានលើកភស្តុតាងណាមួយជូនក្រុមប្រឹក្សាជំនុំជម្រះនៃគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត លោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ សម្អាងត្រឹមថា នីតិវិធីឈ្មោះនៅក្នុងបញ្ជីចុងក្រោយមិនអាចលុបបាន ។ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សួរលោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ ថា មានបានចុះទៅធ្វើការអង្កេតទេ លោកចៅសង្កាត់គីឡូម៉ែត្រលេខ៦ បានឆ្លើយថា អត់បានចុះទៅអង្កេតទេ ។ តាមការស្រាវជ្រាវរបស់ក្រុមការងារទៅលើឈ្មោះពលរដ្ឋ ២០ នាក់ តាមវិធី Random Check ដើម្បីឱ្យច្បាស់ថា ការរាយការណ៍របស់ប៉ូលីសប៉ុស្តិ៍ត្រឹមត្រូវឬទេ ? ជាលទ្ធផលបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋ ២០ នាក់នេះ ពុំមានទីលំនៅក្នុងសង្កាត់គីឡូម៉ែត្រលេខ៦ ប្រាកដមែន ។

២-ចំពោះបញ្ជីរាយនាមដែលស្រង់ដោយលោកមេភូមិ និង មានហត្ថលេខារបស់លោកមេភូមិ លោកអនុប្រធានភូមិ និង លោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាល គីឡូម៉ែត្រលេខ៦ គឺជាភស្តុតាងដែលដើមចោទផ្តល់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមការតម្រូវរបស់មាត្រា ៦៤ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ អំពីបញ្ហាប្រតិភូកម្ម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិតជាបានប្រតិភូកម្មដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺនៅក្នុងដំណាក់កាលធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ដំណាក់កាលចុះឈ្មោះបោះឆ្នោត នៅពេលធ្វើការងារនេះចប់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបិទបញ្ជីបោះឆ្នោតដំបូងនេះ ដើម្បីឱ្យគេប្តឹងតវ៉ា ឬ ប្តឹងជំទាស់ ។ យោងតាមមាត្រា ៦៤ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ លោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលគីឡូម៉ែត្រលេខ៦ ដែលជាអ្នកធ្វើសៀវភៅស្នាក់នៅដឹងច្បាស់ជាងគេអំពីការស្នាក់នៅរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានសង្កាត់គីឡូម៉ែត្រលេខ៦

- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **ម៉ាង ស៊ីមអេង** មេភូមិស្ថានខ្ពស់ ដែលជាអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតបានបំភ្លឺថា ចៅសង្កាត់បានអញ្ជើញប្រធានភូមិឱ្យធ្វើបញ្ជី ដើម្បីត្រៀមសម្អាតបញ្ជី ។ ប្រធានភូមិបានធ្វើ ហើយក៏បញ្ជូនទៅសង្កាត់ ប៉ុន្តែចៅសង្កាត់មិនឯកភាព
- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **អ៊ុង បូរិន្ទ** នាយបុស្តិ៍នគរបាលរដ្ឋបាលសង្កាត់គីឡូម៉ែត្រលេខ៦ ដែលជាអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតបានបំភ្លឺថា ប្រជាពលរដ្ឋទាំង ៣.២៤៤ នាក់ ដែលប្រធានភូមិបានធ្វើ គឺអនុវត្តតាមការណែនាំរបស់គណៈកម្មការធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសម្អាតបញ្ជី ដោយសុំឱ្យនាយបុស្តិ៍នគរបាលរដ្ឋបាលជួយសហការក្នុងការពិនិត្យ ខ្ញុំបានចាត់តាំង

នគរបាលឱ្យចុះត្រួតពិនិត្យសៀវភៅស្នាក់នៅក១ ហើយបានបញ្ជាក់ថា មិនមានមនុស្សនៅក្នុងមូលដ្ឋាននោះទេ

-យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ លោក **ឆុក សាន** មេភូមិបឹងឈូក ដែលជាអ្នកពាក់ព័ន្ធក្នុងការបោះឆ្នោតបានបំភ្លឺថា ក្នុងការសម្អាតបញ្ជីឈ្មោះ ប្រធានភូមិ និង មេ ៥០ខ្ទង បានរួមគ្នាស្រង់ឈ្មោះមនុស្សដែលមិនឃើញនៅក្នុងមូលដ្ឋាន ប៉ុន្តែមានឈ្មោះក្នុងបញ្ជី ។ បញ្ជីនេះបានផ្ញើទៅក្រុមប្រឹក្សាសង្កាត់ ដើម្បីពិនិត្យពិចារណា ប៉ុន្តែចៅសង្កាត់មិនបានបិទផ្សាយ ជាហេតុនាំឱ្យគ្មានអ្នកមកតវ៉ា

-យល់ឃើញថា ទឡ្ហីករណ៍ដែលលោក **លី សុវិជ្ជា** បានផ្តល់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ពុំមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ ដើម្បីសុំរក្សាឈ្មោះប្រជាពលរដ្ឋចំនួន ៣.២៤៤ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូង

-យល់ឃើញថា ទឡ្ហីករណ៍ដែលលើកឡើងដោយតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានខាងផ្លូវច្បាប់ ដែលយកជាការបាន

# សម្រេច

**មាត្រា ១.** ~ ទទួលពាក្យបណ្តឹងរបស់លោក **លី សុវិជ្ជា** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** ~ តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់គីឡូម៉ែត្រលេខ៦ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ចោលជាអាសារបង់ និង លុបឈ្មោះអ្នកបោះឆ្នោត ចំនួន ៣.២៤៤ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងសង្កាត់គីឡូម៉ែត្រលេខ៦ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** ~ សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០៧ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ១៨/២០០៧.កបធ.សសរ

# សេចក្តីសម្រេច

# ស្តីពីការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ
- យោងការសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងពិធីផ្ទេរតំណែង និងការចូលកាន់តំណែងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៤
- យោងការសម្រេចរបស់សម័យប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០០៧
- តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១** : ត្រូវបានបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី៤ ( ឆ្នាំ២០០៧ - ឆ្នាំ២០១០) ដូចខាងក្រោម :

**ក្រុមទី១**

១-ឯកឧត្តម **សឺន ស៊ូប៊ែរ្តិ៍**

២-ឯកឧត្តម **ឈួរ លាងហួត**

៣-ឯកឧត្តម **ឯក សំអុល**

**ក្រុមទី២**

១-ឯកឧត្តម **តុប សំ**

២-ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ**

៣-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ផាន់ដារ៉ាវង្ស**

**ក្រុមទី៣**

១-ឯកឧត្តម **ប្រាក់ សុខ**

២-ឯកឧត្តម **ប៉ែន ថុល**

៣-លោកជំទាវ **ស៊ុំ នីផា**

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** សេចក្តីសម្រេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០០៧

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- រាជកិច្ច
- សាមីខ្លួន
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ១៩/២០០៧ .កបធ.សសរ

# សេចក្តីសម្រេច

# ស្តីពីការចាត់តាំងអ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១ :** ចាត់តាំងឯកឧត្តម **ច្រាក់ សុខ** និង ឯកឧត្តម **ប៉ែន ថុល** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកនាំពាក្យរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី៤ ( ឆ្នាំ២០០៧ - ឆ្នាំ២០១០ ) ។

**ប្រការ២ :** ឯកឧត្តម **ច្រាក់ សុខ** និង ឯកឧត្តម **ប៉ែន ថុល** និង អគ្គលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេច នេះឱ្យបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល

- រាជកិច្ច
- សាមីខ្លួន
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ១៣៩/០០២/២០០៨

ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**សេចក្តីសម្រេច**

លេខ : ០៩៦/០០១/២០០៨ កបធ.ច

ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤៦១ រស ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ វេលាម៉ោង ១៧ និង១០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០០៧ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា នៅក្នុងគ្រប់មាត្រាទាំងអស់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃ អង្គារ ទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ នៃព្រឹទ្ធសភា នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៤០/០០៣/២០០៨

ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**សេចក្តីសម្រេច**

លេខ :០៩៧/០០២/២០០៨ កបធ.ច

ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤៦០ រស ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ព្រមនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ វេលាម៉ោង ១៧ និង ១០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- យល់ឃើញថា រដ្ឋសភាបានអនុវត្តតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មីនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងអនុម័តច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលមាន ៦ជំពូក ៩២មាត្រា ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយកាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៤១/០០៤/២០០៨

ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៨

**សេចក្តីសម្រេច**

លេខ : ០៩៨/០០៣/២០០៨ កបធ.ច

ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៨

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ១៤២/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨ បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ
- បានឃើញពាក្យបណ្តឹងគ្មានលេខ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៨ របស់លោក **អឿន សារ៉ាត់** ប្រធានគណបក្សសង្គមខ្មែរនិយម សុំប្តឹងដើម្បីបំពេញឈ្មោះបេក្ខជនចំនួន ២៥រូប ជំនួសបេក្ខជនដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដើម្បីបានសុពលភាពបញ្ជីបេក្ខជនផ្លូវការពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតវិញ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងនេះនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៨ វេលាម៉ោង ១៥ និង ៤៥ នាទី
- បានឃើញកំណត់ហេតុចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៨ របស់ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ សួរយកចម្លើយលោក **អឿន សារ៉ាត់** ជាដើមបណ្តឹង
- បានឃើញកំណត់ហេតុចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៨ របស់ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ សួរយកចម្លើយតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាចុងចម្លើយ

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **អឿន សារ៉ាត់** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ ស្របតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២៥ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា បណ្តឹងរបស់លោក **អឿន សារ៉ាត់** បានដាក់ក្នុងរយៈពេលដែលច្បាប់បានកំណត់ តាមមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលបណ្តឹងនេះយកមកពិនិត្យបាន
- យល់ឃើញថា បណ្តឹងផ្ទាល់មាត់របស់លោក **អឿន សារ៉ាត់** នៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ សុំប្តឹងប្តូរកម្មវត្ថុនៃបណ្តឹងមកជា : " សុំប្តឹងបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត និង សុំបំពេញបន្ថែមបេក្ខជនថ្មី ចំនួន ២៥រូប ជំនួសបេក្ខជនដែលគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោតបានបដិសេធ ... " ពុំអាចទទួលយកមកពិនិត្យបានឡើយ ដោយខុសនឹងបទបញ្ញត្តិនៃមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា នៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឆ្លើយបំភ្លឺថា គណបក្សសង្គមខ្មែរនិយមបានដាក់ពាក្យសុំចុះបញ្ជីនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០៨ ហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានរយៈពេល ៧ ថ្ងៃ ដើម្បីត្រួតពិនិត្យ បើក្នុងរយៈពេល ៧ ថ្ងៃហើយ មិនបានកែតម្រូវជាបឋមទៀត គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញលិខិតជាផ្លូវការលេខ ១៨៤/០៨ គ.ជ.ប ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៨ ឱ្យគណបក្សបំពេញបន្ថែមរយៈពេល ៥ ថ្ងៃ ពិសេសទាក់ទងនឹងបេក្ខជនដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ លិខិតជូនដំណឹងនេះមានចំនួន ១៥ មណ្ឌល ត្រូវកែតម្រូវ តែគណបក្សសាមីនៅតែមិនបានបំពេញបន្ថែម រហូតដល់ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨ វេលាម៉ោង ១៧ ទើបគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញសេចក្ដីសម្រេចបដិសេធ
- យល់ឃើញថា នៅពេលសវនាការជាសាធារណៈ លោក **អឿន សារ៉ាត់** ( ដើមបណ្ដឹង ) ឆ្លើយថា ពាក្យបណ្ដឹងចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៨ ពិតជាពាក្យបណ្ដឹងរបស់ខ្ញុំបាទមែន។ ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បេក្ខជនឈរឈ្មោះ មានការខុសឆ្គងខ្លះលើបញ្ជីបេក្ខជន ដោយមិនបានអនុវត្តត្រឹមត្រូវតាមច្បាប់បោះឆ្នោត ប៉ុន្តែជាកំហុសឆ្គងដោយអចេតនា ហើយសុំឱ្យគណបក្សបានដើរទៅមុខផង
- យល់ឃើញថា នៅពេលសវនាការជាសាធារណៈ លោក **មាន សឆិ** តំណាងគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត ឆ្លើយបំភ្លឺថា ក្នុងកម្មវត្ថុបណ្ដឹងនេះ លោកគ្មានយោបល់ទេ ។ លោកបានបញ្ជាក់បន្ថែមថាគណបក្សនេះបានដាក់ពាក្យចុះឈ្មោះគណបក្សនយោបាយនិងបេក្ខជនឈរឈ្មោះនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០៨ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុករយៈពេល ៧ ថ្ងៃ ឱ្យគណបក្សនេះធ្វើការកែតម្រូវបំពេញបន្ថែម ។ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញលិខិតជាផ្លូវការឱ្យគណបក្សនេះបំពេញបន្ថែមរយៈពេល ៥ ថ្ងៃ ពិសេសទាក់ទងបេក្ខជនដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨ វេលាម៉ោង ៥ កន្លះល្ងាច គណបក្សនេះនៅតែមិនបានបំពេញការខ្វះខាត ទើបគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះ
- យល់ឃើញថា ការអនុញ្ញាតឱ្យបំពេញឈ្មោះបេក្ខជន ចំនួន ២៩រូប ជំនួសបេក្ខជនដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ពុំមានចែងក្នុងច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពិសេសបទបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

### ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **អឿន សារ៉ាត់** គ្មានលេខ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៨ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៤៣/០០៦/២០០៨

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៨

**សេចក្តីសម្រេច**

លេខ : ០៩៩/០០៤/២០០៨ កបធ.ច

ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៨

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៨ បដិសេធពាក្យបណ្តឹងលេខ ០៦៤ ក.ទ.ជ.ប ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០០៨ របស់លោកស្រី **ថៃ ណារី**
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៨ របស់លោកស្រី **ថៃ ណារី** ផ្ទេរសិទ្ធិជូនលោក **ហ៊ុល ឌុល** ដើម្បីរៀបចំបណ្តឹង និង ចូលរួមក្នុងសវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញពាក្យបណ្តឹងគ្មានលេខ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៨ របស់លោក **ហ៊ុល ឌុល** ជាបេក្ខជនបម្រុងលំដាប់លេខរៀងទី២ មណ្ឌលភ្នំពេញ គណបក្ស សម រង្ស៊ី តំណាងលោកស្រី **ថៃ ណារី** ប្តឹងបដិសេធសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៨ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យបណ្តឹងនេះ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៨ វេលាម៉ោង ១១ និង ២៥ នាទី
- បានឃើញកំណត់ហេតុចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០៨ របស់ក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ សួរយកចម្លើយលោក **ហ៊ុល ឌុល** ជាដើមបណ្តឹង
- បានឃើញកំណត់ហេតុចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០៨ របស់ក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ សួរយកចម្លើយតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាចុងចម្លើយ
- បានឃើញកំណត់ហេតុចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០៨ របស់ក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ សួរយកចម្លើយលោក **សោម សុផាត** ជាជនដែលត្រូវគេចោទ
- បានឃើញលិខិតលេខ ៨៥៣/០៨ គ.ជ.ប របស់ឯកឧត្តម **អ៊ឹម សូស្តី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៨ ឧទ្ទេសនាមជូនឯកឧត្តម **មាន សតិ** សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោកជំទាវ **ក្អុយ ម៉េត** សមាជិកាគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត និង លោក **កែ រិទ្ធិ** អនុប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និង វិវាទកម្មមកជាតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅក្នុងសវនាការជំនុំជម្រះជាសាធារណៈរបស់ក្រុមប្រឹក្សាធម្មនុញ្ញថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៨ វេលាម៉ោង ០៨ ព្រឹក

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សាក្សី**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **ហ៊ុល ឌុល** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលឃោសនាបោះឆ្នោតស្របតាមមាត្រា ៧៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា បណ្តឹងរបស់លោក **ហ៊ុល ឌុល** បានដាក់ក្នុងរយៈពេលដែលបានកំណត់តាមប្រការ ៨ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សា-ធម្មនុញ្ញ អាចទទួលបណ្តឹងនេះយកមកពិនិត្យបាន
- យល់ឃើញថា លោក **ហ៊ុល ឌុល** នៅពេលឆ្លើយចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាឆ្លើយនៅពេលសវនាការ លោក **ហ៊ុល ឌុល** បានអះអាងថា សុំបដិសេធសេចក្តីសម្រេចរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៨។ លោក **ហ៊ុល ឌុល** បានជូនសំអាងសាក្សី ០២ រូប ដែលដឹងរឿងនេះគឺ ÷ ឈ្មោះ **ខឹម មន្ថា** និង ឈ្មោះ **ពេជ្រ សុខណា**
- យល់ឃើញថា នៅពេលសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញសួរថា តាមផ្លូវច្បាប់ បើយើងយកតែគ្នាយើងជាសាក្សី គេពិតជាពិបាកទទួលយកណាស់ លោក **ហ៊ុល ឌុល** ឆ្លើយថា ខ្ញុំយល់ដូច្នេះដែរ ប៉ុន្តែនៅពេលដាក់ពាក្យបណ្តឹងបើគ្មានសាក្សី គេនឹងបដិសេធ ។ លោក **ហ៊ុល ឌុល** បានបញ្ជាក់ថែមទៀត តាមសេចក្តីថ្លែងការណ៍របស់ម្ចាស់ផ្ទះ គាត់បានហែកក្រដាសនេះនៅក្រោយម៉ោងដប់ តាមបណ្តឹងក្រដាសមួយសន្លឹកនេះត្រូវបានហែកនៅម៉ោង ៩:៤៥ នាទីព្រឹក ដូច្នេះក្រដាសមួយសន្លឹកនេះ មិនអាចហែកម្តងទៀតនៅម៉ោងជាងដប់ទេ ។ ខ្ញុំទទួលស្គាល់ថា គ្មានសាក្សីណាបញ្ជាក់ច្បាស់ទេ ។ ខ្ញុំគ្រាន់តែចង់បានយុត្តិធម៌ ។ ខ្ញុំប្តឹងនេះគ្រាន់តែចង់បានការពិតទេ បើសិន **សោម សុផាត** ឆ្លើយថា " *ពូ ខ្ញុំពិតជាបានហែកខិត្តប័ណ្ណនេះ ខ្ញុំនឹងដកពាក្យបណ្តឹងនេះចោល* "
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈឈ្មោះ **ខឹម មន្ថា** ឆ្លើយបញ្ជាក់ថា ខ្ញុំជាសមាជិកគណបក្ស សម រង្ស៊ី ។ នៅថ្ងៃទី ២៨ គ្នាខ្ញុំមានបួននាក់ដើរបិទខិត្តប័ណ្ណ ក្រោយវិហារចាមស្រាប់តែអ៊ំស្រីដែលនៅអង្គុយមុខផ្ទះនោះប្រាប់ថា កុំបិទនៅកន្លែងនោះអី ខ្លាចត្រូវភ្លៀងរហែកទាំងអស់គ្នាមកបិទកន្លែងនេះវិញ ខ្ញុំក៏អស់ខិត្តប័ណ្ណចែក ខ្ញុំក៏ធ្វើដំណើរត្រឡប់ក្រោយវិញដើរប្រហែលជាប្រាំម៉ែត្រឃើញគេហែក ហើយខ្ញុំក៏ឡូឡារកប្រដាប់ថត១ អ្នកដែលហែករត់ចូលផ្ទះសំណាក់ពួនទៅ
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈឈ្មោះ **ពេជ្រ សុខណា** ឆ្លើយបញ្ជាក់ថា ខ្ញុំជាសមាជិកក្រុមប្រឹក្សាសង្កាត់ស្រះចក ជាសមាជិកគណបក្ស សម រង្ស៊ី ។ នៅថ្ងៃដែលនាងខ្ញុំចុះបិទខិត្តប័ណ្ណថ្ងៃទី ២៨ ថ្ងៃសៅរ៍វេលាម៉ោង ៩:៤៥ នាទី នៅពេលដែលនាងខ្ញុំបិទហើយមានប្អូនប្រុសម្នាក់បានមកបកមុខនាងខ្ញុំ មុននាងខ្ញុំបិទ ខ្ញុំបានសុំអ៊ំស្រីម្នាក់ ផ្ទះហ្នឹង រួចហើយនាងខ្ញុំមិនមែនសុំបិទនៅផ្ទះគាត់ទេ នាងខ្ញុំសុំបិទជញ្ជាំងវិហារចាម គាត់ថាកុំបិទអីត្រូវទឹកភ្លៀងរបក បិទខាងក្នុងវិញទៅ
- យល់ឃើញថា **សោម សុផាត** បានឆ្លើយនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០០៨ ថា " *ខ្ញុំមិនដឹងថាហែកលិខិតអ្វីទេ ពីព្រោះខ្ញុំទៅស្ងួចត្រី ខ្ញុំមិនបានចាប់អារម្មណ៍ទៅលើអ្វីទេ* " .... " *គេចោទប្រកាន់ខ្ញុំមិនមែននៅថ្ងៃកើតហេតុនោះទេ ខ្ញុំចាំថ្ងៃសៅរ៍*

*ទី ២៨ ហើយនៅពេលភ្លាមៗដែលជាថ្ងៃគេចោទប្រកាន់នេះ គ្មានគេដេញចាប់ទេ "*

- យល់ឃើញថា **ឌូច សាម៉ុន** ដែលជាម្ចាស់ផ្ទះបានឆ្លើយនៅចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថា "*កាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០០៨ នៅវេលាម៉ោងប្រហែល ៩:៤៥ នាទី សកម្មជនគណបក្ស សម រង្ស៊ី បានយកខិត្តប័ណ្ណផ្សព្វផ្សាយមកបិទលើជញ្ជាំងខាងមុខផ្ទះរបស់ខ្ញុំបាទ ដោយគ្មានការអនុញ្ញាតពីខ្ញុំបាទជាម្ចាស់ផ្ទះ ។ នៅពេលនោះ ខ្ញុំបាទមិនមានវត្តមាននៅផ្ទះទេ ប៉ុន្តែប្រពន្ធខ្ញុំបាទនៅផ្ទះ ដោយមិនបានដឹងថា គេយកខិត្តប័ណ្ណមកបិទនៅមុខផ្ទះឡើយ ។ នៅពេលខ្ញុំបាទត្រឡប់មកផ្ទះវិញ ខ្ញុំបាទបានឃើញខិត្តប័ណ្ណ ខ្ញុំបាទបានសួរទៅប្រពន្ធថា តើគណបក្សសមរង្ស៊ី បានសុំការអនុញ្ញាត ដើម្បីបិទខិត្តប័ណ្ណនៅមុខផ្ទះ ឬ អត់ ? ប្រពន្ធខ្ញុំបាទ បានឆ្លើយថា ឥតបានដឹងទេ ។ ខ្ញុំបាទក៏បានសម្រេចបកខិត្តប័ណ្ណផ្សព្វផ្សាយនេះចេញពីជញ្ជាំងខាងមុខផ្ទះរបស់ខ្ញុំបាទចេញ "*
- យល់ឃើញថា ឯកឧត្តម **មាន សតិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឱ្យនាយកដ្ឋាន ( សេវាកម្ម ) ច្បាប់ ចុះទៅទីកន្លែងកើតហេតុ ឥតមានភស្តុតាង អ្វីចោទលោក **សោម សុផាត** ជាអ្នកហែកទេ ។ លោក **ឌូច សាម៉ុន** បានសំអាងថា គាត់ជាម្ចាស់ផ្ទះ ហើយគាត់បានហែក ពីព្រោះគេមិនបានសុំការអនុញ្ញាត ។ នៅក្នុងសវនាការលោកស្រី **ថៃ ណារី** បានឱ្យលោក **ហ៊ុល ថុល** ធ្វើជាតំណាង ហើយបញ្ជាក់ថា គាត់មិនបានប្តឹងពីម្ចាស់ផ្ទះនោះទេ តែប្តឹងលោក **សោម សុផាត**
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈឯកឧត្តម **មាន សតិ** បានឆ្លើយបញ្ជាក់ថា ចំណុចសំខាន់ៗ ដែលជាមូលដ្ឋានរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការបដិសេធមាន÷

  ចំណុចទី ១ : ដើមបណ្តឹងមិនបានផ្តល់ភស្តុតាង

  ចំណុចទី ២ : សាក្សីដែលដើមចោទបានឱ្យមកបំភ្លឺ គឺជាមនុស្សក្នុងក្រុមការងារតែមួយ ហើយសាក្សីសំខាន់ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចង់សួរ គឺអ្នកដែលបានអនុញ្ញាតឱ្យបិទ តែភាគីដើមចោទបញ្ជាក់ថាមិនស្គាល់គាត់ទេ សាក្សីដើមចោទឆ្លើយថាជាម្តាយមីងរបស់ម្ចាស់ផ្ទះ ។ ម្ចាស់ផ្ទះឆ្លើយថាគ្មានមនុស្សចាស់ហើយគ្មានម្តាយមីងនៅផ្ទះខ្ញុំទេ

  ចំណុចទី ៣ : គឺដើមចោទនិងចុងចោទព្រមព្រៀងថារឿងកើតឡើងនៅចន្លោះ ម៉ោង ៩:៣០ នាទីទៅម៉ោង ១០:០០ ។ ភាគីដើមចោទ ចោទប្រកាន់ ភាគីចុងចោទបដិសេធ ហើយដើម្បីឱ្យច្បាស់លាស់ទៅលើរឿងហ្នឹង គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និង គណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត ក៏បានចុះអង្កេតទាំងបី ។ ដល់ស្រាវជ្រាវទៅ ប្រជាពលរដ្ឋនៅជុំវិញ

នោះបញ្ជាក់ថា គ្មានកើតហេតុអ្វីទេនៅចន្លោះពេលម៉ោង ៩:៣០ នាទី ទៅម៉ោង ១០:០០ ហ្នឹង

ចំណុចទី ៤ :ម្ចាស់ផ្ទះដែលជាតួអង្គសំខាន់នៅក្នុងរឿងហ្នឹងបានសារភាព ហើយទទួលស្គាល់ថាគាត់ជាអ្នកបកខិត្តប័ណ្ណហ្នឹង ។ ដូច្នេះបើយោងទៅលើហេតុផលច្បាស់លាស់របៀបហ្នឹងបញ្ជាក់ថា **សោម សុផាត** មិនបានហែក អ្នកហែកគឺជាម្ចាស់ផ្ទះ ដូច្នេះហើយបានជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចបដិសេធបណ្តឹង ហើយឱ្យ **សោម សុផាត** រួចផុតពីការដាក់ទោសទៅតាមមាត្រាច្បាប់ ។

- យល់ឃើញថា តាមគោលការណ៍ច្បាប់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនដែលត្រូវគេចោទ ។

# សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **ហ៊ុល ថុល** គ្មានលេខ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈនៅរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៨ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៤៤/០០៧/២០០៨

ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៨

លេខ : ១៤៥/០០៨/២០០៨

ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៨

លេខ : ១៤៦/០០៩/២០០៨

ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨

**សេចក្តីសម្រេច**

លេខ : ១០០/០០៥/២០០៨ កបធ.ច

ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៨

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ លើពាក្យបណ្តឹងលេខ ០៧៤ ០៧៥ ០៧៦ ០៧៧ ០៧៨ ០៨៣ ០៨៤ ០៨៥ ០៨៦ ០៨៧ ០៨៨
- បានឃើញពាក្យបណ្តឹងរបស់លោក បែនសុន សម័យ មេធាវីតំណាងគណបក្សប្រជាជនកម្ពុជា ខេត្តក្រចេះ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៨ ប្តឹងតវ៉ាលើសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញពាក្យបណ្តឹងរបស់លោក គា អ៊ាវ មេធាវីតំណាងគណបក្សប្រជាជនកម្ពុជា ខេត្តកំពង់ចាម ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៨ ប្តឹងមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញពាក្យបណ្តឹងរបស់ឯកឧត្តម ថាច់ សេដ្ឋា តំណាងឯកឧត្តម សម រង្ស៊ី ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨ ប្តឹងបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក គា អ៊ាវ កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម ថាច់ សេដ្ឋា កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក បែនសុន សម័យ កាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៩ និង ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៨

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក បែនសុន សម័យ មេធាវីតំណាងគណបក្សប្រជាជនកម្ពុជា ខេត្តក្រចេះ ជាបណ្តឹងស្ថិតក្នុងដំណាក់កាលឃោសនាបោះឆ្នោត ស្របតាមមាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ បណ្តឹងនេះ បានដាក់ក្នុងរយៈពេលដែលបានកំណត់តាមប្រការ ៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលបណ្តឹងរបស់លោក បែនសុន សម័យ យកមកពិនិត្យបាន
- យល់ឃើញថា បណ្តឹងរបស់លោក គា អ៊ាវ មេធាវីតំណាងគណបក្សប្រជាជនកម្ពុជា ខេត្តកំពង់ចាម ជាបណ្តឹងស្ថិតក្នុងដំណាក់កាលឃោសនាបោះឆ្នោត ស្របតាមមាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ បណ្តឹងនេះ បានដាក់ក្នុងរយៈពេលដែលបានកំណត់តាមប្រការ ៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលបណ្តឹងរបស់លោក គា អ៊ាវ យកមកពិនិត្យបាន

- យល់ឃើញថា បណ្តឹងរបស់ឯកឧត្តម ថាច់ សេដ្ឋា តំណាងឯកឧត្តម សម រង្ស៊ី ជាបណ្តឹងស្ថិតក្នុងដំណាក់កាលឃោសនាបោះឆ្នោត ស្របតាមមាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ បណ្តឹងនេះ បានដាក់ក្នុងរយៈពេលដែលបានកំណត់តាមប្រការ ៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលបណ្តឹងរបស់ឯកឧត្តម ថាច់ សេដ្ឋា យកមកពិនិត្យបាន
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ និង ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោក បែនសុន សម័យ និង លោក គា អ៊ារ៉ាវ បានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា ខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ ដោយមូលហេតុបីគឺ :
  - +ទី១ : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយកករណី ០៤ នៅខេត្តកំពង់ចាម មកបញ្ចូលតែមួយ ថែមទាំងបញ្ចូលជាមួយសំណុំរឿងខេត្តក្រចេះទៀត ។
  - +ទី២ : ការប្តឹង គឺប្តឹងចំឈ្មោះឯកឧត្តម សម រង្ស៊ី តែម្តង ប៉ុន្តែការចូលមកដោះស្រាយ ឱ្យតែតំណាងរបស់គាត់មក ។
  - +ទី៣ : ការផ្តន្ទាទោសនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្រាលពេក ពីព្រោះឯកឧត្តម សម រង្ស៊ី ប្រមាថ មើលងាយដល់ថ្នាក់ដឹកនាំកំពូល ដែលជាឥស្សរជនរបស់ខ្មែរ ។ ការប្រមាថមើលងាយកើតមានច្រើនដង និង ច្រើនកន្លែង ។ បើយើងមើលលើសមត្ថភាព ឯកឧត្តម សម រង្ស៊ី គឺជាបុគ្គលដែលមានសមត្ថភាពខ្ពស់ ជាតំណាងរាស្ត្រ ជាអ្នកធ្វើច្បាប់ ជាប្រធានគណបក្សមួយ ដូច្នេះសម្តីរបស់គាត់ធ្វើដោយចេតនាមោះមុត ពុំគួរដាក់ទោសស្រាលពេកទេ ប៉ុន្តែគួរពិន័យជាប្រាក់ផង និង លុបឈ្មោះពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផង ។
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម ថាច់ សេដ្ឋា បានប្តឹងសូមក្រុមប្រឹក្សាធម្មនុញ្ញ បដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ ដោយសំអាងថា ការចោទប្រកាន់ពុំមានមូលដ្ឋានច្បាស់លាស់ ព្រមទាំងផ្ទុយនឹងគតិច្បាប់នៃមាត្រា ៧៣ថ្មី និង មាត្រា ៧៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ ហើយបើយោងតាមប្រការ ៧.១៨.១ នៃបទបញ្ជា និងនីតិវិធី របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ថា ការនិយាយនោះ ទាល់តែធ្វើឱ្យរំខាន ឬ ជ្រៀតជ្រែក ឬ រាំងស្ទះ ចំណែកឯការនិយាយរបស់លោកប្រធាន សម រង្ស៊ី មិនចូលក្នុងប្រការ ៧.១៨.១ នេះទេ ។ បណ្តឹងរបស់គណបក្សប្រជាជនកម្ពុជាដែលប្តឹងលោកប្រធាន សម រង្ស៊ី ថាប្រមាថថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជានោះមិនពិតទេ ពីព្រោះលោកប្រធាន សម រង្ស៊ី និយាយទៅតាមឯកសាររបស់ Global Witness គឺមិនសំដៅទៅលើថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ឬ បុគ្គលណា

មួយឡើយ និងគ្រាន់តែនិយាយថា រូបថតនោះ ដូចជារូបថតក្នុងសៀវភៅរបស់ Global Witness ដូច្នេះ មិនបញ្ជាក់ឈ្មោះប្រាកដប្រជាទេ ។ ហេតុនេះ ការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តន្ទាទោសលោកប្រធាន សម រង្ស៊ី ពិន័យជាប្រាក់ចំនួន ដប់លាន (១០.០០០.០០០) រៀល មិនត្រឹមត្រូវ និងមិនស្របតាមគតិច្បាប់ឡើយ ។

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅចំពោះមុខក្រុមទី១ និង ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម ឯម សូផាត ឯកឧត្តម មាន សទិ ឯកឧត្តម ឃ្លោក ប៊ុតឌី តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺថា ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចបញ្ចូលសំណុំរឿងទាំង ៤ នៅខេត្តកំពង់ចាមជាមួយសំណុំរឿង ៧ ទៀត ហើយបើកសវនាការរួមគ្នាតែមួយ ដោយហេតុថា អ្នកប្រព្រឹត្តអំពើល្មើសមានតែម្នាក់ គឺឯកឧត្តម សម រង្ស៊ី អ្នកប្តឹងមានតែគណបក្សប្រជាជនកម្ពុជាតែមួយ ទីកន្លែងនៃការឃោសនាបោះឆ្នោតមាននៅទូទាំងប្រទេសតែមួយ រយៈពេលនៃការឃោសនាបោះឆ្នោតមានតែមួយ គឺចាប់ពីថ្ងៃទី ២៦ ខែ មិថុនា ដល់ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៨ កម្មវត្ថុបណ្តឹងមានតែមួយ គឺប្រមាថមើលងាយ ។ ឯកឧត្តម សម រង្ស៊ី បានឃោសនាដោយផ្ទាល់មាត់ជាច្រើនកន្លែងនៅក្នុងខេត្តក្រចេះ និង ជាច្រើនកន្លែងផងដែរ នៅខេត្តកំពង់ចាម ។ គាត់ប្រើពាក្យសម្តីដូចមានថតក្នុងខ្សែអាត់ជាភស្តុតាង ដូចជាពាក្យថា " ខ្ញុំឃើញមានរូបប្រុសបីនាក់ អានៅកណ្តាលខូចជាងគេ "។ល។ ម្យ៉ាងទៀត ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចសេចក្តីដោយផ្អែកលើមាត្រា ១៦ថ្មី មាត្រា ៧៣ថ្មី មាត្រា ៧៦ មាត្រា ១២៤ថ្មី និង មាត្រា ១៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងចំណុច ៧.១៨.១ នៃបទបញ្ជា និង នីតិវិធី ព្រមទាំងចំណុច ៦ និង ចំណុច ១៥ ក្នុង **IV** នៃក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និង តំណាងគណបក្សនយោបាយ ។

- យល់ឃើញថា ភស្តុតាងដាក់បន្ទុកលើឯកឧត្តម សម រង្ស៊ី មានគ្រប់គ្រាន់ គឺខ្សែអាត់ថតបានសម្លេងចំនួន ៦ កាសែត គឺកាសែតនៅឃុំស្នួល ឃុំសំបូរ ឃុំព្រែកស្រសព្វ ឃុំក្រចេះ (ខេត្តក្រចេះ) ឃុំផ្ទាវ ឃុំពាមជីកង (ខេត្តកំពង់ចាម) ។ ក្នុងកាសែតអាត់សម្លេងនោះ ឯកឧត្តម សម រង្ស៊ី បានប្រើសម្តីជាអាទិ៍ថា " ខ្ញុំឃើញគេលើកស្លាក គេលើកបដា ខ្ញុំឃើញមានរូបថតបីនាក់ ខ្ញុំមើលប្រុសបីនាក់ហ្នឹង ខ្ញុំថាហ្នឹងហើយ មុខហ្នឹងហើយ ដែលជាចោរលួចជាតិ...។ ក្នុងចំណោមចោរលួចជាតិបីនាក់ហ្នឹង អានៅកណ្តាលហ្នឹង ខូចជាងគេ...។ល។ "

- យល់ឃើញថា មាត្រា ៧៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចែងថា "*ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយ និង បេក្ខជនទាំងអស់ មិនត្រូវប្រើអំពើហិង្សា អំពើរំលោភសំដីប្រមាថមើលងាយ មិនត្រូវសាបព្រោះឱ្យមានការភ័យខ្លាច ការភ័ន្តច្រឡំ ធ្វើឱ្យមានភាពច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។* "

- យល់ឃើញថា មាត្រា ១៣១ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចែងថា *"ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ប្រាំលាន (៥.០០០.០០០)រៀល ទៅ ដប់លាន (១០.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវដកហូតប័ណ្ណបោះឆ្នោតសម្រាប់រយៈពេលប្រាំឆ្នាំ ឬ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណា ឬ គណបក្សនយោបាយណា ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ ឬ មាត្រា ៧៦ នៃច្បាប់នេះ "*
- យល់ឃើញថា ទោសដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចផ្ដន្ទានោះ ជាទោសពិន័យជាប្រាក់អតិបរមាហើយ ដែលស្ថិតក្នុងបរិមាណទោសកំណត់ក្នុងមាត្រា ១៣១ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា ការសម្រេចយកទោសណាមួយ ឬ ទោសទាំងពីរមកផ្ដន្ទា នោះគឺជាមូលវិចារអធិបតេយ្យរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ ពិតជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្ដឹងរបស់លោក បែនសុន សម័យ លោក គា អ៊ាវ និង ឯកឧត្ដម ថាច់ សេដ្ឋា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្ដីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៨ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៤៨/០១១/២០០៨

ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨

**សេចក្ដីសម្រេច**

លេខ :១០១/០០៦/២០០៨ កបធ.ច

ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៨ ដែលតម្កល់សេចក្ដីសម្រេចរបស់គណៈកម្មការខេត្តកំពង់ធំរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញពាក្យបណ្ដឹងរបស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨ ប្ដឹងមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៨ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ១៥:១១ នាទី

- បានឃើញលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ របស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** សុំដកពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨ ដែលអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ០៩:១៥ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតដកពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ របស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** សុំដកពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែសីហាឆ្នាំ២០០៨ ដែលប្តឹងមិនសុខចិត្ត ចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៨ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាច ទទួលយកមកពិនិត្យបាន
- យល់ឃើញថា តាមគោលការណ៍ច្បាប់ ម្ចាស់បណ្តឹងមានសិទ្ធិសុំដកពាក្យបណ្តឹងរបស់ខ្លួនទាំងអស់ ឬ មួយផ្នែក បានគ្រប់ពេលវេលាទាំងអស់នៃនីតិវិធី ។

## សម្រេច

**មាត្រា ១.-** ទទួលលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ របស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៨ ដែលតម្កល់សេចក្តីសម្រេចរបស់គណៈកម្មការខេត្តកំពង់ធំរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ នាពេលប្រជុំពេញអង្គរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាច ទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ១៥៣/០១៦/២០០៨
ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៨

**សេចក្តីសម្រេច**
លេខ :១០២/០០៧/២០០៨ កបធ.ច
ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៩០/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨

- បានឃើញពាក្យបណ្តឹងរបស់លោក មាស ខេង តំណាងគណបក្សសម រង្ស៊ី ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ ប្តឹងពីភាពមិនប្រក្រតីនៃការសរុបសន្លឹកឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត និង ១១០៤ សរុបដោយគណបក្សសមរង្ស៊ីខេត្តស្វាយរៀង សូមឱ្យរាប់សន្លឹកឆ្នោតទាំង ៦៥០ ការិយាល័យឡើងវិញ
- បានឃើញលិខិតផ្ទេរសិទ្ធិរបស់ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសម រង្ស៊ី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨ ផ្ទេរសិទ្ធិជូនលោក មាស ខេង ដើម្បីជាតំណាងក្នុងការដាក់ពាក្យបណ្តឹង និង សវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ១០០១/គ.ជ.ប ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក មាស ខេង កាលពីថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៨

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក មាស ខេង តំណាងគណបក្សសម រង្ស៊ី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ១៣:៤៩ នាទី ជាបណ្តឹងស្ថិតក្នុងអំឡុងពេល ៧២ ម៉ោង បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៥៩០/០៨ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ដែលបដិសេធពាក្យបណ្តឹងរបស់លោក មាស ខេង តំណាងគណបក្សសម រង្ស៊ី ប្តឹងបដិសេធលទ្ធផលបណ្តោះអាសន្ននៅខេត្តស្វាយរៀង ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៨ ។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី ២ នៃមាត្រា ២៧ ថ្មីនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពាក្យបណ្តឹងរបស់លោក មាស ខេង យកមកពិនិត្យបាន
- យល់ឃើញថា លោក មាស ខេង នៅក្នុងបណ្តឹង ក៏ដូចជានៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ និង នៅពេលសវនាការជំនុំជម្រះជាសាធារណៈ បានអះអាងថាសូម " *ប្តឹងពីភាពមិនប្រក្រតីនៃការសរុបសន្លឹកឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ១១០៤ សរុបដោយគណបក្សសម រង្ស៊ី ខេត្តស្វាយរៀង សូមឱ្យរាប់សន្លឹកឆ្នោតទាំង ៦៥០ ការិយាល័យឡើងវិញ* " ដោយសំអាងថា តួលេខដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

កាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៨ ដោយប្រៀបធៀបតួលេខរបស់គណបក្សសម រង្ស៊ី សរុបទៅឃើញថាខុសគ្នា។ លោក មាស ខេង បានបញ្ជាក់នៅចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញថា របៀបបូកសរុបលទ្ធផល គឺប្រើប្រាស់តាមម៉ាស៊ីនបូកលេខ (CASIO) ប៉ុន្តែនៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកបានឆ្លើយថា ប្រើប្រាស់តាមម៉ាស៊ីនកុំព្យូទ័រ ។ រីឯការលម្អៀងតួលេខស្ថិតនៅការិយាល័យណាមួយ លោកថា មិនដឹងទេ ។ ម្យ៉ាងទៀត លោក មាស ខេង បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញថា លោកមិនចាំបាននៅការិយាល័យនិងឃុំណាដែលមានដាក់ពាក្យបណ្តឹងទាក់ទងនឹងការរាប់សន្លឹកឆ្នោតនោះទេ ។ នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោក មាស ខេង ធ្វើសំណូមពរជាចុងក្រោយឱ្យរាប់សន្លឹកឆ្នោតឡើងវិញតែមួយការិយាល័យក៏បាន

- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ ឯកឧត្តម ឯម សូផាត ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិកគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត និង ជាតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឆ្លើយបំភ្លឺថា លោក មាស ខេង បានដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ ហើយនៅថ្ងៃនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រជុំពិនិត្យ និង ពិចារណាទៅលើពាក្យបណ្តឹងរបស់លោក មាស ខេង ដោយបានកំណត់ឱ្យដើមបណ្តឹងប្រគល់ភស្តុតាងដែលជាក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ (ទម្រង់បែបបទ ១១០៤) និង បានសម្រេចឱ្យមានការពិនិត្យផ្ទៀងផ្ទាត់តួលេខនៃការបូកសរុបលទ្ធផលនៃការបោះ-ឆ្នោតខេត្តស្វាយរៀងឡើងវិញ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានធ្វើការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតនៅតាមការិយាល័យក្នុងទម្រង់បែបបទ ១១០៤ ដោយមានវត្តមានលោក មាស ខេង តំណាងគណបក្ស សម រង្ស៊ី និង មានតំណាងគណបក្សនយោបាយនានា មានជាអាទិ៍គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ គណបក្សប្រជាធិបតេយ្យខ្មែរ គណបក្សសិទ្ធិមនុស្ស គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ព្រមទាំងអ្នកសង្កេតការណ៍ អ្នកយកព័ត៌មានមួយចំនួន ។ នៅពេលផ្ទៀង-ផ្ទាត់នោះ លោក មាស ខេង បានយកទម្រង់ ១១០៤ ចំនួន ៦៤២ ការិយាល័យក្នុងចំណោម ៦៥០ ការិយាល័យក្នុងខេត្តស្វាយរៀង ក្រៅពីនោះពុំមានភស្តុតាងអ្វីបន្ថែមទៀតទេ ។ ភស្តុតាង ដែលជាក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ (ទម្រង់បែបបទ ១១០៤) របស់លោក មាស-ខេង ភាគច្រើនមានការកែសម្រួលតួលេខ ដោយសរសេរប៊ិកជាន់ពីលើស្នាមលេខចាស់ ។ ដោយឡែកទម្រង់បែបបទ ១១០៤ របស់លោក មាស ខេង ដែលយកមកសុំពិនិត្យផ្ទៀងផ្ទាត់ជាអាទិភាព ក្នុងនោះមាន ÷

  **ទីមួយ :** ទម្រង់បែបបទ ១១០៤ នៃការិយាល័យចំនួន ១១ ដែលមានលេខកូដ ០៣៣១ , ០៣៩៣ , ០១៩៨ , ០២៣៤ , ០២៥៦ , ០២៦៥ , ០២៦៦ , ០២៧៨ , ០២៦៨ , ០៥៣៦ , ០២១៣ , ០១៨៦ , ០០៩៧ និងលេខកូដ ០០៩៣ ទោះបីការដាមជាតិកាបោន

មិនសូវច្បាស់ក្តី ឬ ក៏កែសម្រួលតួលេខដោយប៊ិកក្តី គឺមានតួលេខដូចគ្នានឹងទម្រង់បែបបទ ១១០៤ ច្បាប់ដើមតម្កល់ទុកជាឯកសារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ទីពីរ :** ទម្រង់បែបបទ ១១០៤ នៃការិយាល័យ ចំនួន ៤ ដែលមានលេខកូដ ០១៨៤ , ០១៨៥ , ០៦៣៨ និង លេខកូដ ០៥៩៧ ក៏មានដាមជាតិកាបោន ប៉ុន្តែទម្រង់បែបបទ ១១០៤ ខ្លះមានលក្ខណៈមិនសូវច្បាស់ និង មានការកែសម្រួលតួលេខដោយប៊ិក ហើយតួលេខសន្លឹកឆ្នោតបានការនៃគណបក្សនយោបាយនីមួយៗ មានលក្ខណៈខុសពីតួលេខទម្រង់បែបបទ ១១០៤ និងទម្រង់បែបបទ ១១០២ ជាច្បាប់ដើមតម្កល់ទុកជាឯកសារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ម្យ៉ាងទៀត ផលបូកនៃសន្លឹកឆ្នោតបានការនៃគណបក្សនយោបាយទាំង-ឡាយ ដែលមានការកែសម្រួលតួលេខ មិនមានលក្ខណៈត្រូវគ្នានឹងតួលេខសន្លឹកឆ្នោតបានការសរុបដែលមានកត់ត្រាក្នុងក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ( ទម្រង់បែបបទ ១១០៤ ) និង កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត( ទម្រង់បែបបទ ១១០២ ) ជាច្បាប់ដើមតម្កល់ទុកជាឯកសារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺទៀតថា តាមកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោត ( ទម្រង់បែបបទ ១១០២ ) របស់ការិយាល័យរាប់សន្លឹកឆ្នោត នៅថ្ងៃរាប់សន្លឹកឆ្នោត គឺពុំមានពាក្យបណ្តឹងតវ៉ាភ្លាមៗជាផ្លូវការទាក់ទងទៅនឹងការរាប់ ឬ ការសរុបសន្លឹកឆ្នោតឡើយ ។ តាមការស្រាវជ្រាវទៅលើភស្តុតាងឯកសារដែលជាក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ ( ទម្រង់បែបបទ ១១០៤ ) ដែលលោក មាស ខេង បានដាក់ជាភស្តុតាងនៅក្រុមប្រឹក្សាធម្មនុញ្ញ និងភស្តុតាង ( ទម្រង់បែបបទ ១១០៤ ) ពិនិត្យផ្ទៀងផ្ទាត់ជាអាទិភាពនៅទីស្តីការគណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត ជាមួយនឹងទម្រង់បែបបទ ១១០២ របស់បណ្តាការិយាល័យរាប់សន្លឹកឆ្នោតក្នុងមណ្ឌលខេត្តស្វាយរៀង ភាគច្រើនសុទ្ធតែមានតំណាងគណបក្សនយោបាយ និង អ្នកសង្កេត-ការណ៍ ជាពិសេសតំណាងគណបក្សសម រង្ស៊ី ចូលរួមចុះហត្ថលេខា គឺជាភស្តុតាងនៃការទទួលស្គាល់ដំណើរការរាប់សន្លឹកឆ្នោត ។ តាមការស្រាវជ្រាវទៅលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ ហៅកាត់ថា " ទម្រង់បែបបទ ១១០៣ " នៃមណ្ឌលខេត្តស្វាយរៀង ជាពិសេសឃុំដែលមានការិយាល័យរាប់សន្លឹកឆ្នោត ដែលលោក មាស ខេង បានស្នើជាអាទិភាពក្នុងការពិនិត្យផ្ទៀងផ្ទាត់នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឃើញថា ក្រៅពីគណបក្សនយោបាយមួយចំនួន និង អ្នកសង្កេតការណ៍ ក៏មានតំណាងគណបក្សសម រង្ស៊ី ចុះហត្ថលេខានៅលើទម្រង់បែបបទ ១១០៣ ដែលជាភស្តុតាងនៃការទទួលស្គាល់ការបូកសរុបសន្លឹកឆ្នោតនៅតាមបណ្តាគណៈកម្មការឃុំរៀបចំការបោះឆ្នោត

- យល់ឃើញថា ភស្តុតាងដែលលោក មាស ខេង បានដាក់ភ្ជាប់មកជាមួយនឹងពាក្យបណ្តឹង ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ១៣:៤៥ នាទី គឺជាក្រដាសលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ ហៅកាត់ថា " ទម្រង់បែបបទ ១១០៤ " ដែលបំពេញដោយគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ។ ប៉ុន្តែភស្តុតាង

ទម្រង់បែបបទ ១១០៤ ខាងលើនេះ ចំនួន ១៨ សន្លឹក ជាលិខិតក្លែង ដោយត្រូវបានកែបន្ថែម កែបន្ថយតួលេខ និង មានស្នាមកែផ្លាស់ប្តូរឈ្មោះគណបក្សនយោបាយ ខុសពីច្បាប់ដើមដែលគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតបានប្រគល់ឱ្យតំណាងគណបក្សនយោបាយ

- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៩០/០៨ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ពិតជាមានមូលហេតុគ្រប់គ្រាន់ និង ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក មាស ខេង តំណាងគណបក្សសម រង្ស៊ី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៩០/០៨ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :  ១៥៤/០១៧/២០០៨

ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៨

**សេចក្តីសម្រេច**

លេខ : ១០៣/០០៨/២០០៨ កបធ.ច

ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី  ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨

- បានឃើញពាក្យបណ្ដឹងរបស់លោកមេធាវី គង់ សំអុន ជាដើមបណ្ដឹងតំណាងឱ្យគណបក្ស សម រង្ស៊ី ប្ដឹងតវ៉ាសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេធាវី គង់ សំអុន កាលពីថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៨
- បានឃើញសារណាជាលាយល័ក្ខអក្សររបស់លោកមេធាវី គង់ សំអុន កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្ដាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្ដឹងរបស់លោកមេធាវី គង់ សំអុន ដើមបណ្ដឹងតំណាងឱ្យគណបក្ស សម រង្ស៊ី ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៨ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញ បានទទួលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ១៧ និង ៤០ នាទី ជាបណ្ដឹងស្ថិតក្នុងអំឡុងពេល ៧២ ម៉ោង បន្ទាប់ពីបានទទួលសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពាក្យបណ្ដឹងរបស់លោកមេធាវី គង់ សំអុន យកមកពិនិត្យបាន
- យល់ឃើញថា លោក គង់ សំអុន នៅក្នុងពាក្យបណ្ដឹង ក៏ដូចជានៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សា-ធម្មនុញ្ញ នាថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៨ និងនៅពេលសវនាការជំនុំជម្រះជាសាធារណៈបានលើកឡើងថា សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ បានសម្រេចថា " អ្នកប្ដឹងពុំបានផ្ដល់ភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតី ដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មស្ដីពីច្បាប់នេះ ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយកមកពិនិត្យនិងពិចារណាបានឡើយ " ។ ការអះអាងបែបនេះជាការមួលបង្កាច់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយមិនយកចិត្តទុកដាក់ក្នុងការស្វែងរកយុត្តិធម៌ និង ភាពត្រឹមត្រូវសម្រាប់អ្នកប្ដឹង ។

យោងតាមមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មស្តីពីច្បាប់នេះ គោលការណ៍ទាក់ទងនឹងភស្តុតាងដែលត្រូវលើកយកមកបង្ហាញមាន : ( ១ ) ការបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មាធិការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ( ២ ) កាលបរិច្ឆេទធ្វើខុស ( ៣ ) ទីកន្លែងប្រព្រឹត្តខុស ( ៤ ) ឈ្មោះ និង អាសយដ្ឋានសាក្សី និង ( ៥ ) ឯកសារ ឬភស្តុតាងដទៃទៀត ។

ទាក់ទងនឹងចំណុច (១) ក្នុងពាក្យបណ្តឹងបានសរសេរថា ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៨ តែមិនបានបោះឆ្នោតដោយសារ :

+ ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទោះបីពួកគាត់ធ្លាប់បានបោះឆ្នោតនៅឆ្នាំ២០០៧ ហើយមិនបានផ្លាស់ប្តូរទីលំនៅក៏ដោយ

+ រកឈ្មោះមិនឃើញនៅក្នុងបញ្ជីបោះឆ្នោត នៅថ្ងៃបោះឆ្នោត ដោយសារមានការផ្លាស់ប្តូរការិយាល័យបោះឆ្នោត ឬ ប្តូរបញ្ជីឈ្មោះអ្នកបោះឆ្នោត

+ ត្រូវបានអ្នកផ្សេងបោះឆ្នោតជំនួស ។

ដើម្បីបញ្ជាក់ថា ចំណុចខាងលើនេះសុទ្ធតែជាការពិត គណបក្ស សម រង្ស៊ី បានភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះរបស់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៨ តែមិនអាចបោះឆ្នោតបាន ដោយសារមានភាពមិនប្រក្រតីបីយ៉ាងខាងលើមានចំនួនជាងបីពាន់នាក់ ដែលមានឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ ដែលអាចឱ្យអ្នកស៊ើបអង្កេតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានការងាយស្រួលស៊ើបអង្កេតទៀតផង ។ ផ្ទុយទៅវិញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចថា បណ្តឹងរបស់គណបក្ស សម រង្ស៊ី គ្មានភស្តុតាងគ្រប់គ្រាន់ តែខ្លួនមិនបានហៅសាក្សីណាម្នាក់ក្នុងចំណោមអ្នកដែលមានឈ្មោះ និង ផ្តិតមេដៃដែលគណបក្ស សម រង្ស៊ី ដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យនោះមកសាកសួរឡើយ ។

ទាក់ទងនឹងចំណុច (២) ស្តីពីកាលបរិច្ឆេទធ្វើខុស មិនពិបាកធ្វើការបង្ហាញភស្តុតាងនោះទេ ។ អំពើខ្លះ មានចុះកាលបរិច្ឆេទនៅលើឯកសារ ដែលបានភ្ជាប់ជាមួយពាក្យបណ្តឹងនោះស្រាប់តែម្តង ដូចជាមាននៅក្នុងទម្រង់បែបបទ ១០១៨ ជាដើម ។ ក្រៅពីនេះ អំពើខ្លះមិនអាចកំណត់កាលបរិច្ឆេទជាក់លាក់បានទេ ដូចជាការលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាដើម ។ ប៉ុន្តែការមិនអាចកំណត់កាលបរិច្ឆេទដោយជាក់លាក់ថា តើមន្ត្រីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ មន្ត្រីដែលមានសមត្ថកិច្ច បានលុបឈ្មោះអ្នកបោះឆ្នោតចេញពីពេលណានោះ មិនមែនជាមូលដ្ឋានសម្រាប់ទាត់ចោលបណ្តឹងរបស់គណបក្ស សម រង្ស៊ី នោះទេ ព្រោះថា ការលុបឈ្មោះធ្វើឡើង

ក្នុងអំឡុងពេលនៃការបោះឆ្នោតជាតិឆ្នាំ២០០៨ នេះឯង គឺយើងមិនបានប្តឹងពីការលុបឈ្មោះនៃការបោះឆ្នោតជាតិលើកមុនៗនោះទេ ។

ទាក់ទងនឹងចំណុច (៣) ទីកន្លែងប្រព្រឹត្តខុស ក៏មិនមែនជាការលំបាកសម្រាប់បង្ហាញភស្តុតាងដែរ ។ គណបក្ស សម រង្ស៊ី បានប្តឹងបដិសេធលទ្ធផលបោះឆ្នោតបណ្តោះអាសន្នទូទាំងប្រទេស ដូចនេះមិនចាំបាច់លើកបញ្ជាក់ទីតាំងណាមួយជាក់លាក់ក៏បានដែរ ។ ពីព្រោះវិសាលភាពនៃបណ្តឹងគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ទាក់ទងនឹងចំណុច (៤) ឈ្មោះ និង អាសយដ្ឋានសាក្សី កាន់តែងាយស្រួលបង្ហាញភស្តុតាងទៅទៀត ព្រោះថា ក្នុងទម្រង់ផ្តិតមេដៃ និងក្នុងទម្រង់បែបបទ ១០១៨ សុទ្ធតែបានបញ្ជាក់ពីឈ្មោះនិងអាសយដ្ឋានរបស់សាក្សីទាំងនោះ ហើយថែមទាំងមានលេខទូរស័ព្ទ ដែលជាមធ្យោបាយងាយស្រួលសម្រាប់ទំនាក់ទំនងជាមួយសាក្សីទាំងនោះទៀតផង ។

ទាក់ទងនឹងចំណុច (៥) ឯកសារ ឬ ភស្តុតាងដទៃទៀត ច្បាប់មិនតម្រូវឱ្យមាននោះទេ ។ ម៉្យាងវិញទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានអះអាងដោយសន្និដ្ឋានក្នុងសេចក្តីសម្រេចរបស់ខ្លួនថា " ការក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណ មិនមែនជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឡើយ ។ ការសន្និដ្ឋានបែបនេះ ជាការបង្ហាញនូវការខ្វះខាតសមត្ថភាព និងការទទួលខុសត្រូវនៃតួនាទីរបស់ខ្លួន ក៏ដូចជាការមិនបានយល់ឱ្យស៊ីជម្រៅអំពីច្បាប់នោះដែរ " ។

អាជ្ញាធរឃុំ សង្កាត់ មានអំណាចចេញទម្រង់បែបបទ ១០១៨ ដោយសារតែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអ្នកផ្តល់អំណាចឱ្យ មានន័យថា ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកធ្វើការក្នុងនាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវបណ្តោយឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព្រឹត្តកំហុសស្រេចតែចិត្ត ដោយគ្មានការដោះស្រាយតាមបែបបទរដ្ឋបាលនោះទេ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែត្រួតពិនិត្យតាមភារកិច្ចរបស់ខ្លួនតាមមាត្រា ១៦ថ្មី ដូចបានរៀបរាប់ខាងលើ ។

ដោយមូលហេតុដូចរៀបរាប់ខាងលើ ទើបខ្ញុំជាដើមបណ្តឹងតំណាងឱ្យគណបក្ស សម រង្ស៊ី សូមប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញដូចតទៅ : សុំប្តឹងក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ សូមផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋ ដែលសិទ្ធិបោះឆ្នោតរបស់ពួកគាត់ត្រូវបានរំលោភបំពាន សុំបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ និងបញ្ជូនទៅគណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោតឱ្យរៀបចំការបោះឆ្នោតសាឡើងវិញ ចំពោះខេត្ត ក្រុងណាដែលមានភាពមិនប្រក្រតីច្រើនករណី ។ ម្យ៉ាងទៀតលោកមេធាវី គង់ សំអុន នៅក្នុងសារណាជាលាយល័ក្ខអក្សរ ចុះ

ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨ ស្នើសុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យរៀបចំការបោះឆ្នោតឡើងវិញ ( ១ ) ខេត្តស្វាយរៀង ( ២ ) ខេត្តពោធិសាត់ ( ៣ ) ខេត្តកំពត និង ( ៤ ) ខេត្តកំពង់ចាម

- យល់ឃើញថា ឯកឧត្តម មាន សទិ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈបានឆ្លើយបំភ្លឺថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញសេចក្តីសម្រេច លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ដោយមានមូលហេតុសង្ខេបដូចខាងក្រោម :

+ ចំណុច ក : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ថាការប្តឹងអំពីការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ត្រូវធ្វើនៅពេលបិទបញ្ជីបោះឆ្នោតដំបូង ហើយនៅពេលដែលបញ្ជីបោះឆ្នោតផ្លូវការត្រូវបានអនុម័តហើយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចយកបណ្តឹងអំពីការលុបឈ្មោះមកដោះស្រាយម្តងទៀតទេ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុករយៈពេលប្រមាណបីខែ គិតចាប់ពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០០៧ ដល់ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៧ សម្រាប់ឱ្យប្រជាពលរដ្ឋប្តឹងតវ៉ា ឬ ប្តឹងជំទាស់ ។

+ ចំណុច ខ : ក្រោយពីប្រកាសបញ្ជីបោះឆ្នោតផ្លូវការរួចហើយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចផ្លាស់ប្តូរការិយាល័យបោះឆ្នោត ឬ ប្តូរបញ្ជីឈ្មោះអ្នកបោះឆ្នោតនោះទេ ។ ចំពោះការិយាល័យណាដែលស្មៀនឃុំ សង្កាត់ចុះឈ្មោះជូនប្រជាពលរដ្ឋលើសពីចំនួន ៧០០ នាក់ គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត បំបែកជាពីរការិយាល័យភ្លោះ ( តាមមាត្រា ៤៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ) ដោយថែមអក្សរ អា ( A ) និង បេ ( B ) ។ ការិយាល័យភ្លោះ អា ( A ) និង បេ ( B ) ត្រូវនៅជិតគ្នា និង ក្នុងទីតាំងតែមួយ ។

+ ចំណុច គ : ដើមបណ្តឹងបានលើកយកករណីភ្នំពេញ និងករណីបាត់ដំបង មកឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោះស្រាយ ។ ប៉ុន្តែនៅទីក្រុងភ្នំពេញ បណ្តឹងលើករណីនេះមានតែពីរទេ ហើយសាមីខ្លួនបានបោះឆ្នោតទាំងអស់គ្នា ។ នៅខេត្តបាត់ដំបង គ្មានបណ្តឹងលើករណីនេះទេ ។ នៅខេត្តបាត់ដំបង ដើមបណ្តឹងបានផ្តល់ឈ្មោះប្រជាពលរដ្ឋ ចំនួន ១៨ នាក់ ហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យឃើញថា មានតែ ០៥ នាក់ ប៉ុណ្ណោះ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។ នៅក្រុងភ្នំពេញ ក្នុងឈ្មោះប្រជាពលរដ្ឋ ៤៩ នាក់ ដែលដើមបណ្តឹងផ្តល់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនោះ គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិនិត្យឃើញថា មានតែ ២៨ នាក់ ប៉ុណ្ណោះ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

+ ចំណុច ឃ : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបំពេញតួនាទីជាតំណាងរបស់ខ្លួនតែក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយ

ប្រើត្រាការិយាល័យចុះឈ្មោះបោះឆ្នោត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រគល់ឱ្យ ( មាត្រា ៥៣ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ) ។ ចំពោះការចេញទម្រង់បែបបទ ១០១៨ គឺជាសមត្ថកិច្ចរបស់មេឃុំ ចៅសង្កាត់ក្នុងនាមជាអាជ្ញាធរដែនដី ដោយប្រើត្រាឃុំ សង្កាត់ ( មាត្រា ៥៤ថ្មី ចំណុច ខ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ )។ មតិមួយចំនួនយល់ច្រឡំថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអ្នកធ្វើប្រតិភូកម្មអំណាចឱ្យមេឃុំ ចៅសង្កាត់ក្នុងការចេញទម្រង់បែបបទ ១០១៨ នេះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្មានសិទ្ធិត្រួតពិនិត្យលើការចេញទម្រង់បែបបទ ១០១៨ ទេ ហើយរឿងធ្វើទម្រង់បែបបទ ១០១៨ ក្លែងក្លាយ ជាសមត្ថកិច្ចរបស់តុលាការ ។

ចំពោះបញ្ជីឈ្មោះ និង ស្នាមមេដៃសាក្សីដែលជាអ្នកមិនបានទៅបោះឆ្នោតឆ្នាំ២០០៨ ហើយដែលដើមបណ្តឹងសំអាងនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលបញ្ជី ០៤ ក្បាល គឺ ភ្នំពេញ ចំនួន ០២ ក្បាល និង បាត់ដំបង ចំនួន ០២ ក្បាល ។

ហេតុផលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនបានចុះស៊ើបសួរដល់ប្រជាពលរដ្ឋទាំងនោះ ពីព្រោះបានបញ្ជាក់ក្នុងចំណុច ( ក ) ( ខ ) និង ( គ ) ខាងលើរួចហើយ

- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ពិតជាមានមូលហេតុគ្រប់គ្រាន់ ព្រមទាំងធ្វើឡើងត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.** ទទួលពាក្យបណ្តឹងរបស់លោកមេធាវី គង់ សំអុន ជាដើមបណ្តឹងតំណាងឱ្យគណបក្ស សម រង្ស៊ី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៨៩/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៨ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៥៥/០១៨/២០០៨

ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៨

**សេចក្តីសម្រេច**

លេខ : ១០៤/០០៩/២០០៨ កបធ.ច

ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចលេខ ៩៩១/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៨ របស់លោក ញ៉ឹក វណ្ណារ៉ា តំណាងគណបក្សសិទ្ធិមនុស្ស ប្តឹងជំទាស់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បំប៉ោងបញ្ជីឈ្មោះបោះឆ្នោត ដោយបន្ថែមឈ្មោះស្ទួនច្រើននាក់ក្នុងបញ្ជីបោះឆ្នោតតាមការិយាល័យនីមួយៗ
- បានឃើញលិខិតផ្ទេរសិទ្ធិលេខ ២១១៦/០៨ គ.ស.ម ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៨ របស់ឯកឧត្តម កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស ផ្ទេរសិទ្ធិជូនលោក ញ៉ឹក វណ្ណារ៉ា ឱ្យធ្វើជាតំណាងក្នុងការដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៅតាមនីតិវិធីច្បាប់
- បានឃើញលិខិតខុទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១០០៣/០៨ គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក ញ៉ឹក វណ្ណារ៉ា កាលពីថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៨
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៨ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៨ របស់លោក ញ៉ឹក វណ្ណារ៉ា តំណាងគណបក្សសិទ្ធិមនុស្ស បានដាក់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៨ វេលាម៉ោង ៩ និង ២៥ នាទី ជាបណ្តឹងស្ថិតក្នុងអំឡុងពេល ៧២ ម៉ោង បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩៩១/០៨គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលបណ្តឹងរបស់លោក ញ៉ឹក វណ្ណារ៉ា យកមកពិនិត្យបាន
- យល់ឃើញថា ក្នុងកម្មវត្ថុនៃបណ្តឹងចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៨ លោក ញ៉ឹក វណ្ណារ៉ា តំណាងគណបក្សសិទ្ធិមនុស្ស ប្តឹងជំទាស់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ដោយ គ.ជ.ប.បំប៉ោងបញ្ជីឈ្មោះបោះឆ្នោត ដោយបន្ថែមឈ្មោះស្ទួនច្រើននាក់ក្នុងបញ្ជីបោះឆ្នោតតាម

ការិយាល័យនីមួយៗ

- យល់ឃើញថា លោក ញ៉ឹក វណ្ណារ៉ា បានបញ្ជាក់ក្នុងពាក្យបណ្ដឹងខាងលើនេះ ថាកាលពីថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ លោក " បានដាក់ពាក្យបណ្ដឹងចំនួន ៣ ច្បាប់ទៅ គ.ជ.ប. ដោយសំណូមពរឱ្យ គ.ជ.ប. រៀបចំការបោះឆ្នោតនៅទូទាំងប្រទេសឡើងវិញ ។ ផ្ទុយទៅវិញ គ.ជ.ប. បានបដិសេធអ្នកប្ដឹងថា ពុំបានផ្ដល់ភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ដើម្បីឱ្យ គ.ជ.ប. យកមកពិនិត្យ និង ពិចារណាបានឡើយ ។ "
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោក ញ៉ឹក វណ្ណារ៉ា បានឆ្លើយថា " ភាពមិនប្រក្រតីមានច្រើនណាស់ រាប់មិនអស់ទេ ប៉ុន្តែពេលនេះ ខ្ញុំប្ដឹងពីបញ្ជីបោះឆ្នោត ចំពោះរឿងផ្សេងទៀត ខ្ញុំប្ដឹងដាច់ដោយឡែក ដើម្បីជៀសវាងកុំឱ្យមានភាពរញ៉េរញ៉ៃ ។ ក្នុងបណ្ដឹង ខ្ញុំបានបញ្ជាក់ច្បាស់ថា បញ្ជីបោះឆ្នោតដែល គ.ជ.ប. បំបាំងដែលមានឈ្មោះស្ទួនជាច្រើននាក់តាមការិយាល័យនីមួយៗ ខ្ញុំប្ដឹងតែភាពមិនប្រក្រតីលើបញ្ជីបោះឆ្នោតទេ "
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោក ញ៉ឹក វណ្ណារ៉ា បានឆ្លើយថា មិនមានអ្វីបន្ថែមលើពាក្យបណ្ដឹងទៀតទេ ប៉ុន្តែលោកបានលើកជាសំណូមពរឱ្យមានការកែសម្រួលឱ្យមានភាពសុក្រឹត ។ ការប្ដឹងនេះមិនមែនដើម្បីចង់ឈ្នះចាញ់ទេ គឺដើម្បីការពារកុំឱ្យថ្ងៃក្រោយមានករណីដូចនេះតទៅទៀត
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម ឯម សូផាត តំណាង គ.ជ.ប.បានឆ្លើយថា " លោក ញ៉ឹក វណ្ណារ៉ា ប្ដឹងអំពីលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ប៉ុន្តែលោកបង្ហាញតែអំពីបញ្ជីបោះឆ្នោតទៅវិញ ដែលត្រូវធ្វើការតវ៉ានៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។ គ.ជ.ប. បានពិនិត្យសម្រេចលើបណ្ដឹងនេះ ដោយយល់ឃើញថា បើលោកប្ដឹងពីលទ្ធផលបណ្ដោះអាសន្ន ឬមួយផ្នែកនៃលទ្ធផលបណ្ដោះអាសន្ន គឺលោកមានរយៈពេល ៧២ ម៉ោង ដោយបញ្ជាក់ពីភាពមិនប្រក្រតីដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ដោយសារលោកមិនមានភស្តុតាងបញ្ជាក់អំពីភាពមិនប្រក្រតីបញ្ជាក់អំពីការបោះឆ្នោត អំពីការរាប់សន្លឹកឆ្នោត និង បូកសរុបលទ្ធផលនៃការរាប់សន្លឹកឆ្នោតនេះហើយ ទើប គ.ជ.ប. បដិសេធបណ្ដឹងរបស់លោក ។ គ.ជ.ប ផ្អែកលើមាត្រា ១១៥ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប.បានចេញសេចក្ដីសម្រេចបដិសេធបណ្ដឹង ព្រោះគ្មានភស្តុតាងបញ្ជាក់ច្បាស់លាស់ពីមូលហេតុ ។ " ម្យ៉ាងទៀត ឯកឧត្តម ឯម សូផាត បានបញ្ជាក់ថា " មុនឱ្យសុពលភាពបញ្ជីបោះឆ្នោតមានបណ្ដឹងតិចតួចណាស់ទាក់ទងនឹងការដែលមានឈ្មោះស្ទួន ឬ លុបឈ្មោះ ហើយបណ្ដឹងនេះបាន

ដោះស្រាយដោយ គ.ជ.ប. និង ក្រុមប្រឹក្សាធម្មនុញ្ញរួចរាល់អស់ហើយ ។ បញ្ជីដែលលោក ញឹក វណ្ណារ៉ា បានយកមកសំអាងនោះ ជាបញ្ជីផ្លូវការដែល គ.ជ.ប. បានផ្តល់សុពលភាពរួចហើយ កាលពីថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ "

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ឯកឧត្តម ឯម សូផាត បានឆ្លើយបំភ្លឺ មានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងខ្លឹមសារដែលបានឆ្លើយបំភ្លឺនៅមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញដែរ
- យល់ឃើញថា សេចក្តីសម្រេចលេខ ៥៩១/០៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិតជាមានមូលហេតុគ្រប់គ្រាន់ និងធ្វើឡើងតាមទម្រង់ និងគតិច្បាប់ ។

**សម្រេច**

**ចំពោះមុខគូភាគី**

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក ញឹក វណ្ណារ៉ា ជាដើមបណ្តឹងតំណាងឱ្យគណបក្សសិទ្ធិមនុស្ស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៥៩១/០៨ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៨ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៦៤/00២/២00៩

ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២00៩

**សេចក្តីសម្រេច**

លេខ :១0៥/00១/២00៩ កបធ.ច

ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២00៩

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0៤៩៨/0៦ ចុះថ្ងៃទី 0៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១0៧/00៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0៥0៨/0១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២00៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញលិខិតលេខ ១៦៨ លស ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២00៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២00៩ វេលាម៉ោង ១៦ និង ៥0 នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ស្របតាមមាត្រា១៣៦ថ្មី មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយ លេខ ១៦៨ លស ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី យកមកពិនិត្យបាន
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបកស្រាយថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលកំពុងបំពេញមុខងារជាសកម្ម គ្មានសិទ្ធិជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានទេ មានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និង យោធា មិនអាចធ្វើការងាររបស់ខ្លួនផង និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផងបានទេ ។ ពាក្យថា " **មន្ត្រីរាជការស៊ីវិល** " រួមមាន មន្ត្រីរាជការក្នុងក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត
- យល់ឃើញថា តាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ បទបញ្ញត្តិបន្ថយសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត
- យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំបានហាមឃាត់ដាច់ខាតមិនឱ្យឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ ប្រសិនបើមន្ត្រីរាជការស៊ីវិល និងយោធាទាំងនោះ មានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវតែបំពេញលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់នេះ
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា១៨ ដែលចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចខាងក្រោមនេះ÷

ក/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ១ មានន័យថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។ ពាក្យថា " **ដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ(០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ** " មានន័យថា ដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមែនមានន័យថា ដាក់ពាក្យសុំលាលែងពីមុខងារ ឬពីមុខតំណែងឡើយ ។ បទបញ្ញត្តិនេះមានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធាដែលចង់ស្នើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវសុំការអនុញ្ញាតអវត្តមានពីការងារ ក្នុងរយៈពេលដូចបានកំណត់ខាងលើ ។

ខ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ២ មានន័យថា សាមីខ្លួនជាប់ឆ្នោត ត្រូវធ្វើពាក្យទៅក្រសួង ឬ ស្ថាប័នរបស់ខ្លួន សុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតក្នុងរយៈពេលនៃអាណត្តិនោះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬ ឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង ។

ប្រសិនបើបេក្ខជនជាប់ឆ្នោតហើយ ហើយគ្មានបំណងចង់នៅបម្រើការងារជាសមាជិកក្រុមប្រឹក្សាទេនោះ សាមីខ្លួនត្រូវធ្វើពាក្យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសុំដកបេក្ខភាពរបស់ខ្លួនចេញពីបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ ក្នុងករណីនេះ សាមីខ្លួនអាចមកកាន់ការងារដើមរបស់ខ្លួនវិញបាន។

គ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី៣ មានន័យថា នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចត្រឡប់មកបម្រើការងារនៅក្រសួង ឬ ស្ថាប័នដើមរបស់ខ្លួនវិញបាន ប៉ុន្តែសាមីខ្លួននឹងអាចបានទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញបាននោះ គឺអាស្រ័យដោយក្រសួង ឬ ស្ថាប័នជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញ ដោយស្វ័យប្រវត្តិនោះឡើយ ។

## សម្រេច

**មាត្រា ១៖** បទបញ្ញត្តិនៃមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២៖** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៦៧/០០៥/២០០៩

ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩

**សេចក្តីសម្រេច**

លេខ : ១០៦/០០២/២០០៩ កបធ.ច

ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/០០៣/២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨
- បានឃើញលិខិតគ្មានលេខ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមអ្នកតំណាងរាស្ត្រចំនួន ១៥នាក់ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ និង ពិនិត្យធម្មនុញ្ញភាពមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង បកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៦ និង ៥០ នាទី

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់អ្នកតំណាងរាស្ត្រចំនួន ១៥ នាក់ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយ និងពិនិត្យធម្មនុញ្ញភាព មាត្រា ២៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងបកស្រាយមាត្រា ១៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ រួមទាំងមាត្រា ២៩ ផង ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨ ។ ដូច្នេះ សំណើខាងលើនេះ ត្រូវចាត់ទុកថា **ជាសំណើសុំបកស្រាយច្បាប់**
- យល់ឃើញថា មាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី១ បានចែងថា *" ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ "* និងវាក្យខ័ណ្ឌទី៥ បានចែងថា *" បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។ "*
- យល់ឃើញថា បទបញ្ញត្តិមាត្រា ២៩ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពាក់ព័ន្ធតែនឹងបញ្ជីបោះឆ្នោត ពោលគឺបញ្ជីអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងតែប៉ុណ្ណោះ ។ មាត្រានេះ ចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចតទៅ ÷

ក/វាក្យខ័ណ្ឌទី១ បានចែងថា *" គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់សុពលភាពបញ្ជីបោះឆ្នោតក្នុងរយៈពេលយ៉ាងតិចសាមសិបប្រាំ ( ៣៥ ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ "*

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំអាចផ្ដល់សុពលភាពបញ្ជីបោះឆ្នោត ក្រោយសាមសិបប្រាំ ( ៣៥ ) ថ្ងៃ មុនថ្ងៃបោះឆ្នោតបានទេ ។

ខ/វាក្យខ័ណ្ឌទី២ បានចែងថា *" បញ្ជីបោះឆ្នោតដែលត្រូវបានផ្ដល់សុពលភាពរួចហើយ គឺជាបញ្ជីបោះឆ្នោតជាផ្លូវការ មិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។ "*

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ក្នុងពេលដែលបញ្ជីបោះឆ្នោតត្រូវបានផ្ដល់សុពលភាពរួចហើយ បញ្ជីនោះក្លាយជាបញ្ជីបោះឆ្នោតផ្លូវការដែលមិនអាចកែប្រែបានឡើយ លើកលែងតែករណីមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការរួចហើយបានទទួលមរណភាព ។

គ/វាក្យខ័ណ្ឌទី៣ បានចែងថា *"ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទ ផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេលប្រាំពីរ ( ០៧ ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត ។"*

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការហើយ ហើយបានទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទធ្វើការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះឱ្យបានរួចស្រេច ហើយផ្ញើទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យបានយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោតផ្លូវការបាន ។

**ចំពោះករណីផ្សេងទៀត មាត្រា ២៩ នេះ មិនអនុញ្ញាតឱ្យធ្វើការផ្លាស់ប្តូរឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឡើយ ។**

- យល់ឃើញថា បទបញ្ញត្តិមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលចែកជា ២ វាក្យខ័ណ្ឌត្រូវបានបកស្រាយដូចខាងក្រោមនេះ ÷

ក/វាក្យខ័ណ្ឌទី១ បានចែងថា *"សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :*

- *សាមីខ្លួនទទួលមរណភាព*
- *សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច*
- *សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់*
- *សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ*
- *សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤ នៃច្បាប់នេះ*
- *ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ*
- *សាមីខ្លួនត្រូវបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួនហើយ ។"*

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីណាមួយនៃករណីទាំង ៧ ដូចបានរៀបរាប់ខាងលើ ។

ខ/វាក្យខ័ណ្ឌទី២ បានចែងថា *"កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាពត្រូវជ្រើសរើសបេក្ខជនបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។"*

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ត្រូវបានជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយ មកជំនួសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបាត់បង់សមាជិកភាព ដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

## សម្រេច

**មាត្រា ១.-** បទបញ្ញត្តិនៃមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ និង មាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៦៩/០០៧/២០០៩

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩

**សេចក្តីសម្រេច**

លេខ : ១០៧/០០៣/២០០៩ កបធ.ច

ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ដោយយោងតាមសំណើលេខ ០៦៥/០៩ ស.ន.ក.ជ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៩ របស់គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៤ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ

បានធ្វើឡើង ស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

- យល់ឃើញថា មាត្រា ៤ នៃរដ្ឋធម្មនុញ្ញចែងថា *" បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ "* ។ បាវចនានៃព្រះរាជាណាចក្រកម្ពុជា ជារូបមន្តសរុបមួយតែប៉ុណ្ណោះ បញ្ជាក់អំពីទិសដៅកំណត់សកម្មភាពទាំងឡាយរបស់បុគ្គល រួមមានរូបវន្តបុគ្គល និង នីតិបុគ្គល ដែលរស់នៅ និង មានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ បុគ្គលទាំងនោះត្រូវយកចិត្តទុកដាក់ចំពោះ ជាតិ សាសនា និង ព្រះមហាក្សត្រ ។ ចំពោះការប្រតិបត្តិខាងផ្លូវសាសនា មានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រាផ្សេងៗទៀតនៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា មាត្រា ៤៣ ចែងអំពីសិទ្ធិខាងជំនឿរបស់ប្រជាពលរដ្ឋខ្មែរ ។

• វាក្យខ័ណ្ឌទី១ ចែងថា *" ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ "* ។ វាក្យខ័ណ្ឌនេះមានន័យថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសេរីភាពបរិបូរណ៍ក្នុងការជឿ ឬ ការប្រតិបត្តិជំនឿ និង សាសនាតាមសតិសម្បជញ្ញៈរបស់ខ្លួន គ្រប់ពេលវេលា និង គ្រប់កាលៈទេសៈ ។

• វាក្យខ័ណ្ឌទី២ ចែងថា *" សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ "* ។ វាក្យខ័ណ្ឌទី២ នេះ មានន័យថា រដ្ឋត្រូវធានាឱ្យសេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនាដំណើរការបានជាធម្មតា **ប៉ុន្តែសេរីភាព និង ការប្រព្រឹត្តនេះ ក៏មានព្រំដែនកំណត់ដែរ** ។ ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃ ព្រមទាំងត្រូវគោរពសិទ្ធិសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ ឬ សាសនារបស់អ្នកដទៃទៀតផង ។ ម្យ៉ាងវិញទៀត ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈជាដាច់ខាត ។

• វាក្យខ័ណ្ឌទី៣ ចែងថា *" ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ "* ។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយវាក្យខ័ណ្ឌទី៣ នៃមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងដូច្នេះហើយ ទើបបទប្បញ្ញត្តិនៃមាត្រាដទៃផ្សេងទៀតនៃរដ្ឋធម្មនុញ្ញ និង អត្ថបទច្បាប់ ព្រមទាំងអត្ថបទក្រោមច្បាប់កំណត់ស្របតាមស្មារតីខាងលើនេះ

- យល់ឃើញថា ដោយសារ *ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ* ទើប ÷

• នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបានផ្តល់ការជួយឧបត្ថម្ភ គាំទ្រ និង លើកតម្កើងវិស័យព្រះពុទ្ធសាសនាឱ្យបានរីកចម្រើន ថ្កុំថ្កើង រុងរឿង ស័ក្តិសមជាសាសនារបស់រដ្ឋ ។ ហេតុនេះ ទើបនៅក្នុងព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រកម្ពុជាគ្រងរាជសម្បត្តិ ក៏មានវត្តមានរបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ តាមព្រះរាជប្បវេណីដែរ ។ មិនតែប៉ុណ្ណោះ ថ្ងៃបុណ្យធំៗក្នុងព្រះពុទ្ធសាសនា ជាអាទិ៍ថ្ងៃបុណ្យមាឃបូជា វិសាខបូជា ត្រូវបានចាត់ទុកជាថ្ងៃបុណ្យជាតិ

• សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ និង សម្ដេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ត្រូវបានឱ្យគង់ជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចមានចែងក្នុងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ម្យ៉ាងទៀត សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះអង្គត្រូវបានគង់ជាអធិបតីក្នុងពិធីធ្វើសច្ចាប្រណិធានធំៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទាំងឡាយនៃរដ្ឋធម្មនុញ្ញ ហើយនៅក្នុងភ្លេងជាតិនគររាជទៀតសោត វគ្គទី៣ ចែងថា " *គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌ សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ ប្រយោជន៍ឱ្យ ដល់ប្រទេសខ្មែរ ជាមហានគរ ។* "

• វាក្យខ័ណ្ឌទី៣ មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា " *រដ្ឋជួយផ្សព្វផ្សាយ និង លើកតម្កើងសាលាបាលី និង ពុទ្ធិកសិក្សា* "

• ហើយប្រជាពលរដ្ឋខ្មែរភាគច្រើនលើសលប់នៅព្រះរាជាណាចក្រកម្ពុជា បានលើក **ទង់ជាតិ ទង់ព្រះពុទ្ធសាសនា** និង **ទង់ព្រះមហាក្សត្រ** នៅទន្ទឹមគ្នា ព្រមទាំងមានសតិសម្បជញ្ញៈជឿជាក់ថា អាណាចក្រ និង ពុទ្ធចក្រ ត្រូវដើរទន្ទឹមគ្នា ទើបជាតិបានចុំចម្រើន រុងរឿង ។

## សម្រេច

**មាត្រា ១.** មាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ១៧០/០០១/២០១០
ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១០
**សេចក្តីសម្រេច**
លេខ:១០៨/០០១/២០១០ កបធ.ច
ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៣៩ រស ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១០ របស់ឯកឧត្តម **ខ្វួន ញ៉ិល** ប្រធានរដ្ឋសភាស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២នៃព្រឹទ្ធសភា នាថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១០ វេលាម៉ោង ០៩ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុង មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីអស្សាមិករណ៍
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខ្លួន ញឹល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីអស្សាមិករណ៍ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៍ ដែលមាន ៨ ជំពូក និង ៣៩ មាត្រា ក្នុងនោះ ៖

  • មាត្រា ១ ចែងថា " ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធី នៃអស្សាមិករណ៍ និងសំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។ "

  • មាត្រា ២ ចែងថា " ច្បាប់នេះមានគោលបំណងជាអាទិ៍ :

  -ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌

  -ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌

  -បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ

  -ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។ "

មាត្រាទាំងពីរនេះ ស្របនឹងមាត្រា ៤៤ វាក្យខ័ណ្ឌទី២ និង ទី ៣នៃរដ្ឋធម្មនុញ្ញដែលចែងថា ៖

*" កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។ "*

*" ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យនិងយុត្តិធម៌ ។ "*

ជាមួយគ្នានេះមាត្រា ៦១នៃរដ្ឋធម្មនុញ្ញ ចែងថា " *រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និង មធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និង ប្រព័ន្ធឥណទាន* "

- យល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៍បានធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌ដូចមានបញ្ជាក់នៅក្នុង ៖

•មាត្រា ១៩ ដែលចែងថា " ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុអាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង នីតិវិធីនៃការទូទាត់សំណង ... ។ "

•មាត្រា ២២ ដែលចែងថា " ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយតាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ "

•មាត្រា ២៤ ដែលចែងថា " សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួស ទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ... ។ "

- យល់ឃើញថា មាត្រា ៣៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ ដែលចែងថា " ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យនិងយុត្តិធម៌ ... " ស្របទៅនឹងមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការ*

*រដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។"*

- យល់ឃើញថា ខ្លឹមសារនៅក្នុងមាត្រាទាំងអស់នៃច្បាប់ស្តីពីអស្សាមិករណ៍ ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ នៃព្រឹទ្ធសភា នាថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ .-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧២/០០៣/២០១០

ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ : ១០៩/០០២/២០១០ កបធ.ច

ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញលិខិត ០០២/១០ រ.ស.គសរ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១០ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ជូនមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា១៦ វាក្យខ័ណ្ឌទី ៤ នៃច្បាប់ភូមិបាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា ១៦ វាក្យខ័ណ្ឌទី ៤ នៃច្បាប់ភូមិបាល បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

-យល់ឃើញថា វាក្យខ័ណ្ឌទី ៤ មាត្រា ១៦ នៃច្បាប់ភូមិបាល បានចែងថា " **ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ** " ។ បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា កាលណាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋណាមួយ ត្រូវបានឈប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈតទៅទៀតហើយ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន តាមរយៈច្បាប់អនុបយោគ ។ ពាក្យថា " **ច្បាប់អនុបយោគ**" គឺជា ច្បាប់ដែលរំសាយពីប្រភេទទ្រព្យសម្បត្តិមួយទៅប្រភេទទ្រព្យសម្បត្តិមួយទៀត ដូចជារំសាយពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាដើម ។

## សម្រេច

**មាត្រា ១.** បទប្បញ្ញត្តិ នៃវាក្យខ័ណ្ឌទី ៤ មាត្រា ១៦ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧៣/០០៤/២០១០

ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ : ១១០/០០៣/២០១០ កបធ.ច

ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១០

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញលិខិតលេខ ១៩៤ រ.ស. ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១០ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១០ នាសម័យប្រជុំវិសាមញ្ញនៃរដ្ឋសភា នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់

ដោយឥតកែប្រែ នាសម័យប្រជុំវិសាមញ្ញនៃព្រឹទ្ធសភា នីតិកាលទី២ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១០ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៤៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា ចែងពីគោលបំណង គោលដៅ វិសាលភាពនៃច្បាប់ និង និយមន័យនៃពាក្យបច្ចេកទេសដែលប្រើនៅក្នុងអត្ថបទច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីស្ថាប័នប្រឆាំងអំពើពុករលួយ មាន ១១ មាត្រា ចែងពីស្ថាប័នប្រឆាំងអំពើពុករលួយ ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិ ការដកចេញពីតំណែង និង ការជំនួសតំណែង ការជ្រើសតាំងប្រធាន និង អនុប្រធាន ឋានៈរបស់សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ លក្ខណសម្បត្តិនៃប្រធាន និង អនុប្រធាននៃអង្គភាពប្រឆាំងអំពើពុករលួយ ភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុកលួយ មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ និង បណ្តាញនៃអង្គភាពប្រឆាំងអំពើពុករលួយ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពីថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយមាន ១ មាត្រា ចែងពីថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្ដីពីការប្រកាសទ្រព្យសម្បត្តិ និង បំណុល មាន ៤ មាត្រា ចែងពីសមាសភាពបុគ្គល ដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល របបប្រកាសទ្រព្យសម្បត្តិ និង បំណុល ជនផ្សេងទៀតដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល និងការរក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិ និង បំណុល ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្ដីពីនីតិវិធីអនុវត្តចំពោះបទល្មើសពុករលួយ និង អាជ្ញាធរមានសមត្ថកិច្ច មាន ១១ មាត្រា ចែងពីនីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយ មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើសពុករលួយ ការផ្ដល់នីតិសម្បទាចំពោះមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ សម្បថអំណាចស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការតាមដាន បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង្កកទ្រព្យសម្បត្តិរបស់បុគ្គល បុព្វសិទ្ធិរបស់អង្គភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសាធារណៈ ការចាប់យក និង នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ ។ ជំពូកទី៥នេះ ទាក់ទងនឹងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញ ដែលចែងអំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។ ជាគោលការណ៍ សិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋខ្មែរ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែក្នុងករណីដែលមានតម្រុយជាក់លាក់ ថាមានបទល្មើសពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយអាចចាប់ផ្ដើមស៊ើបអង្កេតតែទៅលើបទល្មើសពុករលួយប៉ុណ្ណោះ ដោយចាត់វិធានការទៅតាមនីតិវិធីដែលមានចែងក្នុងច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ និង ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដូច្នេះជំពូកទី៥ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៦ ស្ដីពីបទល្មើសពុករលួយ និង ទោស ចែងពីបទល្មើសពុករលួយដែលមានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌ បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ បទសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ បទរំលោភអំណាច បទមានទ្រព្យសម្បត្តិដោយខុសច្បាប់ បទទទួលផលបន្តពីបទល្មើសពុករលួយ បទមិនប្រកាសទ្រព្យសម្បត្តិ និង បំណុល បទទម្លាយការសម្ងាត់នៃប្រភពព័ត៌មានស្ដីពីអំពើពុករលួយ បទរារាំង និង ការជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ បទប្ដឹងបរិហារដោយការភូតកុហក បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក បទល្មើសពុករលួយតូចតាច និង ទោសការប៉ុនប៉ង ទោសបន្ថែមអនុវត្តចំពោះបទល្មើសពុករលួយ ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល ការផ្សាយចេញនូវកំណត់ត្រារបស់ធនាគារ សេចក្ដីសម្រេចរឹបអូស និង ការទាមទារឱ្យបញ្ជូននូវផលនៃបទល្មើសពុករលួយ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៧ ស្តីពីបត្យាប័ន និង ជំនួយផ្នែកច្បាប់ទៅវិញទៅមក មាន ៤ មាត្រា ចែងពីបទប្បញ្ញត្តិដែលត្រូវអនុវត្តនៅក្នុងរឿងបត្យាប័ន ជំនួយផ្នែកច្បាប់ទៅវិញទៅមក ករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ និង នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមក ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៨ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា ចែងពីការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៩ ស្តីពីអវសានប្បញ្ញត្តិ មាន ៣ មាត្រា ចែងពីនិរាករណ៍ ការប្រកាសឱ្យប្រើច្បាប់ និងការអនុវត្តច្បាប់ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៩ ជំពូក ៥៧ មាត្រា នៃច្បាប់នេះ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១០ នាសម័យប្រជុំវិសាមញ្ញនៃរដ្ឋសភា នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ នាសម័យប្រជុំវិសាមញ្ញនៃព្រឹទ្ធសភា នីតិកាលទី២ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧៦/០០៧/២០១០

ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ : ១១១/០០៤/២០១០ កបធ.ច

ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១០

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញបទបញ្ញត្តិផ្ទៃក្នុងនៃព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ញត្តិផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញលិខិតលេខ ៤៧៨ រ.ស ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ របស់ឯកឧត្តម **សៅ រ៉ានី** តំណាងរាស្ត្រមណ្ឌលព្រៃវែង និង ជាតំណាងគណបក្សជាតិនិយម តាមរយៈសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដោយមានចំណារចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១០ ជូនឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំបកស្រាយច្បាប់មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៣០ នាទីព្រឹក

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា តំណាងរាស្ត្រមួយរូបបានធ្វើលិខិតមួយ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ ជូនមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្ស នយោបាយដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ មាត្រា ១៤១ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី វាក្យខ័ណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាធម្មនុញ្ញ

កន្លងមក សំណើរបស់តំណាងរាស្ត្រមួយរូបតាមរយៈប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលមកពិនិត្យបាន

- យល់ឃើញថា លិខិតរបស់ឯកឧត្តម **សៅ រ៉ានី** តំណាងរាស្ត្រមណ្ឌលព្រៃវែង និង ជាតំណាងគណបក្សជាតិនិយម សុំឱ្យបកស្រាយបំភ្លឺនូវខ្លឹមសារមាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយដែលបានចែងអំពីគណបក្សនយោបាយ អាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបានក្នុងបរិបទនៃសំណួរមួយដែលសួរថា : **តើការប្រកាសរួមបញ្ចូលគ្នានេះ ធ្វើឱ្យប៉ះពាល់ដល់អាសនៈ ឬ លទ្ធផលបោះឆ្នោតសកល និង អសកលកន្លងមកដែរឬទេ ?**
- យល់ឃើញថា មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ÷

• វាក្យខ័ណ្ឌទី១ ចែងថា " *គណបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបាន តាមការកំណត់របស់លក្ខន្តិកៈ ។ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែង ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាតគណបក្សនយោបាយ* " ។

**វាក្យខ័ណ្ឌទី១ នៃមាត្រា ៣៦ នេះ មានន័យថា** ច្បាប់អនុញ្ញាតឱ្យគណបក្សនយោបាយ អាចរួមបញ្ចូលគ្នាតាមលក្ខន្តិកៈកំណត់ ឬ បើពុំដូច្នោះទេ តាមសេចក្តីសម្រេចនៃមហាសន្និបាតរបស់គណបក្សនយោបាយនោះ ។

• វាក្យខ័ណ្ឌទី២ ចែងថា " *ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះគណបក្សនយោបាយ ដែលបានប្រកាសរួមបញ្ចូលគ្នានោះ ចេញពីបញ្ជីគណបក្សនយោបាយ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីការរួមបញ្ចូលនោះ* " ។

**វាក្យខ័ណ្ឌទី២ នៃមាត្រា ៣៦ នេះ មានន័យថា** តម្រូវឱ្យគណបក្សនយោបាយដែលប្រកាសរួមបញ្ចូលគ្នាធ្វើលិខិតជូនដំណឹងទៅក្រសួងមហាផ្ទៃ ។ ក្រសួងមហាផ្ទៃក្រោយបានទទួលលិខិតជូនដំណឹងនេះ **ត្រូវលុបឈ្មោះគណបក្សនយោបាយនោះចេញពីបញ្ជីគណបក្សនយោបាយ ។**

**ទោះបីជាមាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយខាងលើនេះ** ពុំបានចែងពីផលប៉ះពាល់ដល់អាសនៈ ឬ លទ្ធផលបោះឆ្នោតសកល និង អសកលកន្លងមក ក្រោយពីការប្រកាសរួមបញ្ចូលគ្នានេះក្តី ប៉ុន្តែបញ្ហានឹងកើតមានឡើង ដូចមានចែងនៅក្នុងមាត្រា ១១៨ ថ្មី ចំណុច "ង" នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ " *ក្នុងករណីគណបក្សនយោបាយមួយទទួលបានអាសនៈមួយ ឬ ច្រើននៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និង បេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថាជាប់ឆ្នោតរួចហើយ <u>មិនមានសុពលភាព និង មិនមានគុណសម្បត្តិទៅទៀតបានឡើយ</u>* ។

*ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះក្នុងរយៈពេលប្រាំពីរ ( ៧ ) ថ្ងៃ ទៅឱ្យគណបក្សនយោបាយផ្សេង ដែលទទួលបានអាសនៈក្នុងខេត្ត ក្រុង ជាមួយតាមជំហានទាំងឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់អាសនៈ ... ។ "*

ដូច្នេះ យោងតាមមាត្រា ១១៨ ថ្មី ចំណុច "ង" នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃប្រកាសលុបឈ្មោះគណបក្សនយោបាយដែលប្រកាសរួមបញ្ចូលជាមួយគណបក្សនយោបាយមួយផ្សេងទៀតពីបញ្ជីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏មានភារកិច្ចពិនិត្យ និង អនុវត្តទៅតាមបទប្បញ្ញត្តិមួយចំនួនដូចខាងក្រោម ÷

- មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "*ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ ខែ យ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ* ***តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។ "***

- មាត្រា ១១៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា " *ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាព ដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំង ឬ ជ្រើសតាំងសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ "*

- មាត្រា ៣១ ជំពូកទី៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង ប្រការ ១០ ថ្មី វាក្យខ័ណ្ឌទី២ ប្រការ ១១ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

- មាត្រា ៣៧ ថ្មី វាក្យខ័ណ្ឌទី២ នៃជំពូកទី៤ មាត្រា ១២០ ថ្មី នៃជំពូកទី៩ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ប្រការ ៨៣ ថ្មី នៃជំពូកទី១៧ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

- មាត្រា ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

- មាត្រា ១៣ ចំណុច ង មាត្រា ១៦ និង មាត្រា ២២ វាក្យខ័ណ្ឌទី៣ និង វាក្យខ័ណ្ឌទី៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

- មាត្រា ២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

• មាត្រា ២៧ មាត្រា ៥០ ថ្មី ( មាត្រា ៩៩ ចាស់ ) និង មាត្រា ៥២ ថ្មី ( មាត្រា ១០១ ចាស់កែប្រែ ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

- យល់ឃើញថា ប្រព័ន្ធបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា **ជាប្រព័ន្ធសមាមាត្រ** ដូចមានចែងនៅក្នុង ÷

• មាត្រា ៨ ជំពូកទី២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ចែងថា " *ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ...* "

• មាត្រា ៥ វាក្យខ័ណ្ឌទី២ ជំពូកទី២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា " *ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមខេត្ត ក្រុងជាមណ្ឌលបោះឆ្នោត ។* "

• មាត្រា ១៣ ផ្នែកទី២ ជំពូកទី២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ចែងថា " **ក-** *ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ... ។* "

• មាត្រា ៥ ជំពូកទី១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែងថា " *ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមប្រព័ន្ធសមាមាត្រ ... ។* "

- យល់ឃើញថា ដើម្បីចុះឈ្មោះជាបេក្ខជនឈរឈ្មោះបោះឆ្នោតបាន បុគ្គលម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនគណបក្សនយោបាយមួយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងមហាផ្ទៃ ដូចមានចែងនៅក្នុង ÷

• មាត្រា ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ចែងថា " *ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ។*

*បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។* "

• មាត្រា ៥០ ថ្មី ( មាត្រា ៩៩ ចាស់ ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែងថា " *បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។* "

• មាត្រា ៥២ ថ្មី ( មាត្រា ១០១ ចាស់កែប្រែ ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែងថា " *ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ :*

*- សេចក្តីចម្លងលិខិតបញ្ជាក់ពីការចុះបញ្ជីគណបក្សនយោបាយនៃក្រសួងមហាផ្ទៃមួយច្បាប់ ។*

*... ។"*

- យល់ឃើញថា តាមបទប្បញ្ញត្តិមួយចំនួនដូចបានលើកឡើងខាងលើ បញ្ជាក់បានថា បេក្ខជនគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនគណបក្សនយោបាយមួយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងមហាផ្ទៃ ។ ដូច្នេះ ប្រសិនជាគណបក្សនយោបាយត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ តំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភា ក្នុងតំណែងរបស់គណបក្សនយោបាយនោះ នឹងត្រូវបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា ១២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រការ ៨៣ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា មាត្រា ៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង ប្រការ ១០ ថ្មី វាក្យខ័ណ្ឌទី២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- យល់ឃើញថា ដោយសារការបោះឆ្នោតសកល និង អសកលកន្លងមក ត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ ដូចបានលើកឡើងក្នុងបទប្បញ្ញត្តិមួយចំនួនខាងលើ នៅពេលគណបក្សនយោបាយដែលមានអាសនៈ ប្រកាសរួមបញ្ចូលគ្នា ក្នុងករណីណាមួយខាងក្រោមនេះ មានផលប៉ះពាល់ដូចតទៅ ÷

**ករណីទីមួយ :**

• ករណីគណបក្សនយោបាយ **ក** និង គណបក្សនយោបាយ **ខ** ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សនយោបាយតែមួយ ដោយធ្វើការជ្រើសរើសយកឈ្មោះគណបក្សនយោបាយ **ក** ជាគណបក្សនយោបាយដែលបានពីការប្រកាសរួមបញ្ចូលគ្នា ។

ករណីនេះ គណបក្សនយោបាយ **ខ** ត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។ ដូច្នេះគណបក្សនយោបាយ **ខ** ត្រូវបានរងការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។

**ករណីទីពីរ :**

• ផ្ទុយទៅវិញគណបក្សនយោបាយ **ក** និង គណបក្សនយោបាយ **ខ** ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សនយោបាយតែមួយដោយធ្វើការជ្រើសរើសយកឈ្មោះគណបក្សនយោបាយ **ខ** ជាគណបក្សនយោបាយដែលបានពីការប្រកាសរួមបញ្ចូលគ្នា ។

ករណីនេះ គណបក្សនយោបាយ **ក** ត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។ ដូច្នេះគណបក្សនយោបាយ **ក** ត្រូវបានរងការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។

**ករណីទីបី :**

• គណបក្សនយោបាយ **ក** និង គណបក្សនយោបាយ **ខ** ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សនយោបាយតែមួយដោយបង្កើតគណបក្សនយោបាយថ្មីមួយទៀតឈ្មោះ **គ** ។

ករណីនេះ គណបក្សនយោបាយ **ក** និង គណបក្សនយោបាយ **ខ** ត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។ ដូច្នេះ គណបក្សនយោបាយទាំងពីរ **ក** និង **ខ** ត្រូវបានរងការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ

- យល់ឃើញថា ទោះក្នុងករណីណាក៏ដោយ គណបក្សនយោបាយណាមួយដែលបានទទួលអាសនៈមួយ ឬច្រើន ហើយត្រូវបានក្រសួងមហាផ្ទៃប្រកាសលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និង បេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយនោះ មិនមានសុពលភាព និង មិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

## សម្រេច

**មាត្រា ១ ~** មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២ ~** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧៧/០០៨/២០១០

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០

**សេចក្តីសម្រេច**

លេខ : ១១២/០០៥/២០១០ កបធ.ច

ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិត ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១០ របស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រ ចំនួន ២២រូប ដែលមានឯកឧត្តម **ស៊ុក ច៊ុនហុក** ជាតំណាង ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយអំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៩៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតនេះ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០ វេលាម៉ោង ១៦ និង ១៥នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតរបស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រចំនួន ២២រូប ដែលបានស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ អំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ បានធ្វើឡើងស្របតាមមាត្រា ១៣៦ថ្មី មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ថ្មី មាត្រា ១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើនេះមកពិនិត្យបាន
- យល់ឃើញថា សមាជរដ្ឋសភានិង ព្រឹទ្ធសភា មានចែងក្នុងមាត្រា១១៦ថ្មី និង មាត្រា១១៧ថ្មី ជំពូកទី៩ថ្មី នៃរដ្ឋធម្មនុញ្ញ ដូចតទៅ ÷

មាត្រា ១១៦._ថ្មី *ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។*

មាត្រា ១១៧._ថ្មី *បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជ នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។*

- យល់ឃើញថា មាត្រា ១៥៧ថ្មី ជំពូកទី១៦ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា ÷

មាត្រា ១៥៧._ថ្មី *នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។*

*សម្រាប់នីតិកាលទី១ នៃព្រឹទ្ធសភា :*

*-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។*

*-ព្រះមហាក្សត្រ ទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។*

*-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភានិង ប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ។*

*-កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។*

តាមខ្លឹមសារនៃមាត្រា ១៥៧ថ្មីនេះ ថិរវេលាសុពលភាពនៃចំណុចទី៤ វាក្យខណ្ឌទី២ នៃមាត្រាខាងលើ មានមិនលើសពីថិរវេលានៃនីតិកាលទី១របស់ព្រឹទ្ធសភាទេ មានន័យថា កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយប្រធានរដ្ឋសភា និង ប្រធានព្រឹទ្ធសភា ក្នុងឋានៈជាសហប្រធានបានតែនៅក្នុងនីតិកាលទី១នៃព្រឹទ្ធសភាតែប៉ុណ្ណោះ ។

ចំពោះកិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ក្នុងនីតិកាលជាបន្តបន្ទាប់ទៀតរបស់ព្រឹទ្ធសភា នឹងត្រូវរៀបចំ និង ប្រព្រឹត្តទៅតាមច្បាប់មួយ ដូចមានចែងក្នុងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។

## សម្រេច

**មាត្រា ១.-** បទប្បញ្ញត្តិនៃចំណុចទី៤ វាក្យខណ្ឌទី២ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៧៨/០០១/២០១១

ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៣/០០១/២០១១ កបធ.ច

ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៦៩ រ.ស ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ២០១១ របស់ឯកឧត្តម **ឈួន ញិល** ប្រធានរដ្ឋសភាស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែមករា ឆ្នាំ២០១១ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១ វេលាម៉ោង ១៥ និង ៤៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខួន ញុឹល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា ដែលចែងអំពីគោលដៅកំណត់ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា និយមន័យនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីការរៀបចំសមាជ មាន ៦ មាត្រា ចែងអំពីប្រធានសមាជ ទីកន្លែងប្រារព្ធធ្វើសមាជ សមាសភាពគណៈកម្មាធិការសមាជ មុខងាររបស់ប្រធានសមាជ អគ្គលេខាធិការដ្ឋានសមាជ និងបន្ទុកចំណាយសម្រាប់ដំណើរការសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពីការប្រព្រឹត្តទៅនៃសមាជ មាន ៤ មាត្រា ចែងអំពីឥស្សរជនដែលមានសិទ្ធិផ្តួចផ្តើមឱ្យមានការប្រជុំសមាជ ការកោះអញ្ជើញឱ្យចូលរួមប្រជុំសមាជ កូរ៉ុមនៃការប្រជុំសមាជ សំឡេងអនុម័តរបស់សមាជ តម្លៃនៃសេចក្តីសម្រេចរបស់សមាជ ការផ្សព្វផ្សាយ និង ការចុះក្នុងរាជកិច្ច ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៤ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា ចែងអំពីរយៈពេលនៃការកោះប្រជុំលើកដំបូងរបស់សមាជ ដើម្បីពិនិត្យ និង អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សមាជ និង ការអនុវត្តបទបញ្ជាផ្ទៃក្នុងរដ្ឋសភាសម្រាប់ដំណើរការកិច្ចប្រជុំសមាជលើកដំបូង ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង៤ជំពូក ១៤មាត្រា នៃច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សំណុំរឿង**

លេខ : ១៧៩/០០២/២០១១

ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៤/០០២/២០១១ កបធ.ច

ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១១

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១១/០០៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ១១៣/០០១/២០១១កបធ.ច ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១ ប្រកាសថា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- បានឃើញលិខិតលេខ ០០៤/១១ ស.ម ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១ របស់សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ប្រធានសមាជស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ដែលសមាជរដ្ឋសភានិងព្រឹទ្ធសភាប្រជុំលើកដំបូង នាថ្ងៃទី ២៦ ខែ មេសា

ឆ្នាំ២០១១ បានអនុម័តដោយសំឡេង ១៣១/១៥៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ២០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ជាបទបញ្ជាផ្ទៃក្នុងមួយពិសេសសម្រាប់ស្ថាប័ននីតិបញ្ញត្តិកំពូលរដ្ឋសភានិងព្រឹទ្ធសភា អនុវត្តក្នុងកាលៈទេសៈដែលប្រទេសជាតិមានបញ្ហាសំខាន់ៗត្រូវដោះស្រាយ
- យល់ឃើញថា នៅក្នុងដំណើរការនៃកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភាលើកដំបូង បទបញ្ជាផ្ទៃក្នុងរដ្ឋសភាត្រូវយកមកអនុវត្ត រហូតដល់សមាជអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនបាន
- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុងនេះ
- យល់ឃើញថា លិខិតរបស់សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ប្រធានសមាជស្តីទី ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន
- យល់ឃើញថា សមាជរដ្ឋសភានិងព្រឹទ្ធសភាលើកដំបូង បានអនុម័តបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ ដោយទទួលបានសំឡេងចំនួន ១៣១/ ១៥៥ ស្របតាមមាត្រា១៤ ជំពូកទី៤ អំពីអន្តរប្បញ្ញត្តិ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១១/០០៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១១ ដែលចែងថា " *សមាជប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល៦០ ( ហុកសិប) ថ្ងៃ យ៉ាងយូរក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បីពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល និង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* ។ "
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី១ អំពីបទប្បញ្ញត្តិទូទៅ** មានពីរប្រការ ដែលកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា អំពីនីតិវិធីទាំងឡាយដែលត្រូវអនុវត្តក្នុងសមាជ និង អំពីអធិបតីភាព ព្រមទាំងសមាជិកនៃអង្គសមាជ ពុំមានបទប្បញ្ញត្តិណា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **ជំពូកទី២ អំពីប្រធាន អនុប្រធាន និង គណៈកម្មាធិការសមាជ** មានបួនប្រការ គឺប្រការ ៣ ដល់ប្រការ៦ ក្នុងនោះ ប្រការ ៣ និង ប្រការ ៦ ចែងអំពីសមាសភាពគណៈកម្មាធិការសមាជ និង អំពីតួនាទីរបស់គណៈកម្មាធិការសមាជ រីឯប្រការ ៤ ចែងអំពីមុខងារប្រធានសមាជ ។ ប្រការ ៣ ប្រការ ៤ និង ប្រការ ៦ នៃបទបញ្ជាផ្ទៃក្នុងនេះស្របទៅនឹងមាត្រា ៦ មាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ព្រមទាំងស្របនឹងរដ្ឋធម្មនុញ្ញ ។ ចំណែកឯវាក្យខណ្ឌទី១ នៃប្រការ ៥ គឺផ្ទុយនឹងបទប្បញ្ញត្តិវាក្យខណ្ឌទី២ មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ដែលពុំមានចែងអំពី " អនុប្រធានសមាជ " និង " អនុប្រធានសមាជធ្វើការជួសប្រធានតាមលិខិតផ្ទេរសិទ្ធិ " ទេ ។ ចំពោះវាក្យខណ្ឌទី២ នៃប្រការ ៥ គឺស្របនឹងបទប្បញ្ញត្តិវាក្យខណ្ឌទី៣ មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា និងស្របតាមរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី៣ អំពីអគ្គលេខាធិការដ្ឋានសមាជ** ដែលមានពីរប្រការ គឺប្រការ ៧ និងប្រការ ៨ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី៤ អំពីរបៀបវារៈ** មានពីរប្រការ គឺប្រការ ៩ និង ប្រការ១០ ដែលចែងអំពីគណៈកម្មាធិការសមាជជាអ្នករៀបចំរបៀបវារៈកិច្ចប្រជុំសមាជ និង អំពីការរៀបចំលំដាប់មុនក្រោយរបស់របៀបវារៈនៃអង្គប្រជុំសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី៥ អំពីរបៀបប្រជុំសមាជ** មានដប់បួនប្រការ ពីប្រការ ១១ ដល់ប្រការ ២៤ ដែលចែងអំពីការរៀបចំអាសនានុក្រមនៃសមាជិកសមាជ អំពីប្រធាន អនុប្រធាន និងចំនួនសមាជិកនៅក្នុងក្រុមនីមួយៗ អំពីថ្ងៃប្រជុំនិងទីកន្លែងប្រជុំសមាជ អំពីលិខិតអញ្ជើញ អំពីកូរ៉ុម អំពីការប្រជុំសមាជ អំពីលេខាធិការសមាជ និងភារកិច្ចរបស់លេខាធិការសមាជ អំពីការជជែកពិភាក្សា និង អំពីវិន័យនៃការជជែកពិភាក្សា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី៦ អំពីការរក្សាសេចក្តីស្ងប់ស្ងាត់ក្នុងពេលប្រជុំ** មានមួយប្រការ គឺប្រការ ២៥ ដែលចែងអំពីភារៈរបស់ប្រធានសមាជ រក្សាការពារមិនឱ្យមានភាពជ្រួលច្របល់ និង ភយន្តរាយកើតមានឡើងដល់សមាជ ហើយប្រធានសមាជអាចសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងទ័ព ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី៧ អំពីការខានមកប្រជុំ** មានមួយប្រការ គឺប្រការ ២៦ ដែលកំណត់អំពីអវត្តមាននិងការជូនដំណឹងមកប្រធានសមាជអំពីអវត្តមានរបស់សមាជិកសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **ជំពូកទី៨ អំពីការបញ្ចេញមតិ** មានបីប្រការ គឺប្រការ ២៧ ដល់ប្រការ ២៩ ដែលចែងអំពីវិធីនៃការបញ្ចេញមតិ អំពីនីតិវិធីនៃការបោះឆ្នោតបញ្ចេញមតិរបស់អង្គសមាជត្រូវអនុវត្តតាមប្រការ ៣៧ ប្រការ ៣៨ ថ្មី និង ប្រការ ៣៩ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និង កំណត់ចំនួនសំឡេងអនុម័តរបស់សមាជ ព្រមទាំងការប្រកាសលទ្ធផលនៃការបញ្ចេញមតិរបស់អង្គសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី៩ អំពីវិន័យ** មានមួយប្រការ គឺប្រការ ៣០ ដែលកំណត់យកប្រការ ៧៣ ប្រការ ៧៤ ប្រការ ៧៥ និង ប្រការ ៧៩ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា សម្រាប់ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះសមាជិកសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី១០ អំពីការកែប្រែបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា** មានមួយប្រការ គឺប្រការ ៣១ ដែលកំណត់នូវចំនួនសមាជិកសមាជដែលអាចសុំកែប្រែបទបញ្ជាផ្ទៃក្នុង និងចំនួនសំឡេងនៃការអនុម័ត ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា នៅក្នុងគ្រប់ជំពូក និងប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែវាក្យខណ្ឌទី១ នៃប្រការ ៥ ។

## សម្រេច

**មាត្រា ១.-** បទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ដែលសមាជរដ្ឋសភានិងព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែវាក្យខណ្ឌទី១ នៃប្រការ ៥ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៨០/០០៣/២០១១

ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៥/០០៣/២០១១ កបធ.ច

ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញលិខិតលេខ ៣៦០ រ.ស ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១១ របស់ឯកឧត្តម **ខួន ញឹុល** ប្រធានរដ្ឋសភាស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ៤០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខួន ញ៉ឹល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ មាន **ពីរមាត្រា** និង មានខ្លឹមសារដូចខាងក្រោម ៖

**មាត្រាមួយ.-** ត្រូវបានបន្ថែមមាត្រា ១០ស្ទួន កែប្រែមាត្រា ១៦ និង លុបមាត្រា ៥៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១០ ។

**មាត្រាពីរ.-** ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

- យល់ឃើញថា វិសោធនកម្មខាងលើនេះ បានធ្វើឡើងតែទៅលើ បីមាត្រា ប៉ុណ្ណោះ ÷
  ១- មាត្រា ១០ស្ទួន ចែងថា ÷ " *ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចេញប្រកាសក្នុងការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន និងការតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច មន្ត្រីក្របខណ្ឌស្ថាប័នប្រឆាំងអំពើពុករលួយចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។* " មាត្រា ១០ស្ទួន នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។
  ២- មាត្រា ១៦ថ្មី ចែងថា ÷ " *ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការបស់ជាតិ ។ ស្ថាប័នប្រឆាំងអំពើពុករលួយទទួលធនធានចាំបាច់នានាពីរដ្ឋាភិបាល និងមានសិទ្ធិទទួលនូវអំណោយ ឬ ជំនួយពីអង្គការជាតិ អន្តរជាតិនានា ។ ស្ថាប័នប្រឆាំងអំពើពុករលួយ មិនត្រូវទទួលជំនួយណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ។*

  *ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអាណាប័កដើមខ្សែ ។*

*ការគ្រប់គ្រង និងចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។ "*

ពាក្យ "*រដ្ឋាភិបាល* " ដែលមានសរសេរនៅក្នុងឃ្លាទី២ វាក្យខណ្ឌទី១ មាត្រា ១៦ថ្មី មិនស្របនឹងជំពូកទី ១០ថ្មី នៃរដ្ឋធម្មនុញ្ញទេ។ ហេតុដូច្នេះ បទប្បញ្ញត្តិនៃវាក្យខណ្ឌទី១ មាត្រា ១៦ថ្មី ត្រូវបានប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ។ រីឯបទប្បញ្ញត្តិនៃវាក្យខណ្ឌទី២ និង វាក្យខណ្ឌទី៣ មាត្រា ១៦ថ្មី ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៣- **មាត្រា ៥៧** ត្រូវបានលុបចោល ។ មាត្រានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែវាក្យខណ្ឌទី១ មាត្រា ១៦ថ្មី ក្នុង **មាត្រាមួយ** ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែវាក្យខណ្ឌទី១ មាត្រា ១៦ថ្មី ក្នុង **មាត្រាមួយ** ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៨១/០០៤/២០១១

ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៦/០០៤/២០១១ កបធ.ច

ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១១

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៤៣៤ រ.ស ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១

ខែ ឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១ វេលាម៉ោង ១៧ និង ០៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាន **ពីរមាត្រា** និង មានខ្លឹមសារដូចខាងក្រោម ÷

**មាត្រាមួយ.**_ ត្រូវបានកែប្រែមាត្រា ១០៩ មាត្រា ១៣១ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះ-ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ មាត្រា ៣២ថ្មី មាត្រា ៥៤ថ្មី មាត្រា ៥៦ថ្មី មាត្រា ៥៩ថ្មី មាត្រា ៦១ថ្មី មាត្រា ៦២ថ្មី មាត្រា ៦៤ថ្មី មាត្រា ៦៥ថ្មី មាត្រា ៦៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ និងមាត្រា ៤៩ថ្មី(ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។

**មាត្រាពីរ.-** ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រខាងលើនេះ បានធ្វើវិសោធនកម្មទៅលើ ១៣ មាត្រា ដូចខាងក្រោម ÷

១-មាត្រា ៣២.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **៣២.- ថ្មី**(ពីរ)

- កែពី " គណៈកម្មការខេត្ត ក្រុង " ទៅជា *" គណៈកម្មការរាជធានី ខេត្ត "* ក្នុងវាក្យខ័ណ្ឌទី២
- កែពី " មាត្រា ១៣ ថ្មី " ទៅជា *" មាត្រា ១៣ថ្មី (ពីរ) "* ក្នុងវាក្យខ័ណ្ឌទី៤

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៣២ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

២-មាត្រា ៤៩.- ថ្មី(ពីរ) ត្រូវបានធ្វើវិសោធនកម្មទៅជា **មាត្រា ៤៩.- ថ្មី**(បី)

កែពី " ដប់ប្រាំ (១៥)ថ្ងៃ " ទៅជា *" សាមសិប (៣០) ថ្ងៃ "* ក្នុងវាក្យខ័ណ្ឌទី២ និងបានបន្ថែមមួយវាក្យខ័ណ្ឌ *" ការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត និង ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបង្កើតថ្មីដែលត្រូវកែប្រែព្រំប្រទល់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌដែលចែងក្នុងច្បាប់នេះ និងបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "* ជាវាក្យខ័ណ្ឌទី៤ ។

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៤៩ ថ្មី(បី)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៣-មាត្រា ៥៤.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **៥៤.- ថ្មី**(ពីរ)

- កែពី " មាត្រា ៤៩ ថ្មី(ពីរ) " ទៅជា *" មាត្រា ៤៩ ថ្មី(បី) "* ក្នុងចំណុច **ក**
- កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងចំណុច **ឃ ខ** និង **ច**

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៥៤ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៤-មាត្រា ៥៦.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **៥៦.- ថ្មី**(ពីរ)

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី១
- កែពី " គណៈកម្មការខេត្ត ក្រុង " ទៅជា *" គណៈកម្មការរាជធានី ខេត្ត "* ក្នុងវាក្យខ័ណ្ឌទី២

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៥៦ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៥-មាត្រា ៥៩.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៥៩.- ថ្មី(ពីរ)

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី១

- កែពី " គណៈកម្មការខេត្ត ក្រុង " ទៅជា *" គណៈកម្មការរាជធានី ខេត្ត "* ក្នុងវាក្យខ័ណ្ឌទី២

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៥៩ ថ្មី (ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៦-មាត្រា ៦១.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦១.- ថ្មី(ពីរ)

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី២

- កែពី " មាត្រា ៦២ ថ្មី " ទៅជា *" មាត្រា ៦២ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី៣

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦១ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៧-មាត្រា ៦២.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦២.- ថ្មី(ពីរ)

កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី៤

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦២ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

៨-មាត្រា ៦៤.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦៤.- ថ្មី(ពីរ)

កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* និងបន្ថែមវាក្យខ័ណ្ឌទី៤ *" នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹងដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ មានរយៈពេលដប់ (១០) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។ "*

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦៤ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៩-មាត្រា ៦៥.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦៥.- ថ្មី(ពីរ)

កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី៥

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦៥ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១០-មាត្រា ៦៦.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦៦.- ថ្មី(ពីរ)

កែពី " មាត្រា ៥៤ ថ្មី " ទៅជា *" មាត្រា ៥៤ ថ្មី(ពីរ) "* ក្នុងវាក្យខ័ណ្ឌទី៣ បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦៦ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

១១-មាត្រា ១០៩.~ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១០៩.- ថ្មី

"គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត *រួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។ កំណត់ហេតុនេះត្រូវធ្វើជាបួនច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត មួយច្បាប់បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងមួយច្បាប់ទៀតទុកជាឯកសារ* ។ "

បន្ថែមវាក្យខ័ណ្ឌទី២ និងទី៣ ដូចតទៅ *"ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬ ពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់ ។ "*

*" ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬ តំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះ-ឆ្នោតជាបន្ទាន់ ។"*

មាត្រា ១០៩ ថ្មីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១២-មាត្រា ១៣១.~ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១៣១.- ថ្មី

"ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.000.000)រៀលទៅដល់ដប់លាន (១០.000.000) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ និង*ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ* ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹង *មាត្រា ៧៣ថ្មី* ឬ មាត្រា ៧៦ នៃច្បាប់នេះ។ "

មាត្រា ១៣១ ថ្មីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១៣-មាត្រា ១៣៣.~ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១៣៣.- ថ្មី

" ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧២ នៃច្បាប់នេះ ។ ក្នុងករណីដែលពុំ

ព្រមអនុវត្តតាម ត្រូវ*លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត* សម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬនិងត្រូវផ្តន្ទា ទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ដល់ដប់លាន(១០.០០០.០០០) រៀល ។"

មាត្រា ១៣៣ ថ្មីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា មាត្រាមួយ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៨២/០០៥/២០១១

ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៧/០០៥/២០១១ កបធ.ច

ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញលិខិតលេខ ៤៣៥ រ.ស ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភា

បានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ហើយអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១ វេលាម៉ោង ១៧ និង ០៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាន **ពីរមាត្រា**
- យល់ឃើញថា ក្នុង**មាត្រាមួយ**នៃច្បាប់ខាងលើនេះ មាត្រា ១៩០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១៩០ ថ្មី(ពីរ) ដោយពន្យារកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ទៅធ្វើនៅថ្ងៃអាទិត្យ ទី ០៣ ខែ មិថុនា ឆ្នាំ២០១២ វិញ ។

មាត្រា ១៩០.- ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៨៤/០០៧/២០១១

ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៨/០០៦/២០១១ កបធ.ច

ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១១

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញសេចក្តីសម្រេចលេខ ១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញលិខិតលេខ ៦៣៣ រ.ស ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានរដ្ឋសភាអនុម័តកែសម្រួលនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថា គ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ ឡើយ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី០៦ ខែ កក្កដា ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន
- យល់ឃើញថា តាមសេចក្តីសម្រេចលេខ ១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចក្នុងមាត្រា១ ដូចតទៅ " *ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែវាក្យខណ្ឌទី១ មាត្រា ១៦ ថ្មី ក្នុង**មាត្រាមួយ*** ។ "
- យល់ឃើញថា បន្ទាប់ពីមានសំណើរបស់រាជរដ្ឋាភិបាលលេខ ៣៩៩ លស.កបច ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១១ រដ្ឋសភាបានកែតម្រូវវាក្យខណ្ឌទី១ មាត្រា១៦ថ្មី *ក្នុង**មាត្រាមួយ*** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយរួចហើយ កាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ ដើម្បីឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ ។ ព្រឹទ្ធសភាបាន

ប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថាគ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ ឡើយ

- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

# សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានកែតម្រូវនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថាគ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ឡើយ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៨៩/០១២/២០១១

ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១១៩/០០៧/២០១១ កបធ.ច

ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១១

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០០១/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោតដំបូងឃុំកំពង់លួង ចំនួន ១៩ នាក់ និង រក្សាទុកឈ្មោះអ្នកបោះឆ្នោតចំនួន ៣៩ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងក្នុងឃុំកំពង់លួង
- បានឃើញពាក្យបណ្តឹងលេខ គសរ : ១៣៥/១១ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់លោក **រស់ សួរ** តំណាងឱ្យឈ្មោះ **ម៉ៅ ឌីយ៉ាម៉ង់** មានតួនាទីជាតំណាងគណបក្ស សម រង្ស៊ី ប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ០០១/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចលេខ ០០១/១១ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

លោក **រស់ សួរ** ជាតំណាងរបស់លោក **ម៉ៅ ឌីយ៉ាម៉ង់** បានមកដាក់ពាក្យបណ្តឹងលេខ គសរ : ១៣៥/១១ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចលេខ ០០១/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អគ្គ-លេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យបណ្តឹងនេះ នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ វេលាម៉ោង ១៥:១៥ នាទី ។

បណ្តឹងរបស់លោក **រស់ សួរ** ខាងលើនេះ ស្ថិតក្នុងរយៈពេលកំណត់ក្នុងមាត្រា ៦៥ថ្មី(ពីរ) វាក្យខណ្ឌទី៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើនេះមកពិនិត្យបាន

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ និង នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោក **រស់ សួរ** បានបញ្ជាក់ថា :

" បណ្តឹងចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១១ ដែលបានអានឱ្យខ្ញុំស្តាប់នេះ ជាពាក្យបណ្តឹងខ្ញុំហើយ

ហើយលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១១ របស់លោក **ម៉ៅ ឌីយ៉ាម៉ង់** ផ្ទេរសិទ្ធិឱ្យខ្ញុំបាទដើម្បីប្តឹងបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិតជាពាក្យរបស់លោក **ម៉ៅ ឌីយ៉ាម៉ង់** មែន ។ ខ្ញុំសូមបញ្ជាក់បន្ថែមលើពាក្យបណ្តឹងរបស់ខ្ញុំដូចតទៅនេះ : នៅក្នុងពាក្យបណ្តឹងរបស់ខ្ញុំ ដែលដាក់ថាមានតួនាទីជាតំណាងគណបក្ស សម រង្ស៊ី មកពីលោក **ម៉ៅ ឌីយ៉ាម៉ង់** កាលពីនៅថ្នាក់ ឃុំកំពង់លួង លោក **ម៉ៅ ឌីយ៉ាម៉ង់** ប្តឹងក្នុងនាមគណបក្ស សម រង្ស៊ី ហើយនៅគណៈកម្មាធិការជាតិរៀបចំការ-បោះឆ្នោត គាត់ប្រគល់សិទ្ធិមកឱ្យខ្ញុំជាតំណាង ។ ហេតុនេះហើយ ទើបខ្ញុំប្តឹងមកក្រុម-ប្រឹក្សាធម្មនុញ្ញ ដាក់ថាជាតំណាងគណបក្ស សម រង្ស៊ី ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំប្តឹងមកនេះ ជាតំណាងរបស់ឈ្មោះ **ម៉ៅ ឌីយ៉ាម៉ង់** មានតួនាទីជាតំណាងគណបក្ស សម រង្ស៊ី ។

នៅថ្នាក់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ខ្ញុំប្តឹងទាមទារឱ្យលុបឈ្មោះជនបរទេស ៥៨ នាក់ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសម្រេចលុបឈ្មោះ ១៩ នាក់ និង រក្សាទុក ៣៩ នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ។ ដូច្នេះ ខ្ញុំសូមក្រុម-ប្រឹក្សាធម្មនុញ្ញ មេត្តាសម្រេចលុបឈ្មោះជនជាតិវៀតណាម ៣៩ នាក់ទៀត ចេញពីបញ្ជីបោះឆ្នោតដំបូងក្នុងឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ។

ចំពោះជនជាតិវៀតណាមទាំងនោះ មកតាំងទីលំនៅនៅកម្ពុជា ឆ្នាំ១៩៩១ ១៩៩២ មានខ្លះនៅឆ្នាំ១៩៨៥ ។ តាមខ្ញុំបានដឹង ឈ្មោះវៀតណាមទាំងនោះ មានឈ្មោះបោះឆ្នោតតាំងពីឆ្នាំ២០០៣ មក ។ ”

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ និង នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយថា :

“ លោក **រស់ សួរ** បានប្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យលុបឈ្មោះជនបរទេសក្នុងបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១១ សរុបចំនួន ៥៨ នាក់ នៅឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ។

ខ្ញុំសូមជម្រាបថា បញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១១ គឺជាបញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ២០១០ ដែលត្រូវបានធ្វើបច្ចុប្បន្នភាព ដោយលុបឈ្មោះអ្នកស្លាប់ អ្នកប្តូរទីលំនៅ និងអ្នកគ្មានទីលំនៅជាដើម និង ដែលកែតម្រូវឈ្មោះ បូកបញ្ចូលជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោតថ្មីក្នុងឆ្នាំ២០១១ ។

ជនទាំង ៥៨ នាក់ ដែលលោក **រស់ សួរ** អះអាងថាជាជនបរទេសនោះ ពុំមានអ្វីជាសំអាងត្រឹមត្រូវទេ តាមពិតគឺអ្នកទាំងនោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតតាំងពីឆ្នាំ២០០៣ មកម្ល៉េះ ។

នៅពេលសាកសួរបន្ថែម ក៏ដូចជានៅពេលសវនាការជំនុំជម្រះនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១១ លោក **រស់ សួរ** គ្រាន់តែអះអាងដោយផ្ទាល់មាត់ ដោយសំដៅទៅលើសំនៀងនិយាយ ពណិសម្បុរ ឈ្មោះ ត្រកូល ដោយពុំមានឯកសារភស្តុតាងបញ្ជាក់ច្បាស់លាស់ឡើយ ។

ខ្ញុំបាទសូមបញ្ជាក់បន្ថែមទៀតថា ក្នុងចំណោមឈ្មោះទាំង ៥៨ នាក់ ដែលឈ្មោះ **រស់ សួរ** បានលើកឡើងនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសម្រេចលុបឈ្មោះ ១៩ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងឃុំកំពង់លួង ដោយមូលហេតុថាក្នុងអ្នកទាំង ១៩ នាក់នោះ មាន ១៥ នាក់ គ្មានទីលំនៅក្នុងឃុំកំពង់លួង និង ៤ នាក់ទៀត ស្លាប់។ ចំពោះអ្នក ៣៩ នាក់ផ្សេងទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចរក្សាទុកក្នុងបញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១១ឃុំកំពង់លួង ដោយហេតុថា ÷

-កំពុងរស់នៅក្នុងឃុំកំពង់លួង

-គ្មានឈ្មោះក្នុងបញ្ជីគ្រប់គ្រងជនអន្តោប្រវេសន៍

-មានលក្ខខណ្ឌគ្រប់គ្រាន់ស្របតាមមាត្រា ៥៤ថ្មី(ពីរ)ចំណុច គ -(ត្រេ)ទី៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា តាមបទប្បញ្ញត្តិនៃមាត្រា ៥៤ ថ្មី(ពីរ) ចំណុច គ " ដើម្បីបញ្ជាក់ថាខ្លួនជាប្រជាពលរដ្ឋខ្មែរ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម :

- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលបានផ្តល់ឱ្យ អនុលោមទៅតាមច្បាប់សញ្ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬ កងយោធពលខេមរភូមិន្ទ ឬ នគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

- ឆាយារបស់ព្រះសង្ឃ ។

- ភស្តុតាងដែលបង្ហាញថា ឈ្មោះរបស់អ្នកសុំចុះឈ្មោះមាននៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ និងសៀវភៅបញ្ជីបោះឆ្នោតរបស់ឃុំ សង្កាត់ ។

- សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែរ ។

- លិខិតបញ្ជាក់ថាជាប្រជាពលរដ្ឋខ្មែរ ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា ។

- លិខិតបញ្ជាក់ ឯកសារ ឬ សេចក្តីសម្រេចស្ថាពររបស់តុលាការដែលបញ្ជាក់ថា ឪពុក ឬ ម្តាយរបស់អ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និង ឯកសារដែលបង្ហាញថាអ្នកសុំចុះឈ្មោះ គឺជាកូនរបស់ឪពុក ឬ ម្តាយនោះ ។

- ឯកសារជាផ្លូវការបង្ហាញថា អ្នកសុំចុះឈ្មោះកើតនៅក្នុងប្រទេសកម្ពុជា ហើយឪពុក និង ម្តាយបរទេសរបស់ជននោះ ក៏កើតនិងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និង ឯកសារជាផ្លូវការដែលបង្ហាញថា អ្នកសុំចុះឈ្មោះ គឺជាកូនរបស់ឪពុក និង ម្តាយនោះ ។"

- យល់ឃើញថា សេចក្តីសម្រេចលេខ ០០១/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ
- យល់ឃើញថា លោក **រស់ សួរ** ដែលបានប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១១ ពុំមានឯកសារ ឬ ភស្តុតាងជាលាយលក្ខណ៍អក្សរ ដែលអាចឱ្យបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឡើយ
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១**.- ទទួលពាក្យបណ្តឹងលេខ គសរ : ១៣៥/១១ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់លោក **រស់ សួរ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២**.- តម្កល់សេចក្តីសម្រេចលេខ ០០១/១១ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣**.-សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១១ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៩១/០១៤/២០១១

ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១១

**សេចក្តីសម្រេច**

លេខ : ១២០/០០១/២០១២ កបធ.ច

ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១២

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញសេចក្តីសម្រេចលេខ ០០៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចតម្កល់សេចក្តីសម្រេចលេខ ១២.១៨៥ /១១ គប/មគ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរី ទុកជាបានការទាំងមូល
- បានឃើញពាក្យបណ្តឹងលេខ ១៦៧ គសរ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១១ របស់លោក **ហ៊ីង យឿន** តំណាងឱ្យឈ្មោះ **អន សំណាង** មានតួនាទីជាតំណាងគណបក្ស សម រង្ស៊ី ប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ០០៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចេញសេចក្តីសម្រេចលេខ ០០៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ ទទួលពាក្យបណ្តឹងរបស់លោក **ហ៊ីង យឿន** ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ តម្កល់សេចក្តីសម្រេចលេខ ១២.១៨៥/១១ គប/មគ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ របស់គណៈកម្មការរៀបចំការបោះឆ្នោត ខេត្តមណ្ឌលគិរី ទុកជាបានការទាំងមូល។ លោក **ហ៊ីង យឿន** ជាតំណាងរបស់លោក **អន សំណាង** បានមកដាក់ពាក្យបណ្តឹងលេខ ១៦៧ គសរ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១១ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចលេខ ០០៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យបណ្តឹងនេះ នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១១ វេលា ម៉ោង ១៥:៤៥ នាទី ។ បណ្តឹងរបស់លោក **ហ៊ីង យឿន** ខាងលើនេះ ស្ថិតក្នុងរយៈពេលកំណត់ក្នុងមាត្រា ៦៥ថ្មី(ពីរ) វាក្យខណ្ឌទី៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងមាត្រា២៦ ចំណុចទី២ នៃច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើនេះមកពិនិត្យបាន

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោក **ហ៊ីង យឿន** បានបញ្ជាក់ថា ÷

*" បណ្តឹងចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១១ ដែលបានបង្ហាញទូលបង្គំ/ខ្ញុំនេះ ពិតជាពាក្យបណ្តឹងរបស់ទូលបង្គំ/ខ្ញុំ មែនហើយ ។ ទូលបង្គំ/ខ្ញុំសូមដាក់សារណាការពារក្តី ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ បន្ថែមទៀត ។ ទូលបង្គំ/ខ្ញុំសូមស្នើដាក់បញ្ចូលឈ្មោះ លោក តេស ទុង ក្នុងបញ្ជីបោះឆ្នោតដំបូងនៃក្រុមប្រឹក្សាឃុំដាក់ដាំ របស់គណបក្ស សម រង្ស៊ី ពីព្រោះពេលបោះឆ្នោតជិតឈានមកដល់ហើយ បើមិនបំពេញឈ្មោះបេក្ខជនមួយរូបទៀតទេ គឺមិនគ្រប់សមាជិកក្រុមប្រឹក្សាឃុំ ដែលច្បាប់បានកំណត់យ៉ាងតិចចំនួន ៥ រូប ហើយគណបក្ស សម រង្ស៊ី នឹងបាត់បង់សមាជិកមួយរូប សម្រាប់ចូលរួមការបោះឆ្នោតហើយ ។*

*ទូលបង្គំ/ខ្ញុំ ជូនបន្ថែមឯកសារ លិខិតសូមបដិសេធមិនធ្វើជាជំទប់ទី២ឃុំដាក់ដាំ ខេត្តមណ្ឌលគិរី មកពីគណបក្ស សម រង្ស៊ី ដីកាអមរបស់គណបក្ស សម រង្ស៊ី ជូនលោកប្រធានក្រុមប្រឹក្សាឃុំដាក់ដាំ និង សំណើសុំធ្វើបែបបទផ្លាស់ប្តូរលោក ក្រេត អាន ជំទប់ទី២ ឃុំដាក់ដាំ ។ ឯកសារទាំងអស់នេះទូលបង្គំ/ខ្ញុំ មិនបានជូនទៅ គ.ជ.ប ទេ ប៉ុន្តែទូលបង្គំ/ខ្ញុំ មានឯកសារគ្រប់គ្រាន់ ហើយមូលហេតុមិនបានប្រគល់ជូន ព្រោះនៅពេលសវនាការក្រុមប្រឹក្សាជំនុំជម្រះឱ្យបង្ហាញតែម្តង បើឱ្យទូលបង្គំ/ខ្ញុំដឹងមុន ទូលបង្គំនឹងត្រៀមឯកសារជូន ។*

*ទូលបង្គំ/ខ្ញុំសូមទូលថ្វាយបន្ថែមថា គណៈកម្មការរៀបចំការបោះឆ្នោតខេត្តមណ្ឌលគិរី លុបឈ្មោះចេញពីសមាជិកក្រុមប្រឹក្សាឃុំ ដោយគ្មានប្រកាសរបស់ក្រសួងមហាផ្ទៃទេ ប៉ុន្តែដល់ពេលដាក់ចូលវិញទាមទារឱ្យមានប្រកាសរបស់ក្រសួងមហាផ្ទៃវិញ ។ តាមផ្លូវច្បាប់ការបាត់បង់សមាជិកភាព គឺគ្រាន់តែរាយការណ៍ទៅក្រុមប្រឹក្សាឃុំជាការគ្រប់គ្រាន់ រីឯការងាររដ្ឋបាលដទៃទៀតគឺជាការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីព្រោះថាច្បាប់បានកំណត់ទុករយៈពេល ១៤ ថ្ងៃ ។ ដូច្នេះ សំណូមពរចុងក្រោយ ទូលបង្គំ/ខ្ញុំសូមសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ដាក់ជំនួស លោក ក្រេត អាន ដោយលោក តេស ទុង វិញ ។ "*

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានឆ្លើយតបវិញថា ÷

*" ទូលបង្គំ/ខ្ញុំ សូមទូលថ្វាយ និង ជម្រាបជូនអំពីសេចក្តីសម្រេចរបស់ គ.ជ.ប ដែលប្តឹងទាស់ដោយលោក ហ៊ីង យឿន នោះ គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ផ្អែកលើមាត្រា ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលចែងថា "អ្នកបោះឆ្នោត និង អង្គបោះឆ្នោត គឺតំណាងរាស្ត្រក្នុងតំណែង និង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។" ទូលបង្គំ/ខ្ញុំសូមទូលថ្វាយ ជម្រាបជូនបន្ថែមទៀតថា ក្រោយពីការ*

*បោះឆ្នោតហើយ គ.ជ.ប ត្រូវប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រសួងមហាផ្ទៃជាអ្នកចេញប្រកាសសុពលភាពបេក្ខជនទាំងនោះជាសមាជិកក្រុមប្រក្សាឃុំសង្កាត់។ តាមមាត្រា ១៦៧ ថ្មី (មាត្រា ២១៩ ចាស់) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានកំណត់ថា បេក្ខជនជាប់ឆ្នោតនឹងក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ពីពេលដែលចូលកាន់តំណែង។ មាត្រា ១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កំណត់ថា ក្រសួងមហាផ្ទៃត្រូវប្រកាសសុពលភាពក្នុងរយៈពេល១៥ថ្ងៃ។ ដូច្នេះដើម្បីឱ្យក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ លុះត្រាមានប្រកាសពីក្រសួងមហាផ្ទៃ។ម្យ៉ាងវិញទៀត ចំពោះការផ្លាស់ប្តូរបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាការងាររបស់គណបក្សនយោបាយជាមួយក្រសួងមហាផ្ទៃ។ ទូលបង្គំ/ខ្ញុំ សូមជម្រាបជូនពីបណ្តឹងរបស់លោក ហ៊ីង យឿន ដែល គ.ជ.ប សម្រេចមិនបញ្ចូលលោក តេស ទុង ជំនួសលោក ក្រេត អាន ដោយមូលហេតុពុំមានប្រកាសរបស់ក្រសួងមហាផ្ទៃក្នុងការទទួលស្គាល់លោក តេស ទុង ជាសមាជិកក្រុមប្រឹក្សាឃុំដាក់ដាំទេ។ ទូលបង្គំ/ខ្ញុំ សូមទូលថ្វាយជម្រាបជូនពីមូលដ្ឋានច្បាប់ដែល គ.ជ.ប យកមកអនុវត្តក្នុងការបដិសេធការស្នើសុំរបស់លោក ហ៊ីង យឿន គឺយោងទៅលើមាត្រា ១៦ មាត្រា ១៩ និង មាត្រា ៣៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង មាត្រា ១៦៧ថ្មី (មាត្រា២១៩ ចាស់) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ជាចុងក្រោយ ទូលបង្គំ/ខ្ញុំ សូមក្រុមប្រឹក្សាធម្មនុញ្ញមេត្តាតម្កល់សេចក្តីសម្រេចលេខ 00៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។"*

- យល់ឃើញថា សេចក្តីសម្រេចលេខ 00៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគតិយុត្តត្រឹមត្រូវ ដោយហេតុថាការសុំបញ្ចូលឈ្មោះ **តេស ទុង** នៅក្នុងបញ្ជីបោះឆ្នោតដំបូង សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ដោយគ្មានឯកសារភស្តុតាងបញ្ជាក់ពីការទទួលស្គាល់លោក **តេស ទុង** ជាសមាជិកក្រុមប្រឹក្សា និង ជាជំទប់ទី២ ឃុំដាក់ដាំ ពីក្រសួងមហាផ្ទៃ មានលក្ខណៈមិនត្រឹមត្រូវស្របតាមមាត្រា ១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យល់ឃើញថា បណ្តឹងរបស់លោក **ហ៊ីង យឿន** ខាងលើនេះ គឺពាក់ព័ន្ធទៅនឹងបែបបទ និង នីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ហើយស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ពុំមែនស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង របស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។

**សម្រេច**

**មាត្រា ១.** ទទួលពាក្យបណ្ដឹងលេខ ១៦៧ គសរ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១១ របស់លោក **ហ៊ីង យឿន** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្ដីសម្រេចលេខ ០០៦/១១ គ.ជ.ប ស.ស.រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្ដីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១២ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៩២/០០១/២០១២

ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១២

**សេចក្ដីសម្រេច**

លេខ : ១២១/០០២/២០១២ កបធ.ច

ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១២

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី ៣ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១១ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចតម្កល់សេចក្តីសម្រេចលេខ ០៣៥/១២ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង ទុកជាបានការពេញទាំងមូល
- បានឃើញពាក្យបណ្តឹងលេខ ០២០/១២ គ.ស.រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់លោក **ហ៊ីង យឿន** តំណាងឱ្យឈ្មោះ **ជួង ចន្ថា** មានមុខងារជាតំណាងគណបក្ស សម រង្ស៊ី ខេត្តកំពង់ឆ្នាំង ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់លោក **ជួង ចន្ថា** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ តម្កល់សេចក្តីសម្រេចលេខ ០៣៥/១២ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង ទុកជាបានការពេញទាំងមូល ។ លោក **ហ៊ីង យឿន** ជាតំណាងរបស់លោក **ជួង ចន្ថា** បានមកដាក់ពាក្យបណ្តឹងលេខ ០២០/១២ គ.ស.រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យបណ្តឹងនេះ នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១៤:៥០ នាទី ។ បណ្តឹងរបស់លោក **ហ៊ីង យឿន** ខាងលើនេះ ស្ថិតក្នុងរយៈពេលកំណត់ដែលមានចែងក្នុងចំណុច ក.៣ ប្រការ ៨.៩.២៣ ជំពូកទី ៨ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ និងធ្វើឡើងស្របតាមមាត្រា ៧៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង

តំណាងរាស្ត្រ មាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង មាត្រា ២៥ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើនេះមកពិនិត្យបាន

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅពេលឆ្លើយបំភ្លឺនៅចំពោះមុខ ក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោក **ហ៊ីង យឿន** បានបញ្ជាក់ថា :

*" បណ្តឹងលេខ ០២០/១២ គ.ស.រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ជាបណ្តឹងរបស់ខ្ញុំពិតប្រាកដមែន ។ ខ្ញុំសូមប្តឹងបដិសេធសេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយសូមប្តឹងផ្តន្ទាទោស លោក* ***សំ សុទ្ធី*** *អធិការនគរបាលក្រុងកំពង់ឆ្នាំង លោក* ***ញ៉ៅក ម៉ុនធី*** *ប្រធានប៉ុស្តិ៍នគរបាលផ្សារឆ្នាំង និង លោក* ***ស៊ុំ សុជាតិ*** *មន្ត្រីនគរបាល ដោយលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និង ពិន័យជាប្រាក់ចំនួនម្ភៃប្រាំលាន ( ២៥.000.000 ) រៀល ក្នុងម្នាក់ៗ ឱ្យស្របតាមមាត្រា ១២៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយហេតុថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតខាងលើនេះ មានភាពអយុត្តិធម៌ទាំងស្រុង ព្រោះថានៅថ្ងៃកើតហេតុ ( ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ វេលាម៉ោង ៥ និង ៣០នាទី ល្ងាច នៅកំពង់ផែដើមពោធិ៍ ក្នុងសង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង និង វេលាម៉ោង ៧ និង ៣០នាទី យប់ ថ្ងៃដដែលនៅបេនរ៉ឺម៉កផ្សារលើ ក្រុងកំពង់ឆ្នាំង ) នៅពេលដែលក្រុមការងារឃោសនារបស់គណបក្សសម រង្ស៊ី កំពុងធ្វើការផ្សព្វផ្សាយតាមរយៈការចាក់ផ្សាយកាសែតវីដេអូខ្នាតធំនៅទីលានសាធារណៈទាំងពីរខាងលើស្របតាមចំណុច ៥.១.៥ នៃប្រការ ៥.១ និង ចំណុច ៥.២.២ នៃប្រការ ៥.២ ក្នុងជំពូកទី ៥ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្រាប់តែមានកំលាំងចំរុះនៃកំលាំងនគរបាលជាតិដឹកនាំដោយលោក* ***សំ សុទ្ធី*** *អធិការនគរបាលក្រុងកំពង់ឆ្នាំង លោក* ***ញ៉ៅក ម៉ុនធី*** *ប្រធានប៉ុស្តិ៍នគរបាលផ្សារឆ្នាំង និង លោក* ***ស៊ុំ សុជាតិ*** *មន្ត្រីនគរបាលមួយរូបទៀត បានធ្វើសកម្មភាពរារាំងការឃោសនាផ្សព្វផ្សាយរបស់គណបក្សសម រង្ស៊ី ដោយរុញច្រានក្រុមការងារឃោសនារបស់គណបក្ស ក្នុងនោះមានទាំងអ្នកតំណាងរាស្ត្រទៀតផង យ៉ាងសាហាវឃោរឃៅព្រៃផ្សៃ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋ និងសាធារណជន រន្ធត់តក់ស្លុត ហើយមានការភ័យខ្លាចរួចគេចខ្លួនបែកខ្ញែកគ្នាអស់ ។ ម្យ៉ាងទៀតទីកន្លែងចាក់ផ្សាយទាំងពីរខាងលើ មិនមែនជារោងមហោស្រព មណ្ឌលកីឡា សាលសាធារណៈ ដែលតម្រូវឱ្យគណបក្សសម រង្ស៊ី ជួលនោះទេ គឺជាទីសាធារណៈដែលសាធារណជនអាចប្រើប្រាស់បានទាំងអស់គ្នា ។ តែទោះយ៉ាងណាក្តីក៏គណបក្សសម រង្ស៊ី បានធ្វើលិខិតលេខ ០០៤/១២ គសរ.កឆ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ ដើម្បីសុំការអនុញ្ញាតពីលោកចៅសង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង និង លេខ ០០៥/១២ គសរ.កឆ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ ដើម្បីសុំការអនុញ្ញាតពីចៅសង្កាត់ផ្សារឆ្នាំង*

*ក្រុងកំពង់ឆ្នាំងរួចហើយដែរ ប៉ុន្តែពុំមានការឆ្លើយតប និង មានការបង្កលំបាកទៀតផង ។ ខ្ញុំសូមជម្រាប ក្រុមប្រឹក្សាជំនុំជម្រះថា ពាក្យស្នើសុំរបស់គណបក្សសម រង្ស៊ី ដែលចុះហត្ថលេខានៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១២ បានយកទៅដាក់នៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១២ គណៈកម្មការរៀបចំការបោះឆ្នោតខេត្តណែនាំឱ្យយកពាក្យសុំទៅដាក់នៅអាជ្ញាធរដែនដីវិញ ។ គណបក្សសម រង្ស៊ី បានយកពាក្យសុំនោះទៅដាក់នៅសង្កាត់ផ្សារឆ្នាំង និងសង្កាត់ខ្សាម នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ។"*

- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្ដីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១២ របស់លោក **ជួន ចន្ថា** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ហើយតម្កល់សេចក្ដីសម្រេចលេខ ០៣៥/១២ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មការ-រៀបចំការបោះឆ្នោតខេត្តកំពង់ឆ្នាំង ទុកជាបានការពេញទាំងមូលដោយហេតុថា :

១-លោក **ជួន ចន្ថា** តំណាងគណបក្សសម រង្ស៊ី បានដាក់ពាក្យទៅអាជ្ញាធរស្នើសុំទីតាំង ដើម្បីធ្វើការឃោសនានៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ហើយចាប់ផ្ដើមចាក់វីដេអូឃោសនាភ្លាម ក្នុងថ្ងៃដដែល ដែលផ្ទុយនឹងមាត្រាច្បាប់ និង បទបញ្ជា និងនីតិវិធី ដែលតម្រូវឱ្យមានការស្នើសុំឱ្យបាន ៣ថ្ងៃ មុនការឃោសនាបោះឆ្នោត ។

២-លោក **ញៀក ប៊ុនឆៃ** លោក **សំ សុន្ធី** លោក **ស៊ុំ សុជាតិ** គ្រាន់តែជាអ្នកអនុវត្តតួនាទី របស់ខ្លួនក្នុងការការពារសណ្ដាប់ធ្នាប់សាធារណៈ ហើយគ្រាន់តែសួរនាំរកលិខិតអនុញ្ញាតតែប៉ុណ្ណោះ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជានៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយតប វិញថា :

*"ពាក្យបណ្ដឹងរបស់លោក **ហ៊ុំ យឿន** ជាបណ្ដឹងស្ថិតក្នុងដំណាក់កាលឃោសនាបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ។ តាមមាត្រា ២០ និង មាត្រា ៣៣ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា និង មាត្រា ៧៣ ថ្មី មាត្រា ១៣១ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ និង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់ នីតិកាលទី៣ ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យកមកសំអាង ។ មាត្រា ២០ នៃ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បញ្ជាក់អំពីការឃោសនាបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ មាត្រា ៣៣ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បញ្ជាក់ពីទោសប្បញ្ញត្តិក្នុងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺត្រូវយកច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មកអនុវត្ត ដែរ ។ មាត្រា ៧៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បញ្ជាក់អំពីការឃោសនា*

*បោះឆ្នោត គឺគណបក្សនយោបាយទាំងអស់ និង បេក្ខជន ត្រូវគោរពតាមបទបញ្ជា និងនីតិវិធី និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ មាត្រា ១៣១ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បញ្ជាក់អំពីការផ្តន្ទាទោសចំពោះជនណា ឬ គណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ តាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ ចំណុច ៥.១៥ បញ្ជាក់ថា គណបក្សនយោបាយ ឬ បេក្ខជនដែលមានបំណងជួលទីកន្លែងសាធារណៈ ត្រូវដាក់ពាក្យសុំយ៉ាងតិច ៣ថ្ងៃមុនថ្ងៃធ្វើការឃោសនា ហើយអ្នកអនុញ្ញាតឱ្យ ត្រូវឆ្លើយតបឱ្យបានយ៉ាងតិច ១ថ្ងៃមុនថ្ងៃធ្វើការឃោសនា ។ តាមការចុះស្រាវជ្រាវរបស់មន្ត្រីជំនាញនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បញ្ជាក់ថា គណបក្សសម រង្ស៊ី បានសុំច្បាប់នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ មានន័យថា រយៈពេលខ្លីពេកដែលអ្នកអនុញ្ញាតមិនទាន់ឆ្លើយបាន ប៉ុន្តែគណបក្សសម រង្ស៊ី បានបញ្ចាំងវីដេអូខ្នាតធំនោះរួចហើយ ។ សំណូមពរសូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញ តម្កល់សេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។”*

- យល់ឃើញថា លោក **ហ៊ីង យឿន** ដែលបានប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ពុំមានឯកសារ ឬ ភស្តុតាងជាលាយលក្ខណ៍អក្សរបន្ថែម ដែលអាចឱ្យបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឡើយ
- យល់ឃើញថា សេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងលេខ ០២០/១២ គ.ស.រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់លោក **ហ៊ីង យឿន** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១២ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៩៣/00២/២០១២

ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១២

**សេចក្តីសម្រេច**

លេខ : ១២២/00៣/២០១២ កបធ.ច

ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០២៦/០៧១២/ពស/ព.ន.វ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ របស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលបានអនុម័តយល់ព្រមចំនួន ៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នាសម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោង ០៩ និង ៤៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សំណើរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការ

រៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយមានសំឡេងយល់ព្រម ៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល គឺស្របនឹងមាត្រា ១១៤ថ្មី ( មួយ ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ១ "អំពីការិយាល័យបណ្តោះអាសន្ន និងការកិច្ច"** ដែលមាន ៣ ប្រការ គឺប្រការ ១ ដល់ប្រការ ៣ ស្របនឹងមាត្រា ១០៦ថ្មី ( មួយ ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ២ "អំពីសុពលភាពនៃអាណត្តិរបស់សមាជិកព្រឹទ្ធសភា"** ដែលមាន ២ ប្រការ គឺប្រការ ៤ និងប្រការ ៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៣ "អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់ព្រឹទ្ធសភា"** ដែលមាន ២១ ប្រការ គឺប្រការ ៦ ដល់ប្រការ ២៦ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៤ "អំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា"** ដែលមាន ៤ ប្រការ គឺប្រការ ២៧ ដល់ប្រការ ៣០ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៥ "អំពីថវិកា"** ដែលមាន ១ ប្រការ គឺប្រការ ៣១ ធ្វើឡើងស្របនឹងមាត្រា ១០៥ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ៦ "អំពីការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានាំងពួង"** ដែលមាន ៤ ប្រការ គឺប្រការ ៣២ ដល់ប្រការ ៣៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៧ "អំពីរបៀបវារៈប្រជុំ"** ដែលមាន ២ ប្រការ គឺប្រការ ៣៦ និងប្រការ ៣៧ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៨ "អំពីរបៀបប្រជុំ"** ដែលមាន ១៩ ប្រការ គឺប្រការ ៣៨ ដល់ប្រការ ៥៦ ធ្វើឡើងស្របនឹងមាត្រា ១១០ថ្មី និងមាត្រា ១១១ថ្មី ( ពីរ ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ៩ "អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានាំងពួងក្នុងពេលប្រជុំព្រឹទ្ធសភា"** ដែលមាន ៤ ប្រការ គឺប្រការ ៥៧ ដល់ប្រការ ៦០ ធ្វើឡើងស្របនឹងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ១០ "អំពីការបញ្ចេញមតិ"** ដែលមាន ៧ ប្រការ គឺប្រការ ៦១ ដល់ ប្រការ ៦៧ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១១ "អំពីការរក្សាសេចក្តីស្ងប់ស្ងាត់ក្នុងពេលប្រជុំ"** ដែលមាន ៣ ប្រការ គឺប្រការ ៦៨ ដល់ប្រការ ៧០ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **ជំពូកទី ១២ "អំពីការឈប់ ឬការខានមកប្រជុំ"** ដែលមាន ៥ ប្រការ គឺប្រការ ៧១ ដល់ប្រការ ៧៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១៣ "អំពីវិន័យក្នុងព្រឹទ្ធសភា"** ដែលមាន ៦ ប្រការ គឺប្រការ ៧៦ ដល់ប្រការ ៨១ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១៤ "អំពីការសុំកែប្រែបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា"** ដែលមាន ២ ប្រការ គឺប្រការ ៨២ និងប្រការ ៨៣ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ១៥ "អំពីអវសានប្បញ្ញត្តិ"** ដែលមាន ១ ប្រការ គឺប្រការ ៨៤ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា បទប្បញ្ញត្តិទាំងអស់នៃប្រការទាំង ៨៤ នៅក្នុងជំពូកទាំង ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនាសម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ១៩៥/០០៤/២០១២

ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១២

**សេចក្តីសម្រេច**

លេខ : ១២៣/០០៤/២០១២ កបធ.ច

ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១២

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០០៤/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចតម្កល់សេចក្តីសម្រេចលេខ ០២/០១២ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាឃុំសំពៅពូន ទុកជាបានការ
- បានឃើញសេចក្តីសម្រេចលេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចតម្កល់សេចក្តីសម្រេចលេខ ០៤/០១២ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាឃុំសំពៅពូន ទុកជាបានការទាំងមូល
- បានឃើញសេចក្តីសម្រេចលេខ ០០៦/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចតម្កល់សេចក្តីសម្រេចលេខ ០១/០១២ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាឃុំសំពៅពូន ទុកជាបានការទាំងមូល
- បានឃើញសេចក្តីសម្រេចលេខ ០០៧/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានសម្រេចតម្កល់សេចក្តីសម្រេចលេខ ០៣/០១២ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាឃុំសំពៅពូន ទុកជាបានការ
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់លោក **លី សុត្ថ័ណ្ណ** ជាតំណាងគណបក្ស សម រង្ស៊ី ប្តឹងជំទាស់នឹងសេចក្តីសម្រេចទាំង ៤ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់ឯកឧត្តម **គង់ គាំ** ប្រធានគណបក្ស សម រង្ស៊ី ផ្ទេរសិទ្ធិជូនលោក **លី សុត្ថ័ណ្ណ** ជាតំណាងគណបក្ស សម រង្ស៊ី ដើម្បីដាក់ពាក្យបណ្តឹង និងចូលរួមសវនាការជំនួសនៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុសួរយកចម្លើយរបស់លោក **លី សុត្ថ័ណ្ណ** កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកមេឃុំសំពៅពូន កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១២
- បានឃើញរបាយការណ៍ស្តីពីការផ្ទៀងផ្ទាត់ឈ្មោះរវាងឈ្មោះក្នុងសំណុំរឿងរបស់ដើមបណ្តឹង លោក **លី សុត្ថ័ណ្ណ** និង បញ្ជីឈ្មោះក្នុងសំណុំរឿងលេខ ១១២/០១២/២០០៦ និង សំណុំរឿងលេខ ១៣៤/០០៦/២០០៧ នៅឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ។ ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសនាសវនាការជាសាធារណៈតាមសេចក្តីសម្រេចលេខ ០៨៤/០១១/២០០៦ កបធ.ច ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា

ឆ្នាំ២០០៦ និង សេចក្តីសម្រេចលេខ ០៩៤/០០៥/២០០៧ កបធ.ច ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០៧ តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឆ្នាំ២០០៦ និងឆ្នាំ២០០៧ ទុកជាបានការ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចលេខ ០០៤/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ លេខ ០០៥/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ លេខ ០០៦/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ និង លេខ ០០៧/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ តម្កល់សេចក្តីសម្រេចលេខ ០១/០១២ សេចក្តីសម្រេចលេខ ០២/០១២ សេចក្តីសម្រេចលេខ ០៣/០១២ និង សេចក្តីសម្រេចលេខ ០៤/០១២ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ទុកជាបានការ
- យល់ឃើញថា លោក **លី សុគ័ណ្ណ** ជាតំណាងគណបក្ស សម រង្ស៊ី បានដាក់ពាក្យបណ្តឹងតវ៉ាចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១២ ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំង ៤ ខាងលើ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យបណ្តឹងនេះ នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ១១ ។ បណ្តឹងនេះស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងមាត្រា ៦៥ថ្មី (ពីរ) វាក្យខណ្ឌទី៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងតវ៉ានេះ មកពិនិត្យបាន
- យល់ឃើញថា រឿងដែលលោក **លី សុគ័ណ្ណ** លើកមកប្តឹងតវ៉ានេះ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចរួចម្តងហើយ តាមសេចក្តីសម្រេចលេខ ០៨៤/០១១/២០០៦ កបធ.ច ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ និង សេចក្តីសម្រេចលេខ ០៩៤/០០៥/២០០៧ កបធ.ច ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០០៧ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទាំងពីរនេះជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ

- យល់ឃើញថា តាមគោលការណ៍នៃច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញពុំអាចលើករឿងដដែល យកមកជំនុំជម្រះសាជាថ្មីទៀតទេ ។

# សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់លោក **លី សុភ័ណ្ឌ** ជាតំណាងគណបក្ស សម រង្ស៊ី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១២ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១២

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ ៖ ១៩៦/០០៥/២០១២

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១២

**សេចក្ដីសម្រេច**

លេខ ៖ ១២៥/០០៦/២០១២ កបធ.ច

ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រង់ចំណុចទី៣ និងទី៤ លុបឈ្មោះ **សម រង្ស៊ី** ចេញពីបញ្ជីបោះឆ្នោតក្នុងសង្កាត់បឹងរាំង
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ របស់លោកមេធាវី **ជួន ជួនី** ជាតំណាងរបស់លោក **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចលេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ តម្កល់សេចក្តីសម្រេចលេខ ០៣៧/១២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាសង្កាត់បឹងរាំង ទុកជាបានការ ដោយគ្រាន់តែធ្វើការកែតម្រូវចំណុច២ មកជា ៖ ការលុបឈ្មោះ **សម រង្ស៊ី** ចេញពីបញ្ជីបោះឆ្នោតក្នុងសង្កាត់បឹងរាំង ។ រីឯលោកមេធាវី **ជួន ជួនី** ជាតំណាងរបស់លោក **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ បានដាក់ពាក្យបណ្តឹងចុះថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០១២ ប្តឹងតវ៉ានឹងសេចក្តីសម្រេចលេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យបណ្តឹងនេះ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង ១៥ និង ១០ នាទី។

បណ្តឹងរបស់លោកមេធាវី **ជួន ជួនី** ខាងលើនេះ ស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងមាត្រា ៦៥ថ្មី (ពីរ) វាក្យខណ្ឌទី៦ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ ចំណុចទី៣ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើនេះមកពិនិត្យបាន

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកមេធាវី **ជួន ជួនី** តំណាងឲ្យឈ្មោះ **សម រង្ស៊ី** បានប្តឹងតវ៉ាមិនសុខចិត្តនឹងសេចក្តីសម្រេចលេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រង់ចំណុចទី៣ និង ទី៤ ដោយសម្អាងថា :

*« ១-សាលដីកាលេខ ៣២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ របស់តុលាការកំពូល រហូតដល់ពេលនេះ មិនទាន់ត្រូវបានតុលាការកំពូលយកមកចាត់ចែងអនុវត្តនៅឡើយទេ តែបែរជាក្រុមប្រឹក្សាសង្កាត់បឹងរាំង យកសាលដីកាតុលាការកំពូលមកអនុវត្តដោយឯងៗ ។*



Rano

*២-មាត្រា ៥០ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មិនបានចែងពីនីតិវិធីលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតទេ ។*

*៣-តាមសេចក្តីណែនាំរួមស្តីពីការពង្រឹងការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតលេខ ០២៧ សណន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អ្នកដែលត្រូវបានដកហូតសិទ្ធិបោះឆ្នោតត្រូវមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។ ប៉ុន្តែក្រុមប្រឹក្សាសង្កាត់បឹងរាំងមិនមានលិខិតបញ្ជាក់ពីការដកហូតសិទ្ធិបោះឆ្នោតចេញដោយស្ថាប័នមានសមត្ថកិច្ចផងទេ ។*

*៤-ឯកឧត្តម **សម រង្ស៊ី** បានដាក់ពាក្យបណ្តឹងសើរើទៅតុលាការកំពូល ទាមទារឱ្យតុលាការកំពូលបើកយកសំណុំរឿងពាក់ព័ន្ធនឹងការផ្តន្ទាទោសលើរូបខ្លួនមកជំនុំជម្រះឡើងវិញ ។ តុលាការកំពូលកំពុងតែចាត់ការតាមនីតិវិធី ។*

*៥-ការដកហូតសិទ្ធិបោះឆ្នោតដែលផ្អែកលើសាលដីកាតុលាការកំពូល គឺជាការអនុវត្តន៍ទោសព្រហ្មទណ្ឌដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់តំណាងអយ្យការ មិនមែនរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំងទេ ។*

*៦-ផ្អែកលើមាត្រា ៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចព្យួរការអនុវត្តន៍ទោសបាន ។*

*ដោយសម្អាងផ្អែកលើចំណុចសំខាន់ទាំង៦ ខាងលើនេះហើយ ខ្ញុំបាទសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតខាងលើនេះចោលជាអសាររបស់ ហើយសុំឱ្យរក្សាឈ្មោះ ឯកឧត្តម **សម រង្ស៊ី** ក្នុងបញ្ជីបោះឆ្នោតក្នុងសង្កាត់បឹងរាំងឱ្យនៅដដែល ។ »*

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ក៏ដូចជា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកឧត្តម **៦ម សុផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺថា :

*« តាមមាត្រា ៥៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោត និង សៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ។ ហេតុនេះហើយ ក្រុមប្រឹក្សា ឃុំ សង្កាត់ មានកាតព្វកិច្ចត្រូវធ្វើកិច្ចការនេះ គឺចុះឈ្មោះអ្នកបោះឆ្នោតថ្មី និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតចុងក្រោយ ដោយត្រូវលុបឈ្មោះអ្នកបោះឆ្នោតដែលបានស្លាប់ បានផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ អ្នកមានឈ្មោះស្ទួន និងអ្នកដែលស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារជាដើម ។ លោក **សម រង្ស៊ី** តាមអំណាចអនុវត្តសាលដីកាស្ថាពររបស់តុលាការកំពូលលេខ៣២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ ជាជនស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។ ក្រុមប្រឹក្សាសង្កាត់បឹងរាំង សម្រេចលុបឈ្មោះ **សម រង្ស៊ី** ចេញពីបញ្ជីបោះឆ្នោត ដោយផ្អែកលើមាត្រា៥០ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ឃើញថា ក្រុមប្រឹក្សាសង្កាត់បឹងរាំង សម្រេចនេះ ត្រឹមត្រូវតាមច្បាប់ ហេតុនេះហើយទើបគណៈកម្មាធិការ*

Rano

*ជាតិរៀបចំការបោះឆ្នោត សម្រេចតម្កល់សេចក្តីសម្រេចលេខ ០៧៧/១២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២ របស់ក្រុមប្រឹក្សាសង្កាត់បឹងរាំង ទុកជាបានការ ដោយគ្រាន់តែធ្វើការកែតម្រូវចំណុច ២ មកជា៖ លុបឈ្មោះ **សម រង្ស៊ី** ចេញពីបញ្ជីបោះឆ្នោតក្នុងសង្កាត់បឹងរាំង។ សេចក្តីសង្ខេបនៃដំណើររឿង និងការយល់ឃើញពិស្តារទាំងអស់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សឹងមាននៅក្នុង សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលខ្ញុំបាទ សូមដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ នូវសេចក្តីថតចម្លងមួយច្បាប់។ »*

– យល់ឃើញថា :

១- តាមសាលដីកាស្ថាពរលេខ ៣២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ តុលាការកំពូល សម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៩ “ង” ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ០១ “ក” ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តស្វាយរៀង ដែលសម្រេចផ្តន្ទាទោសឈ្មោះ **សម រង្ស៊ី** ដាក់ពន្ធនាគារកំណត់ ២ឆ្នាំ (ពីរឆ្នាំ) ពីបទធ្វើឱ្យខូចខាតដោយចេតនា តម្រុយបង្គោលព្រំដែនលេខ ១៨៥ កម្ពុជា-វៀតណាម និងបទញុះញង់ឱ្យមានការរើសអើងជាតិសាសន៍។

២- តាមសាលដីកាស្ថាពរលេខ ៨៤ ក្រ III ឃ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ សាលាឧទ្ធរណ៍ សម្រេចផ្តន្ទាទោស ឈ្មោះ **សម រង្ស៊ី** ដាក់ពន្ធនាគារ កំណត់រយៈពេល៧ ឆ្នាំ (ប្រាំពីរឆ្នាំ) ពីបទក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ។

– យល់ឃើញថា មាត្រា៥០ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលគូភាគីបានលើកឡើងនោះ បានចែងថា :

*« ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញ លក្ខខណ្ឌដូចខាងក្រោម ៖*

*- មានសញ្ជាតិខ្មែរ។*

*- មានអាយុ ១៨ ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត។*

*- មានទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។*

*- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ។*

*-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលដោយមានលិខិតបញ្ជាក់ពី ក្រសួង ស្ថាប័នមានសមត្ថកិច្ច។ »*

និង មាត្រា ៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ៖ *“ សភាព្រហ្មទណ្ឌនៃតុលាការកំពូលដែលបានទទួលពាក្យប្តឹងសើរើ អាចសម្រេចព្យួរការអនុវត្តន៍ទោសបានប្រសិនបើមានមូលហេតុច្បាស់លាស់។ ”*

– យល់ឃើញថា លោកមេធាវី **ជួង ជួងី** ជាតំណាងរបស់លោក **សម រង្ស៊ី** ពុំបានជូនភស្តុតាងជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ថា សភាព្រហ្មទណ្ឌនៃតុលាការកំពូលដែលបានទទួលពាក្យប្តឹងសើរើ បានសម្រេចព្យួរការអនុវត្តន៍ទោស ស្របតាមមាត្រា៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- យល់ឃើញថា សេចក្ដីសម្រេចលេខ ០០៨/១២ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគតិយុត្តត្រឹមត្រូវ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់លោកមេធាវី **ជូង ជូងី** ជាតំណាងរបស់លោក **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ទុកជាបានការតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

**មាត្រា ២.** តម្កល់សេចក្ដីសម្រេចលេខ ០០៨/១២ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

**មាត្រា ៣.** សេចក្ដីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៩៧/០០១/២០១៣

ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១២៦/០០១/២០១៣ កបធ.ច

ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៨៤ រ.ស ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី២ នីតិកាលទី៣ នាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ វេលាម៉ោង១០ និង៤៥ នាទី ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្ដីពីបទប្បញ្ញត្តិទូទៅ មាន១ មាត្រា ដែលចែងអំពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ ដើម្បីធានាការពាររដ្ឋធម្មនុញ្ញ ការពារឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តតួនាទី ភារកិច្ច សមត្ថកិច្ចរបស់កងយោធពលខេមរភូមិន្ទ ព្រមទាំងពិនិត្យ និងអនុម័តគោលនយោបាយការពារជាតិ និងផែនការការពារជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្ដីពីសមាសភាព មាន២ មាត្រា ដែលចែងអំពីសមាសភាពនៃឧត្តមក្រុមប្រឹក្សាការពារជាតិ មានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាព្រះអធិបតី នាយករដ្ឋមន្ត្រីជាអនុប្រធាន រដ្ឋមន្ត្រីក្រសួងការពារជាតិជាសមាជិក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាសមាជិក រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីជាសមាជិក រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជាសមាជិក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសមាជិក និងអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទជាសមាជិក និងចែងអំពីព្រះមហាក្សត្រទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ព្រមទាំងចែងអំពីព្រះរាជសិទ្ធិចាត់តាំងនាយករដ្ឋមន្ត្រីជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ឱ្យធ្វើជាអធិបតីនៃអង្គប្រជុំរបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្ដីពីតួនាទីនិងភារកិច្ច មាន២ មាត្រា ដែលចែងអំពីការធានាការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាការពារឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃ

ព្រះរាជាណាចក្រកម្ពុជា ធានាអព្យាក្រឹតភាពនៃការអនុវត្តតួនាទី ភារកិច្ច និង សមត្ថកិច្ចរបស់កងយោធពលខេមរភូមិន្ទ ធានាការអនុវត្តគោលនយោបាយការពារជាតិនិងផែនការការពារជាតិ ពិនិត្យនិងអនុម័តគោលនយោបាយការពារជាតិនិងផែនការការពារជាតិ ផ្តល់យោបល់ជាចាំបាច់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលទាក់ទងនឹងការរៀបចំកិច្ចការពារជាតិ ការទទួល ឬការដាក់ឱ្យនិរាករណ៍រាល់អនុសញ្ញា សន្ធិសញ្ញា កតិកាសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងលើវិស័យយោធា វាយតម្លៃសភាពការណ៍ក្នុងការដាក់ប្រទេសជាតិឱ្យស្ថិតក្នុងភាពអាសន្នឬសង្គ្រាម ដើម្បីដំណើរការនីតិវិធីស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ ពិនិត្យនិងអនុម័តផែនការនិងរបាយការណ៍នានារបស់អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាការពារជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៤ ស្តីពីការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ មាន៤ មាត្រា ដែលចែងអំពីកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ ដើម្បីធ្វើការកោះប្រជុំសាមញ្ញ ឬវិសាមញ្ញ អំពីសិទ្ធិអញ្ជើញនិងអំពីបែបបទនិងនីតិវិធីការងាររបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ និង ចែងអំពីការបង្កើតអគ្គលេខា-ធិការដ្ឋានមួយជាសេនាធិការ និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៥ ស្តីពីប្រភពធនធាន មាន១ មាត្រា ដែលចែងអំពីការចំណាយសម្រាប់ដំណើរការរបស់ឧត្តមក្រុមប្រឹក្សាការពារជាតិ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិដោយឡែកក្នុងគម្រោងថវិការបស់ក្រសួងការពារជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៦ ស្តីពីអវសានប្បញ្ញត្តិ មាន១ មាត្រា ដែលចែងអំពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ.

-យល់ឃើញថា ខ្លឹមសារទាំង៦ ជំពូក ១១មាត្រា នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី២ នីតិកាលទី៣ នាថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១៩៩/០០៣/២០១៣

ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១២៧/០០២/២០១៣ កបធ.ច

ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ២៧៩ រ.ស ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំវិសាមញ្ញ ព្រឹទ្ធសភានីតិកាលទី៣ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ហើយដែលអគ្គលេខាធិការដ្ឋាន

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ វេលាម៉ោង ១៦ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣-ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០-ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មានពីរមាត្រា និងមានខ្លឹមសារដូចខាងក្រោម :

***មាត្រាមួយ.-***

*មាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :*

*មាត្រា ២៨.- ថ្មី*

*ប្រធានស្ថាប័នមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន វរសេនីយ៍ឯកនិងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ ប្រធានស្ថាប័នមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល ។*

*រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យស្តីពីការផ្ទេរប្រតិភូកម្មអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។*

***មាត្រាពីរ.-***

*ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។*

មាត្រា ២៨-ថ្មី នេះដែលមានពីរវាក្យខ័ណ្ឌ : វាក្យខ័ណ្ឌទី១ ជាវាក្យខ័ណ្ឌដើមដោយឥតកែប្រែ និង វាក្យខ័ណ្ឌទី២ ជាវាក្យខ័ណ្ឌបន្ថែមថ្មី ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ធ្វើឡើងស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងស្របតាមមាត្រា ១៤៦-ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា មាត្រាមួយ និង មាត្រាពីរនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំងមូលនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.**-ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំវិសាមញ្ញ ព្រឹទ្ធសភានីតិកាលទី៣ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២១៣/០១៧/២០១៣

ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១២៨/០០៣/២០១៣ កបធ.ច

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

1/38

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **តុល ប្រាសាទ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **ប៉ូ ចាន់ថេង** ផ្ទេរសិទ្ធិជូនលោក **តុល ប្រាសាទ** ធ្វើជាតំណាងក្នុងការដាក់ពាក្យបណ្តឹង និង សវនាការលើបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុសួរយកចម្លើយរបស់លោក **តុល ប្រាសាទ** កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **តុល ប្រាសាទ** ខាងលើនេះ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១០ ព្រឹក គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងមាត្រា ៧៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ប្រការ ៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ និង ប្រការ ១១.៩ ចំណុច ១១.៩.៣៦ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា ការប៉ះទង្គិចគ្នារវាងក្បួនដង្ហែគណបក្សសង្គ្រោះជាតិ និង គណបក្សប្រជាជនកម្ពុជា ដែលសុទ្ធតែបានជូនដំណឹងដល់គណៈកម្មការរៀបចំការបោះឆ្នោតឃុំ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ នៅឃុំកំពង់អុស គឺបណ្តាលមកពី ៖
    - គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស គ្រាន់តែស្រង់ចម្លងពាក្យស្នើសុំរបស់គណបក្សទាំងពីរចូលក្នុងតារាង តែពុំបានធ្វើការសម្របសម្រួលកំណត់ទីភូមិសាស្ត្រក្នុងឃុំ ដើម្បីកុំឱ្យក្បួន

ហ៊ុន

ដង្ហែគណបក្សដែលសុំឃោសនាចល័តក្នុងឃុំក្នុងថ្ងៃតែមួយដូចគ្នា ប៉ះទង្គិចគ្នា ដោយបណ្តោយឱ្យគណបក្សនីមួយៗឃោសនាតាមចិត្តរៀង១ខ្លួន ដូចនេះ ជាកំហុសឆ្គងរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស ដែលពុំបានបែងចែកកាលវិភាគឱ្យបានច្បាស់លាស់ដើម្បីបញ្ចៀសកុំឱ្យមានការប៉ះទង្គិចគ្នា ពុំមែនជាកំហុសទាំងស្រុងរបស់សកម្មជនគណបក្សទេ ព្រោះសកម្មភាពរំខាននេះប្រព្រឹត្តទៅវិញទៅមកស្ទើរពេញមួយថ្ងៃ ទោះបីជាមានការសម្របសម្រួលពីគណៈកម្មការរៀបចំការបោះឆ្នោតឃុំ និង គណៈកម្មការរៀបចំការបោះឆ្នោតខេត្តក៏ដោយ

- ទីតាំងភូមិសាស្ត្រផ្លូវតូចចង្អៀត ហើយមានប្រជាពលរដ្ឋធ្វើចរាចរណ៍ចុះឡើងជាច្រើនផង

- យល់ឃើញថា តាមការសាកសួររបស់ក្រុមត្រួតពិនិត្យស្រាវជ្រាវរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ ដល់ប្រជាពលរដ្ឋនៅភូមិព្រៃកតាមៃ ភូមិកំពង់អុស និង ភូមិដងគោម សុទ្ធតែឆ្លើយថា ពុំបានឃើញលោក **លឹម គានហោ** នៅក្នុងក្បួនដង្ហែ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ទេ
- យល់ឃើញថា តាមការអះអាងរបស់ លោក **អ៊ុង សារ៉េម** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស ឆ្លើយនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ថាពុំឃើញសកម្មភាពណាមួយដែលថា ឈ្មោះ **នង ណារ៉ុង** បានមករារាំង រំខានការឃោសនារបស់គណបក្សសង្គ្រោះជាតិទេ
- យល់ឃើញថា គួរមានវិធានការទៅលើជនដែលមិនគោរពតាមបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ និង មិនទទួលយកការសម្របសម្រួលរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស និង របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **គុល ប្រាសាទ** តំណាងគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តែបដិសេធចោលការលើកលែងមិនចាត់វិធានការលើឈ្មោះ **ទឹម សារ៉ុផ នុត យ៉ាន់ណារ៉ូ បួរ សម្បត្តិ** និង **វង្ស សាឡន** ។

**មាត្រា** ៣.- ប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការព្រមានលោក **ទឹម សារុផ** លោក **នុត យ៉ាន់ណារ៉ូ** លោក **បូរ សម្បត្តិ** និងលោកស្រី **វង្ស សាឡូន** ដែលមិនគោរពតាមបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ និង មិនទទួលយកការសម្របសម្រួលរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុសនិងរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ។

**មាត្រា** ៤.- សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។ ម/ស

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣១/០៣៥/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**សេចក្ដីសម្រេច**

លេខ : ១២៩/០០៤/២០១៣ កបធ.ច

ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជាម ច័ន្ទនី** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់ ១១០២ និង ទម្រង់ ១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពង់ធំ ចំនួន ៩ ឃុំ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **ជាម ច័ន្ទនី** ធ្វើជាតំណាងគណបក្សសង្គ្រោះជាតិក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ មណ្ឌលខេត្តកំពង់ធំ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៥៦ /១៣ គ.ជ.ប ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ជាម ច័ន្ទនី** កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣របស់ឯកឧត្តម **ជាម ច័ន្ទនី** ខាងលើនេះ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤:៤៥ នាទី គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់ឯកឧត្តម **ជាម ច័ន្ទនី** ចំណុចទី១ តវ៉ាឱ្យផ្ទៀងផ្ទាត់ឡើងវិញលើទម្រង់ ១១០២ និង ទម្រង់ ១១០៤ ចំនួន ៩ ឃុំ គឺឃុំឈូកខ្សាច់ ឃុំក្រវ៉ា ឃុំដីវិស្វាប់ ឃុំកំពង់ស្វាយ ឃុំសាន់គរ ឃុំផាន់ញើម ឃុំត្បៅ ឃុំសំព្រោជ និង សង្កាត់កំពង់រទេះ និងចំណុចទី២

ទាមទារឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តកំពង់ធំឡើងវិញ ដោយហេតុថា ប្រជាពលរដ្ឋបាត់ឈ្មោះច្រើន និងខ្លះទៀតត្រូវគេបោះជំនួស

- យល់ឃើញថា តាមការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **ជាម ច័ន្ទនី** សុំប្ដឹងគ្រប់ការិយាល័យទាំងអស់នៅក្នុងឃុំទាំង ៩ ពីព្រោះប្រធានការិយាល័យប្រញាប់ប្រញាល់ពេក។ ឯកឧត្តម **ជាម ច័ន្ទនី** បានបញ្ជាក់ថា លោកបានដាក់ភ្នាក់ងារសង្កេតការណ៍ គ្រប់ការិយាល័យនៅមណ្ឌលបោះឆ្នោតខេត្តកំពង់ធំ ។ តំណាងគណបក្សរបស់លោកបានចុះហត្ថលេខាទទួលស្គាល់ជាសាក្សីនៅលើគ្រប់ទម្រង់ ១១០២
- យល់ឃើញថា តាមលិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ដូចជាការឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ បានបញ្ជាក់ថា ឯកឧត្តម **ជាម ច័ន្ទនី** ពុំមានភស្តុតាងដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីទីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារឬភស្តុតាងដទៃទៀតស្របតាមមាត្រា ១១៤នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះទេ ។ ឯកឧត្តម **ជាម ច័ន្ទនី** ពុំមានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយដែលតម្រូវឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ផ្ទៀងផ្ទាត់ឡើងវិញនូវទម្រង់ ១១០២ និង ១១០៤ នៅឃុំ សង្កាត់ចំនួន ៩ នៃមណ្ឌលខេត្តកំពង់ធំបានទេ
- យល់ឃើញថា ការទាមទារក្នុងចំណុចទី ២ នៅក្នុងពាក្យបណ្ដឹងរបស់ឯកឧត្តម **ជាម ច័ន្ទនី** ជាកម្មវត្ថុថ្មីមិនមាននៅក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ដាក់នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយក៏មិនទាក់ទងនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា ពុំមានពាក្យបណ្ដឹង ដាក់នៅគណៈកម្មការការិយាល័យរៀបចំការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ដាក់នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ទាំង ៩ ឃុំ សង្កាត់ និងដាក់នៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ធំ តាមកាលកំណត់ក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ទេ
- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិចែងក្នុងមាត្រា ១១៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងស្របតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥

- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលខេត្តកំពង់ធំ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និងដោយសេរី
- យល់ឃើញថា លិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជាម ច័ន្ទនី** តំណាងគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់លិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្ដីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២២៦/០៣០/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣០/០០៥/២០១៣ កបធ.ច

ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **កែវ ភីរម្យ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តក្រចេះ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោក **កែវ ភីរម្យ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៅតាមនីតិវិធីច្បាប់
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៥៤/១៣ គ.ជ.ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **កែវ ភីរម្យ** កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣
- បានឃើញសេចក្តីសម្រេចលេខ ២៨/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៤៣/២០១៣ កបធ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព " ក " នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តក្រចេះ នៅឃុំស្វាយជ្រះ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៩៥/១៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣
- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **កែវ ភីរម្យ** ប្រគល់សិទ្ធិជូនលោកមេធាវី **ជួង ជូងី** និង លោកមេធាវី **កែត ឃី** ដើម្បីការពារនូវ

សិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២២៦/០៣០/២០១៣ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

- បានឃើញលិខិតតំណាងដោយអាណត្តិចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៣ របស់លោកមេធាវី **ជួង ជូងី** និងពាក្យសុំតំណាងដោយអាណត្តិចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី** ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្ដាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្ដឹងរបស់លោក ***កែវ ភីរម្យ*** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១០ និង ៣០ នាទី ជាបណ្ដឹងស្ថិតក្នុងអំឡុងពេល ៧២ ម៉ោង បន្ទាប់ពីបានទទួលសេចក្ដីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ ។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្ដឹងរបស់លោក ***កែវ ភីរម្យ*** មកពិនិត្យបាន
- យល់ឃើញថា លោក ***កែវ ភីរម្យ*** នៅក្នុងពាក្យបណ្ដឹងក៏ដូចជានៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៣ បានឆ្លើយបំភ្លឺថា មានប្រជាពលរដ្ឋជាច្រើនបានបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុ មានការកែតួលេខសន្លឹកឆ្នោតមិនបានការ ។ នៅឃុំដីវផុង សន្លឹកឆ្នោតមិនបានការ ចំនួន ៩៤ សន្លឹក ឃុំកំពង់ដីវ មានសន្លឹកឆ្នោតមិនបានការរហូតដល់ ១១១ សន្លឹក និង ឃុំវឌ្ឍនៈ ប្រធានការិយាល័យបោះឆ្នោតឱ្យត្រាខុសទៅបោះលើសន្លឹកឆ្នោត ដោយយកត្រាការិយាល័យទៅបោះ ដែលខុសនឹងបទបញ្ជា និង នីតិវិធីនៃការបោះឆ្នោត ។ លោក ***កែវ ភីរម្យ*** សំណូមពរឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីផ្ទៀងផ្ទាត់ការរាប់សន្លឹកឆ្នោតឡើងវិញ
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកមេធាវី **កែត ឃី** និង លោកមេធាវី **ជួង ជូងី** តំណាងដោយអាណត្តិឱ្យលោក ***កែវ ភីរម្យ*** ព្រមទាំងលោក ***កែវ ភីរម្យ*** បានបញ្ជាក់អំពីកម្មវត្ថុនៃបណ្ដឹងតវ៉ានេះ គឺ : ១-ប្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំង

តំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តក្រចេះ ២-បដិសេធសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ដើមបណ្តឹង និងលោកមេធាវីទាំងពីររូបបានលើកមូលហេតុនៃការប្តឹងតវ៉ានេះដូចតទៅ ៖

១-ប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១២ ដ៏ច្រើនលើសលប់ ។

២-នៅឃុំស្វាយជ្រះ មានការក្លែងបន្លំតួលេខលើទម្រង់ ១១០៤ ចំនួន ១៣ ការិយាល័យ គឺ ការិយាល័យលេខ ០២៩៥ ០៣៦៨ ០២៧៦ ០២៦០ ០២៧៧ ០៤២៤ ០២៦១ ០២៧៨ ០២៦២ ០៣៧៤ ០២៦៣ ០៣៤៥ ០៤០៧ ។ ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិទទួលបានកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ គឺខុសពីទម្រង់ ១១០៤ តួលេខដែល គជ/ខប បានបង្ហាញកាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៣ ។

៣-នៅឃុំជីរផុង ការិយាល័យលេខ ០០១១ មានសន្លឹកឆ្នោតមិនបានការ ៩៤ សន្លឹក ដែលមានការសង្ស័យ ។

៤-នៅឃុំកំពុងជីរ ការិយាល័យលេខ ០០២៤ មានសន្លឹកឆ្នោតមិនបានការ ១១១ សន្លឹក ដែលមានការសង្ស័យ ។

៥-នៅឃុំវឌ្ឍនៈ ការិយាល័យលេខ ០២៩២ មានសន្លឹកឆ្នោតទាំងអស់ត្រូវបានបោះត្រាខុស គឺប្រធានការិយាល័យប្រគល់ត្រាការិយាល័យទៅបោះលើសន្លឹកឆ្នោត ខុសនីតិវិធីដែលត្រូវប្រើត្រា ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យប្រើសម្រាប់បោះលើសន្លឹកឆ្នោត ។

នៅក្នុងរឿងនេះ លោក កែវ ភិរម្យ មានសំណូមពរដូចខាងក្រោម :

១-ទាមទារឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បង្ហាញហេតុផលដែលប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ច្រើនយ៉ាងនេះ ។

២-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅការិយាល័យទាំង ១៣ នៅឃុំស្វាយជ្រះ ។

៣-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំជីរផុង ការិយាល័យលេខ ០០១១ ។

៤-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំកំពង់ជីរ ការិយាល័យលេខ ០០២៤ ។

៥-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំវឌ្ឍនៈ ការិយាល័យលេខ ០២៩២ ។

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជាសាធារណៈ បានបញ្ជាក់ថា ការប្តឹងតវ៉ាពីការបាត់ឈ្មោះត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះ

បោះឆ្នោត គឺចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។ នៅឆ្នាំដែលមានការបោះឆ្នោតសកល ដូចជាឆ្នាំ២០១៣ នេះ ការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតបានចាប់ធ្វើពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១២ គឺធ្វើមុនមួយខែ ដែលមានចែងក្នុងប្រតិទិនរបស់គណៈ-កម្មាធិការជាតិរៀបចំបោះឆ្នោត ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១២ ស្របតាមបទប្បញ្ញត្តិនៃមាត្រា ៤៩ ថ្មី ( បី ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។ បណ្តឹងតវ៉ា ឬ ជំទាស់នឹងការបាត់ឈ្មោះ លុបឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត បានផុតអាជ្ញាយុកាលតាំងពីខែ ធ្នូ ឆ្នាំ២០១២ ។ នៅឃុំដីរឹផុង ការិយាល័យបោះឆ្នោតលេខ ០០១១ មានសន្លឹកឆ្នោតមិនបានការចំនួន ៩៤ សន្លឹក និង ឃុំកំពង់ដីរ ការិយាល័យបោះឆ្នោតលេខ ០០២៤ មានសន្លឹកឆ្នោតមិនបានការចំនួន ១១១ សន្លឹក ពុំមានភស្តុតាងមកបញ្ជាក់ឱ្យបានច្បាស់លាស់ទេ ។ ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និង អាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬ ភស្តុតាងដទៃទៀត ស្របតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ គ្រប់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតលើទម្រង់ ១១០២ ទម្រង់ ១១០៨ និង ក្រដាសធំកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតនីមួយៗ សុទ្ធតែមានចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ពីតំណាងគណបក្សនយោបាយ

- យល់ឃើញថា ពេលបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១៣ ការិយាល័យនៅឃុំស្វាយជ្រះ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានកញ្ចប់សុវត្ថិភាព "ក" ចំនួន ៨ ការិយាល័យ មិនបិទភ្ជិតដោយការសុវត្ថិភាព គឺជាភាពមិនប្រក្រតី ប៉ុន្តែកញ្ចប់សុវត្ថិភាព "ក" ទាំងអស់នេះ បានរក្សាទុកនៅក្នុងកញ្ចប់ "ខ" បិទភ្ជិតនិងចាក់សោឃ្លុំមានកត់ត្រាលេខ នៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ បន្ទាប់មកបញ្ជូនទៅ គឃ/សប គឃ/សប កាត់សោឃ្លុំចេញនៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ ហើយចងមាត់ បន្ទាប់មកយកកញ្ចប់ "ខ" ទៅដាក់ក្នុងកញ្ចប់ "គ" ដោយសរសេរសម្គាល់ពីក្រៅ ដោយបិចហ្វឹតលុបមិនជ្រះ នូវលេខកូដឃុំ សង្កាត់ និង លេខកូដការិយាល័យ ចងភ្ជិត និង ចាក់សោឃ្លុំមានលេខ នៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ រួចហើយបញ្ជូនកញ្ចប់ "គ" ទៅ គធ/ខប គធ/ខប យកកញ្ចប់ "គ" ទៅដាក់ក្នុងកញ្ចប់ "ឃ" ចងមាត់ចាក់សោឃ្លុំព្រមទាំងកត់ត្រាលេខសោនៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍
- យល់ឃើញថា ការមិនបកប្លាស្ទិកថ្លាចេញ ធ្វើឱ្យកញ្ចប់សុវត្ថិភាព "ក" ចំហរ ជាកំហុសរបស់មន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៨ ការិយាល័យ ។ មន្ត្រីដែលធ្វើការងារនោះផ្ទាល់នៅការិយាល័យ

ទាំង ៨ ការិយាល័យនេះត្រូវទទួលទណ្ឌកម្មតាមច្បាប់កំណត់ ។ ដោយឡែកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាអាណាព្យាបាលពីលើក៏ត្រូវទទួលខុសត្រូវខាងសីលធម៌អំពីការងារគ្រប់គ្រងរបស់ខ្លួន ។ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងកញ្ចប់សុវត្ថិភាព "ក" ទាំង ១៣ ការិយាល័យនៅឃុំស្វាយជ្រះ ឃើញថាសំឡេងឆ្នោតរបស់គណបក្សសង្គ្រោះជាតិ និង សំឡេងឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា ក្នុងទម្រង់ ១១០២ ទម្រង់ ១១០៨ និង ក្រដាសធំកត់ត្រាសំឡេងឆ្នោត មិនមានការប្រែប្រួលទេ ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" ១៣ ការិយាល័យនៅឃុំស្វាយជ្រះ

- យល់ឃើញថា ជាចុងក្រោយ លោក **កែវ ភីរម្យ** និង លោកមេធាវីទាំងពីររូប បានលើកសំណូមពរចំនួន ៤ ចំណុច ៖

១-បដិសេធសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចោលទាំងស្រុង ។

២-អនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការរាប់សន្លឹកឆ្នោតបានការ និង ផ្ទៀងផ្ទាត់ឡើងវិញលើសន្លឹកឆ្នោតមិនបានការទូទាំងខេត្តក្រចេះទាំងមូល ។

៣-ចាត់ឱ្យមានការស៊ើបអង្កេតឡើងវិញ ថាតើកំហុសទាំងអស់ខាងលើនេះ មានការបង្កាប់បញ្ហាពីត្រឹមថ្នាក់ណា ? ត្រឹមថ្នាក់សមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ឬថ្នាក់សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬ ពីថ្នាក់សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះទៅ ។

៤-សុំឱ្យមានការផ្តន្ទាទោសលើជនប្រព្រឹត្តល្មើស តាមមាត្រា ១២៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** នៅពេលសវនាការជាសាធារណៈបានបំភ្លឺបន្ថែមថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបំពេញសមត្ថកិច្ចស្របតាមច្បាប់ និង បទបញ្ជានិងនីតិវិធី ។ ក្រោយពីបានឃើញលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១៣ ការិយាល័យនៅឃុំស្វាយជ្រះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចាត់តាំងមន្ត្រីក្រុមសេវាកម្មច្បាប់របស់ខ្លួនឱ្យចុះទៅធ្វើការត្រួតពិនិត្យ ។ លទ្ធផលនៃការត្រួតពិនិត្យត្រូវបានលោក **កែវ ផល្លា** អានជូនអង្គសវនាការជាសាធារណៈទាំងស្រុង ។ ជាចុងក្រោយបង្អស់ ឯកឧត្តម **ម៉ៅ សុភារិទ្ធ** បានសំណូមពរសុំតម្កល់សេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ ទុកជាបានការពេញទាំងមូល

- យល់ឃើញថា កំហុសរបស់មន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៨ ការិយាល័យនៅឃុំស្វាយជ្រះ ត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់កំណត់
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០១៩/១៣ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ មានមូលហេតុ ព្រមទាំងធ្វើឡើងស្របតាមទម្រង់ និង គតិច្បាប់ លើកលែងតែមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតក្នុងការិយាល័យទាំង ៨ នៃឃុំស្វាយជ្រះ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនបានលើកឡើង
- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលខេត្តក្រចេះពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋក្នុងមណ្ឌលបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរីដែលមានអត្រា ៦៨,៦៣% ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក ***កែវ ភីរម្យ*** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ ប៉ុន្តែសេចក្តីសម្រេចនេះមិនបានចាត់វិធានការលើមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៨ នៅឃុំស្វាយជ្រះដែលបានប្រព្រឹត្តខុស ។

**មាត្រា ៣.-** ប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់វិធានការដាក់ទណ្ឌកម្មលើមន្ត្រីដែលប្រព្រឹត្តខុសដូចមានចែងក្នុងមាត្រា ២ ។

**មាត្រា ៤.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣៣/០៣៧/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣១/០០៦/២០១៣ កបធ.ច

ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជា ប៉ូច** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **ជា ប៉ូច** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពត
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៥៤/១៣ គ.ជ.ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ជា ប៉ូច** កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយឯកសារភស្តុតាងចំនួនពីរដុំ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជា ប៉ូច** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ៣០ នាទី គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន។

- យល់ឃើញថា ពាក្យបណ្ដឹងរបស់ឯកឧត្ដម **ជា ប៉ូច** ប្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ក៏ដូចជាការឆ្លើយបំភ្លឺ ចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺទាមទារឱ្យបដិសេធលទ្ធផលនៃការបោះឆ្នោតនៅមណ្ឌលខេត្តកំពតទាំងមូល ទាមទារឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តកំពតឡើងវិញ និង ទាមទារឱ្យផ្ទៀងផ្ទាត់ឡើងវិញនូវទម្រង់ ១១០២ និងទម្រង់ ១១០៤ ក្នុងកញ្ចប់ " ក " ទូទាំងខេត្តកំពត ។ ដើមបណ្ដឹងបានសង្កត់ធ្ងន់លើចំណុចសំខាន់ពីរ គឺ

-យល់ឃើញថា ការមានប្រជាពលរដ្ឋជាច្រើនត្រូវគេបោះឆ្នោតជំនួសនៅថ្ងៃបោះឆ្នោត ដើមបណ្តឹងពុំបាន បង្ហាញភស្តុតាងច្បាស់លាស់ ដែលបញ្ជាក់ថា អ្នកបោះឆ្នោតជំនួសនោះនៅការិយាល័យលេខប៉ុន្មាន ចំនួនប៉ុន្មាននាក់ និង ឈ្មោះណាខ្លះឡើយ

- យល់ឃើញថា ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការ ដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬ ភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា នៅមណ្ឌលខេត្តកំពតសរុបមាន ៨៤៨ ការិយាល័យ ការបោះឆ្នោតពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមាន អត្រា ៦៨,៩៦%

- យល់ឃើញថា លិខិតលេខ ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **ជា ប៉ូច** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង
លេខៈ២៣៤/០៣៨/២០១៣
ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣
សេចក្ដីសម្រេច
លេខៈ១៣២/០០៧/២០១៣ កបធ.ច
ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានឃើញលិខិតលេខ ៨២៤/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **ឡុង ម៉ុន្នី** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រៃវែង

-បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោក **ឡុង ម៉ុន្នី** ជាតំណាងគណបក្សសង្គ្រោះជាតិក្នុងការដាក់ពាក្យបណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រៃវែង

-បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៥៥/១៣ គ.ជ.ប ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣

-បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ឡុង ម៉ុន្នី** កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយឯកសារភស្តុតាងចំនួនបីរយម្ភៃប្រាំបីទំព័រ

-បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ចំនួនប្រាំពីរទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **ឡុង ម៉ុន្នី** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ៣៧ នាទី គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងចំណុចទី២ មាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

-យល់ឃើញថា បណ្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺទាមទារ ៨ ចំណុច ប្រមូលផ្ដុំលើបញ្ជីឈ្មោះសម្រាប់ការបោះឆ្នោត ការចេញលិខិតបញ្ជាក់អត្តសញ្ញាណ មានក្រុមមនុស្សថ្មីៗ ចេញទៅបោះឆ្នោត ប្រធានភូមិ អនុប្រធានភូមិឈរមុខមណ្ឌលកត់ឈ្មោះប្រជាពលរដ្ឋចូលបោះឆ្នោត ករណីនៅការិយាល័យលេខ ០៩៣៤ នៅក្រុងព្រៃវែង បិទទ្វារបង្អួចនៅពេលរាប់សន្លឹកឆ្នោត ការចេញលិខិតបញ្ជាក់អត្តសញ្ញាណឱ្យជនជាតិវៀតណាម លើទម្រង់ ១១០៤ អត់បានបោះត្រា និង មិនបំពេញទិន្នន័យគ្រប់ និង មានអ្នកដែលគេបោះឆ្នោតជំនួស ។ ដើមបណ្ដឹងលើកសំណូមពរ ៥ចំណុចៈ សូមពិនិត្យឡើងវិញនូវបញ្ជីបោះឆ្នោតឡើងវិញសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ សូមផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលបោះឆ្នោតសម្រាប់ស្រុកមេសាង សូមឱ្យរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យលេខ ០៩៣៤ សូមឱ្យបោះឆ្នោតឡើងវិញនៅស្រុកកំចាយមារទាំងស្រុង និង សូមឱ្យអ្នកមិនបានបោះឆ្នោតបានបោះឆ្នោតឡើងវិញ

-យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ចំនួនប្រាំពីរទំព័រ បានបញ្ជាក់ថា ការប្ដឹងតវ៉ាពីបញ្ជីឈ្មោះបោះឆ្នោតត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ បញ្ហានេះផ្អែកតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់ការបោះឆ្នោត ឆ្នាំ២០១៣ គឺផុតអាជ្ញាយុកាលតវ៉ាហើយ ។ អំពីភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្ត-សញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ការដែលថាមានអ្នកមកបោះឆ្នោតជំនួស ដើមបណ្ដឹងពុំបានផ្ដល់ភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថា អ្នកកាន់លិខិតបញ្ជាក់អត្តសញ្ញាណទៅបោះឆ្នោតនៅការិយាល័យណាមួយទេ និង អ្នកបោះឆ្នោតជំនួសក៏មិនដឹងថាបោះឆ្នោតនៅការិយាល័យណាមួយដែរ ។ ចំពោះទម្រង់ ១១០៤ តំណាង គ.ជ.ប បានបញ្ជាក់ថានេះគ្រាន់តែជាឯកសារចម្លងទិន្នន័យពីទម្រង់ ១១០២ តែប៉ុណ្ណោះ។ ភស្តុតាងដែលដើមបណ្ដឹងបង្ហាញតាមរយៈទម្រង់ ១១០៤ បីសន្លឹកមិនបានបោះត្រា និងទម្រង់ ១១០៤ ខ្លះមិនបានបំពេញព័ត៌មានគ្រប់ គ្រាន់តែជាកំហុសផ្នែករដ្ឋបាលប៉ុណ្ណោះ ។ ចំពោះការសុំផ្ទៀងផ្ទាត់ឡើងវិញលទ្ធផលបោះឆ្នោតក្នុងស្រុកមេសាង ការរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យ ០៩៣៤ ការសុំឱ្យបោះឆ្នោតសាជាថ្មីនៅស្រុកកំចាយមារទាំងស្រុង និង សុំឱ្យអ្នកមិនបានបោះឆ្នោតអាចទៅបោះឆ្នោតឡើងវិញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចទទួលសំណូមពរនេះបានឡើយ ពីព្រោះដើមបណ្ដឹងពុំមានទឡ្ហីករណ៍សមហេតុផលដូចមានចែងក្នុងច្បាប់បោះឆ្នោតទេ ។ ការលើកឡើងអំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និង អាស័យដ្ឋាននៃសាក្សី ព្រមទាំងឯកសារ និង ភស្តុតាងដទៃទៀត ដើមបណ្ដឹងមិនមានអ្វីយកមកបញ្ជាក់ឱ្យត្រូវតាមបទប្បញ្ញត្តិ មាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

-យល់ឃើញថា នៅមណ្ឌលខេត្តព្រៃវែងមាន ១.៦០៥ ការិយាល័យ ការបោះឆ្នោតពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៧១,២១ ភាគរយ

-យល់ឃើញថា លិខិតលេខ ៨២៤/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្ដឹងរបស់លោក **ឡុង ប៊ុន្នី** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់លិខិតលេខ ៨២៤/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្ដីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ ៖ ២២៧/០៣១/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ ៖ ១៣៣/០០៨/២០១៣ កបធ.ច

ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ប្តឹងតវ៉ានឹងលទ្ធផលបោះឆ្នោតបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **រស់ សួ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៦២/១៣ គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **រស់ សួ** កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៤៥ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ នៃមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃបណ្តឹងរបស់លោក **រស់ សួ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ : ១-សើរើបញ្ជី

ឈ្មោះផ្លូវការឆ្នាំ២០១២ ឱ្យត្រឹមត្រូវ ដែលបានបាត់ឈ្មោះ និងឈ្មោះអ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ ២-សេរីបញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ ខុសឈ្មោះ និងឈ្មោះស្ទួនច្រើន និង ៣-ផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោតបណ្ដោះអាសន្នតាមទម្រង់ ១១០៤ ឡើងវិញ។ ដើមបណ្ដឹងសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ មេត្តាពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្ដីសម្រេច(តាមពិតជាលិខិត) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលផ្ទុយពីបទបញ្ជា និងនីតិវិធីដែលច្បាប់បានកំណត់។ ដើមបណ្ដឹងពុំមានភស្តុតាងអ្វីប្រគល់ជូនក្រុមប្រឹក្សាធម្មនុញ្ញទេ

- យល់ឃើញថា ឯកឧត្ដម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញដោយបញ្ជាក់ថា : ការប្ដឹងតវ៉ាពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះ ត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ដើមបណ្ដឹងមិនបានកំណត់ការិយាល័យណាមួយច្បាស់លាស់ ឈ្មោះ និងលេខរៀងក្នុងបញ្ជីឈ្មោះប្រជាពលរដ្ឋនោះឡើយ។ ករណីមានអ្នកបោះឆ្នោតជំនួស ដើមបណ្ដឹងពុំមានភស្តុតាងច្បាស់លាស់ដើម្បីបញ្ជាក់ថា ករណីនេះកើតឡើងនៅការិយាល័យណាមួយដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិនិត្យ និងវាយតម្លៃផលប៉ះពាល់លើលទ្ធផលបោះឆ្នោតបានឡើយ ហើយដើមបណ្ដឹងក៏មិនបានចាំចំនួន និងឈ្មោះទេ តែបញ្ជាក់ថា មានចំនួនតិចតួច។ ចំពោះការតវ៉ាលើទម្រង់ ១១០៤ ដែលមានលទ្ធផលខុសពីការប្រកាសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើមបណ្ដឹងពុំបានផ្ដល់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើជាមូលដ្ឋានពិចារណាសម្រេចតាមច្បាប់បានឡើយ។ ដើមបណ្ដឹងមិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រទេ
- យល់ឃើញថា នៅមណ្ឌលខេត្តកំពង់ស្ពឺសរុបមាន ១.០៦៧ ការិយាល័យ ការបោះឆ្នោតពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៧៦,៦៧ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

# សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្ដឹងរបស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់លិខិតលេខ ៨២៧/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣៥/០៣៩/២០១៣

ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣

**សេចក្ដីសម្រេច**

លេខ : ១៣៤/០០៩/២០១៣ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ របស់លោក **ងឹម ញេង** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តពោធិសាត់
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **ងឹម ញេង** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តពោធិសាត់
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៧៣/១៣ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **ងឹម ញេង** កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ របស់លោក **ងឹម ញេង** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួល នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១០ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ មាត្រា ២៧ ថ្មី

នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **ងិម ញ៉េង** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារ ដូចតទៅ : ទី១ បដិសេធលទ្ធផលការបោះឆ្នោតនៅមណ្ឌលខេត្តពោធិសាត់ ទី២ ឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តពោធិសាត់ឡើងវិញ និងទី៣ ឱ្យបោះឆ្នោតឡើងវិញទូទាំងខេត្តពោធិសាត់ ។ ដើមបណ្តឹងទាមទារយ៉ាងនេះដោយសំអាងថា ១-នៅមណ្ឌលខេត្តពោធិសាត់ទាំងមូលមានប្រជាពលរដ្ឋជាច្រើន បាត់ឈ្មោះពីបញ្ជីបោះឆ្នោត ឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់ ២-នៅការិយាល័យមួយចំនួន ប្រធានការិយាល័យបោះឆ្នោតបានអនុញ្ញាតឱ្យអ្នកកាន់លិខិតបញ្ជាក់អត្តសញ្ញាណមិនត្រឹមត្រូវបោះឆ្នោត ហើយខ្ញុំបាទបានប្តឹងបដិសេធលទ្ធផលបោះឆ្នោត តាមឋានានុក្រមរួចហើយ តែត្រូវគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់បដិសេធ ៣-ករណីទំនាស់ផលប្រយោជន៍រវាងគណៈកម្មការរៀបចំការបោះឆ្នោតខេត្តពោធិសាត់ និងបេក្ខជនតំណាងរាស្ត្ររបស់គណបក្សនយោបាយ និង ៤-ករណីមានឈ្មោះជនបរទេសច្រើននៅក្នុងបញ្ជីបោះឆ្នោត។ ដើមបណ្តឹងពុំមានភស្តុតាងអ្វីប្រគល់ជូនក្រុមប្រឹក្សាធម្មនុញ្ញទេ

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ បានបញ្ជាក់ថា : ការប្តឹងតវ៉ារបស់លោក **ងិម ញ៉េង** ទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅមណ្ឌលខេត្តពោធិសាត់ ដើមបណ្តឹងលើកមូលហេតុថា នៅការិយាល័យលេខ ០៣០១ ០៦២១ ០៤១១ ០៤១២ និង ០៣០៧ ក្នុងឃុំផ្ទះព្រៃ និងឃុំរលាប ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនេះបានអនុញ្ញាតឱ្យប្រជាពលរដ្ឋកាន់លិខិតបញ្ជាក់អត្តសញ្ញាណមិនត្រឹមត្រូវបានបោះឆ្នោត។ ផ្អែកតាមពាក្យបណ្តឹង និងចម្លើយរបស់លោក **ងិម ញ៉េង** ព្រមទាំងឯកសារភស្តុតាង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធបណ្តឹង ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ ដោយហេតុថា : ១-ការអះអាងរបស់លោក **ងិម ញ៉េង** ថា ប្រធានការិយាល័យបោះឆ្នោតបានអនុញ្ញាតឱ្យប្រជាពលរដ្ឋកាន់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតមិនត្រឹមត្រូវបានបោះឆ្នោតនៅការិយាល័យទាំងឡាយដូចរៀបរាប់ខាងលើ។ នគរបាលបច្ចេកទេសវិទ្យាសាស្ត្រខេត្តពោធិសាត់បានធ្វើការត្រួតពិនិត្យស្នាមត្រាលើរូបថតដែលបានបិទ ក្នុងលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតបានលទ្ធផលថា ពិតជាមានស្នាមត្រានៅលើរូបថតប្រាកដមែន ២-បណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬជនបរទេសមានឈ្មោះក្នុងបញ្ជីបោះឆ្នោតត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

បណ្តឹងនេះផុតអាជ្ញាយុកាលតាំងពីចុងឆ្នាំ២០១២ ម្ល៉េះ ៣-ករណីលោក **ផាន់ វណ្ណសិទ្ធិ** មានភរិយាជាបេក្ខជនតំណាងរាស្ត្រមណ្ឌលខេត្តពោធិសាត់ និងលោក **ឯម ភូរីបុទ្ធិ** មានបងស្រីជាបេក្ខជនតំណាងរាស្ត្រមណ្ឌលខេត្តពោធិសាត់នោះ មិនប៉ះពាល់ដល់ទំនាស់ផលប្រយោជន៍ក្នុងការងាររៀបចំការបោះឆ្នោតទេ ៤-ទឡ្ហីករណ៍ ដែលដើមបណ្តឹងសំអាងទាំងប៉ុន្មាន ពុំមានលក្ខណៈត្រឹមត្រូវតាមបទប្បញ្ញត្តិ មាត្រា ១១១ ថ្មី និងមាត្រា ១១២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនាំឱ្យមានការរៀបចំការបោះឆ្នោតសាជាថ្មីទេ ៥-ដើមបណ្តឹងមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីគណៈកម្មការ និងសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារឬភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា នៅមណ្ឌលខេត្តពោធិសាត់សរុបមាន ៦២៥ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៧២,៦០ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **ងឹម ញៀង** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨២២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣២/០៣៦/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣៥/០១០/២០១៣ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញលិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ហូរ ទាវ៉ន់** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **ហូរ ទាវ៉ន់** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលរាជធានីភ្នំពេញ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៨១/១៣ គ.ជ.ប ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ហូរ ទាវ៉ន់** កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយភស្តុតាងជាឯកសារ ស៊ីឌី និង ឌីវីឌី ដាក់ក្នុង ០៣ កេសក្រដាស និងក្នុងកញ្ចប់ក្រដាស ០១
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ហូរ ទាវ៉ន់** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ៣០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់ឯកឧត្តម **ហុរ វ៉ាន់** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តមបានបញ្ជាក់ការទាមទារដូចតទៅ ÷ ១-ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះអ្នកដែលបាត់ឈ្មោះទាំងអស់ឡើងវិញ និង បានបោះឆ្នោតឡើងវិញ ២-ឱ្យបញ្ចេញបញ្ជីឈ្មោះដែលបានបោះឆ្នោតហើយផ្ទៀងផ្ទាត់ឈ្មោះស្ទួន ឈ្មោះខ្មោច (មានតែឈ្មោះតែមិនមានមនុស្ស) គ្រប់សង្កាត់ទាំងអស់ ៣-ឱ្យបោះឆ្នោតឡើងវិញនៅសង្កាត់ចំនួន ៣២ ដែលមានភាពមិនប្រក្រតីច្រើនជាងគេ ៤-កែតម្រូវឈ្មោះប្រជាពលរដ្ឋដែលខុស ហើយឱ្យគាត់បានបោះឆ្នោតឡើងវិញ ៥-លុបឈ្មោះជនបរទេសទាំងអស់នៅក្នុងរាជធានីភ្នំពេញចោល មិនឱ្យជនបរទេសមានសិទ្ធិបោះឆ្នោត ៦-ផ្តន្ទាទោសអ្នកដែលមិនមានទីលំនៅនៅភ្នំពេញ បានមកបោះឆ្នោតនៅភ្នំពេញ។ ដើមបណ្តឹងទាមទារយ៉ាងនេះដោយសំអាងថា : ១-នៅមណ្ឌលរាជធានីភ្នំពេញទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោត។ គណបក្សសង្គ្រោះជាតិបានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋចំនួន ១.៥៤៧ នាក់ ២-នៅការិយាល័យជាច្រើនក្នុងរាជធានីភ្នំពេញមានឈ្មោះស្ទួនជាច្រើន ជាពិសេស នៅសង្កាត់បឹងកេងកង៣ សង្កាត់ផ្សារដើមថ្កូវ និងសង្កាត់ទន្លេបាសាក់ ក្នុងខណ្ឌចំការមន ៣-មានភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណ នៅសង្កាត់កោះដាច់ សង្កាត់បឹងទំពុន ដែលក្នុងករណីនេះ គណបក្សសង្គ្រោះជាតិប្រមូលបានចំនួនប្រាំបី ៤-មានការកែឈ្មោះអ្នកបោះឆ្នោតជាច្រើន ៥-មានករណីបោះឆ្នោតជំនួសជាច្រើន ដែលគណបក្សសង្គ្រោះជាតិបានទទួលបណ្តឹងពីប្រជាពលរដ្ឋចំនួនកៅសិបប្រាំ ៦-មានករណីមិនឱ្យប្រជាពលរដ្ឋបោះឆ្នោតជាច្រើននាក់ដែលគណបក្សសង្គ្រោះជាតិទទួលបានបណ្តឹងចំនួនសាមសិបពីរ ៧-មានជនបរទេសជាច្រើនមកបោះឆ្នោត ៨-មានអ្នកបោះឆ្នោតដែលមិនមានលំនៅស្ថាននៅរាជធានីបានទៅបោះឆ្នោត។ ជាចុងក្រោយឯកឧត្តម **ហុរ វ៉ាន់** បានសំណូមពរមកក្រុមប្រឹក្សាធម្មនុញ្ញដើម្បីដោះស្រាយតាមនីតិវិធីដោយក្តីអនុគ្រោះ

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ បានបញ្ជាក់ថា : ១-ការប្តឹងតវ៉ា ឬជំទាស់ពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោត ការកែឈ្មោះអ្នកបោះឆ្នោត និង មានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតនោះ ត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ បញ្ហានេះ ផ្អែកតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ គឺផុតអាជ្ញាយុកាលតវ៉ាហើយ។ ២-អំពីភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ការដែលថាមានអ្នកមកបោះឆ្នោតជំនួស ដើមបណ្តឹងពុំបានផ្តល់ភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថា អ្នកកាន់លិខិតបញ្ជាក់អត្តសញ្ញាណទៅបោះឆ្នោតនៅការិយាល័យណាមួយទេ និងអ្នកបោះឆ្នោតជំនួស ក៏មិនដឹងថាបោះឆ្នោតនៅការិយាល័យណាមួយដែរ។

៣-ភស្តុតាងទាំងឡាយដែលបានផ្តល់ជូន មិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែលតម្រូវឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀបចំការបោះឆ្នោតសាជាថ្មីនៅ ៣១ សង្កាត់ នៃរាជធានីបានឡើយ (ក្នុងបណ្តឹងតវ៉ាមកក្រុមប្រឹក្សាធម្មនុញ្ញឯកឧត្តម **ហូរ ឡាន់** បន្ថែមឱ្យបោះឆ្នោតសាជាថ្មី ០១ សង្កាត់ទៀត) ។ ៤-ដើមបណ្តឹងមិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាល-បរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលរាជធានីភ្នំពេញសរុបមាន ១.៦៩០ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៦៦,៤៦ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **ហូរ ឡាន់** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់លិខិតលេខ ៨២៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សុីអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២២៨/០៣២/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

**សេចក្ដីសម្រេច**

លេខ : ១៣៦/០១១/២០១៣ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការ-ជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបន្ទាយមានជ័យ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **រស់ សួ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបន្ទាយមានជ័យ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៧១/១៣ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **រស់ សួ** កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៤៥ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សា-ធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **រស់ សួ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារ ដូចតទៅ ÷ ១-បញ្ជីឈ្មោះផ្លូវការឆ្នាំ២០១២ មានខុសឈ្មោះ និង ឈ្មោះស្ទួនច្រើន ២-បាត់ឈ្មោះអ្នកបោះឆ្នោត ៣-អ្នកបោះឆ្នោត បោះឆ្នោតជំនួសឈ្មោះគេ ៤-ទឹកខ្មៅលុបមិនជ្រះ ៥-លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត គ្មានរូបថត និង ត្រា និង ៦-ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្តោះអាសន្នតាមទម្រង់ ១១០៤ ឡើងវិញ។ ដើមបណ្តឹងបានបញ្ជាក់បន្ថែមថា នៅកន្លែងបោះឆ្នោតក្នុងខេត្តបន្ទាយមានជ័យ មានសុវត្ថិភាពទាំងអស់ គ្មានបញ្ហាអ្វីទេ គ្មានអំពើហិង្សាទេ គឺមានតែបញ្ហាបាត់ឈ្មោះតែប៉ុណ្ណោះ ហើយលោកពុំមានភស្តុតាងអ្វីប្រគល់ជូនក្រុមប្រឹក្សាធម្មនុញ្ញទេ។ លោក **រស់ សួ** សំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ និងពិចារណាឡើងវិញ នូវសេចក្តីសម្រេច (តាមពិតជាលិខិត) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ បានបញ្ជាក់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបដិសេធពាក្យបណ្តឹងរបស់លោក **រស់ សួ** តាមលិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ ដោយសំអាងហេតុផលដូចតទៅ ÷ ១-ដើមបណ្តឹងគ្រាន់តែរៀបរាប់អំពីភាពមិនប្រក្រតី ប៉ុន្តែខ្លួនគាត់ក៏មិនច្បាស់លាស់ខ្លួនឯងផង ២-លោក **រស់ សួ** បញ្ជាក់ថាគាត់គ្មានភស្តុតាងទេ និង ៣-អ្នកសង្កេតការណ៍តំណាងគណបក្សសង្គ្រោះជាតិ បានចុះហត្ថលេខាលើកំណត់ហេតុនៅគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងមណ្ឌលខេត្តបន្ទាយមានជ័យរួចអស់ហើយ។ ទន្ទឹមនឹងនេះ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធចំណុចទី៦ ចែងក្នុងពាក្យបណ្តឹងជំទាស់ ដោយហេតុថា ពុំមានក្នុងពាក្យបណ្តឹងនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ ។ រីឯការប្តឹងតវ៉ា ឬ ប្តឹងជំទាស់នឹងបញ្ជីឈ្មោះបោះឆ្នោត និង ការចុះឈ្មោះបោះឆ្នោត បានផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២ ម៉្លេះ ។ ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិក គណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬ ភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិ នៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ
- យល់ឃើញថា នៅមណ្ឌលខេត្តបន្ទាយមានជ័យសរុបមាន ៩៦២ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៥៤,១៦ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិ-ការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨៣២/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សុីអុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣៦/០៤០/២០១៣

ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣៧/០១២/២០១៣ កបធ.ច

ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **អ៊ុក ស៊ុយ** ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់ ១១០២ និងទម្រង់ ១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តតាកែវ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **អ៊ុក ស៊ុយ** ធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តតាកែវ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៦២/១៣ គ.ជ.ប ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **អ៊ុក ស៊ុយ** កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ និងឯកសារថតចម្លងមួយដុំមានចំនួនប៉ែតសិបប្រាំបួនសន្លឹក
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **អ៊ុក ស៊ុយ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១២ និង ២០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២ នៃមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃបណ្តឹងរបស់លោក **អ៊ុក ស៊ុយ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ ៖ ១-តវ៉ាឱ្យផ្ទៀងផ្ទាត់ឡើងវិញលើទម្រង់ ១១០២ និងទម្រង់ ១១០៤នៃមណ្ឌលខេត្តតាកែវទាំងអស់ ២-ទាមទារឱ្យផ្ទៀងផ្ទាត់នូវឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងខេត្តតាកែវឡើងវិញ ដោយហេតុថា ពលរដ្ឋមួយចំនួនមានឈ្មោះក្នុងឆ្នាំ២០១២ តែដល់ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ បាត់ឈ្មោះពីបញ្ជីបោះឆ្នោត។ ពលរដ្ឋមួយចំនួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែត្រូវបានគេបោះឆ្នោតជំនួស ៣-មានពលរដ្ឋខុសឈ្មោះ ថ្ងៃខែឆ្នាំកំណើត ឬកាន់លិខិតបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតក្លែងក្លាយទៅបោះឆ្នោត អ្នកមិនទាន់គ្រប់អាយុទៅបោះឆ្នោតជំនួសលើឈ្មោះពលករដែលធ្វើការនៅក្រៅប្រទេស ឬឈ្មោះអ្នកដទៃទៀតបាន ដោយយករូបថតបិទលើលិខិតបញ្ជាក់អត្តសញ្ញាណរបស់ពលករនៅក្រៅប្រទេស រួចជនមិនទាន់គ្រប់អាយុនោះទៅបោះឆ្នោតបានតែម្តង និង ៤-ទឹកខ្មៅជ្រលក់ដៃលុបលាងជ្រះ។ អនុភូមិតាសួនបានយកទឹកខ្មៅឱ្យឈ្មោះ កា ផាត ជ្រលក់ដៃមុនថ្ងៃបោះឆ្នោត លួងលោមឱ្យជាប្រាក់ទិញទឹកចិត្តចំនួន ៥០.០០០ រៀល។ ដើមបណ្តឹងបានអះអាងថា មានសាក្សី និងភស្តុតាងជាច្រើនទៀត តែចាំបង្ហាញនៅក្នុងសវនាការជាសាធារណៈនៅក្រុមប្រឹក្សាធម្មនុញ្ញ។ ពេលជួបក្រុមទី៣ លោកផ្តល់ជូនឯកសារថតចម្លងមួយចំនួនប៉ុណ្ណោះ តែក្រុមទី៣ ពិនិត្យទៅឃើញថាមិនពេញលក្ខណៈអាចយកមកពិចារណាបានទេ
- យល់ឃើញថា ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចំនួនបួនទំព័រ បានបញ្ជាក់ថា ៖ ការប្តឹងតវ៉ាពីការបាត់ឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះ ត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត រឿងនេះបានផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២មកម្ល៉េះ។ រីឯរឿងផ្សេងទៀតដែលដើមបណ្តឹងបានលើកឡើងតាមពិតត្រូវបានដោះស្រាយតាមលំដាប់លំដោយរហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញចប់សព្វគ្រប់ហើយ
- យល់ឃើញថា ដើមបណ្តឹងធ្វើសំណូមពរដោយទទូចឱ្យក្រុមប្រឹក្សាធម្មនុញ្ញបើកសវនាការជាសាធារណៈនោះ តាមការពិតសាមីខ្លួនពុំមានទឡ្ហីករណ៍សមហេតុផលដូចមានចែងក្នុងវាក្យខ័ណ្ឌទី៥ នៃមាត្រា១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ
- យល់ឃើញថា នៅមណ្ឌលខេត្តតាកែវសរុបមាន ១.៣០២ ការិយាល័យ ការបោះឆ្នោតពុំមានជួបប្រទះករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និងដោយសេរី ដែលមានអត្រា ៧៨,៤១ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **អ៊ុក ស៊ុយ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨២៨/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២២៩/០៣៣/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**សេចក្ដីសម្រេច**

លេខ : ១៣៨/០១៣/២០១៣ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តស្វាយរៀង
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **រស់ សួ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តស្វាយរៀង
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៧២/១៣ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **រស់ សួ** កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ ។

## ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
## ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៤៥ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ម៉ោង បន្ទាប់ពីទទួលលិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ មាត្រា ២៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **រស់ សួ** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកបានបញ្ជាក់ការទាមទារដូចតទៅ ÷ ១-ប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីអ្នកបោះឆ្នោត ២-មានការបោះឆ្នោតជំនួស ៣-មានឈ្មោះខុសច្រើន ៤-ទឹក

ខ្មៅលុបមិនជ្រះ ៥-លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត គ្មានរូបថត និង ត្រា និង ៦-ផ្ទៀងផ្ទាត់លទ្ធផលឆ្នោតបណ្តោះអាសន្នស្រុកចន្ទ្រា ក្រុងបាវិត តាមទម្រង់១១០៤ ឡើងវិញ ។ ដើមបណ្តឹងបានបញ្ជាក់បន្ថែមថា ក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១២ មានការបាត់ឈ្មោះអ្នកបោះឆ្នោតច្រើន បើប្រៀបធៀបទៅនឹងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ១៩៩៨ ។ ចំពោះថ្ងៃបោះឆ្នោតនៅស្រុកចន្ទ្រា និង ក្រុងបាវិត មិនមានការគម្រាមកំហែង មិនមានអំពើហិង្សា និង មិនមានការបាញ់បោះទេ ប៉ុន្តែគេប្រើសង្គ្រាមចិត្តសាស្ត្រ ដោយសារប្រជាពលរដ្ឋនៅទីនោះមានចំណេះដឹងទាប ។ ចំពោះបន្ទប់បោះឆ្នោតពិតជាសម្ងាត់ និង មិនមានចលាចលទេនៅថ្ងៃបោះឆ្នោត ប៉ុន្តែពេលរាប់សន្លឹកឆ្នោតមានការបិទទ្វារបង្អួចនៅការិយាល័យមួយ តែបន្ទាប់ពីយើងធ្វើការតវ៉ា ១៥នាទីក្រោយមកគេក៏បើកវិញ ។ ជាទូទៅនៅការិយាល័យបោះឆ្នោតខេត្តស្វាយរៀង មានសុវត្ថិភាពទាំងអស់ គ្មានបញ្ហាអ្វីទេ គ្មានអំពើហិង្សា គឺមានតែបញ្ហាបាត់ឈ្មោះតែប៉ុណ្ណោះ។ ដើមបណ្តឹងសំណូមពរឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យ និង ពិចារណាឡើងវិញនូវលិខិតជូនដំណឹងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង សូមឱ្យកែតម្រូវបញ្ជីបោះឆ្នោតដែលខុសកន្លងមក និង សូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យលទ្ធភាពកែច្បាប់បោះឆ្នោត និង មុនពេលបោះឆ្នោត សូមឱ្យក្រុមប្រឹក្សាធម្មនុញ្ញអញ្ជើញគ្រប់គណបក្សនយោបាយមកណែនាំរឿងបោះឆ្នោតដើម្បីឱ្យគោរពទាំងអស់គ្នា

-យល់ឃើញថា ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ បានបញ្ជាក់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបដិសេធពាក្យបណ្តឹងរបស់លោក **រស់ សួ** តាមលិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ដោយសំអាងហេតុផលដូចតទៅ ÷ ១-ដើមបណ្តឹងពុំមានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីនីមួយៗ ២-ការបាត់ឈ្មោះ ឬមានឈ្មោះលើសពីមួយក្នុងបញ្ជី ឬឈ្មោះស្ទួន និង ខុសឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺត្រូវប្តឹងតវ៉ា ឬប្តឹងជំទាស់នៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំស្របតាមមាត្រា ៤៩ថ្មី(បី) និងចាប់ពីមាត្រា ៥៧ថ្មី រហូតដល់មាត្រា ៦៨ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ៣-ដើមបណ្តឹងពុំមានភស្តុតាងដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុសពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និង អាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ដែលកើតមានឡើងនៅស្រុកចន្ទ្រា និង ក្រុងបាវិត ដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៤-ដើមបណ្តឹងពុំមានភស្តុតាងបញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា ១១១ ថ្មី និង មាត្រា ១១២ ថ្មី នៃច្បាប់ស្តីពី

វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើការបោះឆ្នោតសាជាថ្មីនៅស្រុកចន្ទ្រា និង ក្រុងបាវិត បានឡើយ ។ ទន្ទឹមនឹងនេះ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធចំណុចទី៦ ដែលចែងក្នុងពាក្យបណ្តឹងជំទាស់ដោយសំអាងថា ពុំមានក្នុងពាក្យបណ្តឹងនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទេ

- យល់ឃើញថា នៅមណ្ឌលខេត្តស្វាយរៀងសរុបមាន ៧៨៣ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៧៥,៥៨ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **រស់ សួ** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨៣៣/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣០/០៣៤/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣៩/០១៤/២០១៣ កបធ.ច

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញលិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **មុឺន ជួន** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនលោក **មុឺន ជួន** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តព្រះសីហនុ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៦៥/១៣ គ.ជ.ប ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **មុឺន ជួន** កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ និងបញ្ជីរាយនាមប្រជាពលរដ្ឋ ចំនួន ៥២៩ នាក់ មានហុកសិបពីរទំព័រ ដែលដើមបណ្តឹងសំអាងថាជាភស្តុតាង
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **មុឺន ជួន** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សា-ធម្មនុញ្ញ អាចទទួលពាក្យបណ្តឹងតវ៉ាខាងលើមកពិនិត្យបាន

- យល់ឃើញថា ពាក្យបណ្ដឹងរបស់លោក **ម៉ីន ជូន** ប្ដឹងតវ៉ានឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ អមដោយឯកសារភស្តុតាងចំនួនហុកសិបពីរទំព័រ និង សារណាការពារពីរទំព័រទៀត ក៏ដូចជាការឆ្លើយបំភ្លឺចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺទាមទារដូចតទៅ÷ ១-បដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅមណ្ឌលខេត្តព្រះសីហនុ ២-ឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តព្រះសីហនុឡើងវិញ ៣-ឱ្យរៀបចំបោះឆ្នោតសាជាថ្មីនៅខេត្តព្រះសីហនុ។ ដើមបណ្ដឹងទាមទារយ៉ាងនេះដោយសំអាងថា នៅខេត្តព្រះសីហនុមានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងមូលហេតុច្បាស់លាស់។ លោក **ម៉ីន ជូន** បានឆ្លើយបញ្ជាក់ថា ការបោះឆ្នោតមណ្ឌលខេត្តព្រះសីហនុ ពុំមានអំពើហិង្សា ពុំមានចលាចលវឹកវរ ពុំមានការគំរាមកំហែងបង្កឱ្យប្រជាពលរដ្ឋមានរបួសស្នាម និង ពុំមានករណីប្រធានសក្តិទេ។ រីឯក្នុងការិយាល័យបោះឆ្នោតប្រជាពលរដ្ឋពិតជាបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី។ ជាចុងក្រោយដើមបណ្ដឹងស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញ ដោះស្រាយតាមនីតិវិធីដោយអនុគ្រោះ
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ភ្ជាប់ដោយសារណាការពារចំនួនពីរទំព័រ បានបញ្ជាក់ថា បញ្ហាប្រជាពលរដ្ឋជាច្រើនត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដែលអ្នកប្ដឹងបានទទួលព័ត៌មានតាមការផ្ដិតមេដៃរបស់ប្រជាពលរដ្ឋថា បាត់ឈ្មោះ ហើយអ្នកប្ដឹងក៏គ្មានបញ្ជីឈ្មោះអ្នកទាំងអស់នោះដែរ។ ម្យ៉ាងវិញទៀតពួកអ្នកបាត់ឈ្មោះទាំងនោះ ក៏មិនបានបញ្ជាក់ថា ខ្លួនធ្លាប់មានឈ្មោះនៅការិយាល័យបោះឆ្នោតណាមួយនោះទេ ហើយបានទៅបោះឆ្នោតនៅការិយាល័យណាមួយនោះទេ។ បញ្ហាជនជាតិវៀតណាមជាច្រើនបានបោះឆ្នោត ដែលអ្នកប្ដឹងបានព័ត៌មានពីភ្នាក់ងារគណបក្ស ហើយអ្នកប្ដឹងក៏មិនបានដឹងថាមានប៉ុន្មាននាក់ ហើយក៏មិនបានដឹងថា បានបោះឆ្នោតនៅការិយាល័យណាដែរ។ បញ្ហាប្រជាពលរដ្ឋជាច្រើនបានរកការិយាល័យបោះឆ្នោតមិនឃើញ ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្ដូរទីតាំងការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមបញ្ជាក់ថា នៅខេត្តព្រះសីហនុ គ្មានការប្ដូរទីតាំងការិយាល័យបោះឆ្នោតណាមួយនោះទេ។ បញ្ហាមានប្រជាពលរដ្ឋមួយចំនួនត្រូវបានគេបោះឆ្នោតជំនួស តែអ្នកប្ដឹងមិនបានដឹងថាមានចំនួនប៉ុន្មាន ហើយនៅការិយាល័យណាមួយឡើយ។ បញ្ហាមានប្រជាពលរដ្ឋតែចំនួន ៨៧,៤៤៣ នាក់ ប៉ុណ្ណោះបានទៅបោះឆ្នោត ក្នុងបណ្ដាអ្នកមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោត ១២៦,៩៣៧ នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមបញ្ជាក់ថាការបោះឆ្នោតគឺជាការបោះឆ្នោតដោយស្ម័គ្រចិត្ត និង ទៅតាមសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួម

បោះឆ្នោត។ បញ្ហាភាពមិនប្រក្រតីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ករណីនេះ អ្នកប្តឹងមិនបានផ្តល់ភស្តុតាង ឯកសារ និង សាក្សីបញ្ជាក់ថា លិខិតទាំងអស់នោះត្រូវចេញនៅពេលណា ហើយក៏មិនបានបញ្ជាក់អំពីការិយាល័យបោះឆ្នោតដែលបានប្រើឯកសារមិនត្រឹមត្រូវនោះទេ។ បញ្ហាអ្នកសង្កេតការណ៍របស់គណបក្សសង្គ្រោះជាតិ ត្រូវបានដេញចេញឱ្យឆ្ងាយពីការិយាល័យ ហើយការិយាល័យមួយចំនួនបានបិទទ្វារបង្អួចពេលរាប់សន្លឹកឆ្នោត និង ការផ្តល់ទម្រង់ ១២០២ សម្រាប់ការប្តឹងតវ៉ាមានការយឺតយ៉ាវ ការលើកឡើងរបស់ដើមបណ្តឹងក៏គ្មានអ្វីសម្រាប់សំអាងនោះឡើយ។ ចំពោះការតវ៉ាឬការជំទាស់នឹងការបាត់ឈ្មោះ លុបឈ្មោះ និង ការចុះឈ្មោះបោះឆ្នោតបានផុតអាជ្ញាយុកាលតាំងពីចុងឆ្នាំ២០១២ម្ល៉េះ

- យល់ឃើញថា ការទាមទារឱ្យបោះឆ្នោតសាជាថ្មីនៅមណ្ឌលខេត្តព្រះសីហនុ ដើមបណ្តឹងពុំបានបង្ហាញទឡ្ហីករណ៍សមហេតុផលដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១១ ថ្មី និងមាត្រា ១១២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ
- យល់ឃើញថា តាមការឆ្លើយបញ្ជាក់របស់លោក **ម៉ឹន ជួន** នៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញថា ការបោះឆ្នោតនៅមណ្ឌលខេត្តព្រះសីហនុ ពុំមានអំពើហិង្សា ពុំមានចលាចលវឹកវរ ពុំមានការគំរាមកំហែងបង្កឱ្យប្រជាពលរដ្ឋមានរបួសស្នាម និង ពុំមានករណីប្រធានសក្តិទេ។ រីឯនៅក្នុងការិយាល័យបោះឆ្នោតទាំងអស់ ប្រជាពលរដ្ឋពិតជាបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី
- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលខេត្តព្រះសីហនុ សរុបមាន ២៤៨ ការិយាល័យ ការបោះឆ្នោតពុំមានករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៨,៨៩ ភាគរយ
- យល់ឃើញថា លិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

## សម្រេច

**មាត្រា ១**~ ទទួលពាក្យបណ្តឹងរបស់លោក **ម៉ឹន ជួន** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

**មាត្រា ២**~ តម្កល់លិខិតលេខ ៨២១/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល។

**មាត្រា ៣.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។៤/៤៨

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣៧/០៤១/២០១៣

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤០/០១៥/២០១៣ កបធ.ច

ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ./.

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **គួយ ប៊ុនរឿន** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **គួយ ប៊ុនរឿន** ធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៨០/១៣ គ.ជ.ប ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ របស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **គួយ ប៊ុនរឿន** កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយបញ្ជីឈ្មោះស្ទួនក្រៅ និង ក្នុងខេត្ត-រាជធានី ចំនួន៧,៩៨១សន្លឹក បញ្ជីបោះឆ្នោតស្ទួនចំនួន ០៨សឺមី ស្នាមមេដៃប្រជាពលរដ្ឋបាត់បង់សិទ្ធិបោះឆ្នោតចំនួន០៨ដុំ លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការបោះឆ្នោតនៅខេត្តព្រៃវែងចំនួន០១ដុំ និង របាយការណ៍របស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ចំនួន០១ដុំ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៣ មានចំនួនបីទំព័រ និង សេចក្តីបំភ្លឺបន្ថែមលើសារណាការពារចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ចំនួនមួយទំព័រ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **គួយ ប៊ុនរឿន** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៣ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី

នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងតវ៉ារបស់ឯកឧត្តម **គួយ ប៊ុនរឿន** ប្តឹងមកក្រុមប្រឹក្សា-ធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយមានសំអាងប្រាំបីចំណុចប្រមូលផ្តុំលើបញ្ហាដូចតទៅ ÷ ១-បញ្ជីឈ្មោះបោះឆ្នោតផ្លូវការដែលមានសុពលភាពតាំងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ២-ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើការបោះឆ្នោត ៣-ទឹកខ្មៅលុបលាងជ្រះ ៤-ប្រជាពលរដ្ឋគ្មានឯកសារបញ្ជាក់អត្តសញ្ញាណអាចបោះឆ្នោតបាន ៥-ការលុបឈ្មោះប្រជាពលរដ្ឋចេញពីបញ្ជីបោះឆ្នោត ៦-ការមិនអនុញ្ញាតឱ្យពលរដ្ឋមានអត្តសញ្ញាណប័ណ្ណបានបោះឆ្នោតដោយគ្រាន់តែលម្អៀងទិន្នន័យបន្តិចបន្តួចរវាងអត្តសញ្ញាណប័ណ្ណនឹងបញ្ជីឈ្មោះបោះឆ្នោត ៧-ការប្តូរការិយាល័យបោះឆ្នោត និង ៨-ការប្រើប្រាស់បណ្តាញសារព័ត៌មាន (វិទ្យុ ទូរទស្សន៍) មិនស្មើភាពគ្នា។ ដើមបណ្តឹងបានលើកសំណើបីចំណុចមកក្រុមប្រឹក្សាធម្មនុញ្ញគឺ ÷ ១-បដិសេធលិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ទុកជាអាសារបង់ ២-ស៊ើបអង្កេតគ្រប់ករណីនៃភាពមិនប្រក្រតីដូចរៀបរាប់ក្នុងពាក្យបណ្តឹងឱ្យមានតម្លាភាព ដោយបង្កើតក្រុមការងារបច្ចេកទេស និង វាយតម្លៃភាពមិនប្រក្រតីដោយអង្គការសង្គមស៊ីវិលជាតិ និង អន្តរជាតិដែលមានជំនាញខាងកិច្ចការបោះឆ្នោត និង មានតំណាងរបស់អង្គការសហប្រជាជាតិជាអ្នកសង្កេតការណ៍ ៣-ធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោតឡើងវិញ

- យល់ឃើញថា ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ អមដោយសារណាការពារ មានខ្លឹមសារសង្ខេបដូចតទៅ ÷ ១-ដើមបណ្តឹងពុំមានភស្តុតាងជាក់លាក់អំពីចំណុចនៃភាពមិនប្រក្រតីនីមួយៗចំពោះការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតមិនប្រក្រតី មានអ្នកមកបោះឆ្នោតជំនួស និង ករណីទឹកខ្មៅលុបជ្រះនៅការិយាល័យណាមួយដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យ និង វាយតម្លៃលើផលប៉ះពាល់បានឡើយ ២-ការបាត់ឈ្មោះ ឬមានឈ្មោះលើសពីមួយក្នុងបញ្ជីបោះឆ្នោត ឬឈ្មោះស្ទួន និង កែតម្រូវឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២ម្ល៉េះ ៣-ដើមបណ្តឹងពុំមានភស្តុតាងដាក់ជូន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែល

បញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិក គណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីទីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀតដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៤-ពុំមានភស្តុតាងបង្ហាញថា គណៈកម្មការបានអនុវត្តផ្ទុយពីមាត្រា ៧៤ និង មាត្រា ៧៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៥-ពុំមានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិណាដែលអាចឱ្យបង្កើតក្រុមការងារបច្ចេកទេសស៊ើបអង្កេត និង វាយតម្លៃភាពមិនប្រក្រតីនៃការបោះឆ្នោតជាតិ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលជាតិ និង អន្តរជាតិ ព្រមទាំងមានតំណាងអង្គការសហប្រជាជាតិជាអ្នកសង្កេតការណ៍ឡើយ ៦-ដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងមណ្ឌលរាជធានី-ខេត្តត្រូវបានអនុវត្តតាមលំដាប់ថ្នាក់នៅ គឃ/សប គធ/ខប និង គ.ជ.ប ត្រឹមត្រូវស្របតាមច្បាប់ហើយ ៧-ពុំមានទឡ្ហីករណ៍ដាក់បន្ទុកដែលអាចឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតសាជាថ្មី និង កែតម្រូវលទ្ធផលបោះឆ្នោតបានឡើយ ដូចមានចែងក្នុងមាត្រា ១១១ ថ្មី និង មាត្រា ១១២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ៨-លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ ធ្វើឡើងស្របតាមច្បាប់ និង ស្របតាមបទបញ្ជា និង នីតិវិធី។ ឯកឧត្តម **ឯម សូផាត** សំណូមពរសុំតម្កល់លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល

- យល់ឃើញថា សំណូមពររបស់ឯកឧត្តម **គួយ ប៊ុនរឿន** សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បង្កើតក្រុមបច្ចេកទេសស៊ើបអង្កេត និង វាយតម្លៃភាពមិនប្រក្រតី ដោយមានអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិមានជំនាញខាងកិច្ចការបោះឆ្នោត ព្រមទាំងមានតំណាងអង្គការសហប្រជាជាតិធ្វើជាអ្នកសង្កេតការណ៍ សំណើនេះមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពុំមានបទប្បញ្ញត្តិណាមួយអនុញ្ញាតឱ្យបង្កើតក្រុមបច្ចេកទេស ឬ គណៈកម្មការឯករាជ្យមានសមាសភាពដូចខាងលើធ្វើការស៊ើបអង្កេត វាយតម្លៃភាពមិនប្រក្រតីនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកម្ពុជាទេ
- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅក្នុង២៤មណ្ឌល ទូទាំងព្រះរាជាណាចក្រកម្ពុជា សរុបមាន ១៩,០០៩ ការិយាល័យ ការបោះឆ្នោត ពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា បានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៩,៦១ ភាគរយ

- យល់ឃើញថា លិខិតលេខ ៨៣០/១៣ គ.ជ.ប. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈ- កម្មាធិការជាតិរៀបចំការបោះឆ្នោតមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.** ទទួលពាក្យបណ្ដឹងរបស់ឯកឧត្ដម **គួយ ប៊ុនរឿន** តំណាងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្ដែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.** តម្កល់លិខិតលេខ ៨៣០/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.** សេចក្ដីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្ដទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣៨/០៤២/២០១៣

ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤១/០១៦/២០១៣ កបធ.ច

ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **សួន ចំរើន** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោក **សួន ចំរើន** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៅតាមនីតិវិធីច្បាប់
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៧៩/១៣ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **សួន ចំរើន** កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយឯកសារថតចម្លងទម្រង់ ១១០៤ ចំនួនពីររយសាមសិបបីសន្លឹក
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ
- បានឃើញសេចក្តីសម្រេចលេខ ២៩/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង
- បានឃើញលិខិតលេខ ០៤៤/២០១៣ កបធ.ច ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ៣រូប ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព" ក "នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩០១/១៣ គ.ជ.ប ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣



- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ របស់លោក **សួន ចំរើន** ប្រគល់សិទ្ធិជូនលោកមេធាវី **កែត ឃី** និង លោកមេធាវី **ជូង ជូងី** ដើម្បីការពារនូវសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិនៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៣៨/០៤២/២០១៣ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣
- បានឃើញពាក្យសុំតំណាងដោយអាណត្តិចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី** និងលិខិតតំណាងដោយអាណត្តិចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **ជូង ជូងី**
- បានឃើញសេចក្តីសម្រេចលេខ ០៥០/២០១៣ កបធ.ច ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **សួន ចំរើន** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៣ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោក **សួន ចំរើន** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ គឺប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ដើមបណ្តឹងបានរៀបរាប់ថា នៅមណ្ឌលខេត្តបាត់ដំបង មានភាពមិនប្រក្រតីធ្ងន់ធ្ងរក្នុងការបោះឆ្នោត និង ការរាប់សន្លឹកឆ្នោតកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ ដែលមន្ត្រីរៀបចំការបោះឆ្នោតបានរំលោភបំពានច្បាប់បោះឆ្នោត និង បទបញ្ជានីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តបាត់ដំបង ។ ភាពមិនប្រក្រតីធ្ងន់ធ្ងរនោះមានបីករណីគឺ ÷ ១-បញ្ជីបោះឆ្នោតមានភាពមិនប្រក្រតីដូចមានឯកសារថតចម្លងបញ្ជីឈ្មោះ និង

ស្នាមមេដៃប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយត្រូវគេបោះឆ្នោតជំនួសប្រមាណ ១.៧០០ នាក់ និង ឯកសារនៃបញ្ជីឈ្មោះស្ទួនរហូតដល់ ៣៥.០០០នាក់ ២-តួលេខតាមទម្រង់ ១១០៤ ខុសពីតួលេខបណ្ដោះអាសន្នដែលផ្សព្វផ្សាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ។ ក្នុងនោះដើមបណ្ដឹងស្នើឱ្យធ្វើការផ្ទៀងផ្ទាត់តាមទម្រង់ ១១០២ និង ១១០៨ ក្នុងកញ្ចប់ "ក"ចំនួន ១១៧ ការិយាល័យ ៣-ភាពមិនប្រក្រតីពេលរាប់សន្លឹកឆ្នោត តាមរបាយការណ៍របស់អ្នកសង្កេតការណ៍តំណាងគណបក្សសង្គ្រោះជាតិថា មានការរាប់ញាប់ពេក មានការប្រកែកគ្នាចំពោះសន្លឹកឆ្នោតមិនបានការ ។ រឿងនេះកើតមាននៅ ១១៦ ការិយាល័យ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោក **សួន ចំរើន** អមដោយលោកមេធាវី **កែត ឃី** និង លោកមេធាវី **ជួង ជូងី** តំណាងដោយអាណត្តិ បានរៀបរាប់ឡើងវិញនូវខ្លឹមសារដែលមានចែងក្នុងពាក្យបណ្ដឹងព្រមទាំងលើកអំពីអង្គច្បាប់ដើម្បីដាក់បន្ទុកលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អំពីការបើកកញ្ចប់សុវត្ថិភាព"ក" ចំនួន ០៨ ការិយាល័យ នៅក្រុងបាត់ដំបងដើម្បីផ្ទៀងផ្ទាត់ដើមបណ្ដឹងបានលើកឡើងថា មានចំនួនការិយាល័យតិចពេកមិនស្របតាមសំណូមពរ ។ លោក **សួន ចំរើន** បានឆ្លើយនឹងសំណួររបស់ក្រុមប្រឹក្សាជំនុំជម្រះថា ស្ថានភាពនៅខេត្តបាត់ដំបងក្នុងថ្ងៃបោះឆ្នោត មិនមានប្រធានសក្ដិ មិនមានអសន្តិសុខ មិនមានបះបោរទេ ប៉ុន្តែមានលក្ខណៈចោរលួចមាន់។ ជាចុងក្រោយតំណាងគណបក្សសង្គ្រោះជាតិសំណូមពរ ÷ ១-បដិសេធសេចក្ដីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចោលទាំងស្រុង ២-អនុញ្ញាតឱ្យ(គជប)ធ្វើការរាប់សន្លឹកឆ្នោតបានការ និងផ្ទៀងផ្ទាត់ឡើងវិញលើសន្លឹកឆ្នោតមិនបានការចំនួន ១១៦ ការិយាល័យក្នុងខេត្តបាត់ដំបង និង ផ្ទៀងផ្ទាត់តួលេខចំនួន ១១៧ ការិយាល័យ ៣-ចាត់ឱ្យមានការស៊ើបអង្កេតឡើងវិញ ថាតើកំហុសទាំងអស់ខាងលើនេះ មានការបង្គាប់បញ្ជាពីត្រឹមថ្នាក់ណា ? ត្រឹមថ្នាក់សមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ឬ ថ្នាក់សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬ ពីថ្នាក់សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះទៅ ៤-សុំឱ្យមានការផ្ដន្ទាទោសលើជនប្រព្រឹត្តល្មើសតាមមាត្រា ១២៥ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់នេះដោយក្ដីអនុគ្រោះ

- យល់ឃើញថា ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចំនួនពីរទំព័រ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈ បានបញ្ជាក់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការដោះស្រាយបណ្ដឹងលើលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត គឺអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ មាត្រា ១១៥ ថ្មី និងមាត្រា ១១៦ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំង

តំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ។ ចំពោះការតវ៉ាទាំងឡាយរបស់ដើមបណ្ដឹង គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតបានដោះស្រាយតាមដំណាក់កាលនីមួយៗ មានខ្លឹមសារដូចតទៅ ÷

១-បណ្ដឹងលើភាពមិនប្រក្រតីនៃបញ្ជីឈ្មោះបោះឆ្នោតបានផុតអាជ្ញាយុកាលតវ៉ាតាំងពីចុងឆ្នាំ២០១២ ម្ល៉េះ

២-តួលេខក្នុងទម្រង់ ១១០៤ ខុសពីតួលេខនៃលទ្ធផលបណ្ដោះអាសន្ន ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអញ្ជើញដើមបណ្ដឹង តំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍នានាចូលរួមត្រួតពិនិត្យលទ្ធផល ។ ក្នុងពេលត្រួតពិនិត្យ ដើមបណ្ដឹងយកទម្រង់ ១១០៩ ធ្វើដោយខ្លួនឯងមកផ្ទៀងផ្ទាត់ជាមួយទម្រង់ ១១០៩ និង ទម្រង់ ១១០២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្នុង ១០២ ឃុំ នៃខេត្តបាត់ដំបង មានតែ ៥៣ ឃុំប៉ុណ្ណោះ ដែលទិន្នន័យរបស់គណបក្សសង្គ្រោះជាតិ និង ទិន្នន័យរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានតួលេខខុសគ្នា ។ ការត្រួតពិនិត្យបង្ហាញថា តួលេខរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រឹមត្រូវ ឯតួលេខរបស់គណបក្សសង្គ្រោះជាតិមិនត្រឹមត្រូវទេ នេះមានន័យថា លទ្ធផលបណ្ដោះអាសន្ននៅខេត្តបាត់ដំបង មានភាពត្រឹមត្រូវទាំងអស់

៣-ភាពមិនប្រក្រតីនៅពេលរាប់សន្លឹកឆ្នោត ករណីនេះត្រូវបានបដិសេធចោលតាមស្មារតីនៃបញ្ញត្តិមាត្រា ១១៤ និង មាត្រា ១១៥ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ ព្រោះថាអ្នកប្ដឹងមិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយក៏មិនបានផ្ដល់សាក្សីព្រមទាំងឯកសារ ឬ ភស្តុតាងដូចមានចែងក្នុងមាត្រា ១១៤ ទេ ។ ម្យ៉ាងទៀតទម្រង់ ១១០២ (កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត) មិនបានបញ្ជាក់ពីភាពមិនប្រក្រតី ឬ ការតវ៉ាក្នុងពេលរាប់សន្លឹកឆ្នោតនោះទេ ហើយទម្រង់នេះក៏បានបិទផ្សាយជាសាធារណៈនៅគ្រប់ការិយាល័យរួចហើយ ។ សរុបសេចក្ដីមក បណ្ដឹងនេះត្រូវបានបដិសេធតាមមាត្រា ១១៥ ថ្មី ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចេញសេចក្ដីសម្រេចតាមការធ្វើសវនាការសង្ខេប ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយល់ព្រមធ្វើការត្រួតពិនិត្យដោះស្រាយជាសាធារណៈនូវចំណុចទី២ ជូនដើមបណ្ដឹង ស្របតាមមាត្រា ១១៦ ថ្មី ។ ឯកឧត្តម **មាន សាទិ** សំណូមពរឱ្យក្រុមប្រឹក្សា-ធម្មនុញ្ញមេត្តារក្សាសេចក្ដីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ

- យល់ឃើញថា ពេលបើកកញ្ចប់សុវត្ថិភាព"ក"ចំនួន ០៨ ការិយាល័យនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣ តាមសេចក្ដីសម្រេចលេខ ២៩/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានធ្វើនៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បង្ហាញឱ្យឃើញថា កញ្ចប់សុវត្ថិភាព"ក"បិទការសុវត្ថិភាពជិតតាមលក្ខណៈបច្ចេកទេសទាំងអស់ ហើយមានចុះហត្ថលេខាទទួលស្គាល់ពីតំណាងគណបក្សនយោបាយគ្រប់ការិយាល័យទាំង០៨

ហើយមានការិយាល័យចំនួន០២មានតំណាងអង្គការខុមហ្វ្រែលចុះហត្ថលេខាបន្ថែមពីលើតំណាងគណបក្សនយោបាយ ។ ឯសំឡេងគាំទ្រគណបក្សសង្គ្រោះជាតិ និង គណបក្សប្រជាជនកម្ពុជា គឺត្រឹមត្រូវ លើកលែងតែការិយាល័យលេខ ០២០៤ទេ ដែលគណបក្សសង្គ្រោះជាតិទទួលបានលើស ០១(មួយ)សំឡេង ពោលគឺលើក្រដាសកត់ត្រាសំឡេងឆ្នោតមានតែ ២៧៤ ប៉ុន្តែក្នុងទម្រង់ ១១០២ និង ទម្រង់ ១១០៨ សរសេរ ២៧៥ វិញ ។ ទម្រង់ ១១០២ ទាំង ០៨ ការិយាល័យត្រូវបានបិទលើក្តារខៀនផ្សាយដំណឹង ដើម្បីទុកជូនអ្នកចូលរួមអាចពិនិត្យផ្ទៀងផ្ទាត់មើលបាន ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តបាត់ដំបង

- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ នៅមណ្ឌលខេត្តបាត់ដំបងសរុបមាន ១.៤០១ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និង ពុំមានការបះបោរទេ ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរីដែលមានអត្រា ៦០,៣៦ ភាគរយ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **សួន ចំរើន** ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០២០/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជំនុំជម្រះជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៤០/០៤៤/២០១៣

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤២/០១៧/២០១៣ កបធ.ច

ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់លោកជំទាវ **កែ សុវណ្ណរតនី** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោកជំទាវ **កែ សុវណ្ណរតនី** ជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ មណ្ឌលខេត្តសៀមរាប
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩៧៤/១៣ គ.ជ.ប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣
- បានឃើញភស្តុតាងរបស់ដើមបណ្តឹង រួមមាន : បញ្ជីបោះឆ្នោតឆ្នាំ២០១២ ឯកសារទម្រង់ ១១០៤ រូបថត និង វីស៊ីឌី
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោកជំទាវ **កែ សុវណ្ណរតនី** កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយបញ្ជីបោះឆ្នោតឆ្នាំ២០១២ ចំនួន ០២ ឃុំ មាន ២៤៣ សន្លឹក ទម្រង់ ១១០៤ ចំនួន ១១ ការិយាល័យ ទម្រង់ ១១០៤ ចំនួន ៣២ ការិយាល័យ រូបថតចំនួន ៤៣ សន្លឹក និង វីស៊ីឌី មួយ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៣ ចំនួន ០៤ ទំព័រ
- បានឃើញសេចក្តីសម្រេចលេខ ៣០/២០១៣ កបធ.សសរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប
- បានឃើញលិខិតលេខ ០៤៥/២០១៣ កបធ.ច ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព " ក "

ចំនួន ១២ ការិយាល័យ មណ្ឌលខេត្តសៀមរាបប្រព្រឹត្តទៅនៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញកំណត់ហេតុស្ដីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តសៀមរាប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៩០៦/១៣ គ.ជ.ប ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣
- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិរបស់លោកជំទាវ **កែ សុវណ្ណរតន៍** ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៣ ប្រគល់សិទ្ធិជូនលោកមេធាវី **ជួង ជូងី** និងលោកមេធាវី **កែត ឃី** ដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ ចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៤០/០៤៤/២០១៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **ជួង ជូងី** និងពាក្យសុំតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី**
- បានឃើញសេចក្ដីសម្រេចលេខ ៥២/២០១៣ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្ដាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្ដឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់លោកជំទាវ **កែ សុវណ្ណរតន៍** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញបានទទួលនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៨ និង ២០ នាទី គឺស្ថិតក្នុងអាជ្ញា-យុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលសម្រង់សេចក្ដីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អនុលោមតាមមាត្រា ១១៥ថ្មី មាត្រា ១១៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្ដឹងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** មកពិនិត្យបាន

- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ គឺប្តឹងតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ គ.ជ.ប ។ ដើមបណ្តឹងបានរៀបរាប់ថា នៅមណ្ឌលខេត្តសៀមរាបមានភាពមិនប្រក្រតីធ្ងន់ធ្ងរក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដែលមន្ត្រីបោះឆ្នោតបានបំពានច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ព្រមទាំងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ដែលជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តសៀមរាប ។ ភាពមិនប្រក្រតីធ្ងន់ធ្ងរទាំងនេះហើយដែលដើមបណ្តឹងទាមទារមកក្រុមប្រឹក្សាធម្មនុញ្ញនូវ ៣ ចំណុច ដូចតទៅ ៖ ១-ឱ្យ គ.ជ.ប រៀបចំការបោះឆ្នោតសាជាថ្មី ចំនួន ១៦ ការិយាល័យ នៃស្រុកស្វាយលើ និងស្រុកវ៉ារិន គឺការិយាល័យលេខ ១១៣៦ ១១៥៣ ១០៩៩ ០៦៩៧ ០៦៩៥ ០៨៦៤ ១១៣៧ ១១៣៨ ១១១៦ ១០៥៧ ១១១៥ ១១៤០ ១១៤៣ ១១៧៣ ១១៤២ និង ១១៧២ ព្រោះការិយាល័យទាំង ១៦ នេះ មានការកៀងគរទាហានដែលគ្មានទីលំនៅក្នុងឃុំ ដោយមានការដឹកទាហានតាមរថយន្តយោធាមកបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ។ ទង្វើបែបនេះបានបំពានលើបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ត្រង់ចំណុច ៧.៤.១ ចំណុច ៧.៤.៣ និងបំពានលើមាត្រា ៥៤ ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២-ឱ្យ គ.ជ.ប ពិនិត្យផ្ទៀងផ្ទាត់ រាប់សន្លឹកឆ្នោត និងផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ ចំនួន ២០០ ការិយាល័យ ក្នុងមណ្ឌលខេត្តសៀមរាប តែនៅពេលចូលមកបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ លោកជំទាវយល់ព្រមបន្ថយមកត្រឹមតែ ៣២ ការិយាល័យវិញ ៣-ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" ដកយកទម្រង់ ១១០២ និង ១១០៨ មកផ្ទៀងផ្ទាត់លទ្ធផលជាមួយទម្រង់ ១១០៤ ចំនួន ៧៥ ការិយាល័យ ។ នៅពេលចូលមកបំភ្លឺនៅចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដើមបណ្តឹងបានយល់ព្រមបន្ថយមកត្រឹមតែ ១១ ការិយាល័យវិញ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកជំទាវ **កែ សុវណ្ណរតន៍** អមដោយលោកមេធាវី **កែត ឃី** និងលោកមេធាវី **ជួង ជូងី** តំណាងដោយអាណត្តិបានរៀបរាប់ឡើងវិញនូវខ្លឹមសារដែលមានចែងក្នុងពាក្យបណ្តឹង ព្រមទាំងលើកអំពីអង្គហេតុ និងអង្គច្បាប់ ដើម្បីដាក់បន្ទុកលើគណៈកម្មាធិការ

ជាតិរៀបចំការបោះឆ្នោត។ អំពីការបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១២ ការិយាល័យ នៅមណ្ឌលខេត្តសៀមរាប ដើម្បីផ្ទៀងផ្ទាត់ ដើមបណ្តឹងបានលើកឡើងថា មានចំនួនការិយាល័យតិចពេក មិនស្របតាមទិសដៅ និងសំណូមពរ។ ដើមបណ្តឹងបានលើកអំពីការប្រព្រឹត្តល្មើសច្បាប់ និងបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ អំពីករណីយករថយន្តយោធាដឹកទាហានឈរជើងនៅសមរភូមិមុខ តាមខ្សែក្រវ៉ាត់ព្រំដែនទៅបោះឆ្នោតនៅ ១៦ ការិយាល័យ នៃស្រុកស្វាយលើ និងស្រុកវ៉ារិន។ ជាចុងក្រោយ តំណាងគណបក្សសង្គ្រោះជាតិសំណូមពរ៖ ១-បដិសេធសេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចោលទាំងស្រុង ២-អនុញ្ញាតឱ្យ គ.ជ.ប ធ្វើការរាប់សន្លឹកឆ្នោតបានការ និងផ្ទៀងផ្ទាត់ឡើងវិញលើសន្លឹកឆ្នោតមិនបានការចំនួន ២០០ ការិយាល័យ ក្នុងខេត្តសៀមរាប និងផ្ទៀងផ្ទាត់ទម្រង់ ១១០២ ១១០៨ និង ១១០៤ ចំនួន ៧៥ ការិយាល័យ ៣-អនុញ្ញាតឱ្យ គ.ជ.ប បោះឆ្នោតឡើងវិញចំនួន ១៦ ការិយាល័យ នៅស្រុកស្វាយលើ និងស្រុកវ៉ារិន ៤-ចាត់ឱ្យមានការស៊ើបអង្កេតឡើងវិញ ថាតើកំហុសទាំងអស់ខាងលើនេះ មានការបង្គាប់បញ្ជាពីត្រឹមថ្នាក់ណា? ត្រឹមថ្នាក់សមាជិកគណៈកម្មការការិយា-ល័យបោះឆ្នោត ឬថ្នាក់សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោត ឬពីថ្នាក់សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះទៅ ៥-សុំឱ្យមានការផ្តន្ទាទោសលើជនប្រព្រឹត្តល្មើស តាមមាត្រា ១២៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

- យល់ឃើញថា ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី៣ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចំនួន ០៨ ទំព័រ ក៏ដូចជានៅពេលសវនាការជាសាធារណៈ បានបញ្ជាក់ថា គ.ជ.ប ក្នុងការដោះស្រាយបណ្តឹងលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គឺអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ មាត្រា ១១៥ ថ្មី និងមាត្រា ១១៦ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ។ ចំពោះការតវ៉ាទាំងឡាយរបស់ដើមបណ្តឹង គ.ជ.ប បានដោះស្រាយតាមដំណាក់កាលនីមួយៗ ដែលមានខ្លឹមសារដូចតទៅ ៖ ១-ពាក្យបណ្តឹង និងចម្លើយអះអាងរបស់លោកជំទាវ **កែ សុវណ្ណរតនី** មិនបានបញ្ជាក់អំពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត តាមមាត្រា ១១៤

នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះឡើយ ២-ជាក់ស្តែងនៅខេត្តសៀមរាបទាំងមូល ដែលមានការិយាល័យបោះឆ្នោតសរុប ១.១៨១ ការិយាល័យ ក្នុងឃុំ សង្កាត់ចំនួន ១០០ នៅដំណាក់កាលមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ដែលដាក់នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មានបណ្តឹងតែ ១៦ បណ្តឹង ក្នុងនោះមានបណ្តឹងសុំឱ្យផ្តន្ទាទោសមន្ត្រីបោះឆ្នោតចំនួន ៦ សុំឱ្យផ្តន្ទាទោសជនមិនមែនជាមន្ត្រីបោះឆ្នោតចំនួន ៧ និងប្តឹងពីភាពមិនប្រក្រតីចំនួន ៣ ។ បណ្តឹងដែលត្រូវបានប្តឹងបន្តមកគណៈកម្មការរៀបចំការបោះឆ្នោតខេត្តសៀមរាប ចំនួន ១០ បណ្តឹង និងបន្តប្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានតែ ៦ បណ្តឹងតែប៉ុណ្ណោះ ៣-ក្នុងការទទួល និង ដោះស្រាយបណ្តឹងទាក់ទងថ្ងៃស និងថ្ងៃបោះឆ្នោត និងក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោត ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តទាំង ២៤ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុវត្តតួនាទី និងសិទ្ធិអំណាចរបស់ខ្លួនស្របតាម ច.ប.ត.រ ចាប់ពីមាត្រា ១០៩ ថ្មី មាត្រា ១១០ មាត្រា ១១១ ថ្មី មាត្រា ១១២ ថ្មី និងមាត្រា ១១៣ និងស្របតាម ប.ន.ត.រ នៅមុនពេលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។ ជាក់ស្តែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ គឃ/សប គធ/ខប និង គ.ជ.ប បានអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមលំដាប់ថ្នាក់ ដោយមានការអញ្ជើញចូលរួមពីតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ៤-លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១២ ការិយាល័យ នៃខេត្តសៀមរាប ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងទម្រង់ ១១០២ ១១០៨ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ដែលបានធ្វើនៅ គ.ជ.ប តាមសេចក្តីសម្រេចលេខ ៣០/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានក្នុងកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប។ ក្នុងនោះទោះបីជាមានកញ្ចប់សុវត្ថិភាព "ក" មួយចំនួនមិនបានបិទការសុវត្ថិភាព ដែលជាការធ្វេសប្រហែសក្នុងការវេចខ្ចប់ ប៉ុន្តែជារួមសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗ ទទួលបានមានភាពត្រឹមត្រូវទាំងស្រុង ៥-សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

នីតិកាលទី៥ ឆ្នាំ២០១៣ ហើយ។ ឆ្លើយនឹងសំណួររបស់ក្រុមប្រឹក្សាជម្រះ ឯកឧត្តម **ឯម សូជាត** បានបញ្ជាក់ថា ភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំដល់ការបោះឆ្នោតសាឡើងវិញ គឺករណីប្រធានសន្តិអសន្តិសុខ មិនអាចបើកការិយាល័យបោះឆ្នោតបាន ឬបើកការិយាល័យបានតែបន្តិច រួចបិទទៅវិញ ក្រោយពីមានការសម្រេចពី គ.ជ.ប ។ ចំពោះករណីរថយន្តយោធាដឹកទាហានពីខ្សែក្រវ៉ាត់ព្រំដែនសមរភូមិមុខមកបោះឆ្នោត តំណាង គ.ជ.ប បំភ្លឺថា នេះជាករណីពិសេសសម្រាប់តែតំបន់នោះ ហើយបានធ្វើតាំងពីការបោះឆ្នោតឆ្នាំ២០០៨ និងឆ្នាំ២០១២ មក ពីព្រោះអ្នកទាំងនោះមានបន្ទាយបោះទីតាំងនៅតំបន់នោះជាយូរយាមកហើយ។ ការសម្រេចចំពោះករណីពិសេសនេះ ជាឆន្ទានុសិទ្ធិរបស់ គ.ជ.ប ដែលច្បាប់ផ្តល់សិទ្ធិពេញលេញឱ្យ គ.ជ.ប អនុវត្តសមត្ថកិច្ច។ ឯកឧត្តម **ឯម សូជាត** សំណូមពរសុំតម្កល់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល

- យល់ឃើញថា ការដឹកជញ្ជូនកងទ័ពតាមរថយន្តរបស់អង្គភាពយោធាទៅបោះឆ្នោត ពិតជាបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និងចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ដែលប្រកាសឱ្យប្រើដោយសេចក្តីប្រកាសលេខ ០៦៨/១៣ គ.ជ.ប ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ រីឯការបោះឆ្នោតនៅ ១៦ ការិយាល័យក្នុងស្រុកស្វាយលើ និងស្រុកវ៉ារិន ពុំមានបាតុភូតដែលនាំឱ្យប៉ះពាល់ដល់ភាពសម្ងាត់និងភាពសេរីនៃការបោះឆ្នោតទេ
- យល់ឃើញថា តាមការចុះបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១២ ការិយាល័យនៅគណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោត ឃើញថាមានកញ្ចប់សុវត្ថិភាព "ក" ចំនួន ០៦ ការិយាល័យមិនមានបិទការសុវត្ថិភាព និង ០១ ការិយាល័យមានបិទការសុវត្ថិភាព តែរបែក និងមិនបានចាក់សោឃ្លុំកញ្ចប់ "ខ" ចំនួន ០២ ការិយាល័យ មិនបានសរសេរលេខកូដការិយាល័យលើកញ្ចប់ "ក" ខ្លះ និងលើក្រដាសធំកត់ត្រាសំឡេងឆ្នោតខ្លះ។ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងកញ្ចប់សុវត្ថិភាព "ក" ទាំង ១២ ការិយាល័យ នៅក្រុងសៀមរាប និងនៅស្រុកពួក ឃើញថា សំឡេងឆ្នោតរបស់គណបក្សសង្គ្រោះជាតិ និងសំឡេងឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា ក្នុងទម្រង់ ១១០២ ទម្រង់ ១១០៨ និង ក្រដាសធំកត់ត្រាសំឡេងឆ្នោត មិនមានការប្រែប្រួលទេ លើកលែងតែ ២ ការិយាល័យ គឺការិយាល័យលេខ ០៦៧៣ (ឃុំល្វា) សំឡេងឆ្នោតរបស់គនបក្សប្រជាជនកម្ពុជាក្នុងទម្រង់ ១១០២ និង ទម្រង់ ១១០៨ និង ទម្រង់ ១១០៤ មានតួលេខខុសគ្នា ពោលគឺក្នុងទម្រង់ ១១០៨ និង ១១០៤ មានចំនួន ២៩៧ សំឡេង

ឯក្នុងទម្រង់ ១១០២ មានតែ ២៧២ សំឡេង (លំអៀង ២៥ សំឡេង) និង ការិយាល័យលេខ ០៤៤២ ក្នុងទម្រង់ ១១០២ និង ទម្រង់ ១១០៨ សន្លឹកឆ្នោតក្នុងហិបមានចំនួន ៣៥៣ សន្លឹក ដែលតួលេខនេះខុសគ្នានឹងទម្រង់ ១១០៤ របស់គណបក្សសង្គ្រោះជាតិ មាន ៣៥៩ សន្លឹក (លំអៀង ០៦ សំឡេង)។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ការភាន់ច្រឡំក្នុងការសរសេរតួលេខនេះ មិនមែនជាភាពមិនប្រក្រតីធ្ងន់ធ្ងរធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនោះទេ។ ការមិនបកប្លាស្ទិកថ្លាចេញ ធ្វើឱ្យកញ្ចប់សុវត្ថិភាព "ក" ចំហរ និងការរហែកកញ្ចប់សុវត្ថិភាព "ក" ជាកំហុសរបស់មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំង ៧ ការិយាល័យ។ មន្ត្រីដែលធ្វើការងារនោះផ្ទាល់នៅការិយាល័យទាំង ៧ ការិយាល័យនេះ ត្រូវទទួលទណ្ឌកម្មតាមច្បាប់កំណត់។ ដោយឡែកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាអាណាព្យាបាលពីលើ ក៏ត្រូវទទួលខុសត្រូវខាងសីលធម៌អំពីការងារគ្រប់គ្រងរបស់ខ្លួន

- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅមណ្ឌលខេត្តសៀមរាប សរុប ១.១៨១ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានសក្តិ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋក្នុងមណ្ឌលបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៨,៦៦ ភាគរយ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ លើកលែងតែការសម្រេចមិនទទួលបណ្តឹងតវ៉ានឹងការដឹកជញ្ជូនកងទ័ពតាមរថយន្តយោធាទៅបោះឆ្នោតដែលបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និងចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.** ទទួលពាក្យបណ្តឹងរបស់លោកជំទាវ **កែ សុវណ្ណរតន៍** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.** តម្កល់សេចក្តីសម្រេចលេខ ០២២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ លើកលែងតែការសម្រេចមិនទទួល

បណ្តឹងតវ៉ានឹងការដឹកជញ្ជូនកងទ័ពតាមរថយន្តយោធាទៅបោះឆ្នោតដែលបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និងចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ។

**មាត្រា ៣.** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះការបំពានលើប្រការ ៧.៤ ចំណុច ៧.៤.១ និង ចំណុច ៧.៤.៣ នៃបទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ។

**មាត្រា ៤.** ប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាត់វិធានការដាក់ទណ្ឌកម្មលើមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៧ ការិយាល័យ នៅឃុំរើល សង្កាត់ក្របីរៀល សង្កាត់ស្វាយដង្គំ និង សង្កាត់ស្លក្រាម ដែលបានប្រព្រឹត្តខុស។

**មាត្រា ៥.** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៣៩/០៤៣/២០១៣

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

**សេចក្ដីសម្រេច**

លេខ : ១៤៣/០១៨/២០១៣ កបធ.ច

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្ដីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្ដឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** តំណាងគណបក្សសង្គ្រោះជាតិ ប្ដឹងសុំតវ៉ានឹងសម្រេចសេចក្ដីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ពាក្យសុំកែតម្រូវពាក្យបណ្ដឹងរបស់ឯកឧត្តម **អេង ឆៃអ៊ាង** ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ស្នើសុំកែតម្រូវលើពាក្យបណ្ដឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនឯកឧត្តម **អេង ឆៃអ៊ាង** ជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្ដឹងតវ៉ាទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ មណ្ឌលខេត្តកណ្ដាល
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៨៨/១៣ គ.ជ.ប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **អេង ឆៃអ៊ាង** កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៣ អមដោយសារណាការពារ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ
- បានឃើញសេចក្ដីសម្រេចលេខ ៣១/២០១៣ កបធ.សសរ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្ដីពីការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព" ក" មួយចំនួននៅមណ្ឌលខេត្តកណ្ដាល នៅក្រុងតាខ្មៅ សង្កាត់តាខ្មៅ
- បានឃើញលិខិតលេខ ០៤៨/២០១៣ កបធ.ច ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ៣រូបដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព " ក " នៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តកណ្ដាល ដើម្បីផ្ទៀងផ្ទាត់សន្លឹកឆ្នោត ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ៩០៧/១៣ គ.ជ.ប ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣
- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** ប្រគល់សិទ្ធិជូនលោកមេធាវី **ជួង ជូងី** ដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍

ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៣៩/០៤៣/២០១៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** ប្រគល់សិទ្ធិជូនលោកមេធាវី **កែត ឃី** ដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២៣៩/០៤៣/២០១៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣
- បានឃើញលិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **ជួង ជូងី** និងពាក្យសុំតំណាងដោយអាណត្តិចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី**
- បានឃើញសេចក្តីសម្រេចលេខ ០៥៤/២០១៣ កបធ.ច ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **អេង ឆៃអ៊ាង** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៩ ខែសីហាឆ្នាំ២០១៣ វេលាម៉ោង១៣ និង ៥០ នាទី គឺស្ថិតក្នុងអាជ្ញាយុកាល ៧២ ម៉ោង បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ អនុលោមតាមមាត្រា ១១៥ថ្មី និងមាត្រា១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងចំណុចទី២នៃមាត្រា២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃបណ្តឹងរបស់ឯកឧត្តម **អេង ឆៃអ៊ាង** ប្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជាការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ គឺប្តឹងសុំតវ៉ានឹងសម្រង់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ឯកឧត្តម **អេង ឆៃអ៊ាង** បានរៀបរាប់ថា នៅមណ្ឌលបោះឆ្នោតខេត្តកណ្តាល មានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលមន្ត្រីរៀបចំការបោះឆ្នោតបានរំលោភបំពានច្បាប់បោះឆ្នោត និង បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិដែលត្រូវទទួលបានក្នុងមណ្ឌលខេត្តកណ្តាល ។ ភាពមិនប្រក្រតីធ្ងន់ធ្ងរនោះមានបីករណី ÷ **១**-នៅថ្ងៃបោះ

ឆ្នោត ទី២៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោងប្រមាណ ៩ ព្រឹក ការិយាល័យលេខ ១២០៤ ឃុំស្អាងភ្នំ ត្រូវបានបិទរហូត ដោយសារការកើតមានអសន្តិសុខ ហើយការបោះឆ្នោតទើបតែបោះឆ្នោតបាន ប្រមាណ ៨០ នាក់ នៅសល់ប្រមាណជិត ២០០នាក់ទៀត មិនបានបោះឆ្នោត ។ ម៉្យាងទៀត ហិប ឆ្នោតនៅការិយាល័យលេខ ១២០៤ នេះ ត្រូវបានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល បើកហិបរាប់សន្លឹកឆ្នោតជាឯកតោភាគី ដោយមិនបានអញ្ជើញតំណាងគណបក្ស អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ មកចូលរួមពិនិត្យនោះឡើយ ។ **២**-ឯកឧត្តមបានដាក់ពាក្យបណ្តឹងនៅគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ទាមទារសុំឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្ទៀងផ្ទាត់ទម្រង់ ១១០២ និង១១០៨ ដែលស្ថិតនៅក្នុងកញ្ចប់សុវត្ថិភាព "ក" ចំនួន ១៩៩ ការិយាល័យ ។ បន្ទាប់ពីបានផ្ទៀងផ្ទាត់ ជាបន្តបន្ទាប់តាមឃុំ សង្កាត់ បានចំនួន ១៩១ ការិយាល័យ លុះនៅសល់តែសង្កាត់តាខ្មៅ មាន ០៨ ការិយាល័យ បែរជាគ្មានទម្រង់ ១១០៨ មកពិនិត្យផ្ទៀងផ្ទាត់ ។ **៣**- ឯកឧត្តម សុំបើកកញ្ចប់សុវត្ថិភាព" ក " ដើម្បីយកសន្លឹកឆ្នោតមិនបានការទាំង ៧២ ការិយាល័យមកពិនិត្យផ្ទៀងផ្ទាត់ ដោយហេតុថា តំណាងគណបក្សសង្គ្រោះជាតិនៅមូលដ្ឋានបានផ្តល់ព័ត៌មានថា មន្ត្រីរាប់សន្លឹកឆ្នោតនៅការិយាល័យ រាប់សន្លឹកឆ្នោតទាំងនោះ រាប់លឿនពេក និង មានការបន្លំសន្លឹកឆ្នោតបានការ នាំឱ្យសន្លឹកឆ្នោតបានការ របស់គណបក្សសង្គ្រោះជាតិ ត្រូវបានគេដាក់ចូលទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ។ ដើមបណ្តឹង ឆ្លើយនឹងសំណួររបស់ក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញថា នៅក្នុងថ្ងៃបោះឆ្នោតទី២៨ ខែកក្កដា ឆ្នាំ២០១៣ ពុំឃើញមានការបាញ់គ្នាទេ ប៉ុន្តែឯកឧត្តមបានដឹងថា មានការចាប់មនុស្សនៅឃុំស្អាងភ្នំ ចំនួន ០១នាក់ ហើយនៅឃុំសារិកាកែវចំនួន ០២ នាក់ ប៉ុន្តែនៅវេលាល្ងាចត្រូវបានដោះលែងវិញ ។ នៅក្នុងពេលបោះឆ្នោត ការបោះឆ្នោតបានប្រព្រឹត្តទៅដោយសម្ងាត់ ។ ដើមបណ្តឹងបានសំណូមពរសុំឱ្យ ក្រុមប្រឹក្សាធម្មនុញ្ញបដិសេធសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយសុំទាមទារឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ចេញសេចក្តីសម្រេច ÷ **១**-បង្គាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀបចំការបោះឆ្នោត សាជាថ្មីនៅការិយាល័យលេខ ១២០៤ ឃុំស្អាងភ្នំ ស្របតាមមាត្រា ១១៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ **២**- បង្គាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិ- ភាព " ក " ដើម្បីយកទម្រង់ ១១០២ និង ១១០៨ ធ្វើការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលបោះឆ្នោត ចំនួន ០៨ ការិយាល័យ នៅសង្កាត់តាខ្មៅ គឺការិយាល័យលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២ ដែលបាត់ទម្រង់ ១១០៨ ហើយត្រូវផ្តល់សុពលភាព លើលទ្ធផលបោះឆ្នោតតាមការិយាល័យនីមួយៗ បើរកឃើញមានការប្រែប្រួល **៣**-បង្គាប់ឱ្យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បើកកញ្ចប់សុវត្ថិភាព" ក " ដើម្បីយកសន្លឹកឆ្នោតមិនបានការ ទាំង ៧២ ការិយាល័យមកពិនិត្យផ្ទៀងផ្ទាត់ និង ផ្តល់សុពលភាពលើសន្លឹកឆ្នោតមិនបានការឡើងវិញ

- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ ឯកឧត្តម **អេង ឆៃអ៊ាង** អមដោយលោកមេធាវី **កែត ឃី** តំណាងដោយអាណត្តិ បានអរគុណដល់ក្រុមប្រឹក្សាធម្មនុញ្ញដែលបានបើកសវនាការជាសាធារណៈ និងបានរៀបរាប់ឡើងវិញនូវខ្លឹមសារដែលមានចែងនៅក្នុងពាក្យបណ្តឹង និងខ្លឹមសារដែលឯកឧត្តមបានឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ ហើយលើកពីអង្គហេតុ និង អង្គច្បាប់ដើម្បីដាក់បន្ទុកលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ជាចុងក្រោយដើមបណ្តឹងបានសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាផ្តល់យុត្តិធម៌ដល់គណបក្សសង្គ្រោះជាតិ ។ ឯកឧត្តម **អេង ឆៃអ៊ាង**បាននិយាយបន្ថែមថា សវនាការបីលើកកន្លងមកនៅក្រុមប្រឹក្សាធម្មនុញ្ញធ្វើគ្រាន់តែល្អមើល ។ សវនាការលើកនេះ គាត់និយាយថា គាត់ស្ទើរតែដឹងលទ្ធផលជាមុន ។ ឯកឧត្តម **អេង ឆៃអ៊ាង** បានសុំអត់ទោសចំពោះក្រុមប្រឹក្សាជំនុំជម្រះថា មិនអាចនៅបន្តដល់ចុងបញ្ចប់នៃសវនាការបានទេ ។ ដើមបណ្តឹង និង លោកមេធាវី **កែត ឃី** តំណាងដោយអាណត្តិ បានបោះបង់ការចូលរួមក្នុងសវនាការជាសាធារណៈវេលាម៉ោង ០៨ និង៤០នាទី
- យល់ឃើញថា ឯកឧត្តម **មាន សាទិ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី១នៃក្រុមប្រឹក្សាធម្មនុញ្ញ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ អមដោយសារណាការពារចំនួនបីទំព័រ ក៏ដូចជានៅពេលសវនាការជំនុំជម្រះជាសាធារណៈបានបញ្ជាក់ថា ៖ ១-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចមិនធ្វើការបោះឆ្នោតសាជាថ្មី នៅការិយាល័យលេខ ១២០៤ ឃុំស្វាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ដោយសំអាងថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនបានបិទការិយាល័យបោះឆ្នោតនេះទេ តែការិយាល័យបោះឆ្នោតនេះ ត្រូវបានរាំងរំខានដោយជនមួយក្រុមនិងសកម្មជនរបស់គណបក្សសង្គ្រោះជាតិ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនព្រមបិទការិយាល័យនេះ ពីព្រោះការិយាល័យនេះ មានចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីតែ ២៥៨ នាក់ ហើយពលរដ្ឋបានបោះរួច ចំនួន ៨៨ នាក់ ។ ម្យ៉ាងវិញទៀត ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺខេត្តជាមណ្ឌលបោះឆ្នោត មិនមែនការិយាល័យទេ ហើយខេត្តកណ្តាលនេះមានប្រជាពលរដ្ឋទៅបោះឆ្នោតបានចំនួនរហូតដល់៧៧,៨៣ភាគរយ គឺច្រើនជាងរាជធានី និងខេត្តដទៃទៀតទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែខេត្តតាកែវបាន ៧៨,៤១ ភាគរយ និង ខេត្តកែបបាន ៧៧,៨៨ភាគរយ ។ បើគិតភាគរយចំនួនអ្នកបានបោះឆ្នោតនៅឃុំស្វាងភ្នំ គឺបានរហូតដល់៧៨,៣១ ភាគរយ ។ ចំពោះការបើកហិបឆ្នោត ដើម្បីរាប់សន្លឹកឆ្នោតគឺ ធ្វើឡើងនៅទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល តាមការអនុញ្ញាតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងដោយមានការចូលរួមពីតំណាងគណបក្សប្រជាជនកម្ពុជា អ្នកសង្កេតការណ៍មកពីអង្គការខុមហ្វ្រែល អង្គការសហគមន៍គ្រួសារអភិវឌ្ឍន៍កសិកម្ម លើកលែងតែតំណាងគណបក្សសង្គ្រោះជាតិដែលមិនព្រមចូលរួម តាមការអញ្ជើញ **២**-ចំពោះការប្តឹងតវ៉ាសុំផ្ទៀងផ្ទាត់ទម្រង់ ១១០២ និង ១១០៨ ចំនួន ១៩៩ ការិយាល័យ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រេចយល់ព្រមផ្ទៀងផ្ទាត់ទម្រង់ ១១០២

និង ១១០៨ ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានទម្រង់ ១១០២ និង ១១០៨ ដែលប្រមូលបានពីតាមខេត្ត ហើយទម្រង់នេះ និងទម្រង់ ១១០២ និង ១១០៨ នៅខាងក្នុងកញ្ចប់សុវត្ថិភាព "ក" មានតួលេខទិន្នន័យដូចគ្នា ហើយសុទ្ធតែមានចុះហត្ថលេខារបស់តំណាងគណបក្សនយោបាយផងដែរ ។ ចំពោះការិយាល័យចំនួន ០៨ នៅក្នុងសង្កាត់តាខ្មៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្មានទម្រង់ ១១០៨ ដោយសារគណៈកម្មការរៀបចំការបោះឆ្នោតសង្កាត់តាខ្មៅ បានធ្វើឱ្យបាត់ ប៉ុន្តែ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយកទម្រង់ ១១០៩ ជំនួសវិញ ដោយសារទម្រង់នេះ បានស្រង់ទិន្នន័យចេញពីទម្រង់ ១១០២ និងទម្រង់ ១១០៨។ ការត្រួតពិនិត្យបង្ហាញថា លទ្ធផលត្រឹមត្រូវដដែល **៣-** ចំពោះករណីសុំរាប់សន្លឹកឆ្នោតមិនបានការក្នុង៧២ការិយាល័យ ឯកឧត្តម **អេង ឆៃអ៊ាង** ពុំបានផ្តល់ភស្តុតាងច្បាស់លាស់ ដូចមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺអ្នកប្តឹងត្រូវផ្តល់ឯកសារ ភស្តុតាង និង សាក្សី បញ្ជាក់ថា គណៈកម្មការរាប់សន្លឹកឆ្នោតបានប្រព្រឹត្តខុសទៅនឹងបទបញ្ជា និងនីតិវិធីនៃការរាប់សន្លឹកឆ្នោត ។ ម្យ៉ាងវិញទៀតទម្រង់ ១១០២ មិនបានបញ្ជាក់ពីភាពមិនប្រក្រតី ឬមានការតវ៉ាក្នុងពេលរាប់សន្លឹកឆ្នោតនោះទេ ហើយទម្រង់នេះ ក៏បានបិទផ្សាយជាសាធារណៈនៅគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតរួចហើយ ។ ប៉ុន្តែនៅពេលនេះដើមបណ្តឹងគ្រាន់តែបង្ហាញអំពីការគិតរបស់ខ្លួន តាមតួលេខក្នុងទម្រង់ ១១០៤ ដែលគាត់មានតែប៉ុណ្ណោះ ។ សរុបសេចក្តីមក បណ្តឹងនេះ ត្រូវបានបដិសេធតាមមាត្រា ១១៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ប៉ុន្តែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញសេចក្តីសម្រេចតាមការធ្វើសវនាការសង្ខេប ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយល់ព្រមធ្វើការត្រួតពិនិត្យដោះស្រាយជាសាធារណៈនូវចំណុចទី២ ជូនដើមបណ្តឹង ស្របតាមមាត្រា ១១៦ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់នេះ ។ ជាចុងក្រោយ ឯកឧត្តម **មាន សាទិ** សំណូមពរសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញមេត្តារក្សាសេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ

- យល់ឃើញថា ពេលបើកកញ្ចប់សុវត្ថិភាព"ក" ចំនួន ០៨ ការិយាល័យនៅសង្កាត់តាខ្មៅ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមសេចក្តីសម្រេចលេខ ៣១/២០១៣ កបធ.ច ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ បានបង្ហាញឱ្យឃើញថា កញ្ចប់"ឃ"ទាំងពីរមិនមានសោឃ្លុំ កញ្ចប់ " គ " ទាំងប្រាំមួយមានសោឃ្លុំ កញ្ចប់សុវត្ថិភាព "ក" ទាំងប្រាំបីការិយាល័យមានបិទភ្ជិតដោយការសុវត្ថិភាពត្រូវតាមលក្ខណៈបច្ចេកទេស ។ ចំពោះតួលេខលទ្ធផលនៃសំឡេងឆ្នោតដែលគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ក៏ដូចជាគណបក្សនយោបាយនានាទទួលបានមានទិន្នន័យដូចគ្នា រវាងទម្រង់ ១១០២ ប្រៀបនឹងទម្រង់១១០៨ ជាមួយនឹងផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោត ។ ជាសំខាន់ គឺតួលេខលទ្ធផលទាំងអស់នៅ

ដដែល ពុំមានប្រែប្រួលអ្វីឡើយ ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួន នៅមណ្ឌលខេត្តកណ្តាល

- យល់ឃើញថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកណ្តាលសរុបមានចំនួន ១.៤៤០ ការិយាល័យ ការបោះឆ្នោតពុំមានជួបករណីប្រធានស័ក្តិ ពុំមានករណីអសន្តិសុខ និងពុំមានអំពើហិង្សាទេ ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៧៧,៨៣ ភាគរយ
- យល់ឃើញថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

## តំបាំងមុខដើមបណ្តឹង ចំពោះមុខតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **អេង ឆៃអ៊ាង** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០២១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ឯក សំអុល**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៤២/០៤៦/២០១៣

ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤៤/០១៩/២០១៣ កបធ.ច

ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ៥០៧ រ.ស ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី១ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ ដោយឥតកែប្រែនិងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៨ ព្រឹក ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង ការអនុម័តច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ១ ដែលចែងថា " *ត្រូវបានបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំណុះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ២ ដែលចែងថា " *ក្រសួងឧស្សាហកម្មនិងសិប្បកម្មមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្មនិងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៣ ដែលចែងថា " *ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការនិង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៤ ដែលចែងថា " *ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៥ ដែលចែងថា " *វិស័យឧស្សាហកម្ម និងសិប្បកម្ម ដែលជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលពីមុនត្រូវស្ថិតនៅក្រោមក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។*

  *ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម រ៉ែ និងថាមពល ដែលនៅជាធរមានត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានការកំណត់ជាថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ត្រូវបន្តដឹកនាំនិងគ្រប់គ្រងក្រសួងឧស្សាហកម្ម និងសិប្បកម្ម រហូតដល់មានការតែងតាំងរដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម*" ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា មាត្រា ៦ ដែលចែងថា " ***ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍*** " ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៧ ដែលចែងថា " ***ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់*** " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៧ មាត្រា នៃច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្មដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី១ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៣ នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៤១/០៤៥/២០១៣

ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤៥/០២០/២០១៣ កបធ.ច

ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ៥០៦ រ.ស ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៨ ព្រឹក ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា១ ដែលចែងថា ***"ត្រូវបានបង្កើតក្រសួងមុខងារសាធារណៈ ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា"*** ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា២ ដែលចែងថា ***"ក្រសួងមុខងារសាធារណៈមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យមុខងារសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា"*** ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា៣ ដែលចែងថា ***"ក្រសួងមុខងារសាធារណៈត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬ អនុរដ្ឋលេខាធិការតាមការចាំបាច់"*** ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា៤ ដែលចែងថា ***"ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ"*** ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា៥ ដែលចែងថា ***"ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍"*** ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៦ ដែលចែងថា ***"ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់"*** ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង៦មាត្រា នៃច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយព្រឹទ្ធសភា បានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :២៤៣/០៤៧/២០១៣

ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៤៦/០២១/២០១៣ កបធ.ច

ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ៥០៨ រ.ស ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និង ថាមពល ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភានីតិកាលទី៣ នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៣ វេលាម៉ោង ៨ ព្រឹក ។

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ១ ដែលចែងថា " *ត្រូវបានបង្កើតក្រសួងរ៉ែ និងថាមពល ចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ២ ដែលចែងថា " *ក្រសួងរ៉ែ និងថាមពល មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យរ៉ែ និងថាមពល ដោយរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៣ ដែលចែងថា " *ក្រសួងរ៉ែ និងថាមពល ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការនិង/ឬអនុរដ្ឋលេខាធិការ តាមការចាំបាច់* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៤ ដែលចែងថា " *ការរៀបចំរចនាសម្ព័ន្ធ និង ការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល ត្រូវកំណត់ដោយអនុក្រឹត្យ* " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៥ ដែលចែងថា " *អាជ្ញាធរអគ្គិសនីកម្ពុជា ដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០០១ ត្រូវស្ថិតនៅក្រោមការដឹកនាំ និង គ្រប់គ្រងផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងរ៉ែ និងថាមពល និងត្រូវមានគណនេយ្យភាពហិរញ្ញវត្ថុ ចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨* " ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៦ ដែលចែងថា " *វិស័យរ៉ែ និងថាមពល ដែលជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពីមុនត្រូវស្ថិតនៅក្រោមក្រសួងរ៉ែ និងថាមពល ។*

*ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម រ៉ែ និងថាមពល ដែលនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានការកំណត់ជាថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*រដ្ឋមន្ត្រី និង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ត្រូវបន្តដឹកនាំ និងគ្រប់គ្រងក្រសួងរ៉ែ និងថាមពលរហូតដល់មានការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល* " ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា មាត្រា ៧ ដែលចែងថា " ***បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍*** " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៨ ដែលចែងថា " ***ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់*** " ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៨ មាត្រា នៃច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែ និងថាមពល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែ និងថាមពល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី១ នីតិកាលទី៥ និងព្រឹទ្ធសភា បានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៣

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ២៨/២០១៣.កបធ.សសរ

ប្រញាប់បំផុត

# សេចក្ដីសម្រេច

## ស្ដីពី

## ការអនុញ្ញាតឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព “ក” មួយចំនួននៅមណ្ឌលខេត្តក្រចេះ

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់នេះ
- បានឃើញច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់នេះ
- បានឃើញបទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

**សម្រេច**

**ប្រការ ១** : អនុញ្ញាតឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព “ក” មួយចំនួននៅមណ្ឌលខេត្តក្រចេះ នៅការិយាល័យលេខ ០២៥៩ ០២៦០ ០២៦១ ០២៦២ ០២៦៣ ០២៧៦ ០២៧៧ ០២៧៨ ០៣៤៥ ០៣៦៨ ០៣៧៤ ០៤០៧ និង ០៤២៤ នៅឃុំស្វាយជ្រះ ដើម្បីផ្ទៀងផ្ទាត់ ។

**ប្រការ ២** : ការបើកកញ្ចប់សុត្តិភាព “ក” ខាងលើ ត្រូវធ្វើនៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាថ្ងៃអាទិត្យ ទី ២៥ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ០៨:០០ ព្រឹក ។

**ប្រការ ៣** : ក្រុមប្រឹក្សាធម្មនុញ្ញនឹងចាត់តាំងតំណាងឲ្យទៅចូលរួមស្រាវជ្រាវ ស៊ើបអង្កេត ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣

ឯក សំអុល

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ៣៣០/២០១៣ កបធ.សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តសៀមរាប

ប្រញាប់បំផុត

## ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់នេះ

-បានឃើញច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់នេះ

-បានឃើញបទបញ្ជាផ្ទៃក្នុងស្ដីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅ **មណ្ឌលខេត្តសៀមរាប** នៅ**ក្រុងសៀមរាប សង្កាត់ក្របីរៀល:** ការិយាល័យលេខ ០២៨៣ ០២៨៥ **សង្កាត់ស្វាយដង្គំ:** ការិយាល័យលេខ ០៤២៥ ០៤៤២ និង**សង្កាត់ស្លក្រាម:** ការិយាល័យលេខ ០៨១៧ និង នៅ**ស្រុកពួក ឃុំរើល:** ការិយាល័យលេខ ០៣២៣ ០៣២៤ ០៣២៦ **ឃុំល្វា:** ការិយាល័យលេខ ០២៩៤ ០៦៧៣ ០៧១៨ និង**ឃុំត្រីញ័រ:** ការិយាល័យលេខ ០៣៤៦ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់ ១១០២ ១១០៨ និង ក្រដាសកត់ត្រាសំឡេងឆ្នោត។

**ប្រការ ២**: ការបើកកញ្ចប់សុវត្ថិភាព "ក" ខាងលើ ត្រូវធ្វើនៅទីស្ដីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាថ្ងៃសុក្រ ទី៣០ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ០៨:០០ ព្រឹក។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបំពេញភារកិច្ចស្របតាមច្បាប់កំណត់ និង ធ្វើកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាពខាងលើនេះ។

**ប្រការ ៣** : ក្រុមប្រឹក្សាធម្មនុញ្ញនឹងចាត់តាំងតំណាងឱ្យទៅចូលរួមស្រាវជ្រាវ ស៊ើបអង្កេត។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣

**ឯក សំអុល**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ៣១/២០១៣ ក.ធ.ម.សសម

# សេចក្តីសម្រេច
# ស្តីពី
# ការអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តកណ្តាល

## ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ

-បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ

-បានឃើញបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅ **មណ្ឌលខេត្តកណ្តាល នៅក្រុងតាខ្មៅ សង្កាត់តាខ្មៅ** ការិយាល័យលេខ ១០៦៨ ១០៧១ ០៨៣៣ ១១៨១ ១១៥៦ ១២៣៨ ១២៩១ និង ១២៩២ សរុបមាន ០៨ ការិយាល័យ ដើម្បីផ្ទៀងផ្ទាត់សំឡេងឆ្នោត ក្នុងទម្រង់ ១១០២ ១១០៨ និង ក្រដាសធំកត់ត្រាសំឡេងឆ្នោត។

**ប្រការ ២** : ការបើកកញ្ចប់សុវត្ថិភាព "ក" ខាងលើ ត្រូវធ្វើនៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាថ្ងៃអាទិត្យ ទី០១ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ០៨:០០ ព្រឹក។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបំពេញភារកិច្ចស្របតាមច្បាប់កំណត់ និង ធ្វើកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាពខាងលើនេះ។

**ប្រការ ៣** : ក្រុមប្រឹក្សាធម្មនុញ្ញនឹងចាត់តាំងតំណាងឱ្យទៅចូលរួមស្រាវជ្រាវ ស៊ើបអង្កេត។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**
លេខ :២៤៨/០០៥/២០១៤
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្តីសម្រេច**
លេខ : ១៤៧/០០១/២០១៤ កបធ.ច
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៤ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៤ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្តីពី បទប្បញ្ញត្តិរួម មាន ៧ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៧ ដែលចែងពីគោលបំណងធានាឯករាជ្យនៃអំណាចតុលាការ វិសាលភាពនៃការអនុវត្ត បុគ្គលដែលត្រូវជ្រើសរើសសម្រាប់ឱ្យបំពេញមុខងារជាចៅក្រមនិងព្រះរាជអាជ្ញា និងការកំណត់ដាក់ចៅក្រមនិងព្រះរាជអាជ្ញាឱ្យស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពី ចៅក្រម ចែកចេញជា ១៤ ផ្នែក និង មាន ៦៦ មាត្រា គឺពីមាត្រា ៨ ដល់មាត្រា ៧៣ ដែលចែងពី បទប្បញ្ញត្តិទូទៅ ឋានន្តរស័ក្តិនិងថ្នាក់ ឯកសណ្ឋាន ប្រាក់បៀវត្សប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់និងការឈប់សម្រាក ការជ្រើសរើសចៅក្រម ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខណ្ឌចៅក្រម ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះចៅក្រម កាតព្វកិច្ចចៅក្រម ទណ្ឌកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការចូលនិវត្តន៍ ងារជាកិត្តិយស និងកិច្ចសច្ចាប្រណិធាន ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពី ព្រះរាជអាជ្ញា ចែកចេញជា ១៤ ផ្នែក និង មាន ៣២ មាត្រា គឺពីមាត្រា ៧៤ ដល់មាត្រា ១០៥ ដែលចែងពី បទប្បញ្ញត្តិទូទៅ ឋានន្តរស័ក្តិនិងថ្នាក់ ឯកសណ្ឋាន ប្រាក់បៀវត្សប្រាក់បំណាច់ផ្សេងៗ ប្រាក់រង្វាន់និងការសម្រាកប្រចាំឆ្នាំ ការជ្រើសរើសព្រះរាជអាជ្ញា ការធ្វើកម្មសិក្សានិងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះព្រះរាជអាជ្ញា កាតព្វកិច្ចព្រះរាជអាជ្ញា ទណ្ឌកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការចូលនិវត្តន៍ ងារជាកិត្តិយស និងកិច្ចសច្ចាប្រណិធាន ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពី វិសមិតភាព មាន ២ មាត្រា គឺមាត្រា ១០៦ និង មាត្រា ១០៧ ដែលចែងពី វិសមិតភាពមុខងាររបស់ចៅក្រមនិងព្រះរាជអាជ្ញា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពី អន្តរប្បញ្ញត្តិ មាន ៣ មាត្រា គឺពីមាត្រា ១០៨ ដល់មាត្រា ១១០ ដែលចែងពី ការធ្វើសមាហរណកម្មចៅក្រមនិងព្រះរាជអាជ្ញាក្នុងក្របខណ្ឌគ្រប់គ្រងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចូលទៅក្នុងក្របខណ្ឌចៅក្រមនិងព្រះរាជអាជ្ញា តាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែចៅក្រមនៃ តុលាការយោធានិងព្រះរាជអាជ្ញាអមតុលាការយោធា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៦ ស្តីពី អវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ១១១ ដែលចែងពី បទប្បញ្ញត្តិ ទាំងឡាយណាដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទុកជានិរាករណ៍ ពុំមានបទប្បញ្ញត្តិណាមិនស្រប នឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៦ ជំពូក ១១១ មាត្រា នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.**ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាព ទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នា ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.**សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៤៩/006/២០១៤

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៤៨/00២/២០១៤ កបធ.ច

ចុះថ្ងៃទី0២ ខែកក្កដា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/00៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៥ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៥ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៣ ដែលចែងពីការកំណត់គោលដៅ គោលបំណង និងវិសាលភាពនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការធានាឯករាជ្យភាពនៃអំណាចតុលាការ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី២ ស្តីពីការរៀបចំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចែកចេញជា ២ ផ្នែក និងមាន ៦ មាត្រា គឺពីមាត្រា ៤ ដល់មាត្រា ៩ ៖

-ផ្នែកទី១ ស្តីពីសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ៤ មាត្រា គឺពីមាត្រា ៤ ដល់មាត្រា ៧ ដែលចែងពីសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បែបបទនិងនីតិវិធីនៃការ

បោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាណត្តិរបស់សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការជ្រើសតាំងសមាជិកសម្រាប់ជំនួសសមាជិកដែលទទួលមរណភាព ឬលាលែងពីតំណែង ឬបាត់បង់លក្ខណៈសម្បត្តិ ឬមិនអាចបំពេញមុខងាររបស់ខ្លួនបានដោយប្រការណាមួយ បែបបទនៃការដកចេញពីមុខតំណែងចំពោះសមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម វិសមិតភាពមុខងាររបស់សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងតួនាទីព្រះរាជតំណាងរបស់ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-ផ្នែកទី២ ស្តីពីអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ២ មាត្រា គឺ មាត្រា ៨ និង មាត្រា ៩ ដែលចែងពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអគ្គលេខាធិការដ្ឋានមួយស្ថិតនៅក្រោមរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ ដើម្បីធ្វើជាសេនាធិការសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន ។ ជំពូកទី២ នេះ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៣ ស្តីពីកិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាន ៨ មាត្រា គឺពី មាត្រា ១០ ដល់មាត្រា ១៧ ដែលចែងពីបែបបទនៃការកោះប្រជុំ និងកូរ៉ុមនៃកិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នីតិវិធីនៃការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គោលការណ៍រក្សាការសម្ងាត់នៃកិច្ចប្រជុំ ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងនាមជាតំណាងឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការបង្កើតបទបញ្ជាផ្ទៃក្នុងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការកំណត់កញ្ចប់ថវិកា និងអាណាប័កទទួលសិទ្ធិ ការទទួលប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ម៉ោងប្រជុំ របបឧបត្ថម្ភនានា និងការប្រើប្រាស់ត្រារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពីសមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចែកចេញជា ២ ផ្នែក និងមាន ៩ មាត្រា គឺពី មាត្រា ១៨ ដល់មាត្រា ២៦ ÷

-ផ្នែកទី១ ស្តីពីសមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមាន ២ មាត្រា គឺ មាត្រា ១៨ និង មាត្រា ១៩ ដែលចែងពីបែបបទ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ ការផ្អាកពីមុខងារ ការដាក់ឱ្យនៅក្រៅក្របខណ្ឌ ការដាក់ឱ្យនៅទំនេរ ការលុបឈ្មោះចៅក្រម ការដំឡើងថ្នាក់ ការដំឡើងឋានន្តរស័ក្តិឱ្យចៅក្រមនិងព្រះរាជអាជ្ញា ការផ្តល់យោបល់លើសេចក្តីស្នើច្បាប់ឬសេចក្តីព្រាងច្បាប់ដែល

ទាក់ទងនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃវិស័យតុលាការ ការពិនិត្យនិងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា

-ផ្នែកទី២ ស្តីពីសមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខការដាក់វិន័យចៅក្រមនិងព្រះរាជអាជ្ញាមាន ៧ មាត្រា គឺពីមាត្រា ២០ ដល់មាត្រា ២៦ ដែលចែងពីបែបបទ និងនីតិវិធីនៃការប្រជុំកូរ៉ុមប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យក្នុងការដាក់វិន័យចំពោះចៅក្រម ព្រះរាជអាជ្ញា ប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ការបង្កើតឱ្យមានក្រុមអធិការកិច្ច ដើម្បីជួយការងារក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអានុភាពនៃសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ជំពូកទី៤ នេះ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៥ ស្តីពីអន្តរប្បញ្ញត្តិ មាន ៤ មាត្រា គឺពីមាត្រា ២៧ ដល់មាត្រា ៣០ ដែលចែងពីសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តការងាររបស់ខ្លួនរហូតដល់ពេលសមាសភាពថ្មីត្រូវបានតែងតាំងជាផ្លូវការ បែបបទ នីតិវិធីនិងថិរវេលានៃការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចមានចែងក្នុងមាត្រា ៤ ចាប់ពីចំណុចទី ៨ ដល់ចំណុចទី ១១ ការចាត់ឱ្យចៅក្រមឬព្រះរាជអាជ្ញាដែលបម្រើការងារនៅតាមសាលាជម្រះក្តីនិងនៅតាមអង្គការអយ្យការអមសាលាជម្រះក្តី ចុះស្រាវជ្រាវនិងស៊ើបអង្កេតលើសំណុំរឿងវិន័យសម្រាប់អំឡុងពេលដែលក្រុមអធិការកិច្ចនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនទាន់ត្រូវបានតែងតាំង និងវិសមិតភាពមុខងារដែលបញ្ញត្តក្នុងមាត្រា ៦ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះចៅក្រមឬព្រះរាជអាជ្ញាដែលបំពេញមុខងារក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្តីពីអវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣១ ដែលចែងពីច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលត្រូវបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង ៦ ជំពូក ៣១ មាត្រា នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី២ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៤៧/០០៤/២០១៤

ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៤៩/០០៣/២០១៤ កបធ.ច

ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៣ រ.ស ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី៣ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ១៦ និង ០៣ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ការឆ្លើយបំភ្លឺរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងសហការី លើចំណុចមួយចំនួននៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក្នុងសម័យប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្តីពី បទប្បញ្ញត្តិទូទៅ មាន ១១ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ១១ ដែលចែងពី គោលបំណង គោលដៅ និងវិសាលភាពរបស់តុលាការ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពី សាលាដំបូង និងអយ្យការអមសាលាដំបូង ចែកចេញជា ០៣ ផ្នែក ០២ អនុផ្នែក និងមាន ២៣ មាត្រា គឺពីមាត្រា ១២ ដល់មាត្រា ៣៤ ដែលចែងពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាដំបូង ការបង្កើតឱ្យមានតុលាការជំនាញដូចជា តុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្មនិងតុលាការការងារ សមត្ថកិច្ចរបស់សាលាដំបូងនិងសមត្ថកិច្ចរបស់តុលាការជំនាញនីមួយៗ សមាសភាពនិងមុខងាររបស់អយ្យការអមសាលាដំបូង លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ភារកិច្ចរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ការតែងតាំងនិងវិសាលភាពដឹកនាំលេខាធិការដ្ឋានរដ្ឋបាល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពី សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ចែកចេញជា ០៣ ផ្នែក ០២ អនុផ្នែក និងមាន ២០ មាត្រា គឺពីមាត្រា ៣៥ ដល់មាត្រា ៥៤ ដែលចែងពី ការរៀបចំនិង

ការប្រព្រឹត្តទៅរបស់សាលាឧទ្ធរណ៍ ការបង្កើតឱ្យមានសាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍តំបន់ និងសភាជំនាញនៅតាមសាលាឧទ្ធរណ៍នីមួយៗរួមមាន សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាស៊ើបសួរ សភាពាណិជ្ជកម្មនិងសភាការងារ សមាសភាពរបស់សភានីមួយៗនិងវិធានការគ្រប់គ្រងសម្រាប់ដំណើរការនៃសាលាឧទ្ធរណ៍ សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ សមត្ថកិច្ចរបស់សភាជំនាញនីមួយៗនិងសមត្ថកិច្ចរបស់សភារួមក្រុម សមាសភាពនិងមុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍និងរចនាសម្ព័ន្ធដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពី តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ចែកចេញជា ០៣ ផ្នែក ០២ អនុផ្នែក និងមាន ១៩ មាត្រា គឺពីមាត្រា ៥៥ ដល់មាត្រា ៧៣ ដែលចែងពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការកំពូល ការបង្កើតឱ្យមានសភាជំនាញនៅតុលាការកំពូល ដូចជា សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្មនិងសភាការងារ សមាសភាពរបស់សភានីមួយៗ វិធានការគ្រប់គ្រងនៅក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូលនិងការណែនាំសភាទាំងអស់របស់តុលាការកំពូល សមាសភាពនិងមុខងាររបស់មហាអយ្យការអមតុលាការកំពូល អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលនិងរចនាសម្ព័ន្ធដឹកនាំអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពី វិសមិតភាព មាន ០៥ មាត្រា គឺពីមាត្រា ៧៤ ដល់មាត្រា ៧៨ ដែលចែងពី មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរនិងមុខងារជំនុំជម្រះត្រូវបែងចែកដាច់ពីគ្នា គោលការណ៍ចូលរួមជំនុំជម្រះក្តីរបស់ចៅក្រម និងនីតិវិធីប្តឹងសុំមោឃកម្ម ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៦ ស្តីពី ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី មាន ០១ មាត្រា គឺមាត្រា ៧៩ ដែលចែងពី កញ្ចប់ថវិការបស់សាលាដំបូងនិងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៧ ស្តីពី អន្តរប្បញ្ញត្តិ មាន ១១ មាត្រា គឺពីមា

ក្នុងករណីមិនទាន់មានសាលាឧទ្ធរណ៍តំបន់ សមត្ថកិច្ចនៃសភារដ្ឋប្បវេណីនៃសាលាជម្រះក្ដីជាន់ខ្ពស់ ក្នុងករណីដែលសភាពាណិជ្ជកម្មនិងសភាការងារនៃសាលាជម្រះក្ដីជាន់ខ្ពស់មិនអាចដំណើរការបានដោយមូលហេតុខ្វះចៅក្រម និងសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្ដីជាន់ទាបនិងសភារដ្ឋប្បវេណីនៃសាលាជម្រះក្ដីជាន់ខ្ពស់ ក្នុងករណីមិនទាន់មានសាលាជម្រះក្ដីរដ្ឋបាល និងករណីមិនទាន់មានបទប្បញ្ញត្តិស្ដីពីនីតិវិធីពាណិជ្ជកម្ម នីតិវិធីការងារ និងនីតិវិធីរដ្ឋបាល ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៨ ស្ដីពី អវសានប្បញ្ញត្តិ មាន ០១ មាត្រា គឺមាត្រា ៩១ ដែលចែងពី បទប្បញ្ញត្តិស្ដីពីប្រព័ន្ធព

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៥០/០០៧/២០១៤

ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤

**សេចក្ដីសម្រេច**

លេខ : ១៥០/០០៤/២០១៤ កបធ.ច

ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៣៣២ រ.ស ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ១០ និង ២០ នាទី។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ៨២ ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្នុងការពិនិត្យនិងអនុម័តសេចក្ដីស្នើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញ-ភាពលើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៦ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រ-កម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.-** វិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ២៩២/០០៩/២០១៤
ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤

**សេចក្តីសម្រេច**
លេខ : ១៩១/០០៥/២០១៤ កបធ.ច
ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៩២/០៨១៤/ពស/ន.រ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ របស់ឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ ព្រឹទ្ធសភានីតិកាលទី៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ១៤:០០។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើតាមសេចក្តីសម្រេចលេខ ០១៧/០៨១២/ពស/សរ.ព ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ក្នុងការពិនិត្យនិងអនុម័តសេចក្តីស្នើ

វិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣នៃព្រះរាជាណាចក្រកម្ពុជា

- យល់ឃើញថា សំណើរបស់ឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣នេះមកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តវិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារនៃប្រការ ១៥ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១**-វិសោធនកម្មប្រការ ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២**-សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក ស័អុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៥៣/០១០/២០១៤

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៥២/០០៦/២០១៤ កបធ.ច

ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៥១៧ រ.ស ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មជំពូកទី១២ ប្រការ ៤៨ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៥ ដោយចាត់ទុកជាការប្រញាប់ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ វេលាម៉ោង ១០ និង ៤៦ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ៨២ ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្នុងការពិនិត្យនិងអនុម័តសេចក្ដីស្នើវិសោធនកម្ម ជំពូកទី១២ ប្រការ ៤៨ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញ-ភាពលើវិសោធនកម្ម ជំពូកទី១២ ប្រការ ៤៨ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តវិសោធនកម្មជំពូកទី១២ ប្រការ ៤៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃជំពូកទី១២ថ្មី ប្រការ ៤៨ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជា-ណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១៖** វិសោធនកម្មជំពូកទី១២ ប្រការ ៤៨ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២៖** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ២៥៤/០០១/២០១៥
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥

**សេចក្តីសម្រេច**
លេខ : ១៥៣/០០១/២០១៥ កបធ.ច
ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៦១ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ១១ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន

- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅមាន ៣មាត្រា គឺពីមាត្រា១ ដល់មាត្រា៣ ដែលចែងពីគោលដៅ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឈ្មោះជាអក្សរកាត់ "គ.ជ.ប" រចនាសម្ព័ន្ធ ការអនុវត្តសមត្ថកិច្ចដោយឯករាជ្យនិងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតទាំងអស់ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣ នៃជំពូកទី១នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី២ ស្តីពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចែកចេញជា៤ផ្នែក និងមាន ៣៨មាត្រា គឺពីមាត្រា៤ ដល់មាត្រា៤១

-ផ្នែកទី១ ចែងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ៩រូប ប្រធាន ១រូប អនុប្រធាន ១រូប និងសមាជិក ៧រូប បោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា និងមានអាណត្តិ ៥ឆ្នាំ។ លក្ខណសម្បត្តិសម្រាប់ជ្រើសរើស បែបបទនិងនីតិវិធី ឋានៈ បុព្វសិទ្ធិ វិសមិតភាព ការបាត់បង់មុខតំណែងក៏ត្រូវបានកំណត់ក្នុងផ្នែកទី១ នេះដែរ

-ផ្នែកទី២ ស្តីពីការរៀបចំគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតមាន១២មាត្រា គឺពីមាត្រា១៤ ដល់មាត្រា២៥ ចែងពីសមាសភាពមានប្រធាន ១រូប អនុប្រធាន ១រូប និង សមាជិក ៣ ឬ ៥រូប ឋានៈ បុព្វសិទ្ធិ លក្ខខណ្ឌ តួនាទីភារកិច្ច និងការទទួលខុសត្រូវនៅចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមានលេខាធិការដ្ឋានធានានិរន្តរភាពរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

-ផ្នែកទី៣ ស្តីពីការរៀបចំគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមាន៨មាត្រា គឺពីមាត្រា២៦ ដល់មាត្រា៣៣ ចែងពីសមាសភាពរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតដែលមានប្រធាន ១រូប អនុប្រធាន ១រូប សមាជិក ៣ ឬ ៥រូប ទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ផ្នែកទី៤ ស្តីពីការរៀបចំគណៈកម្មការការិយាល័យបោះឆ្នោតមាន ៨មាត្រា គឺពីមាត្រា៣៤ ដល់មាត្រា៤១ មានសមាសភាពប្រធាន ១រូប អនុប្រធាន ១រូប លេខាធិការ ១រូប និងសមាជិក ៣រូប ទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣៨នៃជំពូកទី២នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៣ ស្តីពីការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចែកចេញជា៣ ផ្នែក និងមាន ១៦មាត្រា គឺពីមាត្រា៤២ ដល់មាត្រា៥៧

-ផ្នែកទី១ ស្តីពីសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន ២៨ ចំណុច ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានភារកិច្ច ៥ចំណុច អនុប្រធានជួយធ្វើការប្រធានតាមការបែងចែកភារកិច្ចពីប្រធាន និង ជំនួសប្រធានពេលប្រធានអវត្តមាន ឬមកធ្វើការពុំបានក្នុងឋានៈជាប្រធានស្តីទីតាមលិខិតផ្ទេរសិទ្ធិ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិកំណត់ប្រាក់បំណាច់ និងប្រាក់កម្រៃផ្សេងៗដល់សមាជិក មន្ត្រី បុគ្គលិកថ្នាក់ក្រោម

-ផ្នែកទី២ ស្តីពីរបៀបរបបការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន៤មាត្រា គឺពីមាត្រា៤៨ ដល់មាត្រា៥១

-ផ្នែកទី៣ ស្តីពីអគ្គលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន៦មាត្រា គឺពីមាត្រា៥២ដល់មាត្រា៥៧។ មន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃលក្ខន្តិកៈដោយឡែកមួយ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៦ នៃជំពូកទី៣នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពីថវិការបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមាន២មាត្រា គឺមាត្រា៥៨ និងមាត្រា៥៩។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ចែង និងប្រើប្រាស់ថវិកាដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២ នៃជំពូកទី៤នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៥ ស្តីពីទោសប្បញ្ញត្តិមាន១មាត្រា គឺមាត្រា៦០។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រី បុគ្គលិកក្រោមឱវាទគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។ បទវិន័យនេះនឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រា៦០ នៃជំពូកទី៥នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្តីពីអន្តរប្បញ្ញត្តិមាន៤មាត្រា គឺពីមាត្រា៦១ ដល់មាត្រា៦៤ ចែងពីការបន្តការងាររបស់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃអគ្គលេខាធិការដ្ឋានបច្ចុប្បន្នរហូតដល់ពេលដែលមានការតែងតាំងចូលកាន់មុខតំណែងរបស់ប្រធាន អនុប្រធាន សមាជិក អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកថ្មី និងការធ្វើសមាហរណកម្ម។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤ នៃជំពូកទី៦នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៧ ស្តីពីអវសានប្បញ្ញត្តិមាន២មាត្រា គឺមាត្រា៦៥និងមាត្រា៦៦ ចែងពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២ នៃជំពូកទី៧នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង ៧ជំពូក ៦៦មាត្រានៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៥៥/០០២/២០១៥

ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥

**សេចក្ដីសម្រេច**

លេខ : ១៥៤/០០២/២០១៥ កបធ.ច

ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៦២ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ១១ និង ៣០ នាទី ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤មាត្រា គឺពីមាត្រា១ ដល់មាត្រា៤ ចែងពីគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤នៃជំពូកទី១នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ មាន ២មាត្រា គឺមាត្រា៥ និងមាត្រា៦ ចែងពីការជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើឡើងដោយការបោះឆ្នោតជាទូទៅ ជាសកលដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ អាសនៈនៅក្នុងរដ្ឋសភាមានចំនួន១២៥ បែងចែកទៅតាម២៥មណ្ឌលរាជធានី ខេត្ត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២នៃជំពូកទី២នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត មាន១៦មាត្រា គឺពីមាត្រា៧ ដល់មាត្រា២២ ចែងពីគណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួនដើម្បីចូលរួមសង្កេតមើលការបោះឆ្នោតនិងរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោត បែបបទនៃការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិនិងភ្នាក់ងារបម្រុង គណៈកម្មការឃុំ

សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្តល់ប័ណ្ណសម្គាល់ដល់ភ្នាក់ងារគណបក្សនយោបាយ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលអាចបញ្ជូនតំណាងរបស់ខ្លួនឱ្យមកចូលរួមជាអ្នកសង្កេតការណ៍ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់ប័ណ្ណសម្គាល់ដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល សិទ្ធិជំទាស់ឬតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយ របៀបបែបបទនៃការជំទាស់ឬការតវ៉ា បម្រាមចំពោះភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ក្នុងការសង្កេតមើលដំណើរការនៃការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ការអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានានិងតំណាងអង្គការអន្តរជាតិឱ្យចូលរួមសង្កេតការណ៍ការបោះឆ្នោត និងការតាក់តែងបទបញ្ជាសម្រាប់ភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៦នៃជំពូកទី៣នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបញ្ជីបេក្ខជនឈរឈ្មោះ មាន១៥មាត្រា គឺពីមាត្រា២៣ ដល់មាត្រា៣៧ ចែងពីលក្ខខណ្ឌសម្រាប់ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើម៩០ថ្ងៃមុនថ្ងៃបោះឆ្នោត។ ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណបក្សនយោបាយត្រូវបំពេញទម្រង់បែបបទចំនួន១០ចំណុច ហើយត្រូវប្រគល់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរ៧០ថ្ងៃមុនថ្ងៃបោះឆ្នោត។ ទន្ទឹមនឹងនេះមានចែងអំពីបណ្តឹងតវ៉ារហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង។ ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ានេះជាបន្ទាន់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៥នៃជំពូកទី៤នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៥ ស្តីពីការិយាល័យបោះឆ្នោត មាន៦មាត្រា គឺពីមាត្រា៣៨ ដល់មាត្រា៤៣ ចែងពីការបង្កើតការិយាល័យបោះឆ្នោតតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ការិយាល័យបោះឆ្នោតនីមួយៗត្រូវមានប្រជាពលរដ្ឋមានឈ្មោះបោះឆ្នោតយ៉ាងច្រើន៧៥០នាក់ គ្រប់ការិយាល័យបោះឆ្នោតនិងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតត្រូវមានបរិវេណខាងក្នុងនិងក្រៅដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ឈ្មោះនិងទីតាំងការិយាល័យបោះឆ្នោតដែលបានកំណត់ហើយត្រូវបិទផ្សាយជាសាធារណៈ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៦នៃជំពូកទី៥នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្ដីពីការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត មាន ២៣មាត្រា គឺពីមាត្រា ៤៤ ដល់មាត្រា៦៦ ចែងពីការចុះឈ្មោះបោះឆ្នោតនិងបញ្ជីបោះឆ្នោតត្រូវធានាសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ។ ក្នុងបញ្ជីបោះឆ្នោតត្រូវកត់ត្រាអំពី : នាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត លំនៅឋាន ឬ ទីសំណាក់ក្នុងឃុំសង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត និងការដៅសម្គាល់អត្តសញ្ញាណដែលមានតែមួយគត់សម្រាប់អ្នកបោះឆ្នោតម្នាក់ៗ ដូចជារូបថត និងស្នាមម្រាមដៃ ឬ/និងការដៅសម្គាល់ផ្សេងទៀតតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ទិន្នន័យទាំងអស់ខាងលើនេះត្រូវស្រង់ចេញពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកបោះឆ្នោតនោះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់សុពលភាពនិងប្រកាសផ្សាយបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ៩០ថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនិងការផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោតត្រូវធ្វើចាប់ពីថ្ងៃទី០១ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែកក្កដា ជារៀងរាល់ឆ្នាំ។ ក្នុងនេះក៏មានចែងពីបណ្ដឹងតវ៉ារហូតដល់ក្រុមប្រឹក្សាធម្មនុញ្ញ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៣នៃជំពូកទី៦នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៧ ស្ដីពីការឃោសនាបោះឆ្នោត មាន២៥មាត្រា គឺពីមាត្រា៦៧ ដល់មាត្រា៩១ ចែងពីការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមរយៈការឃោសនាបោះឆ្នោត សកម្មភាពនៃការឃោសនាបោះឆ្នោត ការលើកស្លាកសញ្ញាគណបក្សនយោបាយរយៈពេលយុទ្ធនាការនៃការឃោសនាបោះឆ្នោត ការគោរពតាមវិធាន បទប្បញ្ញត្តិនិងគោលការណ៍ដែលមានចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជានិងនីតិវិធីរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងពេលឃោសនាបោះឆ្នោត។ យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់២៤ម៉ោងមុនថ្ងៃបោះឆ្នោត។ ការហែក្បួនរបស់គណបក្សនយោបាយអាចធ្វើបានយ៉ាងច្រើន៤ដងក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ រាល់ការស្ទង់មតិនិងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោតត្រូវបញ្ឈប់៧ថ្ងៃមុនថ្ងៃបោះឆ្នោត។ អង្គការមិនមែនរដ្ឋាភិបាលឬសមាគមក្នុងស្រុកនិងសមាគមឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើសកម្មភាពដោយផ្ទាល់ឬប្រយោលក្នុងការឃោសនាបោះឆ្នោតដើម្បីគាំទ្រឬប្រឆាំងគណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៥នៃជំពូកទី៧នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៨ ស្ដីពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត មាន៤៦មាត្រា គឺពីមាត្រា៩២ ដល់មាត្រា១៣៧ ចែងពីការបោះឆ្នោតត្រូវធ្វើតែ១ថ្ងៃចាប់ពី

ម៉ោង៧ព្រឹករហូតដល់ម៉ោង១៥ លើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំសង្កាត់។ មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអាចពិនិត្យតាមដានពេលបោះនិងពេលរាប់សន្លឹកឆ្នោត។ បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួចហើយគណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតរួចផ្ញើជូនគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្ដឹងជំទាស់ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗបិទនៅការិយាល័យបោះឆ្នោតនិងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន។ ក្នុងជំពូកនេះក៏មានចែងពីការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនិងបណ្ដឹងតវ៉ាអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ការបែងចែកអាសនៈតាមរាជធានីខេត្ត និងការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤៦នៃជំពូកទី៨នេះពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៩ ស្ដីពីការបាត់បង់អាសនៈនៃរដ្ឋសភា និងការជ្រើសតាំងជំនួស មាន២មាត្រា គឺមាត្រា១៣៨ និងមាត្រា១៣៩ ចែងពីការបោះបង់ចោលអាសនៈរបស់គណបក្សនយោបាយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការបាត់បង់សមាជិកភាពជាសមាជិករដ្ឋសភា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២នៃជំពូកទី៩នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១០ ស្ដីពីទោសប្បញ្ញត្តិ មាន២៧មាត្រា គឺពីមាត្រា១៤០ ដល់មាត្រា១៦៦ ចែងពីការផាកពិន័យជាប្រាក់ ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ ការប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញរបស់បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៧នៃជំពូកទី១០នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១១ ស្ដីពីអន្តរប្បញ្ញត្តិ មាន៣មាត្រា គឺពីមាត្រា១៦៧ ដល់មាត្រា១៦៩ ចែងពីការរៀបចំបញ្ជីបោះឆ្នោតថ្មីសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៤ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣នៃជំពូកទី១១នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១២ ស្ដីពីអវសានប្បញ្ញត្តិ មាន២មាត្រា គឺមាត្រា១៧០ និងមាត្រា១៧១ ចែងពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ។

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២នៃជំពូកទី១២នេះ ពុំមានចំណុចណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង ១២ជំពូក ១៧១មាត្រានៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៦ នីតិកាលទី៣ នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៥៦/០០៣/២០១៥

ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥

**សេចក្ដីសម្រេច**

លេខ : ១៥៥/០០៣/២០១៥ កបធ.ច

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១០៨/០៧១៥/ពស/នវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១៥ និង ៥១ នាទី ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតលេខ ១០៨/០៧១៥/ពស/នវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឡើងស្របនឹងវាក្យខ័ណ្ឌទី១ មាត្រា១៣៦ថ្មី

មាត្រា១៤១ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នេះមកពិនិត្យបាន

- យល់ឃើញថា មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាន២វាក្យខ័ណ្ឌ ដែលចែងថា :

"***សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។***"

វាក្យខ័ណ្ឌទី១នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់អំពីសិទ្ធិរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី ក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់ ។ វាក្យខ័ណ្ឌទី១នេះ មានន័យថា :

- សមាជិកព្រឹទ្ធសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។
- សមាជិករដ្ឋសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។
- សមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា មានសិទ្ធិរួមគ្នាផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។

ការផ្តួចផ្តើមគំនិតធ្វើច្បាប់ និងការផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ពីសំណាក់សមាជិកព្រឹទ្ធសភា ឬពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភារួមគ្នាជាហត្ថលេខី ត្រូវធ្វើជាសេចក្តីស្នើច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់ ។

- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ។ នាយករដ្ឋមន្ត្រីត្រូវធ្វើជាសេចក្តីព្រាងច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់ ។

វាក្យខ័ណ្ឌទី២នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ មានន័យថា ជាការបញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃវាក្យខ័ណ្ឌទី១ ដោយហាមតំណាងរាស្ត្រមិនឱ្យធ្វើវិសោធនកម្មច្បាប់ដែលសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

- យល់ឃើញថា តាមការបកស្រាយខាងលើនេះ សមាជិកព្រឹទ្ធសភាមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់បាន ។

## សម្រេច

**មាត្រា ១.** មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៥៧/០០៤/២០១៥

ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៥

**សេចក្តីសម្រេច**

លេខ : ១៥៦/០០៤/២០១៥ កបធ.ច

ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើលេខ ៥២៥ រ.ស ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៤ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៧ នីតិកាលទី៣ នាថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១៦ និង ០៥ នាទី
- បានឃើញសំណើរបស់ក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ១៣រូប ពីគណបក្សសង្គ្រោះជាតិមាន ១២ ទំព័រ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៥ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៥ វេលាម៉ោង ៨ និង ៣៦ នាទី ។

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល**

**ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង សំណើរបស់ក្រុមតំណាងរាស្ត្រហត្ថលេខី ចំនួន ១៣រូប ពីគណបក្សសង្គ្រោះជាតិ ដែលមានកម្មវត្ថុតែមួយ ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា គឺពីមាត្រា ១ ដល់ មាត្រា ៤ ដែលចែងពីគោលបំណងធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ កំណត់បែបបទទទួលស្គាល់តាមផ្លូវច្បាប់ដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈដើម្បីអភិវឌ្ឍសង្គមកម្ពុជា និងការឱ្យនិយមន័យវាក្យសព្ទចំនួន ៥ ពាក្យ ដែលប្រើក្នុងច្បាប់នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់មិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា ។ ជំពូកទី១ នេះស្របនឹងបទប្បញ្ញត្តិនៃមាត្រា ៣១ និងបទប្បញ្ញត្តិនៃមាត្រា ៤២ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញដែលចែងថា “ *ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។* ” ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីការបង្កើត និងការចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មាន ៧ មាត្រា គឺពីមាត្រា ៥ ដល់ មាត្រា ១១ ដែលចែងពីលក្ខខណ្ឌនិងទម្រង់បែបបទដែលត្រូវបំពេញ

ក្នុងការបង្កើតនិងការចុះបញ្ជីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងនោះរួមមាន ចំនួនសមាជិកស្ថាបនិក៣រូប និងត្រូវមានអាយុ១៨ឆ្នាំឡើង ចំនួនសំណុំលិខិត ៤ ចំណុចសម្រាប់ការបង្កើតនិងការចុះបញ្ជី លក្ខន្តិកៈរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដោយមានបញ្ជាក់ ៨ ចំណុចសំខាន់ៗ ការរាយការណ៍ពីគណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួនទៅក្រសួងមហាផ្ទៃនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការរាយការណ៍ពីការផ្លាស់ប្តូរសំខាន់ៗក្នុងសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។ ក្រសួងមហាផ្ទៃត្រូវចេញប្រកាសកំណត់នូវលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើតនិងចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សម្រាប់នីតិបុគ្គល និងជនបរទេស រាប់ទាំងសមាគមសម្រាប់អនីតិជន ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៣ ស្តីពីការចុះបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបរទេសមាន ៦មាត្រា គឺពីមាត្រា ១២ ដល់ មាត្រា ១៧ ដែលចែងពីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវចុះបញ្ជីនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់ជាការចុះអនុស្សរណៈ ក្នុងនោះរួមមាន ចំនួនសំណុំលិខិត ៦ ចំណុចសម្រាប់សុំចុះបញ្ជី សុពលភាពអនុស្សរណៈរយៈពេល ៣ឆ្នាំ ការរាយការណ៍ពីគណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការផ្លាស់ប្តូរសំខាន់ៗ ក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ។ ជំពូកទី៣ នេះស្របនឹងមាត្រា ១ វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញដែលចែងថា *"ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹតអចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ"* ស្របនឹងមាត្រា ៥៣ វាក្យខ័ណ្ឌទី១ ឃ្លាទី២ ដែលចែងថា *" ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក "* ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៤ ស្តីពីធនធាន និងទ្រព្យសម្បត្តិរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល មាន ២ មាត្រា គឺមាត្រា ១៨ និង មាត្រា ១៩ ដែលចែងពីប្រភពស្របច្បាប់នៃធនធាននិងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងធនធាននិងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៥ ស្តីពីសិទ្ធិ ផលប្រយោជន៍ និងកាតព្វកិច្ចរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល មាន ៦ មាត្រា គឺពីមាត្រា ២០ ដល់ មាត្រា ២៥ ដែលចែងពីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬអនុស្សរណៈហើយ ត្រូវស្ថិតនៅក្រោមនីតិរួមនៃរបបសារពើពន្ធជាធរមាន

និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងត្រូវមានកាតព្វកិច្ចមួយចំនួនជាអាទិ៍ សិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តគម្រោងសកម្មភាព សិទ្ធិជ្រើសរើសបុគ្គលិកឬកម្មករដើម្បីបម្រើការងារ ។ បុគ្គលិកបរទេសពុំទទួលបានអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិជាអ្នកការទូតដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ។ ការផ្តល់ជូនក្រសួងមហាផ្ទៃនូវរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។ អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍បូកសរុបសកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។ ក្នុងករណីចាំបាច់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យនិងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៦ ស្តីពីការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលមាន ៤ មាត្រា គឺពីមាត្រា ២៦ ដល់ មាត្រា ២៩ ដែលចែងពីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ក្នុងនោះមុននឹងរំលាយត្រូវធ្វើរបាយការណ៍ និងត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អាចផ្អាកសកម្មភាពបានដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងនោះមុននឹងបញ្ចប់សុពលភាពអនុស្សរណៈត្រូវធ្វើរបាយការណ៍ និងត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៧ ស្តីពីវិធានការរដ្ឋបាលនិងទោសប្បញ្ញត្តិមាន ៧ មាត្រា គឺពីមាត្រា ៣០ ដល់មាត្រា ៣៦ ដែលចែងពីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា ១០ ឬមាត្រា ២៤ ឬកថាខណ្ឌទី១ ឬកថាខណ្ឌទី២ នៃមាត្រា ២៥ និង ជំពូកទី២ នៃច្បាប់នេះ ត្រូវរងនូវវិធានការរដ្ឋបាលដែលមានជាអាទិ៍ ការជូនដំណឹងរបស់ក្រសួងមហាផ្ទៃឱ្យផ្អាកសកម្មភាពជាបណ្តោះអាសន្ន ការពិន័យនិងការលុបឈ្មោះចេញពីបញ្ជី។ ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជី

ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការពិន័យទៅតុលាការ ។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមិនបានអនុវត្តតាមមាត្រា ១៧ ឬមាត្រា ២៤ ឬកថាខណ្ឌទី៣ នៃមាត្រា ២៥ និង ជំពូកទី៣ នៃច្បាប់នេះ ត្រូវរងវិធានការរដ្ឋបាលដែលមានជាអាទិ៍ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ការព្រមានជាលាយលក្ខណ៍អក្សរ ការសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ និងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលសកម្មភាពរបស់ខ្លួនធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ជំពូកទី៧ នេះស្របតាមមាត្រា ៥២ នៃរដ្ឋធម្មនុញ្ញដែលចែងថា "*រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទម្លាប់ និង ប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាពចំពោះជីវភាពរស់នៅ និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។*" ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៨ ស្តីពីអន្តរប្បញ្ញត្តិ មាន ២ មាត្រា គឺមាត្រា ៣៧ និង មាត្រា ៣៨ ដែលចែងថា ក្រោយពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជីនិងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិរួចហើយត្រូវចាត់ទុក

ថាបានចុះបញ្ជីស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ជំពូកទី៩ ស្តីពីអវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣៩ ដែលចែងពីបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារទាំង ៩ ជំពូក ៣៩ មាត្រា នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៤ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៧ នីតិកាលទី៣ នាថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៥

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ២៥៨/00៥/២០១៥

ចុះថ្ងៃទី0៥ ខែវិច្ឆិកា ឆ្នាំ២០១៥

**សេចក្តីសម្រេច**

លេខ : ១៥៧/00៥/២០១៥ កបធ.ច

ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0៤៩៨/0៦ ចុះថ្ងៃទី0៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១0៧/00៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៦៦៤ រ.ស ចុះថ្ងៃទី0៥ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ៣ថ្មី ប្រការ ៧ថ្មី ប្រការ ៨ ប្រការ ១០ថ្មី (ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និង ប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៥ នីតិកាលទី៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី0៥ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង ១៦ និង ២៨ នាទី។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ 0៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

- យល់ឃើញថា រដ្ឋសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ៨២ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៨២ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្នុងការពិនិត្យនិងអនុម័តសេចក្ដីស្នើវិសោធនកម្មប្រការ ៣ថ្មី ប្រការ ៧ថ្មី ប្រការ ៨ ប្រការ ១០ថ្មី (ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និង ប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្ម ប្រការ ៣ថ្មី ប្រការ ៧ ថ្មី ប្រការ ៨ ប្រការ ១០ថ្មី (ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និង ប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តវិសោធនកម្មប្រការ ៣ថ្មី ប្រការ ៧ថ្មី ប្រការ ៨ ប្រការ ១០ថ្មី (ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និង ប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣ថ្មី(ពីរ) ស្របតាមមាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៧ថ្មី(ពីរ) ស្របតាមមាត្រា ៨០ មាត្រា ៨៤ និងមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៨ថ្មី ស្របតាមមាត្រា ៨៧ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ១០ថ្មី(បី) ស្របតាមមាត្រា ៨២ថ្មី និងមាត្រា ៨៨ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ១៤ថ្មី(ពីរ) ស្របតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ១៨ថ្មី ស្របតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ២០ថ្មី ស្របតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ២១ថ្មី ស្របតាមមាត្រា ៩១ថ្មី និងមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ២២ថ្មី(ពីរ) ស្របតាមមាត្រា ៩១ថ្មី និងមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣១ថ្មី(បី) ស្របតាមមាត្រា ៨១ និងមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣៣ថ្មី(ពីរ) ស្របតាមមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣៤ថ្មី ស្របតាមមាត្រា ៩៧ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣៦ថ្មី(ពីរ) ស្របតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣៨ថ្មី(ពីរ) ស្របតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៤០ថ្មី(ពីរ) ស្របតាមមាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៤៧ថ្មី(បួន) ស្របតាមមាត្រា ៨៨ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៣ថ្មី(ពីរ) ប្រការ ៧ថ្មី(ពីរ) ប្រការ ៨ថ្មី ប្រការ ១០ថ្មី(បី) ប្រការ ១៤ថ្មី(ពីរ) ប្រការ ១៨ថ្មី ប្រការ ២០ថ្មី ប្រការ ២១ថ្មី ប្រការ ២២ថ្មី(ពីរ) ប្រការ ៣១ថ្មី(បី) ប្រការ ៣៣ថ្មី(ពីរ) ប្រការ ៣៤ថ្មី ប្រការ ៣៦ថ្មី(ពីរ) ប្រការ ៣៨ថ្មី(ពីរ) ប្រការ ៤០ថ្មី(ពីរ) និងប្រការ ៤៧ថ្មី(បួន) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ស្របនឹងរដ្ឋធម្មនុញ្ញ។

## សម្រេច

**មាត្រា ១.-** វិសោធនកម្មប្រការ ៣ថ្មី ប្រការ ៧ថ្មី ប្រការ ៨ ប្រការ ១០ថ្មី(ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និង ប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៥ នីតិកាលទី៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៥៩/០០៦/២០១៥

ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥

**សេចក្ដីសម្រេច**

លេខ : ១៥៨/០០៦/២០១៥ កបធ.ច

ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៦៨២ រ.ស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៥ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង ១៦ និង ៤៥ នាទី។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់
- យល់ឃើញថា សំណើរបស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា-ឃុំសង្កាត់ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្ដីពីបទប្បញ្ញត្តិទូទៅ មាន៦មាត្រា គឺចាប់ពីមាត្រា១ ដល់មាត្រា៦ ចែងពីគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ឃុំសង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំសង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមប្រព័ន្ធសមាមាត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ធ្វើឡើងរៀងរាល់ ៥ ឆ្នាំម្ដង កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៦ នៃជំពូកទី១ នេះ ស្របនឹងមាត្រា៥១ថ្មី វាក្យខ័ណ្ឌទី១និងទី២ មាត្រា១៤៥ថ្មី(មួយ) និងមាត្រា១៤៦ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី២ ស្ដីពីការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ មាន៥មាត្រា គឺចាប់ពីមាត្រា៧ ដល់មាត្រា១១ ចែងពី ការចាត់ចែង រៀបចំ និងគ្រប់គ្រងបញ្ជីបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោត ការដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មុខងារនិងភារកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសិទ្ធិរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការតែងតាំងគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត ឬគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត ឬគណៈកម្មការការិយាល័យរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៥ នៃជំពូកទី២នេះ ស្របនឹងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៣ ស្ដីពីការចុះឈ្មោះបោះឆ្នោត និង បញ្ជីបោះឆ្នោតមាន២មាត្រា គឺមាត្រា១២ និងមាត្រា១៣ ចែងពី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ លក្ខខណ្ឌចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត បែបបទនិងនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតនិងការរៀបចំបញ្ជីបោះឆ្នោត ការផ្ដល់សុពលភាពនិងប្រកាសផ្សាយបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ផ្លូវការ ៩០ ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២ នៃជំពូកទី៣នេះ ស្របនឹងមាត្រា៣៤ថ្មី វាក្យខណ្ឌទី១និងទី២ និងមាត្រា១៥០ថ្មី(ពីរ) វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៤ ស្ដីពីប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ មាន៨មាត្រា គឺចាប់ពីមាត្រា ១៤ ដល់មាត្រា២១ ចែងពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ចំនួនអាសនៈនៃក្រុមប្រឹក្សាឃុំសង្កាត់ត្រូវស្មើគ្នានិងចំនួនសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ការបែងចែកអាសនៈផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោត ករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនបានទទួល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈនោះទៅឱ្យគណបក្សនយោបាយផ្សេងទៀតដែលមានអាសនៈ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៨ នៃជំពូកទី៤នេះ ស្របនឹងមាត្រា១៤៦ថ្មី(មួយ) និងមាត្រា១៥០ថ្មី(ពីរ) វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៥ ស្ដីពីការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោត មាន១៣មាត្រា គឺចាប់ពីមាត្រា២២ ដល់មាត្រា៣៤ ចែងពី ការបង្កើតការិយាល័យបោះឆ្នោតមួយឬច្រើនសម្រាប់ឃុំសង្កាត់នីមួយៗ ការិយាល័យបោះឆ្នោតនេះ ត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ហើយស្ថិតនៅក្នុងព្រំប្រទល់ឃុំសង្កាត់របស់ខ្លួន ត្រូវមានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតយ៉ាងច្រើន ៧៥០ នាក់ ត្រូវប្រមូលផ្ដុំដោយភូមិទាំងមូល និងត្រូវបង្គលក្ខណៈឱ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិនោះបានទៅបោះឆ្នោតនៅទីនោះ ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ចូលឈ្មោះអ្នកដែលលើសទៅក្នុងការិយាល័យបោះឆ្នោតមួយទៀត ដែលស្ថិតនៅជិតបំផុតក្នុងឃុំសង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មី។ ការិយាល័យរាប់សន្លឹកឆ្នោតត្រូវធ្វើឡើងនៅនឹងការិយាល័យបោះឆ្នោត។ ការិយាល័យរាប់សន្លឹកឆ្នោតជាកន្លែងប្រកាសលទ្ធផលបណ្ដោះអាសន្ន។ ការិយាល័យនីមួយៗត្រូវបានកំណត់ឱ្យមានបរិវេណខាងក្នុងជាតំបន់ជុំវិញការិយាល័យបោះឆ្នោត មានកាំប្រវែងយ៉ាងតិច១៥ម៉ែត្រ

និងបរិវេណខាងក្រៅមានកាំប្រវែង ១០០ ម៉ែត្រ។ ការហាមមិនឱ្យធ្វើសកម្មភាពមួយចំនួនក្នុងបរិវេណខាងក្នុង បរិវេណខាងក្រៅ និងក្នុងការិយាល័យបោះឆ្នោត។ ការបិទផ្សាយឈ្មោះ និងទីតាំងការិយា-ល័យបោះឆ្នោតនីមួយៗជាសាធារណៈ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៣ នៃជំពូកទី៥នេះ ស្របនឹងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៦ ស្តីពីការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ មាន៣២មាត្រា គឺចាប់ពីមាត្រា៣៥ ដល់មាត្រា៦៦ ចែងពីល័ក្ខខ័ណ្ឌសម្រាប់ប្រជាពលរដ្ឋទាំងពីរភេទដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ជនគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ការសុំច្បាប់ឈប់ពិសេស និងការស្ថិតនៅក្រៅក្របខណ្ឌដើមចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតត្រូវដាក់យ៉ាងតិច៩០ថ្ងៃ មុនថ្ងៃបោះឆ្នោត ការកំណត់កាលបរិច្ឆេទនៃការទទួលពាក្យនិងការពិនិត្យលើពាក្យសុំ ការកំណត់កាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹងតវ៉ា និងការដោះស្រាយបណ្តឹងនៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត និងនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្តីសម្រេចចុងក្រោយ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៣២ នៃជំពូកទី៦នេះ ស្របនឹងមាត្រា៣៤ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា៣៥ វាក្យខ័ណ្ឌទី១ និងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៧ ស្តីពីការឃោសនាបោះឆ្នោត មាន១៦មាត្រា គឺចាប់ពីមាត្រា៦៧ ដល់មាត្រា៨២ ចែងពី ការផ្សព្វផ្សាយអំពីគោលនយោបាយ កម្មវិធីនយោបាយរបស់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ សកម្មភាពនៃការឃោសនាបោះឆ្នោត ការលើកស្លាកសញ្ញាគណបក្សនយោបាយការគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ក្រមសីលធម៌ និង បទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការឃោសនាបោះឆ្នោតមានរយៈពេល១៤ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់២៤ម៉ោង មុនថ្ងៃបោះឆ្នោត របៀបបែបបទប្តឹងជំទាស់ឬតវ៉ា និងការដោះស្រាយពាក្យបណ្តឹង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ការអនុវត្តសិទ្ធិផ្សព្វផ្សាយរបស់គណបក្សនយោបាយ និងបេក្ខជន ការផ្តល់ទីតាំងសាធារណៈដល់បេក្ខជន ឬគណបក្សនយោបាយ ការហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោ-

បាយដឹកជញ្ជូនរបស់រដ្ឋ។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៦ នៃជំពូកទី៧នេះ ស្របនឹងមាត្រា៥១ថ្មី វាក្យខ័ណ្ឌទី១ និង មាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៨ ស្តីពីភ្នាក់ងារគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ មាន១៨មាត្រា គឺចាប់ពីមាត្រា៨៣ ដល់មាត្រា១០០ ចែងពី គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ហៅថាភ្នាក់ងារគណបក្សនយោបាយនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំសង្កាត់ដែលខ្លួនឈរឈ្មោះបោះឆ្នោត និងសមត្ថកិច្ចរបស់គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ សិទ្ធិក្នុងការជំទាស់ ឬប្តឹងតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយ បម្រាមចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងការសង្កេតមើលដំណើរការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត ការអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិឱ្យចូលរួមសង្កេតការណ៍បោះឆ្នោត និងសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការចាត់ចែងរាល់កិច្ចការខាងលើ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៨ នៃជំពូកទី៨នេះ ស្របនឹងមាត្រា៥១ថ្មី វាក្យខ័ណ្ឌទី១ និងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១ និងទី២ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៩ ស្តីពីការរៀបចំ ការគ្រប់គ្រង និង ការប្រព្រឹត្តទៅនៃការបោះឆ្នោត មាន២០មាត្រា គឺចាប់ពីមាត្រា១០១ ដល់មាត្រា១២០ ចែងពី ឃុំសង្កាត់នីមួយៗត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួនដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់ជូន។ សន្លឹកឆ្នោតនីមួយៗត្រូវមានគល់បញ្ជីសន្លឹកឆ្នោត មានសញ្ញាសម្គាល់គណបក្សនយោបាយ និងមានឈ្មោះគណបក្សនយោបាយ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាផ្តល់ហិបឆ្នោត ត្រាសម្ងាត់ជាផ្លូវការ និងសម្ភារឧបករណ៍ដែលចាំបាច់ឱ្យបានគ្រប់ចំនួនសម្រាប់បម្រើការបោះឆ្នោតទៅឱ្យការិយាល័យបោះឆ្នោតនីមួយៗ តួនាទីនិងភារកិច្ចរបស់មន្ត្រីការិយាល័យបោះឆ្នោត អ្នកដែលមានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត សិទ្ធិរបស់មន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយក្នុងការជំទាស់ជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត សិទ្ធិរបស់ភ្នាក់ងារគណបក្សនយោបាយក្នុងការ

ប្ដឹងជំទាស់ឬតវ៉ា អំពីភាពមិនប្រក្រតីនៃការបោះឆ្នោត និងសិទ្ធិរបស់គណៈកម្មការការិយាល័យបោះ-ឆ្នោត ក្នុងការដោះស្រាយបណ្ដឹងជំទាស់ឬតវ៉ា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២០ នៃជំពូកទី៩នេះ ស្រប នឹងមាត្រា៥១ថ្មី វាក្យខ័ណ្ឌទី១ និងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១ និងទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១០ ស្ដីពីការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ប្រគល់ ទទួល សម្ភារបោះឆ្នោត មាន២២មាត្រា គឺចាប់ពីមាត្រា១២១ ដល់មាត្រា១៤២ ចែងពី ប្រធានការិយាល័យ បោះឆ្នោតត្រូវបិទការបោះឆ្នោតនៅម៉ោង ១៥:០០ នាទី។ សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះ-ឆ្នោតនីមួយៗក្នុងឃុំសង្កាត់។ មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ជាអ្នកទទួលខុសត្រូវ ក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះការិយាល័យបោះឆ្នោតនឹងក្លាយទៅជា ការិយាល័យរាប់សន្លឹកឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការរាប់សន្លឹកឆ្នោត។ បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួច ហើយ ប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតត្រូវធ្វើកំណត់ហេតុស្ដីពីលទ្ធផលបណ្ដោះអាសន្ន នៃការរាប់សន្លឹកឆ្នោតសម្រាប់ការិយាល័យរបស់ខ្លួន រួចផ្ញើជូនគណៈកម្មការឃុំសង្កាត់រៀបចំការបោះ-ឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោត ដែលពុំបានប្រើប្រាស់ ពាក្យបណ្ដឹងជំទាស់ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗ កំណត់ហេតុត្រូវបិទនៅ ការិយាល័យបោះឆ្នោត និងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ការប្រព្រឹត្តទៅ និង នីតិវិធីនៃការរាប់សន្លឹកឆ្នោត សេចក្ដីណែនាំសម្រាប់ធ្វើកំណត់ហេតុពេលរាប់សន្លឹកឆ្នោតក្នុងការិយាល័យ រាប់សន្លឹកឆ្នោត របៀបប្រមូលផ្ដុំ វេចខ្ចប់ និងវាយមុខសម្ភារបោះឆ្នោតឱ្យបានត្រឹមត្រូវ សម្រាប់ការ ប្រគល់ ការទទួល នីតិវិធីត្រួតពិនិត្យកំណត់ហេតុរាប់សន្លឹកឆ្នោត បូកសរុបលទ្ធផលនៃកាបោះឆ្នោត តាមការិយាល័យរាប់សន្លឹកឆ្នោត និងការត្រួតពិនិត្យឧបករណ៍ សម្ភារបោះឆ្នោតដែលបានទទួលពីគ្រប់ ការិយាល័យរាប់សន្លឹកឆ្នោតរបស់គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត នីតិវិធីត្រួតពិនិត្យនូវ លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំសង្កាត់នីមួយៗរបស់គណៈកម្មការឃុំសង្កាត់ និងគណៈ-កម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២២ នៃជំពូកទី១០នេះ ស្របនឹង មាត្រា៥១ថ្មី វាក្យខ័ណ្ឌទី១ និងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១១ ស្ដីពីលទ្ធផលបណ្ដោះអាសន្ន លទ្ធផលផ្លូវការ និងការជំទាស់ចំពោះលទ្ធផល នៃការបោះឆ្នោត មាន១៧មាត្រា គឺចាប់ពីមាត្រា១៤៣ ដល់មាត្រា១៥៩ ចែងពី ជនគ្រប់រូបដែលបាន ចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ

មានសិទ្ធិប្ដឹងជំទាស់ទៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោតអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យឡើងវិញនូវលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំសង្កាត់ ឬការិយាល័យបោះឆ្នោតណាមួយដែលមានការប្ដឹងជំទាស់។ បន្ទាប់ពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំសង្កាត់នីមួយៗត្រូវបានពិនិត្យឡើងវិញឃើញថាត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសជាសាធារណៈនូវលទ្ធផលជាផ្លូវការនៃការបោះឆ្នោតនោះភ្លាម។ ចំពោះឃុំសង្កាត់ណាដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ការប្រកាសលទ្ធផលផ្លូវការត្រូវធ្វើបន្ទាប់ពីការដោះស្រាយបណ្ដឹងរួចរាល់ជាស្ថាពរទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង១៧ នៃជំពូកទី១១នេះ ស្របនឹងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១២ ស្ដីពីការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន មាន៥មាត្រា គឺចាប់ពីមាត្រា១៦០ ដល់មាត្រា១៦៤ ចែងពី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតណាមួយឬមួយចំនួនក្នុងកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុង ហើយត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រី។ ក្នុងករណីការិយាល័យបោះឆ្នោតណាមួយត្រូវបិទ ការបោះឆ្នោតនៅការិយាល័យនោះត្រូវធ្វើសាជាថ្មី ក្នុងរយៈពេល ៣០ ថ្ងៃ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៥ នៃជំពូកទី១២នេះ ស្របនឹងមាត្រា៥២ ឃ្លាទី២ និងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៣ ស្ដីពីការបោះឆ្នោតឡើងវិញ មាន៤មាត្រា គឺចាប់ពីមាត្រា១៦៥ ដល់មាត្រា១៦៨ ចែងពី ការបោះឆ្នោតឡើងវិញត្រូវធ្វើឡើងក្នុងរយៈពេលមិនឱ្យលើសពី១២០ថ្ងៃឡើយ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវកំណត់ពីកាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញក្នុងរយៈពេលយ៉ាងយូរ៧ថ្ងៃ។ ការបោះឆ្នោតត្រូវចាប់ធ្វើពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១៥:០០ នាទី ក្នុងថ្ងៃដដែល។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវចំពោះការបោះឆ្នោតឡើងវិញនេះ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង៤ នៃជំពូកទី១៣នេះ ស្របនឹងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១៤ ស្ដីពីទោសប្បញ្ញត្តិ មាន២៥មាត្រា គឺចាប់ពីមាត្រា១៦៩ ដល់មាត្រា១៩៣ ចែងពី ការកំណត់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការផាកពិន័យជាប្រាក់ ការព្រមានជាលាយលក្ខណ៍អក្សរ ការលុបឈ្មោះចេញពីការងារចំពោះមន្ត្រីរៀបចំការបោះឆ្នោត ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតចំពោះជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ដែលបានប្រព្រឹត្តខុសឆ្គងនឹងបទប្បញ្ញត្តិក្នុងច្បាប់នេះ ដោយពុំគិតដល់ទោសព្រហ្មទណ្ឌ។ សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។ ដំណើរការនីតិវិធី ដើម្បីចេញសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២៥ នៃជំពូកទី១៤ នេះ ស្របនឹងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៥ ស្ដីពីអន្តរប្បញ្ញត្តិ មាន១មាត្រា គឺមាត្រា១៩៤ ចែងពី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីបោះឆ្នោតថ្មី សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៤។ បទប្បញ្ញត្តិក្នុងមាត្រា១៩៤ នៃជំពូកទី១៥នេះ ស្របនឹងមាត្រា១៥០ថ្មី(ពីរ) វាក្យខ័ណ្ឌទី១និងទី២ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៦ ស្ដីពីអវសានប្បញ្ញត្តិ មាន២មាត្រា គឺមាត្រា១៩៥ និងមាត្រា១៩៦ ចែងពី បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ។ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង២ នៃជំពូកទី១៦នេះ ស្របនឹងមាត្រា៩៣ថ្មី វាក្យខ័ណ្ឌទី១ ឃ្លាទី២ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារទាំង ១៦ជំពូក ១៩៦មាត្រា នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ស្របនឹងរដ្ឋធម្មនុញ្ញ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៥ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.**‐ សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក ឃើញអុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៦០/០០១/២០១៦

ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦

**សេចក្តីសម្រេច**

លេខ : ១៥៩/០០១/២០១៦ កបធ.ច

ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើលេខ ០៦៣ រ.ស ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៦ នាសម័យប្រជុំលើកទី៥ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៣ នាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៦ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង ១៦ និង ៣០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ការបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា តាមការឆ្លើយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាលលើចំណុចមួយចំនួននៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាធម្មនុញ្ញកាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៦ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាធម្មនុញ្ញបានប្រព្រឹត្តទៅស្របតាមមាត្រា ២១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ តំណាងរាជរដ្ឋាភិបាលឆ្លើយបញ្ជាក់ច្បាស់ថា ក្រុមប្រឹក្សាជាតិគណនេយ្យ « **ក.ជ.គ** » ស្ថិតនៅក្នុងអំណាចនីតិប្រតិបត្តិ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា គឺចាប់ពីមាត្រា ១ ដល់មាត្រា ៤ ចែងពីគោលបំណងគ្រប់គ្រង វិស័យគណនេយ្យ និងសវនកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាន ព្រមទាំងគោលដៅ វិសាលភាពអនុវត្ត និងបច្ចេកស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៤ នៃជំពូកទី១ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី២ ស្តីពីក្រុមប្រឹក្សាជាតិគណនេយ្យ មាន ៤ មាត្រា គឺចាប់ពីមាត្រា ៥ ដល់មាត្រា ៨ ចែងពីការបង្កើតក្រុមប្រឹក្សាជាតិគណនេយ្យ ដែលសរសេរជាអក្សរកាត់ **ក.ជ.គ** ។ សមាសភាព **ក.ជ.គ** មានអាណត្តិ ៥ ឆ្នាំ ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មុខងារនិងភារកិច្ចរបស់ **ក.ជ.គ** ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃ **ក.ជ.គ** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៤ នៃជំពូកទី២ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ លើកលែងតែត្រង់ចំណុចត្រេទី៤ នៃមាត្រា ៧ ដែលចែងថា « *ពិនិត្យ និងដោះស្រាយបណ្តឹង ឬវិវាទពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម* » មិនស្របនឹងវាក្យខ័ណ្ឌទី៣ មាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា « *អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង* ។ » និងមាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា «*គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ ។*»

- យល់ឃើញថា ជំពូកទី៣ ស្តីពីស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម មាន ២ មាត្រា គឺមាត្រា ៩ និង មាត្រា ១០ ចែងពីវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង និងគាំពារដោយស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មតែមួយគត់និងឯករាជ្យក្នុងវិជ្ជាជីវៈ ។ ការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៣ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៤ ស្តីពីស្តង់ដាគណនេយ្យ មាន ១ មាត្រា គឺមាត្រា ១១ ចែងពីស្តង់ដាគណនេយ្យ ត្រូវសម្រេចដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ** ។ ស្តង់ដាគណនេយ្យមានអានុភាពអនុវត្តចំពោះស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ។ បទប្បញ្ញត្តិក្នុងមាត្រា ១១ នៃជំពូកទី៤ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៥ ស្តីពីស្តង់ដាសវនកម្ម មាន ១ មាត្រា គឺមាត្រា ១២ ចែងពីស្តង់ដាសវនកម្ម ត្រូវសម្រេចដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ** ។ ស្តង់ដាសវនកម្មមានអានុភាពអនុវត្តចំពោះសវនករទាំងអស់ ដែលប្រកបវិជ្ជាជីវៈនៅព្រះរាជាណាចក្រកម្ពុជា ។ បទប្បញ្ញត្តិក្នុងមាត្រា ១២ នៃជំពូកទី៥ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៦ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ មាន ៣ មាត្រា គឺចាប់ពីមាត្រា ១៣ ដល់មាត្រា ១៥ ចែងពីក្រមសីលធម៌សម្រាប់វិជ្ជាជីវៈគណនេយ្យករ និងសវនករ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ **ក.ជ.គ** ។ សវនករមិនអាចផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលខ្លួនធ្លាប់ផ្តល់សេវាគណនេយ្យឡើយ លើកលែងតែការផ្តល់សេវាគណនេយ្យនោះបានបញ្ចប់ទៅក្នុងរយៈពេលយ៉ាងតិចបីឆ្នាំ ។ សវនករមិនត្រូវបន្តផ្តល់សេវាកម្មជូនសហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញណាមួយលើសពីប្រាំឆ្នាំបន្តបន្ទាប់គ្នាឡើយ ។ សវនករមិនត្រូវផ្តល់សេវាសវនកម្មជូនសហគ្រាសដែលខ្លួនទទួលផលប្រយោជន៍ ឬមានសិទ្ធិគ្រប់គ្រង ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី តាមរយៈសហព័ទ្ធ ញាតិលោហិត ឬញាតិពន្ធ រហូតដល់ថ្នាក់ទី៣ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៦ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៧ ស្តីពីកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មាន ៨ មាត្រា គឺចាប់ពីមាត្រា

១៦ ដល់ មាត្រា ២៣ ចែងពីរបាយការណ៍ហិរញ្ញវត្ថុ រួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាគណនេយ្យ ។ របាយការណ៍ហិរញ្ញវត្ថុអាចតម្រូវឱ្យធ្វើសវនកម្មតាមលក្ខខណ្ឌដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ **ក.ជ.គ** ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាមូលដ្ឋានសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ ស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ។ បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល លើកលែងតែក្នុងកិច្ចប្រតិបត្តិការអន្តរជាតិជាប្រចាំ អាចប្រើជាភាសាអង់គ្លេស និងជារូបិយបណ្ណបរទេស អមជាមួយឯកសារខាងដើម ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៨ នៃជំពូកទី៧ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៨ ស្តីពីរបាយការណ៍សវនកម្ម មាន ៣ មាត្រា គឺចាប់ពីមាត្រា ២៤ ដល់មាត្រា ២៦ ចែងពីរបាយការណ៍សវនកម្មរួមមានរបាយការណ៍នានាដែលត្រូវកំណត់ក្នុងស្តង់ដាសវនកម្ម ។ របាយ-ការណ៍សវនកម្មត្រូវរៀបចំឡើងជាភាសាខ្មែរ ដែលអាចអមដោយភាសាអង់គ្លេសមកជាមួយ ។ ភស្តុតាងសវនកម្មត្រូវរក្សាទុកក្នុងរយៈពេល ១០ ( ដប់ ) ឆ្នាំ យ៉ាងតិចគិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍សវនកម្ម ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៨ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៩ ស្តីពីគណនេយ្យករ និងសវនករ មាន ២ មាត្រា គឺមាត្រា ២៧ និង មាត្រា ២៨ ចែងពីបុគ្គលគ្រប់រូប ទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចជាគណនេយ្យករ និង/ឬ សវនករបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។ ប្រភេទគណនេយ្យករ និងសវនករ ដែលជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម ។ ការប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្មមានវិសមិតភាពជាមួយមុខងារសាធារណៈ និងមុខងារនយោបាយក្នុងអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងមុខងារអង្គការតុលាការ ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៩ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១០ ស្តីពីអាជ្ញាបណ្ណ មាន ២ មាត្រា គឺមាត្រា ២៩ និង មាត្រា ៣០ ចែងពីបុគ្គលគ្រប់រូប ទោះជារូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី អាចប្រកបវិជ្ជាជីវៈជាគណនេយ្យករ ឬ សវនករបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងទទួលបានអាជ្ញាបណ្ណ

ពី **គ.វ.គ** ។ អាជ្ញាបណ្ណចែកចេញជា ២ (ពីរ) ប្រភេទ គឺអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ។ លក្ខខណ្ឌ និង នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ **គ.វ.គ** ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី១០ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១១ ស្តីពីទោសប្បញ្ញត្តិ មាន ៧ មាត្រា គឺចាប់ពីមាត្រា ៣១ ដល់មាត្រា ៣៧ ចែងពីទណ្ឌកម្មដែលត្រូវដាក់លើរូបវន្តបុគ្គល និង នីតិបុគ្គលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់គណនេយ្យករ និងសវនករ ។ ទោសប្បញ្ញត្តិចំពោះការប្រកបវិជ្ជាជីវៈគណនេយ្យ ឬ សវនកម្មដោយគ្មានអាជ្ញាបណ្ណ ការក្លែងរបាយការណ៍សវនកម្ម ការមិនប្តឹងបរិហារពីបទល្មើសនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៧ នៃជំពូកទី១១ នេះ ស្របនឹងជំពូកទី៥ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១២ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣៨ ចែងពីលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលបានដាក់ឱ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០០២ ត្រូវបន្តអានុភាពគតិយុត្តរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។ បទប្បញ្ញត្តិក្នុងមាត្រា ៣៨ នៃជំពូកទី១២ នេះ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១៣ ស្តីពីអវសានប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣៩ ចែងពីច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ២០០២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។ បទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃជំពូកទី១៣ នេះ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ខ្លឹមសារទាំង ១៣ ជំពូក ៣៩ មាត្រា នៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែចំណុចត្រេទី៤ នៃមាត្រា ៧ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាព

ទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី៣ នាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែចំណុចត្រេទី៤ នៃមាត្រា ៧។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សិរីវុឌ្ឍ